សាកលវិទ្យាល័យជាតិគ្រប់គ្រង
National University of Management

# គណនេយ្យហិរញ្ញវត្ថុ ភាគ ១

## FINANCIAL ACCOUNTING-1




SOPL

SOFP



ព្រហ្ម សុផាន់ណា
ឆេង រតនា
ចាន់ វិច្ឆិកា
ម៉ៃ រតនា
ប៉ុម លៃហេង
ពិន មនោ
សេង រេត

ឆ្នាំ ២០២១

## ក្រុមអ្នកនិពន្ធ និងរៀបរៀង

លោក **ព្រហ្ម សុផាន់ណា** លោក **ប៉ុម លៃហេង**

លោកស្រី **ឆេង រតនា** លោក **ពិន មនោ**

លោកស្រី **ចាន់ ទិច្ចិកា** លោក **សេង រេត**

លោកស្រី **ម៉ៃ រតនា**

## គណៈកម្មការត្រួតពិនិត្យ

ឯកឧត្តមបណ្ឌិត **ហោ ប៉េង** ប្រធាន

លោកបណ្ឌិត **លី សុខហេង** អនុប្រធាន

លោកស្រី **ប៉ុក នារុន** សមាជិក

**រក្សាសិទ្ធិ ២០២១**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

បោះពុម្ពលើកទីមួយ

# បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ ៥៣% នៅឆ្នាំ២០០៤ មកនៅទាបជាង ១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្របដណ្តប់ ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងបន្តពង្រឹង និងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវ និងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាព និងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូង និងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផលប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូវ និងអាហ្វ្រិក មានប្រមាណ ៥% នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង ២ នេះមានប្រជាជនប្រមាណ ២០% នៃប្រជាជនពិភពលោក។ ប្រទេសចំនួន ៦ ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ ៧០% នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែង

ក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ២០០២ នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកប-ដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទាក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជាមូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ជាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតបចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ចតាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជាស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍

ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរេខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ទនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិនៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូង ពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និង ជាពិសេស គឺការបណ្ដុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ ក្នុងមួយឆ្នាំ មានសៀវភៅជាង ២,២លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន ៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន ៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន ១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើន ជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជន រួមមានការអានសៀវភៅ ការអានលើឧបករណ៍អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំតាមប្រព័ន្ធអេឡិចត្រូនិក និងការអប់រំពីចម្ងាយដើម្បីលើកកម្ពស់អំណាន តាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំ ជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្ដុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

1. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា
2. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ
3. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀនបង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន
4. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថល ជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់និងនិស្សិតគ្រប់កម្រិតសិក្សា អាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណាន កាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន
5. និស្សិតគ្រប់កម្រិតសិក្សា ត្រូវខិតខំនិងចំណាយពេលអាន និងចាត់ទុកវប្បធម៌ និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ
6. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍ សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា "មូលនិធិ ស.គ.ន" និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា "RCI Fund"។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមាន ឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម៤.០ (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពរូបនីយកម្មទៅលើទិសដៅនៃការប្រើប្រាស់ថវិកាមូលនិធិ សម្រាប់ឆ្នាំ ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា(Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀត ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

- ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សា
- លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់
- បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់ឋានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ
- រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហាន ប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច ២ច្បាប់ នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជន ដែលបានស្នើសុំថវិកាមូលនិធិរួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋនិងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំ សូមចូលរួមដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូច និងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

# អារម្ភកថា

សៀវភៅសិក្សាគោលនៅតាមសាកលវិទ្យាល័យ ត្រូវបានគិតគូររៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡា ក្នុងស្មារតីពង្រឹងគុណភាពអប់រំនៅកម្រិតឧត្តមសិក្សា ស្របតាមយុទ្ធសាស្ត្រនៃការកែទម្រង់វិស័យអប់រំនៅកម្ពុជា។ ផ្អែកតាមស្មារតីនេះ, សាកលវិទ្យាល័យជាតិគ្រប់គ្រង ក៏បានរៀបចំបង្កើតឱ្យមានកម្មវិធីធានាគុណភាពអប់រំ ក្នុងគោលបំណងពង្រឹងគុណភាពនៃការផ្តល់សេវាអប់រំជូននិស្សិត។ ការរៀបចំឱ្យមានសៀវភៅសិក្សាគោលទៅតាមមុខវិជ្ជា គឺជាចំណែកមួយក្នុងការសម្រេចបាននូវគោលបំណងនៃកម្មវិធីធានាគុណភាពអប់រំនៅក្នុងសាកលវិទ្យាល័យ។

សៀវភៅសិក្សាគោលនៃមុខវិជ្ជាគណនេយ្យហិរញ្ញវត្ថុ ភាគ ១ នេះ ត្រូវបានប្រសូត្រឡើងក្នុងការរួមចំណែកពង្រឹងគុណភាពអប់រំនៅកម្រិតឧត្តមសិក្សា ជាពិសេស នៅក្នុងសាកលវិទ្យាល័យជាតិគ្រប់គ្រងដោយផ្ទាល់។ សៀវភៅសិក្សាគោលជាខេមរៈភាសានេះ នឹងផ្តល់ភាពងាយស្រួលសម្រាប់អ្នកដែលទើបនឹងចាប់សិក្សាមុខវិជ្ជាគណនេយ្យ។ សៀវភៅសិក្សានេះ នឹងបង្ហាញនូវមូលដ្ឋានគ្រឹះនៃកិច្ចការគណនេយ្យ ដែលនិស្សិតចាំបាច់ត្រូវចេះ ត្រូវដឹង និងយល់ច្បាស់ ដើម្បីប្រើប្រាស់នៅក្នុងការសិក្សាបន្ត ឬនៅក្នុងការបម្រើការងារក្នុងជំនាញគណនេយ្យ ឬជំនាញពាក់ព័ន្ធផ្សេងៗទៀត។

ជាដំបូង, សៀវភៅសិក្សានេះ ផ្តើមចេញពីការណែនាំនូវសមីការគណនេយ្យនៅក្នុងមេរៀនទី១ ដែលនិស្សិតត្រូវចេះវិភាគប្រតិបត្តិការអាជីវកម្ម ទៅលើឥទ្ធិពលសមីការគណនេយ្យ។ នៅក្នុងមេរៀនទី ២ និស្សិតនឹងសិក្សាអំពីគោលការណ៍នៃការកត់ត្រាទ្វេភាគ ដែលជាគ្រឹះចាំបាច់បំផុតសម្រាប់គ្រប់អ្នកសិក្សាគណនេយ្យ។ វដ្តគណនេយ្យជារួម ត្រូវបានបង្ហាញនៅក្នុងមេរៀនទី៣ នៃសៀវភៅសិក្សានេះ។ ក្រៅពីនេះ, មេរៀនទី៤ ដល់មេរៀនទី៨ គឺជាការបង្ហាញអំពីវិធីសាស្ត្រកត់ត្រា ទ្រឹស្តីសំខាន់ផ្សេងៗទៀត ដែលនិស្សិតនឹងត្រូវសិក្សាជាបន្តបន្ទាប់។ ក្នុងនោះ, មេរៀនទី៤ ផ្តោតជាសំខាន់លើបញ្ជីកត់ត្រាប្រចាំថ្ងៃ ដែលជាការកត់ត្រាដំបូងនូវពេលប្រតិបត្តិការអាជីវកម្មបានកើតមានឡើង។ លើសពីនេះ, មេរៀនទី៥ នឹងបង្ហាញអំពីគណនេយ្យសម្រាប់ការទិញ-លក់ទំនិញ ឬផ្គត់ផ្គង់សេវាកម្ម ដែលជាប់ពាក់ព័ន្ធនឹងអាករតម្លៃបន្ថែម (VAT)។ ចំណែកឯមេរៀនទី៦ និស្សិតនឹងយល់បន្ថែមលើការចាត់ថ្នាក់ចំណាយជាទ្រព្យសកម្ម ឬជាចំណាយប្រតិបត្តិការ ដើម្បីអាចបង្ហាញព័ត៌មានហិរញ្ញវត្ថុ ឱ្យបានត្រឹមត្រូវ និងផ្តល់នូវប្រយោជន៍ ជូនអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ។ ផ្ទុយទៅវិញ, មេរៀនទី ៧ គ្រាន់តែចង់បង្ហាញអំពីគោលការណ៍ ឬគោលគំនិតជាមូលដ្ឋាននៃការកត់ត្រា និងការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុ។ ចុងបញ្ចប់នៃសៀវភៅសិក្សានេះ គឺជាកិច្ចការគណនេយ្យនៅចុងការិយបរិច្ឆេទគណនេយ្យរបស់គណនេយ្យករត្រូវអនុវត្ត ពោលគឺ មេរៀនទី ៨ ជាការកត់ត្រាកែតម្រូវលើប្រតិបត្តិការមួយចំនួន។

ទន្ទឹមនេះ, យើងខ្ញុំសង្ឃឹមថាសៀវភៅសិក្សាគោលនេះ នឹងផ្តល់នូវពុទ្ធិជាមូលដ្ឋានក្នុងការសិក្សាគណនេយ្យកម្រិតដំបូង ជាពិសេសដំណាក់កាលដែលត្រូវអនុវត្តនៅក្នុងកិច្ចការគណនេយ្យជាទូទៅ។

ទោះបីជាយ៉ាងណាក៏ដោយ, សៀវភៅនេះ ក៏នៅមានចំណុចខ្វះខាតមួយចំនួន ដែលយើងនឹងព្យាយាមកែសម្រួលទៅតាមការចាំបាច់។ ដូចនេះ, យើងខ្ញុំនឹងទទួលនូវមតិយោបល់ពីអ្នកសិក្សាស្រាវជ្រាវ ឬអ្នកអាចតាមរយៈប្រអប់សាររបស់ក្រុមយើងខ្ញុំ។ យើងខ្ញុំ សង្ឃឹមយ៉ាងមុតមាំថា និស្សិត អ្នកសិក្សាស្រាវជ្រាវ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត នឹងទទួលបាននូវចំណេះដឹងជាមូលដ្ឋានអំពីគណនេយ្យ នៅក្នុងសៀវភៅសិក្សានេះ ព្រមទាំងផ្តល់នូវមតិយោបល់ ដើម្បីស្ថាបនាសៀវភៅសិក្សាគោលរបស់យើងនេះ ឱ្យកាន់តែមានលក្ខណៈស្របតាមការអនុវត្តជាអន្តរជាតិ និងបរិការណ៍ជាក់ស្តែងនៃការអនុវត្តការងារជំនាញគណនេយ្យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជាចុងបញ្ចប់, យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា និងមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលបានផ្តួចផ្តើមឱ្យមានការរៀបរៀង និងនិពន្ធសៀវភៅសិក្សា ជាពិសេសសៀវភៅវិជ្ជាបង្រៀនកម្រិតឧត្តមសិក្សា។ យើងខ្ញុំក៏សូមថ្លែងអំណរគុណជូនចំពោះ ឯកឧត្តមបណ្ឌិត **ហោ ប៉េង** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ដែលតែងតែជំរុញឱ្យមានការរៀបរៀង និងនិពន្ធសៀវភៅសិក្សាគោលសម្រាប់គាំទ្រដល់ការសិក្សារបស់អ្នកសិក្សា។

ថ្ងៃសៅរ៍ ១០ រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២១

ក្រុមអ្នកនិពន្ធនិងរៀបរៀង

# សេចក្តីបញ្ជាក់
# នៃមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោងរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ និងរូបភាព គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយ ពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

# អក្សរកាត់

| | |
|---|---|
| a/c | គណនី (Account) |
| CFRS | ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា (Cambodian Financial Reporting Standards) |
| CFRS for SME | ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា សម្រាប់ក្រុមហ៊ុនធុនតូច និងមធ្យម (Cambodian Financial Reporting Standards for SME) |
| Cr. | ឥណទាន (Credit) |
| Dr. | ឥណពន្ធ (Debit) |
| GAAP | ស្តង់ដាគណនេយ្យទទួលស្គាល់ជាទូទៅ (Generally Accepted Accounting Principles) |
| IAS | ស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standards) |
| IFRS | ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ(International Financial Reporting Standards |
| MCQ | សំណួរពហុជ្រើសរើស (Multi-chioces Questions) |
| SOCE | របាយការណ៍បម្រែបម្រួលមូលធនផ្ទាល់ (Statement of Change in Equity) |
| SOCF | របាយការណ៍លំហូរសាច់ប្រាក់ (Statement of Cash Flow) |
| SOPL | របាយការណ៍ចំណេញ/ខាត (Statement of Profit and Loss) |
| SOFP | របាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ (Statement of Financial Position) |
| P/L Account | គណនីចំណេញ/ខាត (Profit/loss Account) |
| VAT | អាករតម្លៃបន្ថែម (Value Added Tax) |

# មាតិកា


បុព្វកថា ..................................................................................................... i

អារម្ភកថា ..................................................................................................... vi

សេចក្តីបញ្ជាក់នៃមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍.......................................viii

អក្សរកាត់ ..................................................................................................... ix


## មេរៀនទី១៖ សេចក្តីផ្តើមអំពីគណនេយ្យ

(Chapter 1: Introduction to Accounting)


១.១. សេចក្តីផ្តើមអំពីអាជីវកម្ម ..................................................................... 1

១.២. អ្វីទៅជាគណនេយ្យ? ........................................................................... 2

១.៣. ប្រព័ន្ធព័ត៌មានវិទ្យាគណនេយ្យ (Accounting Information System)............................3

១.៤. សមីការគណនេយ្យ (Accounting Equation) ..............................................3

១.៥. ចំណាត់ថ្នាក់មាតិកាគណនី................................................................6

១.៥.១. ទ្រព្យសកម្ម (Assets)...................................................................6

១.៥.២. បំណុល (Liabilities) ...................................................................7

១.៥.៣. មូលធនផ្ទាល់(Capital/Equity) ........................................................7

១.៥.៤. ចំណូល (Income)......................................................................8

១.៥.៥. ចំណាយ (Expenses) ..................................................................8

១.៦. សេចក្តីសន្និដ្ឋាន ........................................................................... 11


## មេរៀនទី២៖ ប្រព័ន្ធកត់ត្រាទ្វេភាគ

(Chapter 2: Double-entry System)


២.១. សេចក្តីផ្តើម................................................................................. 17

២.២. ឯកសារអាជីវកម្ម (Business Documents) ............................................ 18

២.៣. ទស្សនាទាននៃការកត់ត្រាទ្វេភាគ (Double Entry System) ............................ 19

២.៤. គោលការណ៍នៃការកត់ត្រាទ្វេភាគ (Rule of Double-Entry) ............................20

២.៥. គណនេយ្យសម្រាប់ការទិញ-លក់ទំនិញ ..................................................23

២.៥.១. ប្រតិបត្តិការទិញ-លក់ទំនិញជាសាច់ប្រាក់ (Cash Transactions) ......................23

២.៥.២. ប្រតិបត្តិការទិញ-លក់ទំនិញដោយជំពាក់ (Credit Transactions) ...................... 23
២.៥.៣. ប្រតិបត្តិការទំនិញបង្វិលវិញ ........................................................................ 25
២.៦. សមតុល្យគណនីអក្សរ T .................................................................................. 29
២.៧. សេចក្ដីសន្និដ្ឋាន ............................................................................................ 30

## មេរៀនទី៣៖ របាយការណ៍ហិរញ្ញវត្ថុ

Chapter 3: Financial Statements

៣.១. សេចក្ដីផ្ដើម ................................................................................................. 40
៣.២. តារាងតុល្យភាព (Trial Balance) ..................................................................... 41
៣.៣. របាយការណ៍ចំណេញ/ខាត (Statement of profit or loss-SOPL) ............................. 43
៣.៤. របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (Statement of financial position-SOFP) ................ 46
៣.៤.១. ទ្រព្យសកម្ម (Assets) ............................................................................... 46
៣.៤.២. បំណុល (liabilities) ................................................................................. 47
៣.៤.៣. មូលធនផ្ទាល់ (Euqity) ............................................................................. 47
៣.៥. ការកែសម្រួលបន្ថែមទៅលើរបាយការណ៍ចំណេញ/ខាត ............................................ 53
៣.៥.១. សន្និធិ/ស្តុកទំនិញ (Inventory) .................................................................. 53
៣.៥.២. ថ្លៃដឹកជញ្ជូនទំនិញ (Carriage) ................................................................. 53
៣.៥.៣. ការបង្វិលទំនិញមកវិញ (Return) ............................................................... 53
៣.៦. សេចក្ដីសន្និដ្ឋាន ............................................................................................ 55

## មេរៀនទី ៤៖ បញ្ជីកត់ត្រាប្រចាំថ្ងៃ និងបញ្ជីសៀវភៅធំ

Chapter 4: Day Books and Ledgers

៤.១. សេចក្ដីផ្ដើម ................................................................................................. 68
៤.២. បញ្ជីកត់ត្រាប្រចាំថ្ងៃ ........................................................................................ 68
៤.២.១. បញ្ជីលក់ទំនិញប្រចាំថ្ងៃ (Sales Day Book) ................................................... 69
៤.២.២. បញ្ជីប្រចាំថ្ងៃនៃការបង្វិលទំនិញដែលបានលក់ (Sale Returns Day Book) ......... 69
៤.២.៣. បញ្ជីទិញទំនិញប្រចាំថ្ងៃ (Purchase Day Book) ............................................ 70
៤.២.៤. បញ្ជីប្រចាំថ្ងៃនៃការបង្វិលទំនិញដែលបានទិញ (Purchase Returns Day Book) ....... 70
៤.២.៥. បញ្ជីសាច់ប្រាក់ (Cash Book) ..................................................................... 71

៤.២.៦. បញ្ជីសាច់ប្រាក់រដ្ឋទេយ្យ (Petty Cash Book) ..... 71
៤.២.៧. ទិនានុប្បវត្តិ (Journal) ..... 73
៤.៣. បញ្ជីសៀវភៅធំ (General Ledger) ..... 73
៤.៣.១. សៀវភៅធំសម្រាប់អតិថិជនទិញជំពាក់ (Receivables ledger) ..... 74
៤.៣.២. សៀវភៅធំសម្រាប់អ្នកផ្គត់ផ្គង់លក់ជំពាក់ (Payables Ledger) ..... 74
៤.៣.៣. សៀវភៅធំទូទៅ (General Ledger) ..... 74
៤.៤. នីតិវិធីនៃការកត់ត្រាពីបញ្ជីប្រចាំថ្ងៃមកក្នុងគណនីសៀវភៅធំ ..... 74
៤.៤.១. ការកត់ត្រានៅក្នុង Receivables និង Payables Ledgers ..... 74
៤.៤.២. ការកត់ត្រានៅក្នុង General Ledger ..... 75
៤.៥. គណនេយ្យសម្រាប់ការបញ្ចុះតម្លៃ (Accounting for Discounts) ..... 80
៤.៥.១. ការបញ្ចុះតម្លៃជួញដូរ (Trade Discount) ..... 80
៤.៥.២. ការបញ្ចុះតម្លៃសាច់ប្រាក់ (Cash Discount) ..... 81
៤.៦. សេចក្តីសន្និដ្ឋាន ..... 82

## មេរៀនទី៥៖ ពន្ធលើការលក់ទំនិញ/ផ្គត់ផ្គង់សេវា (អាករតម្លៃបន្ថែម)

(Chapter 5: Sales Tax (Value Added Tax))

៥.១. សេចក្តីផ្តើម ..... 92
៥.២. ការគណនា Input VAT និង Output VAT ..... 93
៥.៣. ការកត់ត្រាទ្វេភាគសម្រាប់អាករតម្លៃបន្ថែម ..... 94
៥.៣.១. ការកត់ត្រា Dr. និង Cr. ..... 94
៥.៣.២. បញ្ជីកត់ត្រាប្រចាំថ្ងៃ ..... 95
៥.៣.៣. បញ្ជីសៀវភៅធំ (General Ledger) ..... 97
៥.៤. ប្រភេទផ្សេងទៀតនៃប្រតិបត្តិការពាក់ព័ន្ធនឹងអាករតម្លៃបន្ថែម ..... 98
៥.៤.១. ការទិញទ្រព្យសកម្មរយៈពេលវែង ..... 98
៥.៤.២. ការលក់ជាសាច់ប្រាក់ និងការចំណាយជាសាច់ប្រាក់ដទៃទៀត ..... 99
៥.៥. ទំនាក់ទំនងនៃការបញ្ចុះតម្លៃ និងអាករតម្លៃបន្ថែម (Discount and VAT) ..... 100
៥.៦. សេចក្តីសន្និដ្ឋាន ..... 101

## មេរៀនទី៦៖ ចំណាយមូលធន និងចំណាយប្រតិបត្តិការ

Chapter 6: Capital and revenue expenditure


៦.១. សេចក្តីផ្តើម ............................................................................................................ 109

៦.២.ការចាត់ថ្នាក់ចំណាយមូលធន និងចំណាយប្រតិបត្តិការ ............................................ 109

៦.៣. កិច្ចសន្យាជួលទ្រព្យសកម្ម-ភតិសន្យា (Lease) .........................................................111

៦.៤. ចំណាយស្រាវជ្រាវ និងចំណាយអភិវឌ្ឍន៍ ............................................................... 112

៦.៥. ចំណូលមូលធន និងចំណូលប្រតិបត្តិការ (Capital and revenue income) ................ 113

៦.៦. សារៈសំខាន់នៃការចាត់ថ្នាក់ចំណាយមូលធន និងចំណាយប្រតិបត្តិការ ......................... 113

៦.៧. សេចក្តីសន្និដ្ឋាន ........................................................................................................ 114


## មេរៀនទី៧៖ ទស្សនទាន និងគោលការណ៍ទូទៅគណនេយ្យ

(Chapter 7: Accounting Concepts and Principles)


៧.១. សេចក្តីផ្តើម ............................................................................................................ 124

៧.២. គោលការណ៍គណនេយ្យសំខាន់ៗ ............................................................................ 125

៧.២.១. អង្គភាពអាជីវកម្ម (Business Entity) .......................................................... 125

៧.២.២. និរន្តរភាពអាជីវកម្ម (Going Concern) ........................................................ 125

៧.២.៣. មូលដ្ឋានបង្គរ (Accrual Basis Accounting) ................................................. 126

៧.២.៤. គោលការណ៍តម្លៃដើមគ្រា (Historical Cost) ................................................. 126

៧.២.៥. សង្គតិភាព (Consistency) .......................................................................... 126

៧.២.៦. ភាពជាសារវន្ត (Materiality) ........................................................................ 126

៧.២.៧. គោលការណ៍ប្រុងប្រយ័ត្ន (Prudence) ........................................................... 126

៧.២.៨. គោលការណ៍ទ្វេភាគ (Duality) ..................................................................... 127

៧.២.៩. គោលការណ៍ទទួលស្គាល់ (Realization) ....................................................... 127

៧.៣. ចរិតលក្ខណៈដែលធ្វើឱ្យព័ត៌មានហិរញ្ញវត្ថុអាចប្រើការបាន ........................................ 127

៧.៣.១. សមានគតិភាព (Relevance) ........................................................................ 127

៧.៣.២. ភាពតំណាងពេញលេញ (Faithful Representation) ....................................... 128

៧.៣.៣. ភាពអាចប្រៀបធៀបបាន (Comparability) ..................................................... 128

៧.៣.៤. ភាពអាចផ្ទៀងផ្ទាត់បាន (Verifiability) .......................................................... 128

៧.៣.៥. ភាពទាន់ពេលវេលា (Timeliness) ........ 129
៧.៣.៦. ភាពអាចយល់បាន (Understandability) ........ 129
៧.៤. សេចក្តីផ្តើមអំពីស្តង់ដាគណនេយ្យ ........ 129
៧.៥. សេចក្តីសន្និដ្ឋាន ........ 131

## មេរៀនទី ៨៖ ការកែតម្រូវលើរបាយការណ៍ហិរញ្ញវត្ថុ

(Chapter 8: Adjustment to Financial Statement)

៨.១. សេចក្តីផ្តើម ........ 136
៨.២. ចំណូល-ចំណាយបង្គរ (Accruals) ........ 137
៨.២.១. ចំណូលបង្គរ (Accrued Income) ........ 137
៨.២.២. ចំណាយបង្គរ (Accrued expenses) ........ 137
៨.៣. ចំណាយបង់ប្រាក់ជាមុននិងចំណូលបង់ប្រាក់ជាមុន (Prepayments) ........ 140
៨.៣.១. ចំណាយបង់ប្រាក់ជាមុន (Prepaid expenses) ........ 140
៨.៣.២. ចំណូលបង់ប្រាក់ជាមុន (Unearned income) ........ 141
៨.៤. Accruals និង Prepayments នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ........ 143
៨.៤.១. របាយការណ៍ចំណេញ/ខាត (SOPL) ........ 143
៨.៤.២. របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (SOFP) ........ 144
៨.៥. សេចក្តីសន្និដ្ឋាន ........ 146

ឯកសារយោង ........ 162

# មេរៀនទី១៖ សេចក្តីផ្តើមអំពីគណនេយ្យ

## ( Chapter 1: Introduction to Accounting )

**គោលបំណងនៃមេរៀនទី១ នេះ ផ្តោតលើ៖**

- ការណែនាំអំពីទិដ្ឋភាពរួមនៃការសិក្សាគណនេយ្យ
- សមីការគណនេយ្យ។

បន្ទាប់ពីសិក្សាជំពូកទី១ នេះ យើងអាច៖

- យល់ដឹងអំពីប្រភេទនៃក្រុមហ៊ុនអាជីវកម្ម។
- ស្វែងយល់ពីអត្ថន័យរបស់គណនេយ្យ និងប្រភេទគណនេយ្យ។
- ស្គាល់ច្បាស់អំពីសមីការគណនេយ្យដែលជាមូលដ្ឋានគ្រឹះនៃការសិក្សាគណនេយ្យ។
- ស្គាល់អំពីចំណាត់ថ្នាក់នៃប្រភេទគណនីដែលក្រុមហ៊ុនត្រូវរាយការណ៍។

## ១.១. សេចក្តីផ្តើមអំពីអាជីវកម្ម

ក្រុមហ៊ុនអាជីវកម្ម គឺអង្គភាពមួយដែលប្រើប្រាស់ធនធានរបស់ខ្លួនក្នុងការផលិតទំនិញ ឬក្នុងការផ្តត់ផ្គង់សេវា ជូនអតិថិជន។ គោលដៅចុងក្រោយនៃការធ្វើអាជីវកម្ម គឺដើម្បីស្វែងរកប្រាក់ចំណេញ។ ជារួមក្រុមហ៊ុនអាជីវកម្មត្រូវបានបែងចែកជាបីប្រភេទ គឺ៖

- ក្រុមហ៊ុនឯកកម្មសិទ្ធិ ( Sole-trader/ Proprietorship )

សំដៅដល់អាជីវកម្មធនតូចមួយដែលមានម្ចាស់ក្រុមហ៊ុនតែម្នាក់គ្រប់គ្រងផ្ទាល់។ សម្រាប់ការរកស៊ីជាក្រុមហ៊ុនឯកកម្មសិទ្ធិ មិនទាមទារឱ្យមានការរាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដាកំណត់នោះទេ។ បន្ថែមលើនេះ, យើងគឺជាម្ចាស់គ្រប់គ្រងអាជីវកម្មទាំងស្រុង។ អាជីវកម្មប្រភេទនេះ មានលក្ខណៈទន់ភ្លន់ ងាយបត់បែន។ ប៉ុន្តែ ផលលំបាកក្នុងការរកស៊ីជាក្រុមហ៊ុនប្រភេទនេះ ក៏កើតមានផងដែរ ក្នុងនោះរួមមាន៖ ភាពលំបាកក្នុងការប្រមូលទុនវិនិយោគដើម្បីពង្រីកអាជីវកម្ម, ម្ចាស់អាជីវកម្មត្រូវរ៉ាប់រងទាំងស្រុងក្នុងការគ្រប់គ្រង, និងនៅពេលអាជីវកម្មក្ស័យធន ម្ចាស់ក្រុមហ៊ុនត្រូវទទួលខុសត្រូវទាំងស្រុងលើការសងបំណុលទាំងអស់ដែលកើតចេញពីអាជីវកម្មនេះ។

- ក្រុមហ៊ុនសហកម្មសិទ្ធិ ( Partnership )

សំដៅដល់អាជីវកម្មមួយដែលមានម្ចាស់ក្រុមហ៊ុនចំនួន ២ ឬច្រើន ធ្វើការជាមួយគ្នា ដើម្បីបង្កើត និងបែងចែកប្រាក់ចំណេញ។ ចំពោះក្រុមហ៊ុនប្រភេទនេះ មិនទាមទារឱ្យមានការរាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដាកំណត់នោះទេ។ ក្រុមហ៊ុនក៏ងាយក្នុងការប្រមូលទុនវិនិយោគពីម្ចាស់ក្រុមហ៊ុនដែលបានរួមគ្នាក្នុងការរកស៊ី និងមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងក្រុមហ៊ុន ដោយមានការបែងចែកភារកិច្ចគ្នារវាងម្ចាស់ក្រុមហ៊ុន។ ទោះបីជាយ៉ាងណាក៏ដោយ, ក្រុមហ៊ុនប្រភេទនេះ អាចនឹងបង្កើតឱ្យមានបញ្ហានៃការយឺតយ៉ាវក្នុងការធ្វើសេចក្តីសម្រេចចិត្តណាមួយ ដោយសារមានម្ចាស់ក្រុមហ៊ុនច្រើន។ នៅពេលដែលអាជីវកម្មក្ស័យធន ម្ចាស់ក្រុមហ៊ុនទាំងអស់ត្រូវទទួលខុសត្រូវទាំងស្រុងសងបំណុលទាំងអស់ដែលកើតចេញពីអាជីវកម្មនេះ។

❖ ក្រុមហ៊ុនសាជីវកម្ម (Limited Company/ Corporation)

សំដៅដល់អាជីវកម្មមួយ ដែលមានការកំណត់តាមផ្លូវច្បាប់ នូវទំនួលខុសត្រូវដាច់ដោយឡែកពីម្ចាស់ក្រុមហ៊ុន។ កាតព្វកិច្ចសងបំណុលរបស់ម្ចាស់ក្រុមហ៊ុន គឺមានកម្រិតត្រឹមទឹកប្រាក់ដែលម្ចាស់ក្រុមហ៊ុនបានដាក់វិនិយោគក្នុងអាជីវកម្មតែប៉ុណ្ណោះ ពោលគឺ ម្ចាស់ក្រុមហ៊ុនមានហានិភ័យមានកម្រិត។ បន្ថែមលើនេះ, ម្ចាស់ក្រុមហ៊ុនអាចនឹងផ្លាស់ប្តូរពីម្នាក់ទៅម្នាក់បានយ៉ាងងាយ ហើយក្រុមហ៊ុនប្រភេទនេះ ងាយស្រួលក្នុងការបង្កើនដើមទុនតាមរយៈការបោះភាគហ៊ុនលក់នៅលើទីផ្សារភាគហ៊ុន។ ប៉ុន្តែ, ក្រុមហ៊ុនប្រភេទនេះ ទាមទារនូវការរាយការណ៍តាមស្តង់ដារកំណត់ និងត្រូវរងនូវការធ្វើសវនកម្មឯករាជ្យតាមផ្លូវច្បាប់។

## ១.២. អ្វីទៅជាគណនេយ្យ?

**Accounting:** នៅរាល់ពេលដែលអ្នកអាន ឬស្តាប់ឮនូវពាក្យ "គណនេយ្យ", តើអ្នកនឹងគិតដល់អ្វីមុនគេ ឬអ្នកយល់ថាវាមានន័យយ៉ាងដូចម្តេច ឬតំណាងឱ្យអ្វី? គណនេយ្យ ត្រូវបានគេប្រសិទ្ធនាមថាជា "ភាសាអាជីវកម្ម" ពោលគឺ ជាដំណើរការនៃការកត់ត្រាទិន្នន័យ(Recording), ចាត់ថ្នាក់ និងសង្ខេបទិន្នន័យ (Classify and Summary), និងរាយការណ៍ (Communicate) នូវព័ត៌មានហិរញ្ញវត្ថុដែលក្រុមហ៊ុនបានរកស៊ី។ គោលដៅចម្បងនៃគណនេយ្យ គឺដើម្បីផ្តល់នូវព័ត៌មាន សម្រាប់អ្នកប្រើប្រាស់ ធ្វើការសម្រេចចិត្តអ្វីមួយ។ ឧទាហរណ៍៖ ផ្អែកលើព័ត៌មានគណនេយ្យដែលបានបង្ហាញ, តើយើងដែលជាអ្នកវិនិយោគ គួរដាក់ទុនវិនិយោគជាមួយក្រុមហ៊ុននោះឬទេ?

**Bookkeeping:** ផ្នែកមួយនៃគណនេយ្យដែលពាក់ព័ន្ធនឹងការកត់ត្រាទិន្នន័យ ជាទូទៅត្រូវបានគេស្គាល់ថាជា Bookkeeping ។ អស់រយៈពេលរាប់រយឆ្នាំមកហើយ ទិន្នន័យគណនេយ្យទាំងអស់ ត្រូវបានគេកត់ត្រាទុកដោយប្រើក្រដាសសៀវភៅ ហេតុនេះទើបបានជាគេហៅវាថាជា Bookkeeping ។ សព្វថ្ងៃនេះ, ទោះបីជាមានការប្រើប្រាស់សៀវភៅបញ្ជីដើម្បីកត់ត្រាគណនេយ្យសម្រាប់ក្រុមហ៊ុនធនតូច ប៉ុន្តែទិន្នន័យគណនេយ្យភាគីច្រើនត្រូវបានកត់ត្រា និងរក្សាទុកតាមប្រព័ន្ធអេឡិចត្រូនិច ដោយប្រើប្រាស់កុំព្យូទ័រ។ ហេតុនេះ, Bookkeeping គឺជាដំណើរការនៃការកត់ត្រាទិន្នន័យពាក់ព័ន្ធនឹងប្រតិបត្តិការគណនេយ្យនៅក្នុងសៀវភៅបញ្ជីគណនេយ្យ។

គណនេយ្យជំនាញ ត្រូវបានបែងចែកជាពីរប្រភេទធំៗ៖ ១).គណនេយ្យហិរញ្ញវត្ថុ និង ២). គណនេយ្យគ្រប់គ្រង ឬគណនេយ្យថ្លៃដើម។ ក្រៅពីនេះ, គណនេយ្យជំនាញ ក៏អាចបែងចែកជាគណនេយ្យពន្ធដារ គណនេយ្យបរិស្ថាន គណនេយ្យអន្តរជាតិ គណនេយ្យសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ជាដើម។ ប៉ុន្តែសៀវភៅសិក្សាគោលនេះ ផ្តោតជាសំខាន់លើការសិក្សាអំពីគណនេយ្យហិរញ្ញវត្ថុ។ ទោះបីជាយ៉ាងណាក៏ដោយ យើងត្រូវស្គាល់អំពីភាពខុសគ្នានៃគណនេយ្យហិរញ្ញវត្ថុ និងគណនេយ្យគ្រប់គ្រង/ថ្លៃដើម។

**គណនេយ្យហិរញ្ញវត្ថុ (Financial Accounting)** សំដៅដល់ការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុស្តីពីលទ្ធផល និងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនអាជីវកម្ម ដោយផ្តោតជាសំខាន់លើអ្នកប្រើប្រាស់ខាង

ក្រៅក្រុមហ៊ុន។ ការាយការណ៍ ត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ តាមស្តង់ដាកំណត់ ដែលតម្រូវដោយច្បាប់។ ការរាយការណ៍នេះ គឺជាការបង្ហាញព័ត៌មានដែលកើតឡើងរួចហើយ (Historical Information)។

**គណនេយ្យគ្រប់គ្រង/ថ្លៃដើម (Management/cost Accounting)** សំដៅដល់ការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុ ជូនថ្នាក់ដឹកនាំរបស់ក្រុមហ៊ុនអាជីវកម្ម ដើម្បីធ្វើការសេម្រេចចិត្តអ្វីមួយក្នុងដំណើរការរបស់អាជីវកម្ម។ ការរាយការណ៍នេះ មិនមានទម្រង់ស្តង់ដាជាក់លាក់នោះទេ ហើយខុសៗគ្នាពីក្រុមហ៊ុនមួយទៅក្រុមហ៊ុនមួយ ទៅតាមតម្រូវការជាក់ស្តែង។ ព័ត៌មានដែលបង្ហាញ នឹងលម្អិតទៅតាមតម្រូវការរបស់ថ្នាក់ដឹកនាំ ដោយរួមបញ្ចូលទាំងការវិភាគនូវព័ត៌មានទាំងនោះផងដែរ។

## ១.៣. ប្រព័ន្ធព័ត៌មានវិទ្យាគណនេយ្យ (Accounting Information System)

ក្រុមហ៊ុនអាជីវកម្មសម័យបច្ចុប្បន្ន ចាំបាច់ត្រូវមានប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីជួយគាំទ្រដល់ដំណើរការអាជីវកម្មប្រចាំថ្ងៃ សូម្បីកិច្ចការគណនេយ្យ ក៏តម្រូវឱ្យមានប្រព័ន្ធព័ត៌មានវិទ្យាគាំទ្រផងដែរ។ ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការងារគណនេយ្យ នឹងជួយឱ្យគណនេយ្យអាចធានាបាននូវសុក្រឹត្យភាព និងភាពទាន់ពេលវេលានៃការាយការណ៍ព័ត៌មានហិរញ្ញវត្ថុ។ ដូចនេះ ក្រុមហ៊ុនអាជីវកម្ម នឹងត្រូវរៀបចំដាក់ឱ្យដំណើរការប្រព័ន្ធព័ត៌មានវិទ្យាគណនេយ្យនេះ នៅពេលចាប់ផ្តើមដំណើរការអាជីវកម្មរបស់ខ្លួន។ បច្ចុប្បន្ននេះ ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការងារគណនេយ្យមានច្រើនប្រភេទ ដែលក្រុមហ៊ុនអាចជ្រើសរើសប្រើប្រាស់ទៅតាមទំហំ និងភាពស៊ាំញ៉ាំនៃអាជីវកម្ម។ ក្នុងការជ្រើសរើសប្រព័ន្ធព័ត៌មានក្រុមហ៊ុនអាជីវកម្ម ត្រូវគិតគូរផងដែរនូវថ្លៃទិញនិងថែទាំងប្រព័ន្ធទាំងនេះ ពីព្រោះប្រព័ន្ធព័ត៌មានកាន់តែស៊ាំញ៉ាំ តម្លៃរបស់វាក៏កាន់តែថ្លៃផងដែរ។

សព្វថ្ងៃនេះ គេសង្កេតឃើញថា មានប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការងារគណនេយ្យត្រូវបានប្រើប្រាស់ជាទូទៅ រួមមាន Quickbook, Peachtree, SUN System, SAP Software ជាដើម។

## ១.៤. សមីការគណនេយ្យ (Accounting Equation)

សម្រាប់អាជីវកម្មមួយ គឺត្រូវការធនធាន(ទុនវិនិយោគ) សម្រាប់ដំណើរការរកស៊ី ហើយធនធានទាំងនេះ នឹងត្រូវប្រើប្រាស់នៅក្នុងអាជីវកម្ម។ អាជីវកម្មនៅពេលដំណើរការដំបូង យើងសន្មត់ថាមានតែធនធានរបស់ម្ចាស់ក្រុមហ៊ុនប៉ុណ្ណោះ ដែលបានដាក់ទុនវិនិយោគរកស៊ី។ ដូចនេះយើងបានសមីការគណនេយ្យដ៏សាមញ្ញមួយ គឺ៖

ធនធានដែលម្ចាស់ក្រុមហ៊ុនដាក់វិនិយោគ = ធនធានដែលប្រើប្រាស់ក្នុងអាជីវកម្ម

Resources supplied by the owners = Resources in the business

នៅក្នុងភាសាគណនេយ្យ, ធនធានដែលម្ចាស់ក្រុមហ៊ុនដាក់វិនិយោគ ហៅថា មូលធនផ្ទាល់ (Capital/ Equity) ហើយធនធានដែលប្រើប្រាស់នៅក្នុងអាជីវកម្ម ហៅថា ទ្រព្យសកម្ម (Assets)។ ហេតុនេះ, សមីការគណនេយ្យ អាចសរសេរបានថា៖

មូលធនផ្ទាល់ = ទ្រព្យសកម្ម

Capital = Assets

ប៉ុន្តែនៅក្នុងការប្រកបអាជីវកម្មប្រចាំថ្ងៃ គេឃើញថាមានអ្នកផ្សេងទៀតដែលមិនមែនជាម្ចាស់ក្រុមហ៊ុន បានផ្តល់នូវធនធានសម្រាប់ប្រើប្រាស់នៅក្នុងអាជីវកម្មផងដែរ។ បំណុល (Liabilities) គឺជាឈ្មោះដែលគេឱ្យសម្រាប់ទឹកប្រាក់ដែលក្រុមហ៊ុនជំពាក់គេ យកមកទិញ Assets សម្រាប់ក្រុមហ៊ុន។ នោះយើងបានសមីការគណនេយ្យ៖

| |
|---|
| មូលធនផ្ទាល់ = ទ្រព្យសកម្ម - បំណុល |
| Capital = Assets - Liabilities |

ចេញពីរូបមន្តនេះ, សមីការគណនេយ្យ (Accounting Equation) ដែលគេប្រើប្រាស់ជាទូទៅគឺដូចខាងក្រោម៖

| |
|---|
| **ទ្រព្យសកម្ម = បំណុល + មូលធនផ្ទាល់** |
| **Assets = Liabilities + Capital** |

Capital ត្រូវបានបែងចែកជាពីរ គឺ Capital ដើមគ្រា និង Capital ចុងគ្រា ដែលមានទំនាក់ទំនងគ្នា ដូចខាងក្រោម៖

| |
|---|
| Capital ចុងគ្រា = Capital ដើមគ្រា - Withdrawal + Revenues – Expense |

ដែល Withdrawal = ការដកប្រាក់របស់ម្ចាស់ក្រុមហ៊ុន

Revenues = ចំណូលសរុបរបស់ក្រុមហ៊ុនក្នុងគ្រា

Expenses = ចំណាយសរុបរបស់ក្រុមហ៊ុនក្នុងគ្រា

ឧទាហរណ៍៖ លោក ចិន្តា បានបើកអាជីវកម្មរបស់គាត់ លើការផ្តល់សេវាផ្សាយពាណិជ្ជកម្មជូនអតិថិជន។ គាត់បានជួលមិត្តរបស់គាត់ឈ្មោះ ម៉េង ដើម្បីជួយគាត់នៅក្នុងអាជីវកម្មនេះ។ ខាងក្រោមជាប្រតិបត្តិការដែលបានកើតឡើងនៅក្នុងអាជីវកម្មរបស់គាត់៖

01 ឧសភា ចិន្តា បានដាក់ទុកវិនិយោគរបស់ខ្លួនចំនួន $5,000។

02 ឧសភា ចិន្តា បានទិញកុំព្យូទ័រ មួយគ្រឿង តម្លៃ $2,000។

20 ឧសភា ចិន្តា បានបង្កើត និងផ្តល់សេវាផ្សាយពាណិជ្ជជូនអតិថិជន ចំនួន ៥ ដែលមួយៗមានតម្លៃ $800 ដូចនេះសរុបមានតម្លៃ $4,000។ អតិថិជនបានបង់ជាសាច់ប្រាក់។

28 ឧសភា ចិន្តា បានបើកលុយឱ្យ ម៉េង ចំនួន $350 សម្រាប់ការងារដែលបានបំពេញ។

30 ឧសភា អាជីវកម្មរបស់ចិន្តា បានខ្ចីប្រាក់ $1,000 ពីធនាគារ Acleda ។

សូមមើលនូវឥទ្ធិពលនៃប្រតិបត្តិការខាងលើ នៅក្នុងសមីការគណនីៈ

**A. ចិន្តា បានដាក់ទុកវិនិយោគរបស់ខ្លួនចំនួន $5,000។**

| | Assets = | Liabilities | + Capital |
|---|---|---|---|
| 01 ឧសភា | $+5,000 | $ 0 | $+5,000 |
| **Total** | **$5,000** | **$0** | **$5,000** |

B. ចិន្តា បានទិញកុំព្យូទ័រ មួយគ្រឿង តម្លៃ $2,000

| | Assets = | Liabilities | + Capital |
|---|---|---|---|
| 01 ឧសភា | $+5,000 | $ 0 | $+5,000 |
| 02 ឧសភា | $-2,000 Cash<br>$+2,000 Computer | | |
| **Total** | **$5,000** | **$0** | **$5,000** |

C. ចិន្តា បានបង្កើត និងផ្តល់សេវាផ្សាយពាណិជ្ជជូនអតិថិជន ចំនួន ៥ ដែលមួយៗមានតម្លៃ $800 ដូចនេះសរុបមានតម្លៃ $4,000 ។ អតិថិជនបានបង់ជាសាច់ប្រាក់។

| | Assets = | Liabilities | + Capital |
|---|---|---|---|
| 01 ឧសភា | $+5,000 Cash | $ 0 | $+5,000 Capital |
| 02 ឧសភា | $-2,000 Cash<br>$+2,000 Computer | | |
| 20 ឧសភា | $+4,000 | | $+4,000 Revenue |
| **Total** | **$ 9,000** | **$ 0** | **$ 9,000** |

D. ចិន្តា បានបើកលុយឱ្យ ម៉េង ចំនួន $350 សម្រាប់ការងារដែលបានបំពេញ

| | Assets = | Liabilities | + Capital |
|---|---|---|---|
| 01 ឧសភា | $+5,000 Cash | $ 0 | $+5,000 Capital |
| 02 ឧសភា | $-2,000 Cash<br>$+2,000 Computer | | |
| 20 ឧសភា | $+4,000 | | $+4,000 Revenue |
| 28 ឧសភា | $-350 Cash | | $-350 Expense-Salary |
| **Total** | **$ 8,650** | **$ 0** | **$ 8,650** |

E. អាជីវកម្មរបស់ចិន្តា បានខ្ចីប្រាក់ $1,000 ពីធនាគារ Acleda

| | Assets = | Liabilities | + Capital |
|---|---|---|---|
| 01 ឧសភា | $+5,000 Cash | $ 0 | $+5,000 Capital |
| 02 ឧសភា | $-2,000 Cash<br>$+2,000 Computer | $ 0 | |
| 20 ឧសភា | $+4,000 | $ 0 | $+4,000 Revenue |
| 28 ឧសភា | $-350 Cash | $ 0 | $-350 Expense-Salary |
| 30 ឧសភា | $+1,000 Cash | $+1,000 Bank loan | $ 0 |
| **Total** | **$ 9,650** | **$ 1,000** | **$ 8,650** |

**អនុវត្តៈ**

បន្តពីលំហាត់ខាងលើ, ក្រុមហ៊ុនរបស់លោកចិន្តា បានកើតមានប្រតិបត្តិការនៅក្នុងខែមិថុនា ដូចខាងក្រោម៖

10 មិថុនា ចិន្តា បានបង្កើត និងផ្តល់សេវាផ្សាយពាណិជ្ជជូនអតិថិជន ចំនួន ៣ ដែលមួយៗ មានតម្លៃ $1,000 ដូចនេះសរុបមានតម្លៃ $3,000។ អតិថិជនមិនទាន់បានបង់ប្រាក់។

15 មិថុនា ចិន្តា បានទិញម៉ាស៊ីនស្កេនឯកសារ តម្លៃ $450 ។

29 មិថុនា ចិន្តា បានបង់សេវាអ៊ីនធឺណេត អស់ $80 សម្រាប់មួយខែ។

30 មិថុនា ធនាគារ Acleda បានគិតចំណាយការប្រាក់ អស់ $25។ ប៉ុន្តែចិន្តា មិនទាន់បង់ប្រាក់។

ចូរបំពេញតារាងខាងក្រោម៖

| | Assets = | Liabilities | + Capital |
|---|---|---|---|
| ដើមខែ | $ 9,650 | $ 1,000 | $ 8,650 |
| 10 មិថុនា | | | |
| 15 មិថុនា | | | |
| 29 មិថុនា | | | |
| 30 មិថុនា | | | |
| Total | | | |

## ១.៥. ចំណាត់ថ្នាក់មាតិកាគណនី

ជារួម, ចំណាត់ថ្នាក់មាតិកាគណនីនៃការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុ ត្រូវបានបែងចែកជាទ្រព្យសកម្ម, បំណុល, មូលធនផ្ទាល់, ចំណូល, និងចំណាយ ព្រមទាំងការដកចំណាយផ្ទាល់ខ្លួន។

### ១.៥.១. ទ្រព្យសកម្ម (Assets)

Assets គឺរាល់ទ្រព្យ ឬធនធានដែលក្រុមហ៊ុនកំពុងកាន់កាប់ និងប្រើប្រាស់ ក្នុងការរកស៊ី។ Assets ត្រូវបានបែងចែកជាពីរធំៗ គឺ ទ្រព្យសកម្មរយៈពេលខ្លី (Current Assets) និងទ្រព្យសកម្មរយៈពេលវែង (Noncurrent Assets/ Fixed Assets) ។

❖ ទ្រព្យសកម្មរយៈពេលវែង (Noncurrent Assets/ Fixed Assets) សំដៅដល់ទ្រព្យសកម្មទាំងឡាយណាដែលក្រុមហ៊ុនកាន់កាប់ ដើម្បីប្រើប្រាស់រកស៊ី លើសពីមួយការិយបរិច្ឆេទគណនេយ្យ (អាយុកាលប្រើប្រាស់លើសពី ១ឆ្នាំ)។ ឧទាហរណ៍៖

- Land and building
- Machinery
- Equipment
- Computer

- Vehicles
- Patent

❖ ទ្រព្យសកម្មរយៈពេលខ្លី (Current Assets) សំដៅដល់ទ្រព្យសកម្មទាំងឡាយណាដែលក្រុមហ៊ុនកាន់កាប់ ដើម្បីប្រើប្រាស់រកស៊ី ក្រោមមួយការិយបរិច្ឆេទគណនេយ្យ (អាយុកាលប្រើប្រាស់ក្រោម ១ឆ្នាំ) ឬពេលខ្លះសំដៅលើសាច់ប្រាក់ និងសាច់ប្រាក់សមមូល។ ឧទាហរណ៍៖

- Cash
- Bank
- Receivables
- Inventories
- Supplies
- Prepayment

### ១.៥.២. បំណុល (Liabilities)

Liabilities គឺជាចំនួនទឹកប្រាក់ដែលក្រុមហ៊ុនជំពាក់គេនៅពេលរកស៊ី។ ក្រុមហ៊ុនមានកាតព្វកិច្ចត្រូវសងបំណុលទាំងនេះ។ បំណុលត្រូវបានបែងចែកជាពីរប្រភេទ គឺបំណុលរយៈពេលវែង (Noncurrent Liabilities) និងបំណុលរយៈពេលខ្លី (Current Liabilities)។

❖ បំណុលរយៈពេលវែង (Noncurrent Liabilities) សំដៅដល់កាតព្វកិច្ចទាំងឡាយណាដែលក្រុមហ៊ុនត្រូវសង លើសពីមួយការិយបរិច្ឆេទគណនេយ្យ (ជំពាក់លើសពី ១ឆ្នាំ)។ ឧទាហរណ៍៖

- Long-term Borrowing
- Bonds

❖ បំណុលរយៈពេលខ្លី (Current Liabilities) សំដៅដល់កាតព្វកិច្ចទាំងឡាយណាដែលក្រុមហ៊ុនត្រូវសង នៅក្នុងអំឡុងការិយបរិច្ឆេទគណនេយ្យ (ជំពាក់ក្រោម ១ឆ្នាំ)។ ឧទាហរណ៍៖

- Trade Payables
- Salary payables
- Bank Overdraft

### ១.៥.៣. មូលធនផ្ទាល់ (Capital/Equity)

Capital/Equity សំដៅលើធនធាន ដែលផ្តល់ឱ្យអាជីវកម្មដោយម្ចាស់ក្រុមហ៊ុន ហើយ Capital/Equity គឺជាភាពខុសគ្នានៃទ្រព្យសកម្ម និងបំណុល (Assets – Liabilities) ដែលបង្ហាញពីធនធានដែលម្ចាស់ក្រុមហ៊ុនមាន នៅពេលវេលាជាក់លាក់ណាមួយ។ Capital/Equity រួមមានគណនី៖

- Capital

- Share Capital
- Share Premium
- Retained Earning
- Withdrawal

### ១.៥.៤. ចំណូល ( Income )

Income សំដៅលើទឹកប្រាក់ដែលបានមកពីការផ្តល់សេវាកម្ម ឬលក់ទំនិញជូនអតិថិជន ឬការលក់ ឬជួលទ្រព្យសកម្មរបស់ក្រុមហ៊ុន។ Income រួមមានគណនី៖

- Revenues
- Other income
- Interest income
- Rent income

### ១.៥.៥. ចំណាយ ( Expenses )

Expenses សំដៅលើថ្លៃដំណើរការរបស់អាជីវកម្មមួយ ដើម្បីបង្កើតចំណូល។ Expenses រួមមានគណនី៖

- Cost of goods sold
- Salary expense
- Administration expense
- Marketing expense
- Rent expense

ខាងក្រោមនេះ ជាឧទាហរណ៍នៃមាតិកាគណនី៖

**<u>មាតិកាគណនី នៃប្លង់គណនេយ្យទូទៅរបស់រដ្ឋ</u>**[1]

ថ្នាក់ ១៖ ទ្រព្យសកម្មរយៈពេលខ្លី( Current Assets Account )

11: ធនាគារ

12: ប្រាក់បញ្ញើនៅរតនាគារ

13: បេឡាសាច់ប្រាក់

14: រដ្ឋទេយ្យបុរេប្រទាន

15: គណនីត្រូវទទួល

16:ការវិនិយោគរយៈពេលខ្លី

ថ្នាក់ ២៖ ទ្រព្យសកម្មរយៈពេលវែង( Non-Current Assets Account )

---

[1] ប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចជាតិ នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

20: អចលកម្មអរូបី

2003: សោហ៊ុយសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍន៍

2005: ប្រកាសនីយបត្រ អាជ្ញាបណ្ណ និងសិទ្ធិប្រហាក់ប្រហែល

21: អចលកម្មរូបី

22: ទ្រព្យសម្បត្តិវិនិយោគរយៈពេលវែង

23: អចលកម្មកំពុងដំណើរការ

24: អចលកម្មដែលបានបែងចែក ឬប្រគល់ឲ្យប្រើប្រាស់

26: ការវិនិយោគ

27: អចលកម្មហិរញ្ញវត្ថុផ្សេងៗ

28: រំលស់អចលកម្ម និងការធ្លាក់ចុះតម្លៃ

ថ្នាក់ ៣៖ មូលធន និងធនបំរុង (Capital/Equity Account)

30:មូលធន និងធនបំរុង

31:យោងជាថ្មី

32:លទ្ធផល នៃការិយបរិច្ឆេទ

ថ្នាក់ ៤៖ បំណុលរយៈពេលខ្លី(Current Liabilities Account)

40:អ្នកផ្គត់ផ្គង់

41:ការខ្ចីពីទីផ្សារហិរញ្ញវត្ថុរយៈពេលខ្លី

42:បន្ទុកបុគ្គលិកត្រូវសង

43:គណនីទំនាក់ទំនង

44:ប្រាក់បញ្ញើរបស់រដ្ឋ និងសមូហភាព

45:ប្រាក់បញ្ញើរបស់ក្រុមហ៊ុនឯកជន និងអង្គការជាតិ-អន្តរជាតិ

46:ប្រាក់កក់ធានាសម្រាប់លទ្ធកម្មសាធារណៈ

47:គណនីចម្លង ឬគណនីរង់ចាំ

48:គណនីនិយ័តកម្ម

ថ្នាក់ ៥៖ បំណុលរយៈពេលវែង(Non-Current Liabilities Account)

50:ការខ្ចីប្រាក់ និងបំណុលប្រហាក់ប្រហែល

51:ប្រាក់តម្កល់ធានាសកម្មភាពអាជីវកម្មបានទទួល

ថ្នាក់ ៦៖ ចំណាយចរន្ត(Expenses Account)

60:ការទិញ

61:សេវាកម្ម

62:អត្ថប្រយោជន៍សង្គម

63:ពន្ធ និងអាករ

64:បន្ទុកបុគ្គលិក

65 :ឧបត្ថម្ភកធន

66 :បន្ទុកហិរញ្ញវត្ថុ

67 :បន្ទុកពិសេស (ឥណទេយ្យដែលទទួលស្គាល់តែទារមិនបាន)

68 :ទាយជ្ជទានឲ្យដល់រំលស់អចលកម្ម

ថ្នាក់ ៧៖ គណនីចំណូល( Revenues Account)

70:ចំណូលសារពើពន្ធក្នុងស្រុក

71:ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស

72 :ផលទុននៃទ្រព្យសម្បត្តិរដ្ឋ

73 :ផលទុនលើការលក់-ជួលទ្រព្យសម្បត្តិ និងសេវា

74 :ផលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម

75 :ការឧបត្ថម្ភ-អំណោយ

76 :ផលហិរញ្ញវត្ថុ

77 :ផលផ្សេងៗ និងផលពិសេស

78:ការបញ្ចូលវិញនូវសំវិធានធន និងរំលស់អចលកម្ម

**Chart of Accounts ដែលប្រើប្រាស់នៅក្នុងប្រព័ន្ធ Software គណនេយ្យ**

| Account ID | Account Description | Active? | Type of Account |
|---|---|---|---|
| 100 | Current Assets | No | Current Assets |
| 101 | Cash | Yes | Cash |
| 102 | Bank | Yes | Cash |
| 103 | Inventory | Yes | Current Assets |
| 104 | Account Receivable | Yes | Current Assets |
| 105 | Prepayments | Yes | Current Assets |
| 106 | Supply | Yes | Current Assets |
| 110 | Non-Current Assets | No | Non-Current Assets |
| 111 | Equipment | Yes | Non-Current Assets |
| 112 | Furniture | Yes | Non-Current Assets |
| 200 | Current Liabilities | No | Current Liabilities |
| 201 | Account Payable | Yes | Current Liabilities |
| 210 | Non-Current Liabilities | No | Non-Current Liabilities |
| 211 | Loan | Yes | Non-Current Liabilities |

| | | | |
|---|---|---|---|
| 300 | Capital | Yes | Equity-doesn't close |
| 310 | Drawing | Yes | Equity-gets closed |
| 400 | Revenues | No | Income |
| 401 | Sales | Yes | Income |
| 500 | Cost of goods sold | Yes | Cost of goods sold |
| 600 | Expenses | No | Expenses |
| 601 | Salary | Yes | Expenses |
| 602 | Rent | Yes | Expenses |
| 603 | Supply expense | Yes | Expenses |
| 604 | Utility | Yes | Expenses |

## ១.៦. សេចក្តីសន្និដ្ឋាន

នៅពេលដែលយើងចង់ផ្តើមរកស៊ី យើងត្រូវយល់ដឹងអំពីការបែងចែកក្រុមហ៊ុនអាជីវកម្មជា ៣ ប្រភេទ គឺៈ ១).ក្រុមហ៊ុនឯកកម្មសិទ្ធិ, ២).ក្រុមហ៊ុនសហកម្មសិទ្ធិ និង ៣).ក្រុមហ៊ុនសាជីវកម្ម។ ចំពោះក្រុមហ៊ុនឯកកម្មសិទ្ធិ និងសហកម្មសិទ្ធិ , ម្ចាស់ក្រុមហ៊ុនមានកាតព្វកិច្ចទទួលខុសត្រូវមិនកំណត់ ចំពោះលទ្ធផលកើតចេញពីដំណើរការរកស៊ីនោះ។ ប៉ុន្តែ ចំពោះក្រុមហ៊ុនសាជីវកម្មវិញ ម្ចាស់ក្រុមហ៊ុន មានទំនួលខុសត្រូវមានកម្រិត ពោលគឺប្រសិនបើការរកស៊ីខាត នោះម្ចាស់ក្រុមហ៊ុនប្រភេទនេះ នឹងខាត ត្រឹមតែទឹកប្រាក់ដែលខ្លួនបានវិនិយោគប៉ុណ្ណោះ។

សមីការគណនេយ្យដែលជាមូលដ្ឋានគ្រឹះ សម្រាប់អ្នកសិក្សាជំនាញគណនេយ្យ និងហិរញ្ញវត្ថុ គឺ Assets = Liabilities + Capital ។ រាល់ប្រតិបត្តិការហិរញ្ញវត្ថុដែលបានកើតមាន នឹងត្រូវវងនូវឥទ្ធិពល ពីរ ដែលត្រូវតែធានាថាសមីការគណនេយ្យនៅតែរក្សាបាន។ ជាចុងក្រោយ, យើងត្រូវចងចាំនូវប្រភេទ នៃគណនីនីមួយៗ ដែលនឹងត្រូវយកទៅកត់ត្រាគណនេយ្យនៅក្នុងមេរៀនបន្តបន្ទាប់។

# លំហាត់

## I. សំណួរពហុជ្រើសរើស (MCQ)

1) តើខាងក្រោមនេះ ណាខ្លះផលវិជ្ជមាននៅពេលដែលអ្នកបើកក្រុមហ៊ុនជា ក្រុមហ៊ុនសាជីវកម្ម (Limited Liability Company)

(i). ដំណើរការជាក្រុមហ៊ុនសាជីវកម្ម នឹងធ្វើឱ្យមានភាពងាយស្រួលក្នុងការបង្កើនដើមទុនតាមរយៈការបោះភាគហ៊ុនលក់នៅលើទីផ្សារភាគហ៊ុន។

(ii). ដំណើរការជាក្រុមហ៊ុនសាជីវកម្ម នឹងមានហានិភ័យខ្លាំងជាងដំណើរការជាក្រុមហ៊ុនឯកកម្មសិទ្ធិ ពីព្រោះម្ចាស់ក្រុមហ៊ុនសាជីវកម្មនឹងទទួលខុសត្រូវទាំងស្រុងលើបំណុលដែលក្រុមហ៊ុនមាន ប៉ុន្តែម្ចាស់ក្រុមហ៊ុនឯកកម្មសិទ្ធ មានកាតព្វកិច្ចសងបំណុលត្រឹមទុនវិនិយោគដែលខ្លួនបានដាក់ប៉ុណ្ណោះ។

a. (i) តែប៉ុណ្ណោះ
b. (ii) តែប៉ុណ្ណោះ
c. (i) និង (ii)
d. មិនមែនទាំង (i) និង (ii)

2) លោកសុខ បានចាប់ផ្តើមរកស៊ីជាមួយនឹងដើមទុនចំនួន $10,000 ។ គាត់ក៏ទទួលបានកម្ចីពីធនាគារចំនួន $6,000 ដើម្បីទិញទ្រព្យសកម្មរយៈពេលវែង។ តើតម្លៃទ្រព្យសកម្មសរុបរបស់អាជីវកម្មលោកសុខស្មើប៉ុន្មាន?

a. $4,000
b. $6,000
c. $10,000
d. $16,000

3) ក្រុមហ៊ុនឯកកម្មសិទ្ធិមួយ បានខ្ចីលុយពីធនាគារចំនួន $10,000 ។ តើជាតុមួយណានៃសមីការគណនេយ្យ នឹងប្រែប្រួលដោយសារប្រតិបត្តិការនេះ?

a. Assets និង Liabilities
b. Assets និង Capital
c. Capital និង Liabilities
d. Assets តែប៉ុណ្ណោះ

4) តើខាងមក្រោមនេះមួយណា ជាទ្រព្យដែលក្រុមហ៊ុនកាន់កាប់ និងប្រើប្រាស់ក្នុងការរកស៊ី?

a. Assets
b. Liabilities
c. Equity
d. Income

5) ម៉ាស៊ីនត្រូវបានទិញជាសាច់ប្រាក់តម្លៃ $20,000 ។ តើប្រតិបត្តិការនេះ មានឥទ្ធិពលយ៉ាងណានៅក្នុងសមីការគណនេយ្យ ?
   a. Assets ថយចុះ, Liabilities កើនឡើង, Capital មិនប្រែប្រួល
   b. Assets មិនប្រែប្រួល, Liabilities មិនប្រែប្រួល, Capital មិនប្រែប្រួល
   c. Assets ថយចុះ, Liabilities មិនប្រែប្រួល, Capital ថយចុះ
   d. Assets កើនឡើង, Liabilities កើនឡើង, Capital មិនប្រែប្រួល

6) ដាណេ បានលក់ទំនិញដែលនាងបានទិញចូលតម្លៃ $2,622 ឱ្យទៅអតិថិជនក្នុងតម្លៃ $1,950 ជាសាច់ប្រាក់។ តើ Assets និង Capital រងឥទ្ធិពលយ៉ាងណាពីការលក់នេះ ?
   a. Assets ថយចុះចំនួន $672, និង Capital ថយចុះចំនួន $672
   b. Assets កើនឡើងចំនួន $1,950, និង Capital ថយចុះចំនួន $672
   c. Assets កើនឡើងចំនួន $672, និង Capital កើនឡើងចំនួន $2,622
   d. Assets ថយចុះចំនួន $2,622, និង Capital ថយចុះចំនួន $672

7) មួយណាខាងក្រោមនេះ គឺជាប្រភេទ Asset របស់ក្រុមហ៊ុនមួយ ?
   a. Trade payables
   b. A loan
   c. Bank overdraft
   d. Cash in hand

8) តើខាងក្រោមនេះ មួយណាពិពណ៌នាត្រឹមត្រូវអំពី ទ្រព្យសកម្មរយៈពេលខ្លី (Non-current Assets) ?
   a. ទ្រព្យសកម្មដែលរំពឹងថាអាចក្លាយទៅសាច់ប្រាក់ក្នុងរយៈពេលខ្លី។
   b. ទ្រព្យសកម្មដែលត្រូវបានប្រើប្រាស់ក្នុងការធ្វើអាជីវកម្មបច្ចុប្បន្ន។
   c. ទ្រព្យសកម្មដែលស្ថិតនៅក្នុងអគាររបស់ក្រុមហ៊ុន។
   d. ទ្រព្យសកម្មដែលមិនរំពឹងថាអាចក្លាយទៅជាសាច់ប្រាក់ក្នុងរយៈពេលខ្លីបាន។

9) ក្រុមហ៊ុនរបស់អ្នក បានរកចំណូលក្នុងរយៈពេលមួយឆ្នាំបាន $30,000 និងចំណាយអស់ $24,600 ក្នុងការគាំទ្ររកចំណូលទាំងនេះ។
គេដឹងថានៅចុងឆ្នាំ ទ្រព្យម្ចាស់ផ្ទាល់ (Capital) មានតម្លៃ $45,000 ហើយក្នុងឆ្នាំម្ចាស់បានដកប្រាក់ (Withdrawal) ចំនួន $3,000។ តើទឹកប្រាក់វិនិយោគដំបូងរបស់អ្នកស្មើប៉ុន្មាន ?
   a. $53,400
   b. $47,400
   c. $42,600
   d. $42,000

10) តើខាងក្រោមនេះ មួយណាមិនមែនប្រភេទនៃចំណាត់ថ្នាក់មាតិកាគណនី?

a. Profits
b. Assets
c. Liabilities
d. Equity

## II. ចូរបំពេញតារាងខាងក្រោម៖

1) ចូរបំពេញចន្លោះក្នុងតារាងខាងក្រោម៖

| | Assets | Liabilities | Capital |
|---|---|---|---|
| | $ | $ | $ |
| (a) | ……….. | 4,100 | 1,300 |
| (b) | 3,870 | ……….. | 2,680 |
| (c) | 9,875 | ……….. | 8,680 |
| (d) | ……….. | 543 | 637 |
| (e) | 6,767 | 1,107 | ……….. |

2) ចូរបំពេញចន្លោះក្នុងតារាងខាងក្រោម៖

| | Assets | Liabilities | Capital |
|---|---|---|---|
| | $ | $ | $ |
| (a) | 12,231 | ……….. | 7,887 |
| (b) | 23,434 | 18,312 | ……….. |
| (c) | ……….. | 23,111 | 51,312 |
| (d) | 54,524 | 9,090 | ……….. |
| (e) | 31,231 | ……….. | 20,022 |

3) ចូរបំពេញចន្លោះក្នុងតារាងខាងក្រោម៖

| | Assets | Liabilities | Capital |
|---|---|---|---|
| | $ | $ | $ |
| (a) | ……….. | 31,221 | 33,343 |
| (b) | ……….. | 23,123 | 76,990 |
| (c) | 64,564 | ……….. | 54,693 |
| (d) | 76,575 | 11,200 | ……….. |
| (e) | 86,788 | 31,231 | ……….. |

4) ក្រុមហ៊ុន XYZ បានកើតមាននូវប្រតិបត្តិការដូចខាងក្រោម៖

a. ម្ចាស់ក្រុមហ៊ុន ដាក់ទុនវិនិយោគចំនួន $30,000 ជាសាច់ប្រាក់ និងជាដីនិងអគារតម្លៃ $120,000
b. ទិញសំភារៈបរិក្ខារតំលៃ $26,000 ជាសាច់ប្រាក់
c. រកចំណូលបានសរុប $4,200 ដោយអតិថិជនបង់ជាសាច់ប្រាក់ចំនួន $2,000 ហើយសល់ប៉ុន្មានអតិថិជនជំពាក់
d. ទិញរថយន្តមួយគ្រឿងតម្លៃ $40,000 ដោយជំពាក់
e. បង់ថ្លៃឈ្នួលកម្មករ $700 ជាសាច់ប្រាក់
f. រកចំណូលបាន $1,600 ពីការផ្តល់ប្រឹក្សា និង $300 ពីការជួលសំភារ ប៉ុន្តែអតិថិជនជំពាក់ទាំងអស់
g. អតិថិជនសងប្រាក់ដែលជំពាក់ $2,900
h. ម្ចាស់ក្រុមហ៊ុនបានដកប្រាក់$200 សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន

ចូរបំពេញតារាងខាងក្រោម៖

| | Assets = | Liabilities | + Capital |
|---|---|---|---|
| a. | | | |
| b. | | | |
| c. | | | |
| d. | | | |
| e. | | | |
| f. | | | |
| g. | | | |
| h. | | | |
| **Total** | | | |

## III. សំណួរត្រិះរិះ

1) ចូរចាត់ថ្នាក់នូវគណនីខាងក្រោម មួយណាជា Assets និងមួយណាជា Liabilities ៖
   a) សាច់ប្រាក់ដែលក្រុមហ៊ុននឹងត្រូវបង់ជូនក្រុមហ៊ុនដទៃដើម្បីទិញសម្ភារៈបរិក្ខារ
   b) សាច់ប្រាក់ដាក់នៅធនាគារ
   c) ចំណាយបង់មុនលើការប្រើប្រាស់ទូរស័ព្ទ
   d) សាច់ប្រាក់ក្រុមហ៊ុនជំពាក់គេ
   e) សាច់ប្រាក់ដែលគេជំពាក់ក្រុមហ៊ុន

2) ចូរចាត់ថ្នាក់នូវគណនីខាងក្រោម មួយណាជា Assets និងមួយណាជា Liabilities ៖
   a) ដីនិងអគាររបស់ក្រុមហ៊ុន
   b) សាច់ប្រាក់ក្រុមហ៊ុនជំពាក់ធនាគាររយៈពេលខ្លី (Bank Overdraft)
   c) សាច់ប្រាក់ភាគីផ្សេងជំពាក់ក្រុមហ៊ុន
   d) គ្រឿងសម្ភារបរិក្ខារដែលក្រុមហ៊ុនជំពាក់គេ
   e) កម្ចីទិញដីនិងអគារ
   f) សាច់ប្រាក់ក្នុងដៃ
   g) វិក្កយបត្រមិនទាន់ទូទាត់

3) តើអ្នកយល់ថាចំណាត់ថ្នាក់ទៅតាម Assets ឬ Liabilties ខាងក្រោម ត្រឹមត្រូវឬទេ?

   a) អ្នកបានទិញឡានដឹកទំនិញ (Delivery Truck) ពីអ្នកផ្គត់ផ្គងក្នុងតម្លៃ $120,000 ។ អ្នកផ្គត់ផ្គង់គឺស្ថិតនៅប្រទេសថៃ ប៉ុន្តែអ្នកបានបង់ប្រាក់ជូនអ្នកផ្គត់ផ្គង់រួចហើយ។ ឡានដឹកទំនិញនេះ នឹងប្រគល់ជូនក្រុមហ៊ុនអ្នកនៅរយៈពេលមួយខែក្រោយ។
      តើអ្នកគួរតែទទួលស្គាល់ឡាននេះ ជា Asset ឬទេ?

   b) អ្នកបានលក់ទំនិញតម្លៃ $1,000 ជូនអតិថិជនរបស់ខ្លួន ប៉ុន្តែអតិថិជន មិនទាន់បានបង់ប្រាក់នៅឡើយ។
      តើអ្នកគួរតែទទួលស្គាល់ទឹកប្រាក់ដែលអតិថិជនជំពាក់ជា Asset ឬទេ?

   c) ក្រុមហ៊ុនរបស់អ្នក បានខ្ចីលុយពីធនាគារអភិវឌ្ឍន៍ជនបទចំនួន $50,000។ កម្ចីនេះត្រូវបានធនាគារជូនដំណឹងជាផ្លូវការថា លើកលែង (លុបចោល ពុំចាំបាច់សង)។
      តើអ្នកគួរតែនៅចាត់ទុកកម្ចីនេះ ជា Liability ឬយ៉ាងណា?

   d) អ្នកបានទិញដីមួយកន្លែងតម្លៃ $500,000 ។ ដោយមិនបានគិតទុកជាមុន, អ្នកបានឃើញថា ដីនោះ មានដើមឈើ 200 ដើម ដែលអាចកាប់លក់បានតម្លៃ $120,000។ ម្ចាស់ដី និងអ្នក មិនបានដឹងថាមានដើមឈើទាំងនោះទេ ហេតុនេះ គឺមិនបានបញ្ចូលទៅក្នុងតម្លៃដី $500,000 នោះទេ។
      តើអ្នកគួរទទួលស្គាល់ដើមឈើទាំងនោះជា Asset ឬយ៉ាងណា?

# មេរៀនទី២៖ ប្រព័ន្ធកត់ត្រាទ្វេភាគ

( Chapter 2: Double-entry System )

**គោលបំណងនៃមេរៀនទី២ នេះ ផ្តោតលើ៖**

- ឯកសារអាជីវកម្ម
- ច្បាប់នៃប្រព័ន្ធកត់ត្រាទ្វេភាគ

បន្ទាប់ពីសិក្សាជំពូកទី២ នេះ យើងអាច៖

- ស្គាល់អំពីប្រភេទនៃប្រតិបត្តិការអាជីវកម្ម។
- ស្វែងយល់ពីប្រភេទឯកសារអាជីវកម្មដែលតែងតែកើតមានឡើងនៅក្នុងដំណើរការអាជីវកម្ម។
- យល់ដឹងអំពីប្រព័ន្ធ និងច្បាប់នៃការកត់ត្រាទ្វេភាគសម្រាប់ប្រតិបត្តិការអាជីវកម្ម។
- ចេះកត់ត្រាប្រតិបត្តិការតាមប្រព័ន្ធទ្វេភាគ។

## ២.១. សេចក្តីផ្តើម

នៅពេលណាក៏ដោយដែលរបស់អ្វីមួយ ផ្លាស់ប្តូរកម្មសិទ្ធិពីមនុស្សម្នាក់ទៅម្នាក់ទៀត នោះវានឹងកើតមានប្រតិបត្តិការអាជីវកម្ម។ សម្រាប់អាជីវកម្ម ប្រតិបត្តិការជាធម្មតា( កើតឡើងញឹកញាប់ជាងគេ) គឺ ការទិញ និងការលក់។ ការទិញ និងការលក់ កើតមានឡើងជាពីរប្រភេទ នោះគឺជាសាច់ប្រាក់ និងដោយជំពាក់។

- ការលក់ អាចជា៖
  1. **ការលក់ជាសាច់ប្រាក់** គឺកើតមាននៅពេលដែលទំនិញឬសេវាកម្ម ត្រូវផ្តល់ជូនអតិថិជនស្របពេលដែលមានការទូទាត់ភ្លាម ជាក្រដាសប្រាក់ ឬជាមូលប្បទានបត្រ ឬតាមប្រព័ន្ធធនាគារ។
  2. **ការលក់ដោយជំពាក់** គឺកើតមាននៅពេលដែលទំនិញ ឬសេវាកម្ម ត្រូវផ្តល់ជូនអតិថិជនមុនពេលទូទាត់សាច់ប្រាក់។ ប្រសិនបើជាការលក់ដោយជំពាក់ មានន័យថាការលក់កើតឡើងនៅពេលក្រុមហ៊ុនចេញវិក្កយបត្រជូនអតិថិជន សម្រាប់ទំនិញ ឬសេវាដែលបានផ្តល់ជូន ហើយសាច់ប្រាក់ត្រូវទូទាត់តាមក្រោយ។
- ការទិញ អាចជា៖
  1. **ការទិញជាសាច់ប្រាក់** គឺកើតមាននៅពេលទំនិញ ឬសេវាកម្ម ត្រូវទិញពីអ្នកផ្គត់ផ្គង់ ហើយទូទាត់ប្រាក់ភ្លាមៗ។
  2. **ការទិញដោយជំពាក់** គឺកើតមាននៅពេលទំនិញ ឬសេវាកម្ម ត្រូវទិញពីអ្នកផ្គត់ផ្គង់ ជាមួយនឹងវិក្កយបត្រ ប៉ុន្តែការទូទាត់នឹងត្រូវកើតមាននៅពេលក្រោយ។

ក្រៅពីប្រតិបត្តិការជាធម្មតាខាងលើ, ក៏នៅមានប្រភេទប្រតិបត្តិការអាជីវកម្មផ្សេងទៀត ដែលនឹងត្រូវកត់ត្រាផងដែរ ដូចជា៖

- ❖ ការទូទាត់បៀវត្ស
- ❖ ការខ្ចីប្រាក់
- ❖ ការបញ្ចុះតម្លៃ
- ❖ ការបង់ពន្ធ
- ❖ ផ្សេងៗ

## ២.២. ឯកសារអាជីវកម្ម ( Business Documents )

ប្រតិបត្តិការអាជីវកម្ម អាចត្រូវបញ្ជាក់ដោយឯកសារខាងក្នុង និងឯកសារខាងក្រៅ។ ជាធម្មតា, ការកត់ត្រាប្រតិបត្តិការអាជីវកម្ម តម្រូវឱ្យមានឯកសារ ហើយចំនួនឯកសារតម្រូវ នឹងខុសៗគ្នាទៅតាមប្រភេទប្រតិបត្តិការ និងអ្នកពាក់ព័ន្ធ។ ឯកសារសំខាន់ៗ អាចរួមមាន៖

- ❖ Quotation ៖ ជាឯកសារមួយដែលផ្ញើទៅឱ្យអតិថិជន ដោយអ្នកលក់ ដោយបង្ហាញអំពីតម្លៃលក់ដែលអតិថិជនត្រូវបង់។
- ❖ Purchase order ៖ ជាឯកសារស្នើពីអ្នកទិញ ដើម្បីបញ្ជាទិញទំនិញ ឬសេវាកម្ម ដូចការបញ្ជាទិញវត្ថុជាតុដើម។
- ❖ Sale order ៖ ជាឯកសារដែលរៀបចំដោយអ្នកលក់ ដោយថតចំលងព័ត៌មានពីឯកសារស្នើទិញរបស់អតិថិជន ( Purchase order )។ ពេលខ្លះ Sale order អាចត្រូវបានបំពេញនិងចុះហត្ថលេខាដោយអតិថិជន។
- ❖ Goods dispatched note៖ ជាបញ្ជីរាយមុខទំនិញដែលអ្នកលក់ បានផ្ញើជូនអតិថិជន។ ឯកសារនេះត្រូវផ្ញើទៅឱ្យអតិថិជននៅពេលដែលទំនិញត្រូវបានដឹកទៅអតិថិជន។
- ❖ Goods received note៖ ជាបញ្ជីទំនិញដែលអ្នកទិញបានទទួលបានពីអ្នកលក់។ ឯកសារនេះ ជាធម្មតារៀបចំដោយអ្នកកាន់ឃ្លាំងរបស់ក្រុមហ៊ុនជាអ្នកទិញ។
- ❖ Invoice៖ ជាឯកសារផ្ញើឱ្យអតិថិជន ដោយអ្នកលក់ ដោយត្រូវរាយមុខទំនិញ និងតម្លៃដែលបានលក់។ ឯកសារនេះ ត្រូវបានប្រើសម្រាប់អតិថិជនធ្វើការទូទាត់សាច់ប្រាក់។
- ❖ Statement៖ ជាឯកសារផ្ញើឱ្យអតិថិជន ដោយអ្នកលក់ដែលបង្ហាញអំពី រាល់វិក្កយបត្រ, credit notes និង ការទទួលបាននូវការទូទាត់ពីអតិថិជន។
- ❖ Debit note៖ ឯកសារមួយដែលអតិថិជនផ្ញើទៅឱ្យអ្នកលក់ ពាក់ព័ន្ធនឹងការបញ្ជូនទំនិញត្រឡប់មកវិញ ឬការទូទាត់សាច់ប្រាក់លើស។ ឯកសារនេះ ត្រូវផ្ញើទៅឱ្យអ្នកលក់ ដើម្បីចេញ credit note ។
- ❖ Credit note៖ ជាឯកសារមួយដែលអ្នកលក់ផ្ញើទៅឱ្យអតិថិជនដែលបានបញ្ជូនទំនិញត្រឡប់មកវិញ ឬដែលបានទូទាត់សាច់ប្រាក់លើស។ ឯកសារនេះត្រូវបានគេហៅថា “negative” invoice។

- ❖ Remittance advice៖ ជាឯកសារបង្ហាញពីការទូទាត់ថ្លៃទំនិញ ដោយបង្ហាញលម្អិតពីវិក្កយបត្រណាត្រូវទូទាត់ និង credit note ណាបានកាត់កង។
- ❖ Receipt៖ ជាឯកសារបញ្ជាក់ថាបានទទួលសាច់ប្រាក់ដែលអតិថិជនបានទូទាត់។ ឯកសារនេះ ជាទូទៅកើតមាននៅពេលការលក់ទំនិញ ត្រូវបានទូទាត់សាច់ប្រាក់ភ្លាមៗ។
- ❖ Bank Statement៖ ជារបាយការណ៍មួយ ដែលបង្ហាញជាសង្ខេបអំពីសមតុល្យគណនីធនាគារ, ការទូទាត់សាច់ប្រាក់, ការទទួលបានសាច់ប្រាក់, ការប្រាក់ និងកម្រៃធនាគារ។

| <u>ប្រតិបត្តិការ</u> | <u>ឯកសារដែលត្រូវប្រើ</u> |
| --- | --- |
| លក់ជាសាច់ប្រាក់ | Receipt នឹងត្រូវចេញជូនអតិថិជន |
| លក់ដោយជំពាក់ | វិក្កយបត្រ នឹងត្រូវចេញជូនអតិថិជន |
| Sales return | ១. Debit note នឹងត្រូវចេញដោយអតិថិជន ដើម្បីបញ្ជូនទំនិញវិញ<br>២. Credit note នឹងត្រូវចេញជូនអតិថិជន ដើម្បីបញ្ជាក់ថាបានទទួលទំនិញបង្វិលមកវិញ |
| ទិញជាសាច់ប្រាក់ | នឹងទទួលបាន Receipt ពីអ្នកលក់ |
| ទិញដោយជំពាក់ | នឹងទទួលបាន Invoice ពីអ្នកលក់ |
| Purchase return | ១. Debit note នឹងត្រូវចេញ ដើម្បីបញ្ជូនទំនិញទៅអ្នកលក់វិញ<br>២. Credit note នឹងត្រូវចេញដោយអ្នកលក់ ដើម្បីបញ្ជាក់ថាបានទទួលទំនិញបង្វិលមកវិញ |

**<u>អនុវត្ត៖</u>** ចូរបំពេញឈ្មោះឯកសារនៅក្នុងចន្លោះខាងក្រោម ទៅតាមដំណាក់នៃការទិញទំនិញជាសាច់ប្រាក់ ឬការទិញដោយជំពាក់។

1)-ស្នើសុំទៅក្រុមហ៊ុនផ្គត់ផ្គង់ទំនិញ ដើម្បីផ្តល់ទំនិញ ______

2)-ជូនដំណឹងដោយក្រុមហ៊ុនផ្គត់ផ្គង់ទំនិញ នូវទឹកប្រាក់ដែលបានជំពាក់ពីការទិញទំនិញ ______

3)-ជូនដំណឹងពីក្រុមហ៊ុនទិញទំនិញទៅក្រុមហ៊ុនផ្គត់ផ្គង់ទំនិញ នូវទឹកប្រាក់ដែលបានទូទាត់ ______

4)-លប់ទឹកប្រាក់ដែលបានជំពាក់ក្រុមហ៊ុនផ្គត់ផ្គង់ទំនិញ ______

5)-កត់ត្រាការលក់ជាសាច់ប្រាក់ទៅឱ្យអតិថិជន ______

## ២.៣. ទស្សនាទាននៃការកត់ត្រាទ្វេភាគ (Double Entry System)

យើងបានដឹងរួចមកហើយថារាល់ប្រតិបត្តិនីមួយៗមានឥទ្ធិពលយ៉ាងតិចពីរ នៅក្នុងការសិក្សាសមីការគណនេយ្យ។ ហេតុនេះ យើងក៏ត្រូវបង្ហាញនូវឥទ្ធិពលយ៉ាងតិចទៅលើគណនីពីរនៅក្នុងសៀវភៅបញ្ជីគណនេយ្យ នៅពេលយើងកត់ត្រាប្រតិបត្តិការនីមួយៗជាដំបូង ។ ដំណាក់កាលនៃការកត់ត្រាគណនេយ្យនេះ ត្រូវបានគេហៅថាការកត់ត្រាទ្វេភាគ (Double Entry)។

ដូចនេះ, តើអ្វីទៅជា Double Entry? ការកត់ត្រាទ្វេភាគ គឺជាការកត់ត្រាដែលបង្ហាញនូវការកើនឡើង ឬថយចុះនៃប្រភេទគណនីមួយ និងបង្ហាញនូវការកើនឡើង ឬថយចុះនៃប្រភេទគណនីមួយទៀត ស្របតាមគោលការណ៍សមីការគណនេយ្យ។ ឧទាហរណ៍៖ នៅពេលដែលយើងទិញរថយន្តយកមកប្រើប្រាស់ក្នុងក្រុមហ៊ុនជាសាច់ប្រាក់ នោះនឹងធ្វើឱ្យមានការកើនឡើងនូវទ្រព្យសកម្ម ជារថយន្ត និងថយចុះនូវទ្រព្យសកម្ម ជាសាច់ប្រាក់។ ម្យ៉ាងវិញទៀត, នៅពេលដែលក្រុមហ៊ុនទិញកុំព្យូទ័រដោយជំពាក់ នោះនឹងធ្វើឱ្យមានការកើនឡើងនូវទ្រព្យសកម្ម ជាកុំព្យូទ័រ និងកើនឡើងនូវបំណុល ដែលក្រុមហ៊ុនជំពាក់គេ។

ជារួម, ការកត់ត្រាទ្វេភាគ តម្រូវឱ្យរាល់ប្រតិបត្តិការត្រូវមានការកត់ត្រាគណនេយ្យចំនួនពីរ, ឥណពន្ធ (Debit) និង ឥណទាន (Credit)។ គោលការណ៍នៃការកត់ត្រាទ្វេភាគ ចែងថា រាល់ប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់ នឹងកើតមានការកត់ត្រាគណនីចំនួន ២ នោះគឺ៖ មួយខាងឥណពន្ធ និងមួយទៀតខាងឥណទាន។

ការកត់ត្រាខាងឥណពន្ធ (Debit) មានន័យថាមួយក្នុងចំណោមខាងក្រោម៖

- ❖ ការកើនឡើងនៃទ្រព្យសកម្ម (Increase in Assets)
- ❖ ការកើនឡើងនៃចំណាយ (Increase in Expenses)
- ❖ ការថយចុះនៃបំណុល (Decrease in Liabilities)
- ❖ ការថយចុះនៃទ្រព្យម្ចាស់ (Decrease in Capital/Equity)

ការកត់ត្រាខាងឥណទាន (Credit) មានន័យថាមួយក្នុងចំណោមខាងក្រោម៖

- ❖ ការកើនឡើងនៃបំណុល (Increase in Liabilities)
- ❖ ការកើនឡើងនៃទ្រព្យម្ចាស់ (Increase in Capital/Equity)
- ❖ ការកើនឡើងនៃចំណូល (Increase in Income)
- ❖ ការថយចុះនៃទ្រព្យសកម្ម (Decrease in Assets)

## ២.៤. គោលការណ៍នៃការកត់ត្រាទ្វេភាគ (Rule of Double-Entry)

គោលការណ៍នៃការកត់ត្រាទ្វេភាគ (Rule of Double Entry)៖ គឺជា ប្រព័ន្ធកត់ត្រាគណនីដែលឆ្លុះបញ្ចាំងពី៖

- ❖ គ្រប់ប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់ នឹងកើតមានការកត់ត្រាគណនីចំនួន ២ នោះគឺ៖ ម្ខាងខាងឥណពន្ធ និងម្ខាងទៀតខាងឥណទាន
- ❖ តម្លៃសរុបនៃការកត់ត្រាខាងឥណពន្ធ (Total Debit) ត្រូវតែស្មើនឹងតម្លៃសរុបនៃការកត់ត្រាខាងឥណទាន (Total Credit) សម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុនីមួយៗ។

ប្រតិបត្តិការទាំងអស់ ត្រូវកត់ត្រានៅក្នុងគណនី ដែលត្រូវបានគេស្គាល់ថាជាគណនីអក្សរ T (T-Account) ពីព្រោះគណនីមានរាងជាអក្សរ T ដូចខាងក្រោម៖

## ឈ្មោះគណនី

| *កត់ត្រាខាងឥណពន្ធ(Debit Side)* | *កត់ត្រាខាងឥណទាន(Credit Side)* |
|---|---|
| ថ្ងៃខែឆ្នាំ ការពណ៌នាអំពីការកត់ត្រា ទឹកប្រាក់($) | ថ្ងៃខែឆ្នាំ ការពណ៌នាអំពីការកត់ត្រា ទឹកប្រាក់($) |

ដូចនេះ យើងត្រូវចងចាំនូវច្បាប់នៃការកត់ត្រាសម្រាប់ប្រភេទគណនី ជា Assets, Liabilities, Capital/Equity, Income និង Expenses ដូចខាងក្រោម៖

| *Debit* | *Credit* |
|---|---|
| Assets កើនឡើង | Assets ថយចុះ |
| Capital និង Liabilities ថយចុះ | Capital និង Liabilities កើនឡើង |
| Income ថយចុះ | Income កើនឡើង |
| Expenses កើនឡើង | Expenses ថយចុះ |
| ***ខាងឆ្វេងដៃ*** | ***ខាងស្តាំដៃ*** |

ឧទាហរណ៍៖ អាជីវកម្មមួយកើតមាននូវប្រតិបត្តិការខាងក្រោម។

a) ក្រុមហ៊ុនបានទិញកុំព្យូទ័រជាសាច់ប្រាក់ចំនួន $200
b) ក្រុមហ៊ុនបានបង់ចំណាយជួលទីតាំង សរុប $150
c) ក្រុមហ៊ុនបានទិញកុំព្យូទ័រដោយជំពាក់ពីហាង C ក្នុងតម្លៃ $500
d) ក្រុមហ៊ុនទទួលបានវិក្កយបត្រភ្លើងតម្លៃ $400 និងមិនទាន់បានទូទាត់។

**<u>ចម្លើយ៖</u>**

a) ក្រុមហ៊ុនបានដកសាច់ប្រាក់ទៅទិញកុំព្យូទ័រ $200 នោះគណនីសាច់ប្រាក់ថយចុះ។ ដូច្នេះ យើងត្រូវកត់ត្រាខាង Credit ក្នុងគណនីសាច់ប្រាក់ $200។ ចំណែកឯ, កុំព្យូទ័រ (ជា Assets) បានកើនឡើង $200 នោះយើងកត់ត្រាខាង Debit ក្នុងគណនីកុំព្យូទ័រ $200។
b) ក្រុមហ៊ុនបានដកសាច់ប្រាក់ $150 ទៅបង់ថ្លៃជួល នោះយើងកត់ត្រាខាង Credit ក្នុងគណនីសាច់ប្រាក់ $150 ដោយសារសាច់ប្រាក់(Assets) ថយចុះ។ ម្យ៉ាងវិញទៀត ចំណាយការជួលកើនឡើង $150 នោះយើងកត់ត្រាខាង Debit ក្នុងគណនីចំណាយការជួល $150។
c) ការទិញកុំព្យូទ័រដោយជំពាក់ ធ្វើឱ្យគណនីកុំព្យូទ័រកើនឡើង នោះយើងត្រូវកត់ត្រាខាង Debit ក្នុងគណនីកុំព្យូទ័រ $500 ហើយធ្វើឱ្យគណនីត្រូវសង (Liabilties) កើនឡើង នោះយើងត្រូវកត់ត្រា Credit ក្នុងគណនីត្រូវសង $500 ។

d) នៅពេលដែលក្រុមហ៊ុនទទួលបានវិក្កយបត្រភ្លើង ក្រុមហ៊ុនបានកើតមាននូវចំណាយប្រើប្រាស់អគ្គីសនី នោះយើងកត់ត្រាខាង Debit ចំនួន $400 ក្នុងគណនីចំណាយទឹកភ្លើង ដោយសារចំណាយត្រូវកើនឡើង។ ប៉ុន្តែក្រុមហ៊ុនមិនទាន់បានទូទាត់ នោះធ្វើឱ្យគណនីត្រូវសង (Liabilities) កើនឡើង ដូច្នេះ យើងត្រូវកត់ត្រាខាង Credit ចំនួន $400 នៅក្នុងគណនីចំណាយទឹកភ្លើង (Utilities expense)។

គណនីសាច់ប្រាក់ (Cash Account)

| | $ | | $ |
|---|---|---|---|
| | | a) ទិញកុំព្យូទ័រ | 200 |
| | | b) បង់ថ្លៃជួលទីតាំង | 150 |

គណនីកុំព្យូទ័រ (Computer Account)

| | $ | | $ |
|---|---|---|---|
| a) ទិញកុំព្យូទ័រជាសាច់ប្រាក់ | 200 | | |
| c) ទិញកុំព្យូទ័រដោយជំពាក់ | 500 | | |

គណនីត្រូវសង (Payables Account)

| | $ | | $ |
|---|---|---|---|
| | | c) ទិញកុំព្យូទ័រដោយជំពាក់ | 500 |
| | | d) វិក្កយបត្រភ្លើងមិនទាន់បង់ | 400 |

គណនីចំណាយការជួល (Rent Expense Account)

| | $ | | $ |
|---|---|---|---|
| b) បង់ថ្លៃជួលទីតាំងជាសាច់ប្រាក់ | 150 | | |

គណនីចំណាយទឹកភ្លើង (Utilities Expense Account)

| | $ | | $ |
|---|---|---|---|
| d) វិក្កយបត្រភ្លើងមិនទាន់បង់ | 400 | | |

## ២.៥. គណនេយ្យសម្រាប់ការទិញ-លក់ទំនិញ

### ២.៥.១. ប្រតិបត្តិការទិញ-លក់ទំនិញជាសាច់ប្រាក់ (Cash Transactions)

គោលការណ៍ដែលត្រូវចងចាំសម្រាប់ប្រតិបត្តិការទិញ-លក់ទំនិញជាសាច់ប្រាក់ គឺ៖

| Cash Transactions | Dr | Cr |
|---|---|---|
| លក់ទំនិញជាសាច់ប្រាក់ | Cash | Sales |
| ទិញទំនិញជាសាច់ប្រាក់ | Purchases | Cash |

ឧទាហរណ៍៖ ក្រុមហ៊ុនអាជីវកម្មមួយកើតមាននូវប្រតិបត្តិការខាងក្រោម។

a) ការលក់ជាសាច់ប្រាក់ (Receipt) ចំនួន $200

b) ការបង់ចំណាយជួលទីតាំង សរុប $150

c) ការទិញទំនិញជាសាច់ប្រាក់ ចំនួន $100

**ចម្លើយ៖**

គណនីសាច់ប្រាក់ (Cash Account)

| | | $ | | | $ |
|---|---|---|---|---|---|
| a) | Sale | 200 | b) | Rent expense | 150 |
| | | | c) | Purchases | 100 |

គណនីការលក់ទំនិញ (Sales Account)

| | | $ | | | $ |
|---|---|---|---|---|---|
| | | | a) | Cash | 200 |

គណនីចំណាយការជួល (Rent Expense Account)

| | | $ | | | $ |
|---|---|---|---|---|---|
| b) | Cash | 150 | | | |

គណនីការទិញទំនិញ (Purchases Account)

| | | $ | | | $ |
|---|---|---|---|---|---|
| c) | Cash | 100 | | | |

### ២.៥.២. ប្រតិបត្តិការទិញ-លក់ទំនិញដោយជំពាក់ (Credit Transactions)

ការទិញដោយជំពាក់នឹងកើតមាននូវគណនីត្រូវសង (Account Payables) ដែលជាប្រភេទគណនីបំណុល (Liabilities)។ ចំណែកឯការលក់ដោយជំពាក់ នឹងកើតមាននូវ គណនីត្រូវទារ

(Account Receivables) ដែលជាប្រភេទគណនីទ្រព្យសកម្ម (Assets)។ ខាងក្រោមជាតារាងសង្ខេបនៃការកត់ត្រាប្រតិបត្តិការទិញ-លក់ទំនិញដោយជំពាក់៖

| Credit Transactions | Dr | Cr |
|---|---|---|
| លក់ទំនិញដោយជំពាក់ | Receivables | Sales |
| អតិថិជនសងប្រាក់ដែលជំពាក់ | Cash | Receivables |
| ទិញទំនិញដោយជំពាក់ | Purchases | Payables |
| សងថ្លៃទំនិញដែលបានទិញជំពាក់ | Payables | Cash |

ឧទាហរណ៍៖ ប្រតិបត្តិការខាងក្រោមបានកើតឡើង៖

a) ក្រុមហ៊ុន លក់ទំនិញដោយជំពាក់ទៅឱ្យអតិថិជន A ក្នុងតម្លៃ $2,000
b) ក្រុមហ៊ុន ទិញទំនិញដោយជំពាក់ពីក្រុមហ៊ុន B ក្នុងតម្លៃ $100
c) អតិថិជន A សងប្រាក់ដែលបានជំពាក់ទាំងអស់
d) ក្រុមហ៊ុនបានសងប្រាក់ទៅឱ្យក្រុមហ៊ុន B ទាំងអស់

ខាងក្រោមជាការកត់ត្រាទ្វេភាគ៖

គណនីត្រូវទារ (Receivables Account)

| | | $ | | | $ |
|---|---|---|---|---|---|
| a) | Sale | 2,000 | c) | Cash | 2,000 |

គណនីការលក់ (Sales Account)

| | | $ | | | $ |
|---|---|---|---|---|---|
| | | | a) | Receivables | 2,000 |

គណនីត្រូវសង (Payables Account)

| | | $ | | | $ |
|---|---|---|---|---|---|
| d) | Cash | 100 | b) | Purchase | 100 |

គណនីការទិញ (Purchases Account)

| | | $ | | | $ |
|---|---|---|---|---|---|
| b) | Payables | 100 | | | |

គណនីសាច់ប្រាក់ (Cash Account)

| | | $ | | | $ |
|---|---|---|---|---|---|
| c) | Receivables | 2,000 | d) | Payables | 100 |

### ២.៥.៣. ប្រតិបត្តិការទំនិញបង្វិលវិញ

រាល់ការទិញ-លក់ទំនិញ អាចនឹងកើតមានការបង្វិលទំនិញទៅកាន់អ្នកលក់វិញ ដោយសារមានបញ្ហាណាមួយ ដូចជាទំនិញបាក់បែក ទំនិញខូចគុណភាព ឬទំនិញមិនបំពេញតាមសំណើរបស់អ្នកទិញ ជាដើម។ សម្រាប់ក្រុមហ៊ុនអាជីវកម្ម ការបង្វិលទំនិញ ត្រូវបានបែងចែកជាពីរ៖

- ❖ ការបង្វិលទំនិញពីអតិថិជនមកក្រុមហ៊ុនវិញ (**Returns Inwards**) សំដៅដល់ប្រតិបត្តិការដែលអតិថិជនបង្វិលទំនិញដែលបានទិញ មកក្រុមហ៊ុនវិញដោយសារហេតុផលណាមួយ។ Returns inwards ក៏ត្រូវបានហៅថា **Sales returns** ផងដែរ។ សម្រាប់ការកត់ត្រា យើងត្រូវ Debit គណនីបង្វិលទំនិញមកវិញ (Returns inwards account) និងត្រូវ Credit គណនីត្រូវទទួល (Receivables Account)។
- ❖ ការបង្វិលទំនិញពីក្រុមហ៊ុនទៅអ្នកផ្គត់ផ្គង់វិញ (**Returns Outwards**) សំដៅដល់ប្រតិបត្តិការដែលក្រុមហ៊ុនបង្វិលទំនិញដែលបានទិញ ទៅក្រុមហ៊ុនផ្គត់ផ្គត់វិញ ដោយសារហេតុផលណាមួយ។ Return outwards ក៏ត្រូវបានហៅថា **Purchases Returns** ផងដែរ។ សម្រាប់ការកត់ត្រា យើងត្រូវ Debit គណនីត្រូវសង (Payables Account) និងត្រូវ Credit គណនីបង្វិលទំនិញទៅវិញ (Returns outwards account)។

| Returns Transactions | Dr | Cr |
|---|---|---|
| Returns Inwards/ Sales returns | Returns inwards a/c | Receivables a/c |
| Returns Outwards/Purchases returns | Payables a/c | Returns outwards a/c |

ឧទាហរណ៍៖ ប្រតិបត្តិការខាងក្រោមបានកើតឡើង៖

a) ក្រុមហ៊ុនលក់ទំនិញដោយជំពាក់ទៅឱ្យអតិថិជន A ក្នុងតម្លៃ $2,000
b) ក្រុមហ៊ុនទិញទំនិញដោយជំពាក់ពីក្រុមហ៊ុន B ក្នុងតម្លៃ $100
c) អតិថិជន A បានបង្វិលទំនិញដែលបានទិញមកក្រុមហ៊ុនវិញ ចំនួន $300
d) ក្រុមហ៊ុនបានបង្វិលទំនិញដែលបានទិញទៅឱ្យក្រុមហ៊ុន B ចំនួន $50

ខាងក្រោមជាការកត់ត្រាទ្វេភាគ៖

គណនីត្រូវទារ (Receivables Account)

| | | $ | | | $ |
|---|---|---|---|---|---|
| a) | Sale | 2,000 | c) | Returns inwards | 300 |

គណនីការលក់ (Sales Account)

| | | $ | | | $ |
|---|---|---|---|---|---|
| | | | a) | Receivables | 2,000 |

គណនីត្រូវសង ( Payables Account )

| | $ | | $ |
|---|---|---|---|
| d ) Returns outwards | 50 | b ) Purchase | 100 |

គណនីការទិញ ( Purchases Account )

| | $ | | $ |
|---|---|---|---|
| b ) Payables | 100 | | |

គណនីបង្វិលទំនិញមកវិញ ( Returns Inwards Account )

| | $ | | $ |
|---|---|---|---|
| c ) Receivables | 300 | | |

គណនីបង្វិលទំនិញទៅវិញ ( Returns Outwards Account )

| | $ | | $ |
|---|---|---|---|
| | | d ) Payables | 50 |

**អនុវត្តៈ** ចូរកំណត់ការកត់ត្រា Debit និង Credit សម្រាប់ប្រតិបត្តិការ ដូចខាងក្រោមៈ

a ) ដាក់ទុនវិនិយោគដោយម្ចាស់ក្រុមហ៊ុននៅគណនីធនាគារជាមូលប្បទានបត្រ $10,000

b ) ទិញម៉ាស៊ីនភ្លើងសម្រាប់ប្រើប្រាស់ក្នុងក្រុមហ៊ុន ដោយជំពាក់ ក្នុងតម្លៃ $8,000

c ) ទិញទំនិញដោយជំពាក់ពីក្រុមហ៊ុន B ក្នុងតម្លៃ $500

d ) លក់ទំនិញដោយជំពាក់ទៅឱ្យអតិថិជន C ក្នុងតម្លៃ $1,200

e ) សងប្រាក់ទៅឱ្យក្រុមហ៊ុន B ចំនួន $300

f ) ទទួលបានទំនិញដែលអតិថិជន C បង្វិលមកវិញ ក្នុងតម្លៃ $50

g ) ទទួលបានប្រាក់សងពីអតិថិជន C ចំនួន $1,000

h ) ទូទាត់ប្រាក់បៀវត្សជូនបុគ្គលិក $4,000

i ) ទទួលបានវិក្កយបត្រថ្លៃជួលអគារ $700 ពីម្ចាស់អគារ G

j ) បង់ថ្លៃជួលអគារ $700 ទៅឱ្យម្ចាស់អគារ G

k ) បង្វិលទំនិញទៅក្រុមហ៊ុន B វិញ ក្នុងតម្លៃ $100

l ) បង់ថ្លៃធានារ៉ាប់រង $90 ជូនក្រុមហ៊ុនព្រូដិនសល

m ) ដកប្រាក់ចំនួន $400 ពីម្ចាស់ក្រុមហ៊ុន ដើម្បីចំណាយផ្ទាល់ខ្លួន

គណនីសាច់ប្រាក់នៅធនាគារ ( Bank )

| $ | $ |
|---|---|

គណនីត្រូវទទួល ( Receivables )

| $ | $ |
|---|---|

គណនីគ្រឿងម៉ាស៊ីន ( Machinery )

| $ | $ |
|---|---|

គណនីត្រូវសង ( Payables )

| $ | $ |
|---|---|

គណនីដើមទុន (Capital)

| $ | $ |
|---|---|
| | |

គណនីម្ចាស់ដកប្រាក់ (Drawings)

| $ | $ |
|---|---|
| | |

គណនីការលក់ទំនិញ (Sales)

| $ | $ |
|---|---|
| | |

គណនីបង្វិលទំនិញមកវិញ (Returns Inwards)

| $ | $ |
|---|---|
| | |

គណនីការទិញទំនិញ (Purchases)

| $ | $ |
|---|---|
| | |

គណនីបង្វិលទំនិញទៅវិញ (Returns Outwards)

| $ | $ |
|---|---|
| | |

គណនីចំណាយប្រាក់បៀវត្ស (Salaries expense)

| $ | $ |
|---|---|
| | |

គណនីចំណាយការជួលអគារ (Rent Expense)

| $ | $ |
|---|---|
| | |

គណនីចំណាយធានារ៉ាប់រង (Insurance expense)

| $ | $ |
|---|---|
| | |

## ២.៦. សមតុល្យគណនីអក្សរ T

នៅពេលដែលគ្រប់ប្រតិបត្តិការអាជីវកម្មទាំងអស់ ត្រូវកត់ត្រានៅក្នុងគណនីអក្សរ T រួចរាល់ហើយ សមតុល្យសម្រាប់គ្រប់គណនីទាំងអស់ នឹងត្រូវកំណត់បាន។ ដូចនេះ តើការកំណត់សមតុល្យគណនីនីមួយៗ ត្រូវធ្វើឡើងយ៉ាងដូចម្តេច? នៅចុងការិយបច្ឆេទគណនេយ្យ នឹងមានសមតុល្យមួយកើតមានឡើងសម្រាប់គណនី ពោលគឺការសរុបការកត់ត្រា Debit និងការកត់ត្រា Credit ដែលនឹងកំណត់ដូចខាងក្រោម៖

- ប្រសិនបើគណនីមួយមានតម្លៃសរុបខាង Debit ច្រើនជាងតម្លៃសរុបខាង Credit នោះគណនីនឹងមានសមតុល្យខាង Debit ។
- ប្រសិនបើគណនីមួយមានតម្លៃសរុបខាង Credit ច្រើនជាងតម្លៃសរុបខាង Debit នោះគណនីនឹងមានសមតុល្យខាង Credit ។

ខាងក្រោមជាដំណើរការនៃការរៀបចំសមតុល្យគណនីនីមួយៗ៖

1. គណនាតម្លៃសរុបទាំងសងខាងនៃគណនីសៀវភៅធំ (Total Debit និង Total Credit)
2. យកតម្លៃសរុបខាងណាដែលធំជាង ដកនឹងតម្លៃសរុបខាងដែលតូចជាង
3. ចម្លើយនៃជំហានទី២ នឹងត្រូវបញ្ចូលទៅជាសមតុល្យយោងចុងគ្រា (Balance c/d) កត់ត្រានៅខាងណាដែលមានតម្លៃតូចជាង
4. ពិនិត្យថាសមតុល្យទាំងពីរខាង ឥឡូវស្មើគ្នា
5. បញ្ចូលសមតុល្យទឹកប្រាក់ Balance c/d ទៅជាសមតុល្យថ្មី ជាសមតុល្យយោងចុងគ្រា (Balance b/d) នៅម្ខាងទៀតនៃគណនីនោះ។ ដូចនេះ សមតុល្យថ្មី Balance b/d គឺជាសមតុល្យគណនីនោះ

**ឧទាហរណ៍៖** ក្រោយពីការកត់ត្រាប្រតិបត្តិការអាជីវកម្មទាំងអស់រួចមក គេទទួលបានគណនីខាងក្រោម៖

គណនីសាច់ប្រាក់ (Cash Account)

| 2021 | បរិយាយ | $ | 2021 | បរិយាយ | $ |
|---|---|---|---|---|---|
| 01 Apr | ការលក់ជាសាច់ប្រាក់ | 2,000 | 05 Apr | ទិញកុំព្យូទ័រ | 1,000 |
| 06 Apr | អតិថិជនសងប្រាក់ | 3,000 | 07 Apr | បង់ថ្លៃជួលទីតាំង | 150 |
| | | | 30 Apr | Balance c/d | 3,850 |
| | | 5,000 | | | 5,000 |
| 31 May | Balance b/d | 3,850 | | | |

គណនីត្រូវសង (Payables Account)

| 2021 | បរិយាយ | $ | 2021 | បរិយាយ | $ |
|---|---|---|---|---|---|
| 30 Apr | Balance c/d | 1,200 | 04 Apr | ការទិញទំនិញដោយជំពាក់ | 1,200 |
| | | 1,200 | | | 1,200 |
| | | | 01 May | Balance b/d | 1,200 |

**អនុវត្ត៖**ផ្អែកលើការអនុវត្តខាងលើ នៅចំណុច ២.៥. ចូររៀបចំសមតុល្យគណនីនីមួយៗ បន្ទាប់ពីធ្វើការកត់ត្រាប្រតិបត្តិការទាំងអស់រួចហើយ។

## ២.៧. សេចក្តីសន្និដ្ឋាន

នៅក្នុងមេរៀននេះ យើងបានសិក្សាអំពីមូលដ្ឋានគ្រឹះនៃការកត់ត្រាគណនី ដែលហៅថា ការកត់ត្រាទ្វេភាគ (Double Entry) ពោលគឺរាល់ប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់ ត្រូវកត់ត្រានូវតម្លៃទឹកប្រាក់នៅក្នុងគណនីពីរ ដែលគណនីមួយត្រូវកត់ត្រាខាងឥណពន្ធ និងគណនីមួយទៀតត្រូវកត់ត្រាខាងឥណទាន។ យើងត្រូវយល់ឱ្យបានច្បាស់លាស់នូវច្បាប់នៃការកត់ត្រាទ្វេភាគ មុននឹងឈានទៅសិក្សាមេរៀនក្រោយៗទៀត ព្រមទាំងបន្តទៅមុខវិជ្ជាគណនេយ្យ និងហិរញ្ញវត្ថុផ្សេងៗទៀត។

យើងក៏ត្រូវចងចាំថា ការកត់ត្រាខាងឥណពន្ធ គឺនៅពេលដែលគណនីរបស់ទ្រព្យសកម្ម និងចំណាយ មានការកើនឡើង ហើយការកត់ត្រាខាងឥណទាន គឺនៅពេលដែលគណនីរបស់បំណុល មូលធនផ្ទាល់ និងចំណូលមានការកើនឡើង។ ទន្ទឹមនេះ, ក្រោយពីគ្រប់ប្រតិបត្តិការហិរញ្ញវត្ថុរបស់ក្រុមហ៊ុនអាជីវកម្ម ត្រូវបានកត់ត្រាទៅតាមប្រភេទគណនីនីមួយៗរួចរាល់ហើយ យើងក៏ចាំផងដែរអំពីការរៀបចំធ្វើសមតុល្យគណនី ដោយត្រូវរៀបចំឱ្យមានសមតុល្យដើមគ្រា និងសមតុល្យចុងគ្រា។

# លំហាត់

## I. សំណួរពហុជ្រើសរើស (MCQ)

1) តើក្រុមហ៊ុនរំពឹងថានឹងទទួលបានឯកសារមួយណាខាងក្រោមពីអ្នកលក់ទំនិញ ប្រសិនបើក្រុមហ៊ុនបានបញ្ជូនទំនិញមួយចំនួនត្រឡប់ទៅឱ្យអ្នកលក់នោះវិញ?
   a. Invoice
   b. Credit Note
   c. Purchase order
   d. Goods received note

2) នៅក្នុងប្រព័ន្ធកត់ត្រាទ្វេភាគនៃការកត់ត្រាបញ្ជីគណនេយ្យ មួយណាខាងក្រោមត្រឹមត្រូវសម្រាប់ការកត់ត្រាប្រភេទទាំង ៥ ខាងក្រោមមានការកើនឡើង?

| | Debit | Credit |
|---|---|---|
| a. | Assets និង Income | Liabilities, Capital និង Expenses |
| b. | Revenues, Capital និង Liabilities | Assets និង Expenses |
| c. | Assets និង Expenses | Liabilities, Capital និង Income |
| d. | Assets, Expenses និង Capital | Liabilities និង Income |

3) Credit ត្រូវបានគេប្រើក្នុងការកត់ត្រា៖
   a. ការថយចុះនៃគណនីទ្រព្យសកម្ម
   b. ការថយចុះនៃគណនីចំណូល
   c. ការកើនឡើងនៃគណនីចំណាយ
   d. ការថយចុះនៃគណនីបំណុល

4) ក្រុមហ៊ុន បានទិញឡានមួយគ្រឿងក្នុងតម្លៃ $5,000 ជាសាច់ប្រាក់ និងត្រូវបង់ធានារ៉ាប់រងលើឡាននេះ សម្រាប់ឆ្នាំទី១ $50 ជាសាច់ប្រាក់។ តើមួយណាខាងក្រោមជាការកត់ត្រាត្រឹមត្រូវនៃប្រតិបត្តិការនេះ?
   a. Dr. Car $5,050 ; Cr. Cash $5,050
   b. Dr. Cash $5,050 ; Cr. Car $5,050
   c. Dr. Car $5,000 ; Dr. Insurance expense $50 ; Cr. Cash $5,050
   d. Dr. Cash $5,050 ; Cr. Car $5,000 ; Cr. Insurance expense $50

5) អ្នកកាន់បញ្ជីក្រុមហ៊ុន បានធ្វើការកត់ត្រានូវប្រតិបត្តិការដូចខាងក្រោម៖

| | | | |
|---|---|---|---|
| Dr. | Land and Building | $500,000 | |
| Cr. | Payables | | $500,000 |

តើការកត់ត្រាខាងលើនេះ ជាការកត់ត្រា សម្រាប់ប្រតិបត្តិការណាមួយខាងក្រោម៖

a. ក្រុមហ៊ុនបានខ្ចីលុយពីធនាគារ ដើម្បីជួសជុលអគារស្នាក់ការកណ្តាល។
b. ក្រុមហ៊ុនបានបង់ប្រាក់ដែលជំពាក់ លើការងារជួសជុលការិយាល័យ។
c. ក្រុមហ៊ុនបានទិញអគារដោយជំពាក់។
d. ក្រុមហ៊ុនបានទិញអគារជាសាច់ប្រាក់។

## II. ចូរបំពេញតារាងខាងក្រោម៖

1) ក្រុមហ៊ុន XYZ កើតមាននូវប្រតិបត្តិការដូចខាងក្រោម៖

a. ម្ចាស់ក្រុមហ៊ុន ដាក់ទុនវិនិយោគចំនួន $30,000 ជាសាច់ប្រាក់ និងជាដីនិងអគារតម្លៃ $120,000 នៅថ្ងៃទី០១ ធ្នូ ២០១៩។
b. ទិញសំភារបរិក្ខារតំលៃ $26,000 ជាសាច់ប្រាក់។
c. រកចំណូលបានសរុប $4,200 ដោយអតិថិជនបង់ជាសាច់ប្រាក់ចំនួន $2,000 ហើយសល់ប៉ុន្មានអតិថិជនជំពាក់។
d. ទិញរថយន្តមួយគ្រឿងតម្លៃ $40,000 ដោយជំពាក់។
e. បង់ថ្លៃឈ្នួលកម្មករ $700 ជាសាច់ប្រាក់។
f. រកចំណូលបាន $1,600 ពីការផ្តល់ប្រឹក្សា និង $300 ពីការជួលសំភារៈ ប៉ុន្តែអតិថិជនជំពាក់ទាំងអស់។
g. អតិថិជនសងប្រាក់ដែលជំពាក់ $2,900។
h. ម្ចាស់ក្រុមហ៊ុនបានដកប្រាក់$២០០សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន

ចូរបំពេញគណនីខាងក្រោម៖

Cash

| | |
|---|---|
| | |

Receivables

| | |
|---|---|
| | |

Land and Building

Equipment

Car

Payables

Capital

Wages Expense

Fee Earned

| | |
|---|---|
| | |

Rent Received

| | |
|---|---|
| | |

Drawings

| | |
|---|---|
| | |

2) ចូរកត់ត្រាក្នុងគណនីសៀវភៅធំ នូវប្រតិបត្តិការដូចខាងក្រោម៖

a. ដាក់ទុនវិនិយោគជាសាច់ប្រាក់ $5,000
b. ទិញទំនិញដោយជំពាក់ពីក្រុមហ៊ុន Richard $2,000
c. បង្វិលទំនិញទៅក្រុមហ៊ុន Richard $500
d. បង់ចំណាយជួលអគារក្នុងមួយខែ $500
e. បង់ចំណាយទឹកភ្លើងក្នុងមួយខែ $200
f. ទិញរថយន្តជាសាច់ប្រាក់ $1,000
g. លក់ទំនិញដោយជំពាក់ទៅឱ្យក្រុមហ៊ុន Tish $1,750
h. ទទួលបានទំនិញបង្វិលពីអតិថិជនវិញ $250
i. ដកលុយចាយផ្ទាល់ខ្លួនដោយម្ចាស់ក្រុមហ៊ុន $300
j. លក់ទំនិញជាសាច់ប្រាក់ទៅឱ្យក្រុមហ៊ុន Mi $2,100

Cash

| | |
|---|---|
| | |

Trade Payables

Capital

Purchases

Purchases returns

Rent Expense

Electricity Expense

Car

Drawings

| | |
|---|---|
| | |

Receivables

| | |
|---|---|
| | |

Sales

| | |
|---|---|
| | |

Sales returns

| | |
|---|---|
| | |

## III. សំណួរត្រិះរិះ

1) ចូរកត់ត្រាទ្វេភាគនូវប្រតិបត្តិការខាងក្រោម៖
   a) លោកសុខបានវិនិយោគ $3,000 ជាសាច់ប្រាក់ និង $15,000 ជាសំភារបរិក្ខារ
   b) បង់ $600 ជាសាច់ប្រាក់ក្នុងការទិញគ្រឿងតុទូ
   c) បង់ $500 ជាសាច់ប្រាក់សម្រាប់ជួលហាង
   d) ទិញសំភារៈបរិក្ខារតំលៃ $1,200 ដោយជំពាក់(ដោយប្រើបំណុលរយៈពេលវែង)
   e) ទទួលបានចំណូលពីសេវាកាត់សក់ $825 ជាសាច់ប្រាក់ក្នុងរយៈពេលមួយខែ
   f) ទទួលបានចំណូល $100 ពីសេវាកាត់សក់ ប៉ុន្តែអតិថិជនជំពាក់

2) ចូរកត់ត្រាទ្វេភាគសម្រាប់ក្រុមហ៊ុន K នូវប្រតិបត្តិការខាងក្រោម ក្នុងខែសីហា ឆ្នាំ២០២០៖
   ឆ្នាំ ២០២០
   ០២ សីហា ម្ចាស់ក្រុមហ៊ុន លោកសីហា បានដាក់សាច់ប្រាក់ចំនួន $950 ក្នុងដំណើរការអាជីវកម្ម

០៣ សីហា លោកសីហា បានខ្ចីប្រាក់ពីធនាគារ ABA ចំនួន $1,200

០៧ សីហា លោកសីហា បានទិញរថយន្តដឹកជញ្ជូនមួយគ្រឿង ដោយជំពាក់ ក្នុងតម្លៃ $1,000 ពីក្រុមហ៊ុនតូយ៉ូតា

១២ សីហា លោកសីហា បានទិញម៉ាស៊ីនភ្លើងមួយគ្រឿងជាសាច់ប្រាក់ក្នុងតម្លៃ $340

១៩ សីហា លោកសីហាបានសងប្រាក់ទៅធនាគារ ABA ចំនួន $600 ដោយបញ្ចូលទាំងការប្រាក់ $150 ផងដែរ

២៧ សីហា លោកសីហាបានសងប្រាក់ចំនួន $400 ទៅក្រុមហ៊ុនតូយ៉ូតា។

3) ចូរកត់ត្រាទ្វេភាគសម្រាប់ក្រុមហ៊ុន J នូវប្រតិបត្តិការខាងក្រោម ក្នុងខែកុម្ភៈ ឆ្នាំ២០២១៖

ឆ្នាំ ២០២១

០២ កុម្ភៈ ម្ចាស់ក្រុមហ៊ុន លោកស្រីនីតា បានដាក់សាច់ប្រាក់ចំនួន $400 ក្នុងដំណើរការអាជីវកម្ម

០៣ កុម្ភៈ ការទិញទំនិញបានកើតមានឡើងដោយជំពាក់ ចំនួន $47 ពីក្រុមហ៊ុន P

០៥ កុម្ភៈ ការទិញទំនិញបានកើតមានឡើងដោយជំពាក់ ចំនួន $43 ពីក្រុមហ៊ុន K

០៧ កុម្ភៈ ទំនិញដែលមានតម្លៃ $11 បានបង្វិលទៅក្រុមហ៊ុន P ដោយសារខូចគុណភាព

១២ កុម្ភៈ លោកស្រីនីតា បានលក់ទំនិញជាសាច់ប្រាក់ក្នុងតម្លៃ $102

១៩ កុម្ភៈ លោកស្រីនីតា បានលក់ទំនិញដោយជំពាក់ក្នុងតម្លៃ $95 ជូនក្រុមហ៊ុន L

២០ កុម្ភៈ លោកស្រីនីតា បានសងប្រាក់ទៅក្រុមហ៊ុន P ចំនួន $36

២៤ កុម្ភៈ ក្រុមហ៊ុន L បានបង្វិលទំនិញមកវិញ ចំនួន $28 ដោយសារបាក់បែក។

4) ចូរកត់ត្រាទ្វេភាគសម្រាប់ក្រុមហ៊ុន S នូវប្រតិបត្តិការខាងក្រោម៖

ឆ្នាំ ២០២០

០១ កញ្ញា លោកតុលា បានផ្ទេរសាច់ប្រាក់ចំនួន $4,500 ពីគណនីធនាគារផ្ទាល់ខ្លួន ទៅក្នុងគណនីធនាគាររបស់ក្រុមហ៊ុន

០៣ កញ្ញា លោកតុលាបានទិញទំនិញទុកលក់វិញដោយជំពាក់ ចំនួន $123 ពីក្រុមហ៊ុន P និងចំនួន $89 ពីក្រុមហ៊ុន C

០៤ កញ្ញា ការទិញទំនិញជាសាច់ប្រាក់ មានចំនួន $121

០៩ កញ្ញា លោកតុលា បានទិញម៉ូតូមួយគ្រឿងដើម្បីដឹកឥវ៉ាន់ជូនអតិថិជន តម្លៃ $2,900 ទូទាត់ជាមូលប្បទានបត្រ

១១ កញ្ញា លោកតុលា បានបង្វិលទំនិញខូចគុណភាពទៅក្រុមហ៊ុន P វិញ ចំនួន $87

១៨ កញ្ញា លោកតុលា បានលក់ទំនិញដោយជំពាក់ជូនក្រុមហ៊ុន J តម្លៃ $187

២០ កញ្ញា ក្រុមហ៊ុន J បានបង្វិលទំនិញមកវិញ ចំនួន $31

២១ កញ្ញា លោកតុលា បានទូទាត់សងក្រុមហ៊ុន C ទាំងអស់ ជាមូលប្បទានបត្រ

២៣ កញ្ញា ក្រុមហ៊ុន J បានទូទាត់សងទឹកប្រាក់ដែលជំពាក់ទាំងអស់។

5) ផ្អែកតាមប្រតិបត្តិការខាងក្រោម ចូរកំណត់ថាគណនីណាត្រូវកត់ត្រាខាងឥណពន្ធ និងគណនីណាត្រូវកត់ត្រាខាងឥណទាន៖
   a) ការទូទាត់ថ្លៃធានារ៉ាប់រងជាមូលប្បទានបត្រ
   b) ទំនិញដែលបានទិញពីក្រុមហ៊ុន J ត្រូវបង្វិលត្រឡប់ទៅវិញ ដោយសារខូចគុណភាព
   c) កម្រៃជើងសារទទួលបានជាសាច់ប្រាក់
   d) ចំណាយផ្សព្វផ្សាយពាណិជ្ជកម្ម ទូទាត់ជាមូលប្បទានបត្រ
   e) រថយន្តដែលប្រើប្រាស់ក្នុងក្រុមហ៊ុន ត្រូវបានលក់ជាសាច់ប្រាក់។

6) ចូរកត់ត្រាទ្វេភាគសម្រាប់ក្រុមហ៊ុន H នូវប្រតិបត្តិការខាងក្រោម បន្ទាប់ចូររៀបចំធ្វើសមតុល្យគណនីនីមួយនៅចុងខែ៖

ឆ្នាំ ២០២០

០១ វិច្ឆិកា លោក Hellen បានបើកក្រុមហ៊ុន H ជាមួយនឹងគណនីធនាគាររបស់ក្រុមហ៊ុននៅធនាគារ ACLEDA នូវទឹកប្រាក់ $8,500

០៣ វិច្ឆិកា លោក Hellen បានទិញម៉ាស៊ីនភ្លើងមួយគ្រឿង តម្លៃ $1,500 ទូទាត់ជាមូលប្បទានបត្រ

០៤ វិច្ឆិកា ធានារ៉ាប់រងសម្រាប់ម៉ាស៊ីនភ្លើងនេះ តម្លៃ $95 ក្នុងមួយឆ្នាំ ត្រូវបានទូទាត់ជាមូលប្បទានបត្រ

០៧ វិច្ឆិកា ការទិញទំនិញទុកលក់វិញដោយជំពាក់ បានកើតមានឡើង៖ ទំនិញតម្លៃ $65 ពីក្រុមហ៊ុន M និង ទំនិញតម្លៃ $21 ពីក្រុមហ៊ុន B

១០ វិច្ឆិកា លោក Hellen បានទិញរថយន្តសម្រាប់ដឹកជញ្ជូនទំនិញតម្លៃ $4,300 ដោយជំពាក់

១៤ វិច្ឆិកា លោក Hellen បានលក់ទំនិញដោយជំពាក់ជូនក្រុមហ៊ុន M តម្លៃ $272

១៦ វិច្ឆិកា ក្រុមហ៊ុន M បានបង្វិលទំនិញមកវិញ ចំនួន $34

១៨ វិច្ឆិកា ក្រុមហ៊ុន M បានទូទាត់សងទឹកប្រាក់ដែលជំពាក់ទាំងអស់

២១ វិច្ឆិកា លោក Hellen បានទូទាត់សងក្រុមហ៊ុន B ចំនួន $21 ជាមូលប្បទានបត្រ

២៤ វិច្ឆិកា លោក Hellen បានលក់ទំនិញដោយជំពាក់ជូនក្រុមហ៊ុន T តម្លៃ $180។

7) ចូរកត់ត្រាទ្វេភាគសម្រាប់ក្រុមហ៊ុន D នូវប្រតិបត្តិការខាងក្រោម បន្ទាប់ចូររៀបចំធ្វើសមតុល្យគណនីនីមួយនៅចុងខែ៖

ឆ្នាំ ២០២១

០១ មេសា ម្ចាស់ក្រុមហ៊ុន D បានដាក់សាច់ប្រាក់ផ្ទាល់ខ្លួន ចំនួន $500 នៅគណនីធនាគាររបស់ក្រុមហ៊ុន

០៤ មេសា ក្រុមហ៊ុន D បានទិញទំនិញទុកលក់វិញក្នុងតម្លៃ $67 ដោយជំពាក់ពីក្រុមហ៊ុន J

០៥ មេសា ក្រុមហ៊ុន D បានទិញទំនិញទុកលក់វិញក្នុងតម្លៃ $98 ដោយជំពាក់ពីក្រុមហ៊ុន P

០៨ មេសា ក្រុមហ៊ុន D បានលក់ទំនិញដោយជំពាក់ជូនក្រុមហ៊ុន C តម្លៃ $99
១២ មេសា ក្រុមហ៊ុន D បានបង្វិលទំនិញទៅក្រុមហ៊ុន P វិញ ក្នុងតម្លៃ $22
១៦ មេសា ក្រុមហ៊ុន D ទទួលបានកម្រៃជើងសារជាសាច់ប្រាក់ចំនួន $45
១៨ មេសា ក្រុមហ៊ុន D បានលក់ទំនិញដោយជំពាក់ជូនក្រុមហ៊ុន R តម្លៃ $178
២០ មេសា ក្រុមហ៊ុន R បានបង្វិលទំនិញមកក្រុមហ៊ុន D វិញ ចំនួន $58
២៤ មេសា ម្ចាស់ក្រុមហ៊ុន D បានដកប្រាក់ចំនួន $100 សម្រាប់ចំណាយផ្ទាល់ខ្លួន
២៥ មេសា ក្រុមហ៊ុន C បានទូទាត់សងក្រុមហ៊ុន D ចំនួន $50
២៨ មេសា ក្រុមហ៊ុន D បានប្រាក់បៀវត្សជូនបុគ្គលិកចំនួន $134។

8) ចូរកត់ត្រាទ្វេភាគសម្រាប់ក្រុមហ៊ុន N នូវប្រតិបត្តិការខាងក្រោម បន្ទាប់ចូររៀបចំធ្វើសមតុល្យគណនីនីមួយនៅចុងខែះ

ឆ្នាំ ២០២១

០១ មករា ក្រុមហ៊ុន N បានចាប់ផ្តើមដំណើរការជាមួយនឹងទឹកប្រាក់ចំនួន $3,000 នៅគណនីធនាគាររបស់ក្រុមហ៊ុន នៅធនាគារស្ថាបនា
០៣ មករា ក្រុមហ៊ុន N បានទិញសំភារបរិក្ខារ ក្នុងតម្លៃ $870 ដោយជំពាក់ពីក្រុមហ៊ុន K
០៥ មករា ក្រុមហ៊ុន N បានទិញទំនិញទុកលក់វិញក្នុងតម្លៃ $96 ដោយជំពាក់ពីក្រុមហ៊ុន S
០៩ មករា ក្រុមហ៊ុន N បានទិញទំនិញទុកលក់វិញក្នុងតម្លៃ $45 ដោយជំពាក់ពីក្រុមហ៊ុន P
១៤ មករា ក្រុមហ៊ុន N បានទូទាត់សងក្រុមហ៊ុន P នូវទឹកប្រាក់ដែលបានជំពាក់ទាំងអស់
១៦ មករា ក្រុមហ៊ុន N បានបង់ថ្លៃធានារ៉ាប់រង តម្លៃ $33 ជាមូលប្បទានបត្រ
១៩ មករា ក្រុមហ៊ុន N បានទូទាត់ថ្លៃផ្សព្វផ្សាយពាណិជ្ជកម្ម ចំនួន $45 ជាសាច់ប្រាក់
២០ មករា ក្រុមហ៊ុន N បានលក់ទំនិញដោយជំពាក់ជូនក្រុមហ៊ុន W តម្លៃ $205
២២ មករា ក្រុមហ៊ុន C បានទូទាត់ថ្លៃជួលទីតាំង ចំនួន $70 ជាសាច់ប្រាក់
២៦ មករា ក្រុមហ៊ុន W បានបង្វិលទំនិញទៅក្រុមហ៊ុន N វិញ ក្នុងតម្លៃ $60
២៨ មករា ក្រុមហ៊ុន W បានទូទាត់សងក្រុមហ៊ុន N នូវទឹកប្រាក់ចំនួន $100។

# មេរៀនទី៣៖ របាយការណ៍ហិរញ្ញវត្ថុ

## Chapter 3: Financial Statements

**គោលបំណងនៃមេរៀនទី៣ នេះ ផ្តោតលើ៖**

- ការរៀបចំតារាងតុល្យការ
- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

បន្ទាប់ពីសិក្សាជំពូកទី៣ នេះ យើងអាច៖

- បង្កើតតារាងតុល្យភាពចេញពីសៀវភៅធំ។
- ស្វែងយល់ពីការប្រើប្រាស់ និងកំណត់ របស់តារាងតុល្យភាព។
- ស្វែងយល់ពីអត្ថន័យ និងភាពខុសគ្នាក្នុងការវាស់វែងប្រាក់ចំណេញ។
- បង្កើតរបាយការណ៍លទ្ធផល។
- បង្កើតរបាយការណ៍តុល្យការ។

### ៣.១. សេចក្តីផ្តើម

ការកត់ត្រាប្រព័ន្ធគណនេយ្យទ្វេភាគ មានគោលដៅបង្កើតរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនអាជីវកម្ម ដែលបង្ហាញអំពីចំនួនទឹកប្រាក់សម្រាប់ការិយបរិច្ឆេទកំណត់មួយនៃគណនីនីមួយៗដែលក្រុមហ៊ុនត្រូវរាយការណ៍ជូនអ្នកប្រើប្រាស់។

ដើម្បីបង្ហាញព័ត៌មានហិរញ្ញវត្ថុឱ្យបានពេញលេញ ក្រុមហ៊ុនអាជីវកម្ម ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដូចខាងក្រោម៖[2]

- របាយការណ៍ចំណេញ/ខាត (SOPL)
- របាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ (SOFP)
- របាយការណ៍បម្រែបម្រួលមូលធនផ្ទាល់ (SOCE)
- របាយការណ៍លំហូរសាច់ប្រាក់ (SOCF)
- កំណត់សំគាល់នៃរបាយការណ៍ហិរញ្ញវត្ថុ (Note)។

របាយការណ៍ហិរញ្ញវត្ថុ មានគោលដៅបង្ហាញនូវព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុនអាជីវកម្មក្នុងការិយបរិច្ឆេទណាមួយដែលបានកំណត់។ នៅក្នុងជំពូកនេះ យើងនឹងផ្តោតជាសំខាន់លើការរៀបចំរបាការណ៍ចំណេញ/ខាត និងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ សម្រាប់ក្រុមហ៊ុនឯកកម្មសិទ្ធិ ដោយត្រូវចាប់ផ្តើមពីការរៀបចំតារាងតុល្យភាព។

ខួបជាសង្ខេបនៃការរៀបចំបញ្ជីគណនេយ្យរបស់ក្រុបហ៊ុនអាជីវកម្មមួយ ត្រូវបង្ហាញជាជំហានៗ ដូចបង្ហាញនៅក្នុងរូបភាពខាងក្រោម៖

---

[2] ស្តង់ដាគណនេយ្យអន្តរជាតិ ១ (IAS 1)

ដ្យាក្រាមទី១៖ ខ្ទបជាសង្ខេបនៃវដ្ដគណនេយ្យ




## ៣.២. តារាងតុល្យភាព ( Trial Balance )

បន្ទាប់ពីប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់របស់ក្រុមហ៊ុនអាជីវកម្ម ត្រូវបានកត់ត្រានៅក្នុងគណនីសៀវភៅធំរួចរាល់ហើយ នោះកិច្ចការបន្ទាប់របស់គណនេយ្យករ ត្រូវរៀបចំបូកសរុបគណនីសៀវភៅធំទាំងនោះ ដែលហៅថាការធ្វើសមតុល្យគណនីអក្សរ T ។ សមតុល្យនៃគណនីនីមួយៗនៃសៀវភៅធំនឹងត្រូវបានរៀបចំជាសង្ខេបនៅក្នុងបញ្ជីសមតុល្យគណនីមួយ ដែលហៅថា តារាងតុល្យភាព (Trial Balance)។ នៅក្នុងតារាងតុល្យភាព គណនីទាំងអស់ដែលមាននៅក្នុងបញ្ជីសៀវភៅធំ នឹងត្រូវបង្ហាញតួលេខទឹកប្រាក់ជារួម ទៅតាមសមតុល្យនៅខាងឥណទាន និងឥណពន្ធ។

ជាទូទៅ, ប្រសិនបើការកត់ត្រានៅក្នុងបញ្ជីសៀវភៅធំគោរពទៅតាមប្រព័ន្ធកត់ត្រាទ្វេភាគ នោះតម្លៃសរុបខាងជួរឥណទាន ត្រូវតែស្មើនឹងតម្លៃសរុបខាងជួរឥណពន្ធ។ ប៉ុន្តែ, នៅពេលរៀបចំតារាងតុល្យភាព ក៏នឹងលេចឡើងផងដែរនូវភាពមិនស្មើគ្នានៃតម្លៃសរុបខាងជួរឥណទាន និងតម្លៃសរុបខាងជួរឥណពន្ធ។ បញ្ហាទាំងនេះ កើតចេញពីការកត់ត្រាមិនគោរពតាមច្បាប់នៃការកត់ត្រាប្រព័ន្ធទ្វេភាគ។ ជារួម, កំហុសទាំងនោះ អាចបណ្ដាលមកពី៖

- ការកត់ត្រាប្រតិបត្តិការគណនេយ្យ បានកើតឡើងតែមួយ ពុំមានទ្វេភាគ (មានន័យថាការកត់ត្រាមានតែខាងឥណទាន ឬឥណពន្ធមួយប៉ុណ្ណោះ)
- ការកត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុ ធ្វើឡើងជាទ្វេភាគ ប៉ុន្តែធ្វើការកត់ត្រាតែខាងឥណពន្ធសុទ្ធ ឬឥណទានសុទ្ធប៉ុណ្ណោះ
- ការកត់ត្រាប្រតិបត្តិហិរញ្ញវត្ថុ ធ្វើជាទ្វេភាគ ហើយកត់ម្ខាងឥណពន្ធ និងម្ខាងទៀតឥណទាន ប៉ុន្តែទឹកប្រាក់មិនស្មើគ្នា។

ទោះបីជាយ៉ាងណាក៏ដោយ ក្នុងករណីតារាងតុល្យភាពបង្ហាញនូវភាពស្មើគ្នា ក៏មិនមានន័យថាការកត់ត្រាក្នុងបញ្ជីមានភាពត្រឹមត្រូវនោះដែរ។ ពេលខ្លះ ក៏អាចកើតមាននូវកំហុសមួយចំនួនដូចជា៖

- ភ្លេចមិនបានកត់ត្រាប្រតិបត្តិការទាំងស្រុង
- កត់ត្រាត្រឹមត្រូវតាមច្បាប់នៃប្រព័ន្ធកត់ត្រាទ្វេភាគរួចហើយ ប៉ុន្តែចុះតួលេខទឹកប្រាក់ខុសពីប្រតិបត្តិការដែលបានកើតឡើង
- កត់ត្រាច្រឡំខាងគ្នានៃគណនីដែលបានប្រើប្រាស់ (គណនីដែលត្រូវចុះខាងឥណពន្ធ ចុះខាងឥណទាន ហើយគណនីដែលត្រូវចុះខាងឥណទាន បែរជាចុះខាងឥណពន្ធទៅវិញ)។

មូលហេតុនាំឱ្យតារាងតុល្យភាព មិនមានភាពស្មើគ្នា និងរបៀបនៃការកែតម្រូវភាពមិនស្មើគ្នានេះនឹងត្រូវសិក្សានៅមុខវិជ្ជាគណនេយ្យហិរញ្ញវត្ថុភាគ ២ ។

ខាងក្រោមនេះគឺជាឧទាហរណ៍នៃតារាងតុល្យភាព៖

| I Fraser<br>តារាងតុល្យភាពTrial Balance<br>គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | |
|---|---|---|
| | Dr<br>$ | Cr<br>$ |
| ចំណូលពីការលក់ (Sales) | | 12,000 |
| ការទិញទំនិញ (Purchases) | 8,000 | |
| ចំណាយធានារ៉ាប់រង (Insurance expense) | 1,300 | |
| ចំណាយទឹកភ្លើង (Utility expense) | 900 | |
| ចំណាយទូទៅ (General expense) | 240 | |
| គ្រឿងម៉ាស៊ីន (Machinery) | 4,200 | |
| គណនីត្រូវទារ (Trade receivables) | 1,780 | |
| គណនីត្រូវសង (Trade payables) | | 1,960 |
| គណនីសាច់ប្រាក់នៅធនាគារ (Bank) | 3,940 | |
| ចំណូលពីការជួល (Rent received) | | 220 |
| ចំណាយផ្នែករដ្ឋបាល (Administration expenses) | 260 | |
| ដើមទុន (Capital) | | 6,000 |
| ការដកប្រាក់របស់ម្ចាស់ក្រុមហ៊ុនសម្រាប់ចំណាយផ្ទាល់ខ្លួន(Drawings) | 1,560 | |
| ប្រាក់កម្ចីធនាគារ (Loans) (ត្រូវសងនៅក្នុងឆ្នាំ ២០២៥) | | 2,000 |
| ***សរុប*** | **22,180** | **22,180** |

គណនីដែលបានបង្ហាញនៅក្នុងតារាងតុល្យភាពខាងលើ អាចនឹងមានភាពខុសគ្នាពីក្រុមហ៊ុនមួយទៅក្រុមហ៊ុនមួយទៀត អាស្រ័យលើប្រភេទអាជីវកម្មរបស់ក្រុមហ៊ុនទាំងនោះ។

នៅក្នុងការរៀបចំបង្កើតតារាងតុល្យភាព កំហុសឆ្គង ក៏អាចនឹងកើតឡើងផងដែរ នូវការច្រឡំខាងគ្នានៃសមតុល្យគណនីនីមួយៗ។ ដូចនេះ, យើងត្រូវតែចងចាំនូវប្រភេទគណនីណាដែលមានសមតុល្យ

នៅខាងឥណពន្ធ និងប្រភេទគណនីណាដែលមានសមតុល្យនៅខាងឥណទាន។ តារាងខាងក្រោមនេះ ជាការបង្ហាញប្រភេទសមតុល្យជាធម្មតារបស់គណនីនីមួយៗនៅក្នុងតារាងតុល្យភាព៖

| សមតុល្យមាននៅក្នុងតារាងតុល្យភាព | |
|---|---|
| **សមតុល្យឥណពន្ធ (Debit balance)** | **សមតុល្យឥណទាន (Credit balance)** |
| ទ្រព្យសកម្ម (Assets) | បំណុល (Liabilities) |
| ការដកប្រាក់ (Drawings) | មូលធន (Capital) |
| ការចំណាយ (Expenses) | ចំណូល (Revenues) |

ចំណាំ៖ គណនីមួយចំនួន អាចមានសមតុល្យជាឥណពន្ធផង ឬឥណទានផង។ ឧទាហរណ៍ គណនីសាច់ប្រាក់នៅធនាគារអាចមានសមតុល្យខាងឥណពន្ធ ដែលមានន័យថាគណនីនេះជាទ្រព្យសកម្ម (សាច់ប្រាក់នៅធនាគារ) ប៉ុន្តែប្រសិនបើគណនីនេះ មានសមតុល្យខាងឥណទាន នោះគណនីនេះជាប្រភេទគណនីបំណុល ដែលមានន័យថាក្រុមហ៊ុនបានដកសាច់ប្រាក់ពីធនាគារលើសពីចំនួនសាច់ប្រាក់ដែលក្រុមហ៊ុនមាន (bank overdraft)។

## ៣.៣. របាយការណ៍ចំណេញ/ខាត (Statement of profit or loss-SOPL)

របាយការណ៍ចំណេញ/ខាត (SOPL) គឺជារបាយការណ៍លទ្ធផលដែលបង្ហាញអំពីចំណូល ចំណាយ និងផលចំណេញ/ខាតរបស់អាជីវកម្មមួយសម្រាប់មួយការិយបរិច្ឆេទគណនេយ្យ (ដែលជាធម្មតាមានរយៈពេលមួយឆ្នាំ)។ SOPL ក៏ត្រូវបានគេហៅម្យ៉ាងទៀតថា Income Statement ដែលអាចរៀបចំនៅក្នុងគណនីចំណេញ/ខាត (Profit or Loss Account) ឬពេលខ្លះគេអាចហៅថា SOPL Account។ គណនី P&L ឬគណនី SOPL គឺជាគណនីដែលគេបង្កើតឡើងដើម្បីបិទគណនីចំណូល និងចំណាយ។

នៅពេលការរៀបចំរបាយការណ៍ចំណេញ/ខាត, ជាទម្រង់សាមញ្ញ យើងគ្រាន់តែបង្ហាញចំណូលសរុប ដកនឹងចំណាយសរុប នោះយើង នឹងទទួលបានលទ្ធផលចំណេញ ឬខាតនៅក្នុងរយៈពេលមួយការិយបរិច្ឆេទគណនេយ្យ។

| | $ |
|---|---|
| ចំណូលសរុប | xx |
| ចំណាយសរុប | (xx) |
| ចំណេញ/ខាត | xx |

ប៉ុន្តែនៅក្នុងការរៀបចំរបាយការណ៍ចំណេញ/ខាត គេត្រូវចាំបាច់បែងចែកចំណេញជាពីរប្រភេទ គឺ៖ **ចំណេញដុល (Gross profit)** និង**ចំណេញសុទ្ធ (Net profit)**។ **ចំណេញដុល** សំដៅដល់លទ្ធផលដែលបានមកពីចំណូលពីការលក់ទំនិញ/ផ្គត់ផ្គង់សេវាសរុប (Sales income) ដកនឹងចំណាយថ្លៃដើមទំនិញដែលបានលក់នោះ (Cost of goods sold)។ ចំណេញសុទ្ធ សំដៅដល់លទ្ធផលដែលបានមកពីចំណេញដុល ដកនឹងចំណាយផ្សេងៗទៀត ដើម្បីដំណើរការអាជីវកម្ម អាចរួមមាន ចំណាយលើ

ការលក់ (Selling expense), ចំណាយដឹកជញ្ជូន (distribution cost) ចំណាយរដ្ឋបាល (Administration expense) ជាដើម។

ជាធម្មតា, របាយការណ៍ចំណេញ/ខាត ត្រូវបានរៀបចំសម្រាប់មួយការិយបរិច្ឆេទគណនេយ្យ ដែលជាទូទៅគេកំណត់យករយៈពេលមួយឆ្នាំពេញ ប៉ុន្តែសម្រាប់រយៈពេលមួយឆ្នាំពេញឬយ៉ាងណា ពុំមែនជាបញ្ហានោះទេ។ ក្រុមហ៊ុនអាចជ្រើសរើសរយៈពេលក្នុងការរៀបចំរបាយការណ៍នេះ ទៅតាមតម្រូវរបស់ក្រុមហ៊ុនសាមី។ ខាងក្រោមនេះ ជាទម្រង់នៃរបាយការណ៍ចំណេញ/ខាត៖

**ឈ្មោះក្រុមហ៊ុនអាជីវកម្ម**

**របាយការណ៍ចំណេញ/ខាត**

**សម្រាប់រយៈមួយឆ្នាំ បញ្ចប់ត្រឹមថ្ងៃទី៣១ ធ្នូ ឆ្នាំ២០xx**

| | $ | $ |
|---|---|---|
| ចំណូល (Revenue) | | xx |
| ចំណាយថ្លៃដើមទំនិញដែលបានលក់ (Cost of goods sold) | | (x) |
| ចំណេញដុល (Gross profit) | | xx |
| ចំណូលផ្សេងៗទៀត | | x |
| ចំណាយផ្សេងៗទៀត (Expenses): | | |
| ប្រាក់បៀវត្ស(Salaries) | x | |
| ថ្លៃដឹកជញ្ជូន (distribution costs) | x | |
| ថ្លៃផ្សព្វផ្សាយពាណិជ្ជកម្ម (Marketing costs) | x | |
| ថ្លៃជួលអគារ (Rent expense) | x | (xx) |
| ចំណេញសុទ្ធ (Net profit) | | xx |

នៅក្នុងរបាយការណ៍ចំណេញ/ខាត, ដើម្បីគណនារកចំណាយថ្លៃដើមទំនិញដែលបានលក់ (Cost of goods sold) យើងត្រូវប្រើរូបមន្ត នៅក្នុងខាងក្រោម៖

| | | $ |
|---|---|---|
| | សន្និធិដើមគ្រា (Opening inventory) | x |
| បូក៖ | ការទិញទំនិញ (Purchases) | x |
| ដក៖ | សន្និធិចុងគ្រា (Closing inventory) | (x) |
| | ចំណាយថ្លៃដើមទំនិញដែលបានលក់ (Cost of goods sold) | x |

ឧទាហរណ៍ ១៖ ក្រុមហ៊ុន E បង្ហាញថាមាន សន្និធិដើមគ្រាចំនួន $4,200។ នៅក្នុងគ្រា ក្រុមហ៊ុនបានកើតមាននូវការទិញទំនិញសរុប $14,000 ។ ចូរគណនាចំណាយថ្លៃដើមទំនិញដែលបានលក់ ប្រសិនបើសន្និធិចុងគ្រាមានចំនួន $4,600។

| | | $ |
|---|---|---|
| | សន្និធិដើមគ្រា | 4,200 |
| បូក៖ | ការទិញទំនិញ | 14,000 |
| ដក៖ | សន្និធិចុងគ្រា | (4,600) |
| | ចំណាយថ្លៃដើមទំនិញដែលបានលក់ | 13,600 |

ឧទាហរណ៍ ២៖ ផ្អែកលើតារាងតុល្យភាពរបស់ក្រុមហ៊ុន I Fraser សម្រាប់ការិយបរិច្ឆេទឆ្នាំបញ្ចប់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ខាងក្រោមនេះ ចូររៀបចំរបាយការណ៍ចំណេញ/ខាត។

I Fraser
តារាងតុល្យភាពTrial Balance
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

| | Dr $ | Cr $ |
|---|---|---|
| ចំណូលពីការលក់ (Sales) | | 12,000 |
| ការទិញទំនិញ (Purchases) | 8,000 | |
| ចំណាយធានារ៉ាប់រង (Insurance expense) | 1,300 | |
| ចំណាយទឹកភ្លើង (Utility expense) | 900 | |
| ចំណាយទូទៅ (General expense) | 240 | |
| គ្រឿងម៉ាស៊ីន (Machinery) | 4,200 | |
| គណនីត្រូវទារ (Trade receivables) | 1,780 | |
| គណនីត្រូវសង (Trade payables) | | 1,960 |
| គណនីសាច់ប្រាក់នៅធនាគារ (Bank) | 3,940 | |
| ចំណូលពីការជួល (Rent received) | | 220 |
| ចំណាយផ្នែករដ្ឋបាល (Administration expenses) | 260 | |
| ដើមទុន (Capital) | | 6,000 |
| ការដកប្រាក់របស់ម្ចាស់ក្រុមហ៊ុនសម្រាប់ចំណាយផ្ទាល់ខ្លួន(Drawings) | 1,560 | |
| ប្រាក់កម្ចីធនាគារ (Loans) (ត្រូវសងនៅក្នុងឆ្នាំ ២០២៥) | | 2,000 |
| ***សរុប*** | **22,180** | **22,180** |

គេឱ្យព័ត៌មានបន្ថែមដូចខាងក្រោម៖

- សន្និធិនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ មានចំនួន $600។

ដើម្បីរៀបចំរបាយការណ៍ចំណេញ/ខាត យើងអាចចាប់ផ្តើមជាមួយនឹង ការលក់ទំនិញសរុប បន្ទាប់មកដកជាមួយនឹង ចំណាយថ្លៃដើមទំនិញដែលបានលក់ នោះយើងនឹងទទួលបានចំណេញដុល។ ក្រោយមក, យើងយកតម្លៃចំណេញដុល បូកជាមួយនឹងចំណូលផ្សេងៗទៀត ហើយដកជាមួយនឹងចំណាយផ្សេងៗទៀតដែលបានកើតមាននៅក្នុងដំណើរការនៃក្រុមហ៊ុនអាជីកម្ម នោះយើងនឹងទទួលបានចំណេញសុទ្ធ។

របាយការណ៍លទ្ធផលដែលមានទម្រង់ពេញលេញដូចខាងក្រោម៖

**I Fraser**
**របាយការណ៍ចំណេញ/ខាត**
**សម្រាប់ការិយបរិច្ឆេទឆ្នាំ បញ្ចប់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨**

| | | $ | $ |
|---|---|---|---|
| **ចំណូលពីការលក់** | **Sale** | | **12,000** |
| **ថ្លៃដើមទំនិញដែលបានលក់៖** | **Cost of goods sold:** | | |
| សន្និធិដើមគ្រា | Opening invenoty | 0 | |
| ការទិញទំនិញ | Purchases | 8,000 | |
| សន្និធិចុងគ្រា | Closing inventory | 600 | (7,400) |
| ***ចំណេញដុល*** | ***Gross profit*** | | ***4,600*** |
| ប្រាក់ចំណូលពីការជួល | Rent received | | 220 |
| ចំណាយផ្សេងៗទៀត៖ | Expenses: | | |
| ចំណាយធានារ៉ាប់រង | Insurance expense | 1,300 | |
| ចំណាយទឹកភ្លើង | Utility expense | 900 | |
| ចំណាយទូទៅ | General expense | 240 | |
| ចំណាយផ្នែករដ្ឋបាល | Administration expense | 260 | (2,700) |
| ***ចំណេញសុទ្ធ*** | ***Net Profit*** | | ***2,120*** |

***សំគាល់៖*** ប្រាក់ចំណេញសុទ្ធដែលបង្ហាញនៅក្នុងរបាយការណ៍ចំណេញ/ខាតនេះ មិនមានន័យថាក្រុមហ៊ុនមានសាច់ប្រាក់ចំនួន $2,120 នៅក្នុងគណនីធនាគាររបស់ក្រុមហ៊ុននោះទេ។ ប្រាក់ចំណេញសុទ្ធនេះ អាចត្រូវបានចំណាយទៅលើទ្រព្យសកម្មថ្មី ស្តុកទំនិញ ឬក៏ដកដោយម្ចាស់អាជីវកម្មបាត់ទៅហើយ។

## ៣.៤. របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (Statement of financial position-SOFP)

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ SOFP ជារបាយការណ៍ដែលបង្ហាញអំពី តម្លៃសរុបនៃទ្រព្យសកម្ម (Assets), បំណុល (Liabilities) និងមូលធនផ្ទាល់ (Capital/Equity) នៅចុងការិយបរិច្ឆេទគណនេយ្យ (នៅចុងឆ្នាំ)។ SOFP ក៏ត្រូវបានគេឱ្យឈ្មោះថា តារាងតុល្យការ (Balance Sheet)ផងដែរ។ ផ្នែកសំខាន់ៗ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ រួមមានទ្រព្យសកម្ម (Assets), បំណុល (Liabilities) និងមូលធនផ្ទាល់ (Capital/Equity) ដោយត្រូវជានាឱ្យបានថា ***ទ្រព្យសកម្ម បំណុល = មូលធន +ផ្ទាល់*** ។

### ៣.៤.១. ទ្រព្យសកម្ម (Assets)

នៅក្នុងផ្នែកទ្រព្យសកម្ម, គេតម្រូវឱ្យបែងចែកគណនីទ្រព្យសកម្មទាំងអស់ ជាពីរ៖ ១).**ទ្រព្យសកម្មរយៈពេលវែង (Non-current assets)** និង ២).**ទ្រព្យសកម្មចរន្ត/រយៈពេលខ្លី (Current assets)**។ ទ្រព្យសកម្មរយៈពេលវែង សំដៅដល់ទ្រព្យសម្បត្តិទាំងឡាយណាដែលក្រុមហ៊ុនកាន់កាប់

ដើម្បីប្រើប្រាស់រកស៊ី លើសពីមួយការិយបរិច្ឆេទគណនេយ្យ (លើសពី ១ឆ្នាំ) ដែលជាឧទាហរណ៍ រួមមាន គណនីដីនិងអគារ, គណនីរថយន្ត, គណនីគ្រឿងម៉ាស៊ីន ជាដើម។ ទ្រព្យសកម្មរយៈពេលខ្លី សំដៅដល់ទ្រព្យសម្បត្តិទាំងឡាយណាដែលក្រុមហ៊ុនកាន់កាប់ ដើម្បីប្រើប្រាស់រកស៊ី ក្រោមមួយការិយបរិច្ឆេទគណនេយ្យ (ក្រោម ១ឆ្នាំ)ដែលជាឧទាហរណ៍ រួមមាន គណនីសាច់ប្រាក់, គណនីត្រូវទារ, គណនីសន្និធិ ជាដើម។

### ៣.៤.២. បំណុល ( liabilities )

នៅក្នុងផ្នែកបំណុល, គេតម្រូវឱ្យបែងចែកគណនីបំណុលទាំងអស់ជាពីរដូចគ្នា នោះគឺៈ ១). **បំណុលរយៈពេលវែង** (non-current liabilities) និង ២).**បំណុលរយៈពេលខ្លី**(current liabilities)។ បំណុលរយៈពេលវែង សំដៅដល់កាតព្វកិច្ចទាំងឡាយណាដែលក្រុមហ៊ុនត្រូវសង លើសពីមួយការិយបរិច្ឆេទគណនេយ្យ (លើសពី ១ឆ្នាំ) ដែលជាឧទាហរណ៍ រួមមានគណនីកម្ចីរយៈពេលវែង, គណនីបំណុលរយៈពេលវែង ជាដើម។ បំណុលរយៈពេលខ្លី សំដៅដល់កាតព្វកិច្ចទាំងឡាយណាដែលក្រុមហ៊ុនត្រូវសង នៅក្នុងអំឡុងការិយបរិច្ឆេទគណនេយ្យ (ក្រោម ១ឆ្នាំ) ដែលជាឧទាហរណ៍ រួមមាន គណនីត្រូវសង, គណនីកម្ចីរយៈពេលខ្លី ជាដើម។

### ៣.៤.៣. មូលធនផ្ទាល់ ( Euqity )

មូលធនផ្ទាល់ សំដៅលើធនធាន ដែលផ្តល់ឱ្យអាជីវកម្មដោយម្ចាស់ក្រុមហ៊ុន ហើយ មូលធនផ្ទាល់នេះ គឺជាភាពខុសគ្នានៃទ្រព្យសកម្ម និងបំណុល (Assets – Liabilities) ដែលបង្ហាញពីធនធានដែលម្ចាស់ក្រុមហ៊ុនមាន នៅក្នុងពេលវេលាជាក់លាក់ណាមួយ។ នៅក្នុងផ្នែកមូលធនផ្ទាល់នេះ សម្រាប់ក្រុមហ៊ុនឯកកម្មសិទ្ធិ គឺមានតែគណនីដើមទុន (Capital Account) តែមួយប៉ុណ្ណោះ។ ការកត់ត្រាគណនីដើមទុន ត្រូវបានធ្វើឡើងនៅចុងការិយបរិច្ឆេទ បន្ទាប់ពីគណនីចំណេញនិងខាត ត្រូវបានធ្វើសមតុល្យរួចរាល់។ ខាងក្រោមនេះជាឧទាហរណ៍នៃការរៀបចំគណនីដើមទុន ដើម្បីអាចទទួលបានសមតុល្យនៅចុងការិយបរិច្ឆេទគណនេយ្យៈ

គណនីដើមទុន (Capital Account)

| | | | | | |
|---|---|---|---|---|---|
| 20x0 | | $ | 20x0 | | $ |
| 31 Dec | Drawings | x | 01 Jan | Balance b/d | x |
| 31 Dec | Balance c/d | x | 31 Dec | Net profit | x |
| | | x | | | x |
| | | | 20x1 | | |
| | | | 01 Jan | Balance b/d | x |

ទម្រង់នៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ អាចត្រូវបានរៀបចំជាទម្រង់ជួរឈរ ឬក្នុងទម្រង់ជួរដេក ដូចខាងក្រោមៈ

ឈ្មោះក្រុមហ៊ុន
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០xx

| | $ | $ |
|---|---|---|
| **ទ្រព្យសកម្ម (Assets)** | | |
| ទ្រព្យសកម្មរយៈពេលវែង (Non-current Assets) | | |
| ទ្រព្យ, ដី អគារ និងសំភារៈបរិក្ខា (Property, Plant and Equipment) | x | |
| ទ្រព្យសកម្មអរូបីយ (Intangible Assets) | x | |
| *ទ្រព្យសកម្មរយៈពេលវែងសរុប (Total Non-current Assets)* | | *X* |
| *ទ្រព្យសកម្មរយៈពេលខ្លី (Current Assets)* | | |
| សាច់ប្រាក់បង់មុន(Prepayment) | x | |
| សន្និធិ (Inventories) | x | |
| គណនីត្រូវទារ (Trade Receivables) | x | |
| សាច់ប្រាក់នៅធនាគារ (Bank) | x | |
| *ទ្រព្យសកម្មរយៈពេលខ្លីសរុប (Total Current Assets)* | | *X* |
| **ទ្រព្យសកម្មសរុប (Total Assets)** | | X |
| | | |
| **មូលធនផ្ទាល់ និងបំណុល (Equity and Liabilities)** | | |
| **មូលធនផ្ទាល់ (Equity)** | | |
| គណនីដើមទុន (Capital) | x | |
| **មូលធនផ្ទាល់សរុប (Total Equity)** | | X |
| **បំណុល (Liabilities)** | | |
| *បំណុលរយៈពេលវែង (Non-current Liabilities)* | | |
| កម្ចីធនាគាររយៈពេលវែង (Bank Loans) | x | |
| *បំណុលរយៈពេលវែងសរុប (Total Non-current Liabilities)* | | *x* |
| *បំណុលរយៈពេលខ្លី (Current Liabilities)* | | |
| ប្រាក់បម្រុង (Provision) | x | |
| គណនីត្រូវសងការប្រាក់ (Interest Payables) | x | |
| គណនីត្រូវសង (Trade Payables) | x | |
| *បំណុលរយៈពេលខ្លីសរុប (Total Current Liabilities)* | | *x* |
| **បំណុលសរុប (Total Liabilities)** | | X |
| **មូលធនផ្ទាល់ និងបំណុលសរុប (Total Equity and Liabilities)** | X | |

ឈ្មោះក្រុមហ៊ុន
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០xx

| | $ | | $ |
|---|---|---|---|
| **ទ្រព្យសកម្ម** | | **មូលធនផ្ទាល់ និងបំណុល** | |
| *ទ្រព្យសកម្មរយៈពេលវែង* | | មូលធនផ្ទាល់ | |
| ទ្រព្យ, ដី អគារ និងសំភារៈបរិក្ខា | x | គណនីដើមទុន | x |
| ទ្រព្យសកម្មអរូបីយ | x | មូលធនផ្ទាល់សរុប | X |
| *ទ្រព្យសកម្មរយៈពេលវែងសរុប* | *X* | បំណុល | |
| | | *បំណុលរយៈពេលវែង* | |
| | | កម្ចីធនាគារ | x |
| *ទ្រព្យសកម្មរយៈពេលខ្លី* | | *បំណុលរយៈពេលវែងសរុប* | *x* |
| សាច់ប្រាក់បង់មុន | x | *បំណុលរយៈពេលខ្លី* | |
| សន្និធិ | x | ប្រាក់បម្រុង | x |
| គណនីតត្រូវទារ | x | គណនីត្រូវសងការប្រាក់ | x |
| សាច់ប្រាក់នៅធនាគារ | x | គណនីត្រូវសង | x |
| *ទ្រព្យសកម្មរយៈពេលខ្លីសរុប* | *X* | *បំណុលរយៈពេលខ្លីសរុប* | *x* |
| | | បំណុលសរុប | X |
| **ទ្រព្យសកម្មសរុប** | X | **មូលធនផ្ទាល់ និងបំណុលសរុប** | X |

ម្យ៉ាងវិញទៀត, ក្រុមហ៊ុនអាជីវកម្ម ក៏អាចរៀបចំរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ឬតារាងតុល្យការទៅតាមទម្រង់ផ្សេងមួយទៀតដូចខាងក្រោម៖

ក្នុងន័យនេះ, ក្រុមហ៊ុនអាជីវកម្ម ត្រូវរៀបចំបង្ហាញនូវ ទ្រព្យសកម្មសុទ្ធ (net assets)៖

*Non-currnet Assets*

*+ Current Assets*

*- Current Liabilities*

*- Non-current Liabilities*

*= Net Asstes*

ក្នុងនោះ, Current Assets ដក Current Liabilities ត្រូវបានហៅថា ទុនបង្វិល (Working Capital) ។

# ឈ្មោះក្រុមហ៊ុន
## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២0xx

| | $ | $ |
|---|---|---|
| **ទ្រព្យសកម្ម (Assets)** | | |
| ទ្រព្យសកម្មរយៈពេលវែង (Non-current Assets) | | |
| ទ្រព្យ, ដី អគារ និងសំភារៈបរិក្ខា (Property, Plant and Equipment) | x | |
| ទ្រព្យសកម្មអរូបីយ (Intangible Assets) | x | |
| *ទ្រព្យសកម្មរយៈពេលវែងសរុប (Total Non-current Assets)* | | *X* |
| *ទ្រព្យសកម្មរយៈពេលខ្លី (Current Assets)* | | |
| សាច់ប្រាក់បង់មុន (Prepayment) | x | |
| សន្និធិ (Inventories) | x | |
| គណនីត្រូវទារ (Trade Receivables) | x | |
| សាច់ប្រាក់នៅធនាគារ (Bank) | x | |
| *ទ្រព្យសកម្មរយៈពេលខ្លីសរុប (Total Current Assets)* | *X* | |
| *បំណុលរយៈពេលខ្លី (Current Liabilities)* | | |
| ប្រាក់បម្រុង (Provision) | x | |
| គណនីត្រូវសងការប្រាក់ (Interest Payables) | x | |
| គណនីត្រូវសង (Trade Payables) | x | |
| *បំណុលរយៈពេលខ្លីសរុប (Total Current Liabilities)* | *x* | |
| *ទុនបង្វិល (Working Capital)* | | *x* |
| *ដក បំណុលរយៈពេលវែង (Non-current Liabilities)* | | |
| កម្ចីធនាគាររយៈពេលវែង (Bank Loans) | x | |
| *បំណុលរយៈពេលវែងសរុប (Total Non-current Liabilities)* | | *x* |
| **ទ្រព្យសកម្មសុទ្ធ (Net Assets)** | X | |
| | | |
| **មូលធន (Capital/Equity)** | | |
| គណនីដើមទុនដើមគ្រា (Opening Capital) | | x |
| បូក ចំណេញសុទ្ធ (Net profit) | | x |
| ដក ម្ចាស់ដកប្រាក់ (Drawings) | | x |
| គណនីដើមទុនចុងគ្រា (Closing Capital) | | X |

ឧទាហរណ៍៖ ផ្អែកលើតារាងតុល្យភាពរបស់ក្រុមហ៊ុន I Fraser សម្រាប់ការិយបរិច្ឆេទឆ្នាំបញ្ចប់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ដូចនៅក្នុងឧទាហរណ៍នៃការរៀបចំរបាយការណ៍ចំណេញ/ខាតខាងលើ ចូររៀបរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

មុននឹងរៀបចំរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គេត្រូវរៀបចំគណនីដើមទុនជាមុនសិន ដូចបង្ហាញខាងក្រោម៖

គណនីដើមទុន (Capital Account)

| | | | | | |
|---|---|---|---|---|---|
| 2018 | | $ | 2018 | | $ |
| 31 Dec | Drawings | 1,560 | 01 Jan | Balance b/d | 6,000 |
| 31 Dec | Balance c/d | 6,560 | 31 Dec | Net profit | 2,120 |
| | | 8,120 | | | 8,120 |
| | | | 2019 | | |
| | | | 01 Jan | Balance b/d | 6,560 |

I Fraser

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

| | $ | $ |
|---|---|---|
| **Assets** | | |
| *Non-current assets* | | |
| Machinery | 4,200 | |
| *Total non-current assets* | | *4,200* |
| *Current assets* | | |
| Inventory | 600 | |
| Trade receivable | 1,780 | |
| Bank | 3,940 | |
| *Total current assets* | | *6,320* |
| **Total Assets** | | *10,520* |
| **Equity and Liability** | | |
| Equity | | |
| Capital | *6,560* | |
| Total Equity | | 6,560 |

| | | |
|---|---|---|
| Liabilities | | |
| *Non-current liabilities* | | |
| Bank loan | 2,000 | |
| *Total non-current liabilities* | | *2,000* |
| *Current Liabilities* | | |
| Trade payable | *1,960* | |
| *Total current liabilities* | | *1,960* |
| Total liabilities | | 3,960 |
| **Total equity and liabilities** | | **10,520** |

អនុវត្តន៖ ក្រុមហ៊ុន Mary មានការិយបរិច្ឆេទគណនេយ្យបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងមានតារាងតុល្យភាពដូចខាងក្រោម៖

**Mary Company**

**Trial Balance**

**As at 31 December 2019**

| | Dr. | Cr. |
|---|---|---|
| | $ | $ |
| Cash | 7,982 | |
| Trade Receivables | 1,617 | |
| Inventory | 2,745 | |
| Vehicles | 5,640 | |
| Office Equipment | 740 | |
| Trade Payables | | 3,686 |
| Capital | | 15,000 |
| Sales | | 1,802 |
| Cost of sales | 1,391 | |
| Rent Expense | 80 | |
| Stationary expense | 178 | |
| Wages Expense | 295 | |
| Total | 20,668 | 20,668 |

ចូររៀបចំរបាយការណ៍ហិរញ្ញវត្ថុ៖

a. របាយការណ៍ចំណេញ/ខាត (SOPL)

b. របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (SOFP)

## ៣.៥. ការកែសម្រួលបន្ថែមនៅលើរបាយការណ៍ចំណេញ/ខាត

### ៣.៥.១. សន្និធិ/ស្តុកទំនិញ (Inventory)

នៅពេលដែលអាជីវកម្មបានប្រតិបត្តិការលើសពីមួយឆ្នាំ នោះស្តុកទំនិញដែលនៅសេសសល់នៅគ្រាមុននឹងត្រូវបានបង្ហាញនៅក្នុងគ្រាបន្ទាប់ទៀត។ ដូច្នេះស្តុកទំនិញបានបែកចែកជាស្តុកដើមគ្រា (Opening Inventory) និងស្តុកចុងគ្រា (Ending Inventory)។

ស្តុកដើមគ្រាគឺជាស្តុកដែលអាចយកមកដាក់លក់ ឬប្រើប្រាស់ដោយអាជីវកម្ម ដូច្នេះវានិងបូកបញ្ចូលទៅនិងថ្លៃចំណាយរបស់ទំនិញដែលបានលក់។ ស្តុកដើមគ្រានិងត្រូវកត់ត្រានៅខាងឥណពន្ធនៃតារាងតុល្យភាព។

### ៣.៥.២. ថ្លៃដឹកជញ្ជូនទំនិញ (Carriage)

ថ្លៃដឹកជញ្ជូនទំនិញ គឺជាការចំណាយដែលពាក់ព័ន្ធនឹងសេវាកម្មដឹកជញ្ជូននៃទំនិញ។ ថ្លៃដឹកជញ្ជូនទំនិញ ត្រូវបានបែងចែកជាពីរ៖

| ការបែងចែកនៃការដឹកជញ្ជូន | | |
|---|---|---|
| **ប្រភេទនៃការដឹកជញ្ជូន** | **និយមន័យ** | **ការចាត់ថ្នាក់ប្រភេទចំណាយ** |
| *ដឹកជញ្ជូនចូលក្នុងក្រុមហ៊ុន Carriage inwards* | ចំណាយនៃការដឹកជញ្ជូនទំនិញពីអ្នកផ្គត់ផ្គង់ចូលមកក្រុមហ៊ុន | *ជាចំណាយដែលត្រូវបូកបញ្ចូលទៅក្នុងថ្លៃដើមទំនិញ* |
| *ដឹកជញ្ជូនចេញពីក្រុមហ៊ុន Carriage outwards* | ចំណាយនៃការដឹកជញ្ជូនទំនិញពីក្រុមហ៊ុនទៅអតិថិជន | *ជាចំណាយផ្សេងទៀត ហៅថាចំណាយ Distribution ដែលមិនត្រូវបូកបញ្ចូលទៅក្នុងថ្លៃដើមទំនិញ* |

### ៣.៥.៣. ការបង្វិលទំនិញមកវិញ (Return)

យើងបានសិក្សារួចហើយនូវរបៀបកត់ត្រាការបង្វិលទំនិញមកវិញ នៅក្នុងមេរៀនទី២។ ប៉ុន្តែយើងត្រូវដឹងទៅលើការកែសម្រួលនៃការកត់ត្រានៅក្នុងគណនីថ្លៃដើមទំនិញដែលបានលក់ សម្រាប់ការទទួលទំនិញដែលបានបង្វិលមកវិញ។

ការកែសម្រួល ត្រូវគិតគូរដូចខាងក្រោម៖

| ការកែសម្រួលដែលចាំបាច់ក្នុងករណីដែលមានទំនិញបង្វិលមកវិញ | |
|---|---|
| Return inwards ការបង្វិលទំនិញដែលបានលក់ | ដកចេញពីការលក់ទំនិញ (sales) |
| Return outwards ការបង្វិលទំនិញដែលបានទិញ | ដកចេញពីការទិញទំនិញ (Purchases) |

ថ្លៃដើមទំនិញដែលបានលក់ (Cost of goods sold) ត្រូវបានគណនាដូចខាងក្រោម៖

| ការកែសម្រួលដែលចាំបាច់ក្នុងការចំណាយនៃទំនិញដែលបានលក់ | |
|---|---|
| ស្តុកដើមគ្រា | Opening inventory |
| បូក៖ ការទិញ | Add: Purchase |
| បូក៖ ការដឹកជញ្ជូនចូល | Add: Carriage inwards |
| ដក៖ ការបង្វិលទំនិញដែលបានទិញ | Less: Return outwards |
| ដក៖ ស្តុកចុងគ្រា | Less: Closing inventory |
| **ស្មើ៖ ថ្លៃដើមទំនិញដែលបានលក់** | **= Cost of goods sold** |

**ឧទាហរណ៍៖**

សូមពិនិត្យទៅលើតារាងតុល្យភាពដែលបានដកស្រង់ពីក្រុមហ៊ុន I Fraser សម្រាប់ការិយបរិច្ឆេទឆ្នាំបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ០១៨ ខាងក្រោម៖

| I Fraser<br>តារាងតុល្យភាពសាកល្បង(ដកស្រង់)<br>គិតត្រឹមនៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៨ | | |
|---|---|---|
| | Dr<br>$ | Cr<br>$ |
| សន្និធិនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩ | 5,750 | |
| ចំណូលពីការលក់ទំនិញ | | 28,000 |
| ការទិញទំនិញ | 15,000 | |
| ការបង្វិលទំនិញដែលបានលក់ (Retrun inwards) | 500 | |
| ការបង្វិលទំនិញដែលបានទិញ (Return outwards) | | 320 |
| ថ្លៃដឹកជញ្ជូនចូល (Carriage inwards) | 240 | |
| ថ្លៃដឹកជញ្ជូនចេញ (Carriage outwards) | *410* | |

សន្និធិនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ មានចំនួន $4,300

ដោយមានការកែសម្រួលបន្ថែមដូចខាងលើនេះ របាយការណ៍ចំណេញ/ខាត នឹងមានទម្រង់ដូចខាងក្រោម៖

*I Fraser*

*របាយការណ៍ចំណេញ/ខាត*

*សម្រាប់ឆ្នាំបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨*

| | | $ | $ |
|---|---|---|---|
| ចំណូលពីការលក់ | Sales | 28,000 | |
| | | | |
| ការបង្វិលទំនិញដែលបានលក់ | Return inwards | ( 550 ) | |
| ការលក់ទំនិញសុទ្ធ | Net sales | | 27,450 |
| ថ្លៃដើមទំនិញដែលបានលក់៖ | Cost of goods sold: | | |
| សន្និធិដើមគ្រា | Opening inventory | 5,700 | |
| ការទិញទំនិញ | Purchases | 15,000 | |
| ថ្លៃដឹកជញ្ជូនចូល | Carriage inward | 240 | |
| ការបង្វិលទំនិញដែលបានទិញ | Returns outwards | ( 320 ) | |
| សន្និធិចុងគ្រា | Closing inventory | ( 4,300 ) | ( 16,370 ) |
| ***ចំណេញដុល*** | ***Gross Profit*** | | ***11,080*** |

*សំគាល់៖* ថ្លៃដឹកជញ្ជូនទំនិញជូនអតិថិជន (Carriage outwards) នឹងត្រូវដាក់បញ្ចូលជាចំណាយមួយ ស្ថិតក្រោមចំណាយផ្សេងៗទៀតនៃរបាយការណ៍ចំណេញ/ខាត។

## ៣.៦. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាមេរៀនទី៣ មក យើងនឹងយល់ដឹងទៅលើ៖

- ការបង្កើត និងប្រើប្រាស់នៃតារាងតុល្យភាព។ យល់ដឹងអំពីចំណុចខ្វះខាតនៃព័ត៌មានដែលផ្តល់ដោយតារាងតុល្យភាព។
- ការបង្កើតនិងការគណនានៃរបាយការណ៍ចំណូលចំណាយ ជាពិសេសការស្វែងរកប្រាក់-ចំណេញរបស់ អាជីវកម្ម។
- ការបង្កើតរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ឬតារាងតុល្យការ។

# លំហាត់

## I. សំណួរពហុជ្រើសរើស (MCQ)

1) តារាងតុល្យភាព (Trial Balance) ត្រូវបានរៀបចំជាបញ្ជីបង្ហាញអំពីសមតុល្យ Debit និង សមតុល្យ Credit ។ តើខាងក្រោមនេះមួយណាត្រឹមត្រូវ?
   a. គ្រប់សមតុល្យខាង Debit គឺជាកើតមានសម្រាប់គណនីចំណាយ
   b. គណនីទ្រព្យសកម្ម (Assets) មានសមតុល្យខាង Debit
   c. គណនីបំណុល (Liabilities) មានសមតុល្យខាង Credit
   d. គណនីចំណូល (Income) មានសមតុល្យខាង Debit

2) លោក Z បានដកព័ត៌មានសមតុល្យគណនីពីបញ្ជីសៀវភៅធំ នៅថ្ងៃទី៣១ តុលា ២០១៥ ដូចខាងក្រោម៖

| | $ |
|---|---|
| Sales | 258,542 |
| Opening Inventory | 9,649 |
| Purchases | 142,958 |
| Expenses | 34,835 |
| Non-current assets (carrying amount) | 63,960 |
| Receivables | 31,746 |
| Payables | 13,864 |
| Cash at bank | 1,783 |
| Capital | 12,525 |

តើសមតុល្យ Debit សរុបស្មើប៉ុន្មាន នៅក្នុងតារាងតុល្យភាពនេះ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ ២០១៥?
   a. $267,049
   b. $275,282
   c. $283,148
   d. $284,931

3) តើខាងក្រោមនេះ មួយណាត្រឹមត្រូវអំពីគោលបំណងនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ(SOFP)?
   a. ដើម្បីបង្ហាញពី Assets, Liabilities, និង Capital របស់អាជីវកម្ម នៅពេលកំណត់ជាក់លាក់មួយ។
   b. ដើម្បីបង្ហាញពីការវាយតម្លៃអាជីវកម្ម នៅពេលកំណត់ជាក់លាក់មួយ។
   c. ដើម្បីបង្ហាញពីព័ត៌មានអំពីសកម្មភាពអាជីវកម្ម ក្នុងរយៈពេលណាមួយ។
   d. ដើម្បីរាយការណ៍ពីកំណើនតម្លៃ Capital ចាប់ពីពេលបង្កើតអាជីវកម្មមក។

4) ខាងក្រោមនេះ តើមួយណាត្រឹមត្រូវ ទាក់ទងនឹងរបាយការណ៍ចំណេញ/ខាត?
   a. របាយការណ៍នេះ បង្ហាញលម្អិតពីរបៀបដែលចំណេញ ឬខាតកើតមានឡើងក្នុងរយៈពេលមួយ
   b. របាយការណ៍នេះ បង្ហាញពីតម្លៃចំណូលលក់ ដកនឹងចំណាយសរុប ស្មើនឹងចំណេញដុល (Gross Profit)
   c. របាយការណ៍នេះ បង្ហាញពីសមិទ្ធកម្មហិរញ្ញវត្ថុ (Financial Performance) ក្នុងរយៈពេលមួយ
   d. របាយការណ៍នេះ គឺជារបាយការណ៍មួយក្នុងចំណោមរបាយការណ៍គណនេយ្យសំខាន់ៗ របស់អាជីវកម្ម

5) នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦, Trial Balance របស់ក្រុមហ៊ុន Roger រួមមានសមតុល្យគណនីដូចខាងក្រោម៖

| | $ |
|---|---|
| Machinery at cost | 12,890 |
| Accumulated depreciation | 8,950 |
| Inventory | 5,754 |
| Trade receivables | 11,745 |
| Trade payables | 7,830 |
| Bank overdraft | 1,675 |

តើតម្លៃ Current Assets របស់ក្រុមហ៊ុន Roger នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ ស្មើប៉ុន្មាន?
   a. $17,649
   b. $17,499
   c. $15,974
   d. $13,734

## II. ចូរបំពេញចន្លោះខាងក្រោម៖

1) ចូរបំពេញតួលេខនៅក្នុងរបាយការណ៍ចំណេញ/ខាត សម្រាប់ក្រុមហ៊ុន C Palmer សម្រាប់ឆ្នាំបញ្ចប់ត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ ដោយប្រើប្រាស់ទិន្នន័យខាងក្រោម៖

| | $ |
|---|---|
| ចំណូលការលក់ទំនិញ | 81,400 |
| ការទិញទំនិញ | 74,750 |
| សន្និធិ/ស្តុកចុងគ្រា | 5,890 |
| ចំណាយដំណើរការអាជីវកម្ម | 1,800 |
| ចំណាយអគ្គីសនី | 975 |
| ចំណាយប្រាក់បៀវត្ស | 3,800 |
| ចំណាយជួលអគារ | 4,200 |

## ក្រុមហ៊ុន C Palmer
## របាយការណ៍ចំណេញ/ខាត
## សម្រាប់រយៈមួយឆ្នាំ បញ្ចប់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | $ | $ |
|---|---|---|
| ចំណូល ( Revenue ) | | ………… |
| ចំណាយថ្លៃដើមទំនិញដែលបានលក់ ( Cost of goods sold ): | | |
| ការទិញទំនិញ | ………… | |
| សន្និធិចុគ្រា | ………… | ………… |
| ចំណេញដុល ( Gross profit ) | | ………… |
| ចំណាយផ្សេងៗទៀត ( Expenses ): | | |
| ដំណើរការអាជីវកម្ម | ………… | |
| អគ្គិសនី | ………… | |
| ប្រាក់បៀវត្ស( Salaries ) | ………… | |
| ថ្លៃជួលអគារ ( Rent expense ) | ………… | ………… |
| ចំណេញសុទ្ធ ( Net profit ) | | ………… |

2 ) ចូរបំពេញនៅទិន្នន័យដែលខ្វះខាតនៃគណនីប្រតិបត្តិខាងក្រោម៖

| | $ | $ |
|---|---|---|
| **ចំណូលពីការលក់ទំនិញ** | **54,353** | |
| ការបង្វិលទំនិញលក់ | …………… | |
| **ចំណូលពីការលក់ទំនិញសុទ្ធ** | | **54,231** |
| ថ្លៃដើមទំនិញដែលបានលក់៖ | | |
| សន្និធិដើមគ្រា | 8,798 | |
| ការទិញទំនិញ | 45,434 | |
| ថ្លៃដឹកទំនិញចូលក្នុងក្រុមហ៊ុន | 767 | |
| ការបង្វិលទំនិញដែលទិញ | 453 | |
| សន្និធិចុងគ្រា | …………… | 41,773 |
| **ប្រាក់ចំណេញដុល** | | ………… |

3 ) ចូរបំពេញតួលេខនៅក្នុងរបាយការណ៍ចំណេញ/ខាត របស់ក្រុមហ៊ុន C Woods សម្រាប់ការិយបរិច្ឆេទបញ្ចប់នៅថ្ងៃទី៣ខែមិថុនា ឆ្នាំ២០ ០១៩ ដោយប្រើប្រាស់ទិន្នន័យខាងក្រោម៖

| | $ |
|---|---|
| ចំណូលពីការលក់ | 87,450 |
| ការទិញទំនិញ | 65,264 |
| សន្និធិ/ស្តុកដើមគ្រា | 9,810 |
| ចំណាយទឹក និងអគ្គីសនី | 4,310 |
| ចំណាយផ្សព្វផ្សាយពាណិជ្ជកម្ម | 7,866 |
| ចំណាយប្រាក់បៀវត្ស | 11,721 |
| ចំណូលពីកម្រៃជើងសារ | 1,045 |
| ចំណាយនៃការជួល | 3,290 |

គេឱ្យសន្និធិ/ស្តុកនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ មានតម្លៃ $8,960។

**ក្រុមហ៊ុន C Woods**

**របាយការណ៍ចំណេញ/ខាត**

**សម្រាប់រយៈមួយឆ្នាំ បញ្ចប់ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩**

| | $ | $ |
|---|---|---|
| ចំណូល (Revenue) | | ………… |
| ចំណាយថ្លៃដើមទំនិញដែលបានលក់ (Cost of sales): | | |
| សន្និធិដើមគ្រា | ………… | |
| ការទិញទំនិញ | ………… | |
| សន្និធិចុងគ្រា | ………… | ………… |
| ចំណេញដុល (Gross profit) | | ………… |
| ចំណូលពីកម្រៃជើងសារ | | ………… |
| ចំណាយផ្សេងៗទៀត: | | |
| ទឹក និងអគ្គីសនី | ………… | |
| ផ្សព្វផ្សាយពាណិជ្ជកម្ម | | ………… |
| ប្រាក់បៀវត្ស | ………… | |
| ថ្លៃជួលអគារ | ………… | ………… |
| ចំណេញសុទ្ធ (Net profit) | | ………… |

4) ដោយប្រើប្រាស់ទិន្នន័យក្នុងតារាងខាងក្រោមនេះ ចូរបង្កើតរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (តារាងតុល្យការ) នៃក្រុមហ៊ុន J Harkes សម្រាប់ការិយបរិច្ឆេទបញ្ចប់នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥៖

| | $ |
|---|---|
| អគារ និងដីធ្លី | 56,000 |
| សម្ភារបរិក្ខា | 9,870 |
| សន្និធិ | 9,020 |
| គណនីត្រូវទារ | 3,422 |
| សាច់ប្រាក់នៅធនាគារ | 1,878 |
| គណនីត្រូវសង | 4,321 |
| ដើមទុន | 67,000 |
| ប្រាក់ចំណេញសុទ្ធក្នុងឆ្នាំ | 17,656 |
| ការដកប្រាក់ | 8,787 |

ក្រុមហ៊ុន J Harkes

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

គិតត្រឹមថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥

| | $ | $ |
|---|---|---|
| ទ្រព្យសកម្មរយៈពេលវែង | | |
| អគារ និងដីធ្លី | ………… | |
| សម្ភារបរិក្ខា | ………… | |
| *ទ្រព្យសកម្មរយៈពេលវែងសរុប* | | ………… |
| *ទ្រព្យសកម្មរយៈពេលខ្លី (Current Assets)* | | |
| សន្និធិ | ………… | |
| គណនីត្រូវទារ | ………… | |
| សាច់ប្រាក់នៅធនាគារ | ………… | |
| *ទ្រព្យសកម្មរយៈពេលខ្លីសរុប* | | ………… |
| **ទ្រព្យសកម្មសរុប** | | ………… |
| **មូលធនផ្ទាល់** | | |
| គណនីដើមទុន | ………… | |
| **មូលធនផ្ទាល់សរុប** | | ………… |
| *បំណុលរយៈពេលខ្លី (Current Liabilities)* | | |
| គណនីត្រូវសង | ………… | |
| *បំណុលរយៈពេលខ្លីសរុប* | | ………… |
| **បំណុលសរុប** | | ………… |
| **មូលធនផ្ទាល់ និងបំណុលសរុប** | | ………… |

## III. សំណួរត្រិះរិះ

1) ដោយប្រើប្រាស់ទិន្នន័យខាងក្រោម ចូរបង្កើតរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន D Wilson សម្រាប់ការិយបរិច្ឆេទបញ្ចប់នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩៖

| | $ |
|---|---|
| Fixtures and fittings | 18,500 |
| Equipment | 3,400 |
| Inventory | 5,322 |
| Trade receivables | 2,324 |
| Bank | 1,122 |
| Trade payables | 3,413 |
| Cash | 98 |
| Capital | 16,000 |
| Net profit for year | 4,786 |
| Drawings | 3,433 |
| Long-term loan | 10,000 |

2) ដោយប្រើប្រាស់ទិន្នន័យខាងក្រោម ចូរបង្កើតរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន L Madden សម្រាប់ការិយបរិច្ឆេទបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨៖

| | $ |
|---|---|
| Premises | 75,000 |
| Fixtures and fittings | 12,500 |
| Inventory | 4,995 |
| Trade receivables | 7,212 |
| Bank | 3,323 |
| Trade payables | 5,788 |
| Capital | 62,132 |
| Net profit for year | 14,343 |
| Drawings | 4,233 |
| Long-term loan | 25,000 |

3) ដោយប្រើប្រាស់ទិន្នន័យខាងក្រោម ចូរបង្កើតរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន T Quinn សម្រាប់ការិយបរិច្ឆេទបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០៖

| | $ |
|---|---|
| Buildings | 133,000 |
| Machinery | 19,342 |
| Inventory | 7,565 |
| Trade receivables | 6,285 |
| Bank | 4,324 |
| Trade payables | 9,797 |
| Cash | 314 |
| Loan repayable in 2017 | 54,000 |
| Capital | 95,000 |
| Drawings | 11,390 |
| Net profit for year | 23,423 |

4) ដោយប្រើប្រាស់ទិន្នន័យខាងក្រោម ចូរបង្កើតរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន N Pearson សម្រាប់ការិយបរិច្ឆេទបញ្ចប់នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១៖

| | $ |
|---|---|
| Premises | 105,000 |
| Machinery | 13,700 |
| Motor vehicles | 9,100 |
| Inventory | 9,800 |
| Trade receivables | 4,543 |
| Trade payables | 7,565 |
| Bank Overdraft | 3,423 |
| Cash | 323 |
| Capital | 88,434 |
| Net profit for year | 23,434 |
| Drawings | 7,390 |
| Loan repayable in 2014 | 27,000 |

5) ដោយប្រើប្រាស់ទិន្នន័យខាងក្រោម ចូរបង្កើតរបាយការណ៍ចំណេញ/ខាតរបស់ក្រុមហ៊ុន D Ferdinand សម្រាប់ការិយបរិច្ឆេទបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦៖

| | Dr. | Cr. |
|---|---|---|
| | $ | $ |
| Sales | | 42,321 |
| Purchases | 35,188 | |
| Insurance | 345 | |
| Machinery | 8,000 | |
| Fixtures and fittings | 3,422 | |
| Trade receivables | 6,453 | |
| Trade payables | | 7,585 |
| Bank | | 1,415 |
| Utilties expense | 2,425 | |
| Staff wages | 9,891 | |
| Sundry expenses | 881 | |
| Marketing | 2,866 | |
| Capital | | 29,808 |
| Drawings | 8,745 | |
| Maintenance | 2,667 | |
| Cash | 246 | |
| | *81,129* | *81,129* |

គេឱ្យ៖ សន្និធិនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ មានតម្លៃ $1,890 ។

6) តារាងតុល្យភាពសាកល្បងខាងក្រោមត្រូវបានដកស្រង់ចេញពីសៀវភៅនៃក្រុមហ៊ុន R Grime សម្រាប់ការិយបរិច្ឆេទបញ្ចប់នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥។ ចូរបង្កើតរបាយការណ៍ចំណេញ/ខាត និងតារាងតុល្យការ គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥៖

| | Dr. | Cr. |
|---|---|---|
| | $ | $ |
| Sales | | 323,423 |
| Purchases | 234,354 | |
| Property | 194,000 | |
| Delivery van | 18,700 | |

| | | |
|---|---|---|
| Trade receivables | 18,793 | |
| Trade payables | | 20,912 |
| Bank | 12,346 | |
| Utilities expense | 4,233 | |
| Salaries | 16,565 | |
| Office expense | 2,131 | |
| Rent and rate | 19,213 | |
| Long-term loan | | 50,000 |
| Capital | | 144,798 |
| Drawings | 18,798 | |
| | 539,133 | 539,133 |

គេឱ្យ៖ សន្និធិនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥ មានតម្លៃ $23,223 ។

7) ដោយប្រើប្រាស់ទិន្នន័យខាងក្រោម ចូរបង្កើតរបាយការណ៍ចំណេញ/ខាតរបស់ក្រុមហ៊ុន P Miller សម្រាប់ការិយបរិច្ឆេទបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ៖

| | Dr. | Cr. |
|---|---|---|
| | $ | $ |
| Sales | | 265,000 |
| Purchases | 210,450 | |
| Carriage outwards | 1,100 | |
| Premises | 100,000 | |
| Equipment | 15,900 | |
| Trade receivables | 7,520 | |
| Trade payables | | 6,980 |
| Bank | 6,500 | |
| Administrative | 4,300 | |
| Wage and salaries | 15,328 | |
| Rates and insurance | 3,432 | |
| Repair costs | 2,450 | |
| Capital | | 120,000 |
| Drawings | 16,500 | |
| Motor van | 8,500 | |
| | *391,980* | *391,980* |

គេឱ្យ៖ សន្និធិនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ មានតម្លៃ $9,450។

8) ខាងក្រោមនេះជាតារាងតុល្យភាពសាកល្បងនៃក្រុមហ៊ុន A Bantick។ ចូរបង្កើតរបាយការណ៍ចំណេញ/ខាតសម្រាប់ការិយបរិច្ឆេទបញ្ចប់នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣ខែវិច្ឆិកា ឆ្នាំ២០ ០២០ ៖

| | Dr. | Cr. |
|---|---|---|
| | $ | $ |
| Sales | | 342,312 |
| Purchases | 311,769 | |
| Vehicle expense | 3,212 | |
| Premises | 87,000 | |
| Motor | 13,000 | |
| Trade receivables | 27,878 | |
| Trade payables | | 29,090 |
| Bank | 4,354 | |
| Utilities | 7,891 | |
| Wages and salaries | 23,141 | |
| Rent and rates | 6,543 | |
| Advertising | 2,313 | |
| Capital | | 155,121 |
| Drawings | 12,188 | |
| Repairs | 4,234 | |
| Plant | 23,000 | |
| | 526,523 | 526,523 |

គេឱ្យ៖ សន្និធិនៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២០មានតម្លៃ $27,655។

9) យោងតាមទិន្នន័យខាងក្រោម ចូរបង្កើតរបាយការណ៍ចំណេញ/ខាតរបស់ក្រុមហ៊ុន R Millward សម្រាប់ការិយបរិច្ឆេទបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។

| | $ | $ |
|---|---|---|
| Sales | | 78,678 |
| Purchases | 56,545 | |
| Carriage | 666 | |
| Inventory as at 1 January 2014 | 8,984 | |
| Machinery | 15,000 | |

| | | |
|---|---|---|
| Fixtures and fittings | 8,450 | |
| Trade receivables | 9,878 | |
| Trade payable | | 5,676 |
| Bank overdraft | | 5,344 |
| Water and electricity | 4,212 | |
| Wages | 14,234 | |
| General expenses | 1,254 | |
| Advertising | 3,221 | |
| Capital | | 48,740 |
| Drawings | 9,899 | |
| Maintenance | 2,667 | |
| Commission received | | 870 |
| Equipment | 4,300 | |
| | 139,308 | 139,308 |

គេឱ្យពត៌មានបន្ថែមដូចខាងក្រោម៖

ក) សន្និធិនៅថ្ងៃទី ៣១ ធ្នូ ២០១៤ មានចំនួន $5,467។

ខ) ថ្លៃដឹកជញ្ជូនចូលអាជីវកម្មមាន $321 នៃតម្លៃដឹកជញ្ជូនសរុបរបស់អាជីវកម្ម។

10) យោងតាមទិន្នន័យខាងក្រោម ចូរបង្កើតរបាយការណ៍ចំណេញ/ខាតរបស់ក្រុមហ៊ុន S Rogers សម្រាប់ការិយបរិច្ឆេទបញ្ចប់នៅថ្ងៃទី៣១ ខែកក្កដា ខែ២០១៨ និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែកក្កដា ខែ២០១៨ ។

| | $ | $ |
|---|---|---|
| Sales | | 765,755 |
| Purchases | 545,343 | |
| Returns inwards | 5,424 | |
| Returns outwards | | 6,562 |
| Carriage inwards | 1,213 | |
| Returns inwards | 5,343 | |
| Inventory as at 1 July 2017 | 63,443 | |
| Machinery | 88,500 | |
| Fixtures and fittings | 49,600 | |
| Trade receivables | 42,540 | |
| Trade payable | | 53,453 |

| | | |
|---|---|---|
| Bank | 23,123 | |
| Utilities | 24,211 | |
| Wages and salaries | 43,243 | |
| General expenses | 8,787 | |
| Distribution cost | 5,989 | |
| Loan ( repayable in 2023 ) | | 25,000 |
| Capital | | 99,700 |
| Drawings | 24,343 | |
| Maintenance | 2,667 | |
| Commission received | | 8,676 |
| Equipment | 24,500 | |
| Cash | 877 | |
| | *959,146* | *959,146* |

គេឱ្យ៖ សន្និធិនៅថ្ងៃទី ៣0 ខែកញ្ញា ២០១៧ មានតម្លៃ $75,343។

# មេរៀនទី ៤៖ បញ្ជីកត់ត្រាប្រចាំថ្ងៃ និងបញ្ជីសៀវភៅធំ

## Chapter 4: Day Books and Ledgers

គោលបំណងនៃមេរៀនទី៤ នេះ ផ្តោតលើ៖

- ❖ បញ្ជីកត់ត្រាប្រចាំថ្ងៃសម្រាប់គ្រប់ប្រតិបត្តិការអាជីវកម្មដែលបានកើតឡើង
- ❖ បញ្ជីកត់ត្រាសៀវភៅធំដែលប្រើប្រាស់សម្រាប់កត់ត្រាប្រតិបត្តិការទៅតាមគណនី។

ក្រោយបញ្ចប់មេរៀនទី៤ នេះ យើងអាច៖

- ❖ ស្គាល់បញ្ជីកត់ត្រាប្រចាំថ្ងៃសម្រាប់គ្រប់ប្រតិបត្តិការអាជីវកម្ម
- ❖ ចេះកត់ត្រាប្រតិបត្តិការអាជីវកម្មដែលបានកើតឡើងនៅក្នុងបញ្ជីកត់ត្រាប្រចាំថ្ងៃ
- ❖ ស្គាល់ប្រភេទសៀវភៅធំ ដែលក្រុមហ៊ុនអាជីវកម្មបានប្រើប្រាស់នៅក្នុងការកត់ត្រាសង្ខេបទៅតាមប្រភេទគណនីនីមួយៗ
- ❖ ចេះកត់ត្រាទិន្នន័យពីបញ្ជីកត់ត្រាប្រចាំថ្ងៃ ទៅតាមប្រភេទសៀវភៅធំ
- ❖ ស្គាល់ និងចេះគណនាអប្បហារជួញដូរ និងអប្បហារសាច់ប្រាក់។

### ៤.១. សេចក្តីផ្តើម

រាល់ប្រតិបត្តិការអាជីវកម្មទាំងអស់ដែលបានកើតមានឡើង តែងតែមានឯកសារគាំទ្រជានិច្ច។ ឧទាហរណ៍ សម្រាប់ការលក់ទំនិញដោយជំពាក់ ក្រុមហ៊ុននឹងរៀបចំវិក្កយបត្រលក់សម្រាប់អតិថិជន។ ដូចនេះ ព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុនអាជីវកម្មទាំងអស់ នឹងត្រូវរក្សាទុកនៅក្នុងឯកសារអាជីវកម្ម។ ដើម្បីរក្សាបាននូវភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានទាំងនេះ ទាមទារឱ្យក្រុមហ៊ុនអាជីវកម្មត្រូវកត់ត្រាទុកដាក់ឱ្យបានត្រឹមត្រូវ។

ជាទូទៅ, នៅក្នុងដំណើរការរកស៊ី ក្រុមហ៊ុនអាជីវកម្មនឹងជួបប្រទះនូវឯកសារអាជីវកម្មជាច្រើនទាំងចេញពីក្រុមហ៊ុនសាមីផ្ទាល់ ឬទទួលបានពីភាគីដ៏ទៃទៀត។ ដូចនេះ ក្រុមហ៊ុនអាជីវកម្ម ត្រូវកត់ត្រាទុកដាក់នូវព័ត៌មានទាំងអស់ឱ្យបានលម្អិត និងគ្រប់ជ្រុងជ្រោយ ដើម្បីធានាថាក្រុមហ៊ុនមិនបានទារពីអតិថិជនដែលបានទូទាត់ប្រាក់រួចហើយ ឬក៏ទូទាត់ជូនអ្នកផ្គត់ផ្គង់មួយរូបណា ២ ដងនោះឡើយ។ ព័ត៌មាននៅក្នុងឯកសារទាំងនេះ ជាដំបូង នឹងត្រូវកត់ត្រារក្សាទុកនៅក្នុងបញ្ជីកត់ត្រាប្រចាំថ្ងៃ ឬបញ្ជីកត់ត្រាដំបូង។

### ៤.២. បញ្ជីកត់ត្រាប្រចាំថ្ងៃ

បញ្ជីកត់ត្រាប្រចាំថ្ងៃ ឬបញ្ជីកត់ត្រាដំបូង គឺជាការកត់ត្រាទិន្នានុប្បវត្ត ឬជាការកត់ត្រាដំបូងគេសម្រាប់គ្រប់ប្រតិបត្តិការអាជីវកម្មដែលបានកើតឡើង។ ការកត់ត្រានៅក្នុងបញ្ជីសៀវភៅទាំងនេះ ពុំមែនជាការកត់ត្រាគណនេយ្យទាំងស្រុងឡើយ។ ដើម្បីឱ្យប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់បង្ហាញនៅក្នុង

របាយការណ៍ហិរញ្ញវត្ថុ, ជាដំបូង គ្រប់អាជីវកម្ម ត្រូវកត់ត្រារាល់ប្រតិបត្តិការទាំងនោះ នៅក្នុងបញ្ជីកត់ត្រាចំបង។ តារាងខាងក្រោមបង្ហាញពីទំនាក់ទំនងរវាងបញ្ជីកត់ត្រាចំបង និងប្រភពឯកសារ៖

| Day Books | Source of documents recorded |
|---|---|
| Sales day book | Sale invoices |
| Sale returns day book | Credit notes sent |
| Purchase day book | Purchase invoices |
| Purchase returns day book | Credit notes received |
| Cash book | Cheques, direct debits, standing orders |
| Petty cash book | Currency notes paid and received |
| Journal ( General journal ) | Other transactions beside above |

### ៤.២.១. បញ្ជីលក់ទំនិញប្រចាំថ្ងៃ ( Sales Day Book )

បញ្ជីលក់ទំនិញប្រចាំថ្ងៃ ត្រូវបានប្រើដើម្បីកត់ត្រា និងតាមដានរាល់ប្រតិបត្តិការនៃការលក់ដោយជំពាក់។ រាល់វិក្កយបត្រដែលបានចេញជូនអតិថិជនទិញទំនិញដោយជំពាក់ជាប្រចាំថ្ងៃ នឹងត្រូវកត់ត្រានៅក្នុងបញ្ជីលក់ទំនិញប្រចាំថ្ងៃ។ ខាងក្រោមជាទម្រង់នៃបញ្ជីលក់ទំនិញប្រចាំថ្ងៃ៖

| SALES DAY BOOK | | | | |
|---|---|---|---|---|
| Date | Invoice Number | Customer | Receivables ledger Ref. | Total invoiced |
| 2019 | | | | $ |
| 10 Jan | 247 | Jones Co. | RL 8 | 105.00 |
| | 248 | Smith | RL 14 | 86.40 |
| 11 Jan | 249 | Jones Co. | RL 8 | 31.80 |
| | 250 | Smith | RL 14 | 1,264.60 |
| | | | | **1,487.80** |

### ៤.២.២. បញ្ជីប្រចាំថ្ងៃនៃការបង្វិលទំនិញដែលបានលក់ ( Sale Returns Day Book )

នៅពេលអតិថិជន បង្វិលទំនិញដែលបានទិញមកវិញ ដោយសារហេតុផលណាមួយនោះ, នោះទំនិញបង្វិលមកវិញ នឹងត្រូវកត់ត្រានៅក្នុងបញ្ជីប្រចាំថ្ងៃនៃការបង្វិលទំនិញដែលបានលក់ ( Sale Returns Day Book )។ ខាងក្រោមជាទម្រង់បញ្ជីប្រចាំថ្ងៃនៃការបង្វិលទំនិញដែលបានលក់៖

| SALE RETURNS DAY BOOK | | | |
|---|---|---|---|
| Date | Customer and Goods | Receivables ledger Ref. | Amount |
| 2019 | | | $ |
| 25 Jan | Smith | | |
| | 3 pair Texas Boots | RL 14 | 135.00 |

យើងអាចកត់ត្រាការបង្វិលទំនិញ (Sale returns) នៅក្នុងបញ្ជីលក់ប្រចាំថ្ងៃ (Sales day book) ដូច្នេះ មិនតម្រូវឱ្យមាន បញ្ជីប្រចាំថ្ងៃនៃការបង្វិលទំនិញដែលបានលក់ នោះទេ។

### ៤.២.៣. បញ្ជីទិញទំនិញប្រចាំថ្ងៃ (Purchase Day Book)

បញ្ជីទិញទំនិញប្រចាំថ្ងៃ ត្រូវបានប្រើដើម្បីកត់ត្រា និងតាមដានការទិញដោយជំពាក់។ រាល់វិក្កយបត្រដែលទទួលបានពីការទិញទំនិញដោយជំពាក់ ពីអ្នកផ្គត់ផ្គង់ជាប្រចាំថ្ងៃ នឹងត្រូវកត់ត្រានៅក្នុងបញ្ជីទិញទំនិញប្រចាំថ្ងៃ។ ខាងក្រោមជាទម្រង់នៃបញ្ជីទិញទំនិញប្រចាំថ្ងៃ៖

| PURCHASE DAY BOOK | | | |
|---|---|---|---|
| Date | Suppliers | Payable ledger Ref. | Total Invoiced |
| 2019 | | | $ |
| 04 Jan | RST Co. | PL 18 | 215.00 |
| 10 Jan | WST Co. | PL 45 | 130.00 |
| 12 Jan | RST Co. | PL 18 | 12,000.50 |
| | | | **12,345.50** |

### ៤.២.៤. បញ្ជីប្រចាំថ្ងៃនៃការបង្វិលទំនិញដែលបានទិញ (Purchase Returns Day Book)

នៅពេលទំនិញដែលក្រុមហ៊ុនបានទិញ មានបញ្ហាណាមួយ, នោះទំនិញ នឹងត្រូវបង្វិលទៅអ្នកផ្គត់ផ្គង់វិញ ហើយការបង្វិលទំនិញនេះត្រូវកត់ត្រានៅក្នុងបញ្ជីប្រចាំថ្ងៃនៃការបង្វិលទំនិញដែលបានទិញ (Purchase Returns Day Book)។ ខាងក្រោមជាទម្រង់បញ្ជីប្រចាំថ្ងៃនៃការបង្វិលទំនិញដែលបានទិញ៖

| PURCHASE RETURN DAY BOOK | | | |
|---|---|---|---|
| Date | Suppliers | Payable ledger Ref. | Total Invoiced |
| 2019 | | | $ |
| 29 Jan | RST Co. | | |
| | 300 Cardboard boxes | PL 45 | 46.60 |

យើងអាចកត់ត្រាការបង្វិលទំនិញដែលបានទិញ (Purchase returns) នៅក្នុងបញ្ជីទិញប្រចាំថ្ងៃ (Purchase day book) ដូច្នេះ មិនតម្រូវឱ្យមាន បញ្ជីប្រចាំថ្ងៃនៃការបង្វិលទំនិញដែលបានទិញនោះទេ។

## ៤.២.៥. បញ្ជីសាច់ប្រាក់ (Cash Book)

បញ្ជីសាច់ប្រាក់ (Cash Book) ជាបញ្ជីនៃការកត់ត្រចំបងមួយ ដែលត្រូវបានប្រើប្រាស់ ដើម្បីកត់ត្រារក្សាទុកសាច់ប្រាក់ទទួលបាន និងសាច់ប្រាក់ទូទាត់ (សាច់ប្រាក់ចូល-ចេញ)។ បញ្ជីសាច់ប្រាក់ (Cash Book) ត្រូវបានរៀបចំឡើងដោយគណនេយ្យកររបស់ក្រុមហ៊ុន។ បញ្ជីសាច់ប្រាក់ ត្រូវបានរៀបចំជាពីរផ្នែក ពោលគឺ បញ្ជីសាច់ប្រាក់ទទួលបាន (Cash Receipt Day Book) និង បញ្ជីសាច់ប្រាក់ទូទាត់ (Cash Payment Day Book) មានទម្រង់ដូចខាងក្រោម៖

❖ បញ្ជីសាច់ប្រាក់ទទួលបាន (Cash Receipt Day Book)

| CASH RECEIPT DAY BOOK | | | | | | |
|---|---|---|---|---|---|---|
| **Date** | **Narrative** | **Discounts allowed** | **Total** | **Receivables ledger** | **Cash Sales** | **Sundry** |
| 2019 | | $ | $ | $ | $ | $ |
| 10 Jan | Cash sale | | 150 | | 150 | |
| 16 Jan | Receivables: Smith | 50 | 950 | 1,000 | | |
| | | **50** | **1,100** | **1,000** | **150** | |

❖ បញ្ជីសាច់ប្រាក់ទូទាត់ (Cash Payment Day Book)

| CASH PAYMENT DAY BOOK | | | | | | |
|---|---|---|---|---|---|---|
| **Date** | **Narrative** | **Discounts received** | **Total** | **Payables ledger** | **Cash Purchase** | **Rent Expense** |
| 2019 | | $ | $ | $ | $ | $ |
| 18 Jan | Payables: RST Co. | - | 300 | 300 | - | - |
| | Rent | - | 100 | - | - | 100 |
| | | - | **400** | **300** | - | **100** |

## ៤.២.៦. បញ្ជីសាច់ប្រាក់រងទេយ្យ (Petty Cash Book)

សាច់ប្រាក់រងទេយ្យ គឺជាសាច់ប្រាក់រក្សាទុកសម្រាប់ចំណាយតូចតាច និងចាំបាច់ដើម្បីធានាដំណើរការអាជីវកម្ម។ សាច់ប្រាក់រងទេយ្យ ជានីតិវិធីមួយនៃការចំណាយសាច់ប្រាក់របស់ក្រុមហ៊ុន។ សាច់ប្រាក់នេះ ត្រូវបានរក្សាទុកនៅក្នុងទូដែករបស់ក្រុមហ៊ុន ដើម្បីចាយវាយបានភ្លាមៗ តាមតម្រូវការ

ចាំបាច់និងបន្ទាន់ចំពោះមុខ ដែលទទួលខុសត្រូវដោយរជ្ជទេយ្យករ (Cashier)។ រាល់ការចំណាយតាមរជ្ជទេយ្យ តម្រូវឱ្យមានការអនុម័តជាមុន និងឯកសារគាំទ្រដូចជាប័ណ្ណចំណាយ (Vouchers) និងបង្កាន់ដៃទទួលប្រាក់ (receipts) និងត្រូវកត់ត្រារក្សាទុកនៅក្នុងបញ្ជីសាច់ប្រាក់រជ្ជទេយ្យ។

**PETTY CASH BOOK**
**FOR THE PERIOD COVERED MAY 1 to 28, 2015**

| Date | Received From/ Paid To & Description | PCRV/PCDV RPCA No. | Cash Balance | Receipts: Replenishment | Receipts: Refund of Advance | Amount | Cash Advance | Stationery | Cleaning Supplies | Internet | Office Supplies | Meeting Expense | Mission |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| Balance brought forward | | | $275.00 | | | | | | | | | | |
| 02-May-15 | Finance Unit-Replenishment | PCRV -04 | 1000.00 | 725.00 | | | | | | | | | |
| 03-May-15 | IBC Shop | PCDV -12 | 925.00 | | | 75.00 | | 75.00 | | | | | |
| 05-May-15 | ABC Shop | PCDV-13 | 885.00 | | | 40.00 | | | 40.00 | | | | |
| 07-May-15 | CDE Shop- Toner for laser printer | PCDV-14 | 805.00 | | | 80.00 | | | | | 80.00 | | |
| 16-May-15 | Ezecom-internet fee-May 2015 | PCDV-16 | 760.00 | | | 45.00 | | | | 45.00 | | | |
| 20-May-15 | PTC Shop- Toner for copier | PCDV-17 | 675.00 | | | 85.00 | | | | | 80.00 | | |
| 25-May-15 | CED- water for meeting | PCDV-18 | 663.00 | | | 12.00 | | | | | | 12.00 | |
| Total Receipts This Period | | | 1,000.00 | 725.00 | #REF! | | | | | | | | |
| Unliquidated Cash Advance | | | | | | | 0.00 | | | | | | |
| Amount to be Replenished | | | **337.00** | | | 337.00 | | 75.00 | 40.00 | 45.00 | 160.00 | 12.00 | - |
| Ending Balance | | | 663.00 | | | | | | | | | | |

* Note: Specify the expense per budget category.

**Seen and Approved by:** Name: ____________ Director of Department Date: ____________

**Checked by:** Name: ____________ Position: ____________ Date: ____________

**Prepared by:** Name: ____________ Position: ____________ Date: ____________

វិធីសាស្ត្រនៃការគ្រប់គ្រងសាច់ប្រាក់រជ្ជទេយ្យ គឺ Imprest System ៖

| | $ |
|---|---|
| Cash in box | X |
| Total Vouchers (Expenses)=Top-up | <u>X</u> |
| Maximum Amounts | X |

ខាងក្រោមជាទម្រង់បញ្ជីសាច់ប្រាក់រជ្ជទេយ្យ៖

អនុវត្ត៖

1. ចូរកត់ត្រាថាតើប្រតិបត្តិការខាងក្រោមនេះ មួយណាស្ថិតនៅក្នុងបញ្ជីកត់ត្រាចំបង៖ Sales day book, Purchase day book, Cash book, និង Petty cash book?

<u>**ខែឧសភា**</u> <u>Day Book</u>

០១ លក់ទំនិញ $80 ទៅឱ្យក្រុមហ៊ុន សីហា ដោយជំពាក់

០៤ បង់ថ្លៃចំណាយទូរស័ព្ទអស់ $210 ចេញជាមូលប្បទានបត្រ

០៦ ទិញទំនិញ $600 ដោយជំពាក់ ពីក្រុមហ៊ុន B

០៦ ទទួលបានមូលប្បទានបត្រពីក្រុមហ៊ុន H ទឹកប្រាក់ $180

១០ លក់ទំនិញ $600 ទៅឱ្យក្រុមហ៊ុន G ដោយជំពាក់

១១ ទិញទំនិញ $700 ពីក្រុមហ៊ុន I ដោយបានទូទាត់ជាមូលប្បទានបត្រ

១៦ ទទួលបានការទូទាត់ជាមូលប្បទានបត្រពីក្រុមហ៊ុន J $482

២០ បានចំណាយសាច់ប្រាក់ $80 ក្នុងការទិញទឹកសុទ្ធ

A. ចូរគណនារក Total Sale day book $..................

B. ចូរគណនារក Total Purchase day book $..................

2. ក្រុមហ៊ុនមួយបានប្រើប្រព័ន្ធសាច់ប្រាក់រជ្ជទេយ្យ Imprest ដោយមានកម្រិតទឹកប្រាក់អតិបរមា $100។ ចំណាយខាងក្រោមបានកើតមានឡើងនៅក្នុងខែមិថុនា៖

| | |
|---|---|
| Stamps | $15.80 |
| Travel expense | $22.45 |
| Tea and Coffee | $18.90 |

តើសាច់ប្រាក់ប៉ុន្មាន ចាំបាច់បំពេញបន្ថែមសាច់ប្រាក់រជ្ជទេយ្យនេះ? $..................

### ៤.២.៧. ទិនានុប្បវត្តិ (Journal)

ទិនានុប្បវត្ត(Journal) ត្រូវបានប្រើកត់ត្រានូវការប្រតិបត្តិការដោយឡែក ដែលមិនអាចកត់ត្រានៅក្នុងបញ្ជីកត់ត្រាដំបូងខាងលើបាន។ ទម្រង់នៃទិនានុប្បវត្តិ៖

| JOURNAL | | | | | |
|---|---|---|---|---|---|
| Date | Account Number | Narrative | Reference | Dr. | Cr. |
| 2019 | | | | $ | $ |
| 01 Jan | 10011 | Cash | | 10,000 | |
| | 40011 | Capital | | | 10,000 |
| | | Owner invest $10,000 in cash | | | |

Journal ភាគច្រើន ត្រូវបានគេប្រើក្នុងការកត់ត្រាជាទូទៅគ្រប់ប្រតិបត្តិការទាំងអស់។ សម្រាប់ការសិក្សានៅពេលខាងមុខទៀត យើងនឹងជួបតែការកត់ត្រា Journal ប៉ុណ្ណោះ ជំនួយឱ្យការកត់ត្រានៅក្នុងបញ្ជីកត់ត្រាដំបូងផ្សេងៗទៀត។

### ៤.៣. បញ្ជីសៀវភៅធំ (General Ledger)

បន្ទាប់ពីក្រុមហ៊ុនទទួលបានឯកសារអាជីវកម្មហើយ ក្រុមហ៊ុនត្រូវធ្វើការកត់ត្រា នៅក្នុង Books of Prime Entry ខាងលើ។ ការកត់ត្រាដំបូងនេះ គឺជាការកត់ត្រាតាមពេលវេលាដែលប្រតិបត្តិការបានកើតឡើង។ គណនីនីមួយៗ នៅក្នុងសៀវភៅធំ ត្រូវបានគេស្គាល់ថាជាគណនីអក្សរ T ( T-Account)។

ដើម្បីអាចសង្ខេបប្រតិបត្តិការទាំងនោះ ទៅតាមគណនីនីមួយៗ បាន តម្រូវឱ្យមានការកត់ត្រានៅក្នុងគណនីសៀវភៅធំ (Ledger Accounts) ឬអាចហៅថាការកត់ត្រានៅក្នុងសៀវភៅធំ (Posting to ledger)។ គណនីសៀវភៅធំ ត្រូវបានបែងចែកជាប្រភេទជាច្រើនតាមតម្រូវការរបស់ក្រុមហ៊ុនក្នុងការតាមដានកិច្ចការហិរញ្ញវត្ថុអ្វីមួយ។ ឧទាហរណ៍៖ Receivables Ledger បង្កើតឡើងសម្រាប់គ្រប់គ្រងគណនីអតិថិជនជំពាក់, Payables Ledger សម្រាប់គ្រប់គ្រងគណនីអ្នកផ្គត់ផ្គង់ដែលក្រុមហ៊ុនបានជំពាក់ និង General Ledger សម្រាប់គ្រប់គ្រងប្រតិបត្តិការរបស់ក្រុមហ៊ុនទាំងមូល។

### ៤.៣.១. សៀវភៅធំសម្រាប់អតិថិជនទិញជំពាក់ (Receivables ledger)

Receivables ledger រួមមានគណនីអតិថិជនទាំងអស់ ដែលក្រុមហ៊ុនបានលក់ទំនិញជូន។ គណនីទាំងនោះ គឺសម្រាប់កត់ត្រាការលក់ដោយជំពាក់ទៅតាមគណនីអតិថិជនម្នាក់ៗ។ គណនីនីមួយៗ សម្រាប់អតិថិជនម្នាក់ៗ ត្រូវប្រើសម្រាប់ការកត់ត្រាប្រតិបត្តិការការលក់ទំនិញដោយជំពាក់ជូនអតិថិជននោះ។ នៅចុងការិយបរិច្ឆេទគណនេយ្យ ក្រុមហ៊ុនអាជីវកម្ម នឹងមានព័ត៌មានពេញលេញទៅតាមអតិថិជនម្នាក់ៗ នូវទឹកប្រាក់ដែលបានជំពាក់ក្រុមហ៊ុន។

ចេញពីការកត់ត្រានៅក្នុងបញ្ជីលក់ប្រចាំថ្ងៃ ប្រតិបត្តិការនីមួយៗ របស់អតិថិជន នឹងត្រូវកត់ត្រាបន្តនៅក្នុង Receivables Ledger ក្នុងគណនីអតិថិជននោះ។

### ៤.៣.២. សៀវភៅធំសម្រាប់អ្នកផ្គត់ផ្គង់លក់ជំពាក់ (Payables Ledger)

Payables ledger រួមមានគណនីអ្នកផ្គត់ផ្គង់ទាំងអស់ ដែលក្រុមហ៊ុនបានទិញទំនិញ។ គណនីទាំងនោះ គឺសម្រាប់កត់ត្រាការទិញទំនិញដោយជំពាក់ ទៅតាមគណនីអ្នកផ្គត់ផ្គង់ម្នាក់ៗ។ គណនីនីមួយៗ សម្រាប់អ្នកផ្គត់ផ្គង់ម្នាក់ៗ ត្រូវប្រើសម្រាប់ការកត់ត្រាប្រតិបត្តិការការទិញទំនិញដោយជំពាក់ពីអ្នកផ្គត់ផ្គង់នោះ។ នៅចុងការិយបរិច្ឆេទគណនេយ្យ ក្រុមហ៊ុនអាជីវកម្ម នឹងមានព័ត៌មានពេញលេញទៅតាមអ្នកផ្គត់ផ្គង់ម្នាក់ៗ នូវទឹកប្រាក់ដែលក្រុមហ៊ុនបានជំពាក់។

ចេញពីការកត់ត្រានៅក្នុងបញ្ជីលក់ប្រចាំថ្ងៃ ប្រតិបត្តិការនីមួយៗ របស់អ្នកផ្គត់ផ្គង់ នឹងត្រូវកត់ត្រាបន្តនៅក្នុង Payables Ledger ក្នុងគណនីអ្នកផ្គត់ផ្គង់នោះ។

### ៤.៣.៣. សៀវភៅធំទូទៅ (General Ledger)

សៀវភៅធំទូទៅ គឺជាបញ្ជីកត់ត្រាដែលសង្ខេបនូវរាល់កិច្ចការហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទាំងមូល។ សៀវភៅធំទូទៅ រួមមានគណនីទាំងអស់ (Ledger Accounts) នៃទ្រព្យសកម្ម បំណុល មូលធនផ្ទាល់ ចំណូល ចំណាយ និងចំណេញ/ខាត របស់ក្រុមហ៊ុនអាជីវកម្មមួយ។ Ledger account (គណនីអក្សរ T) មានឈ្មោះ ប្រភេទ និងលេខកូតរបស់វារៀងៗខ្លួន ដែលតំណាងឱ្យប្រភេទជាក់លាក់នៃចំណូល ចំណាយ ទ្រព្យសកម្ម បំណុល និងមូលធនផ្ទាល់។ គោលបំណងនៃការកត់ត្រានៅក្នុង Ledger Accounts គឺដើម្បីសរុបតម្លៃនៃគណនីជាក់លាក់នីមួយៗ បន្ទាប់ពីយើងបានកត់ត្រានូវប្រតិបត្តិការនៅក្នុងដំណើរការរកស៊ីរបស់ក្រុមហ៊ុនរួចមក។ ទម្រង់នៃ Ledger Accounts គឺដូចបង្ហាញនៅក្នុងមេរៀនទី ២ ពាក់ព័ន្ធនឹងគណនីអក្សរ T។

## ៤.៤. នីតិវិធីនៃការកត់ត្រាពីបញ្ជីប្រចាំថ្ងៃមកក្នុងគណនីសៀវភៅធំ

### ៤.៤.១. ការកត់ត្រានៅក្នុង Receivables និង Payables Ledgers

បន្ទាប់ពីប្រតិបត្តិការត្រូវបានកត់ត្រានៅក្នុង Sales day book, Purchases Day Book, Sale returns day book និង Purchases returns day book រួចមក, ប្រតិបត្តិការនីមួយ នឹងត្រូវកត់ត្រាបន្តនៅក្នុងគណនីអតិថិជន ឬគណនីអ្នកផ្គត់ផ្គង់ ទៅតាមឈ្មោះអតិថិជន ឬអ្នកផ្គត់ផ្គង់នោះ នៅក្នុង Receivables Ledger ឬ Payables Ledger។ ការកត់ត្រានេះពុំចាំបាច់គោរពទៅទាមច្បាប់កត់ត្រាទ្វេភាគនោះទេ។

### ៤.៤.២. ការកត់ត្រានៅក្នុង General Ledger

សម្រាប់ទឹកប្រាក់សរុបនៅក្នុង Sales day book, Purchases Day Book, Sale returns day និង Purchases returns day book នឹងត្រូវកត់ត្រាតាមច្បាប់កត់ត្រាទ្វេភាគ នៅក្នុង Ledger account ដូចខាងក្រោម៖

| | Debit | Credit |
|---|---|---|
| សរុបទឹកប្រាក់នៅក្នុង Sales day book: | Receivables control a/c | Sales a/c |
| សរុបទឹកប្រាក់នៅក្នុង Purchase day book: | Purchases | Payables control a/c |
| សរុបទឹកប្រាក់នៅក្នុង Sales returns day book: | Returns inwards a/c | Receivables control a/c |
| សរុបទឹកប្រាក់នៅក្នុង Purchase returns day book: | Payables control a/c | Returns outwards a/c |

**ចំណាំ៖** ទឹកប្រាក់សរុបនៃគណនីអតិថិជនទាំងអស់នៅក្នុង Receivables Ledger ត្រូវតែស្មើគ្នា នឹងទឹកប្រាក់សរុបនៅក្នុងគណនី Receivables control របស់ General Ledger ។ ដូចគ្នាផងដែរ ទឹកប្រាក់សរុបនៃគណនីអតិថិជនទាំងអស់នៅក្នុង Payables Ledger ត្រូវតែស្មើគ្នា នឹងទឹកប្រាក់សរុបនៅក្នុងគណនី Payables control របស់ General Ledger ។

**ឧទាហរណ៍៖**

ផ្អែកតាមឧទាហរណ៍នៅក្នុង Sales day book, Purchases Day Book, Sale returns day Purchases returns day book, Cash receipt day និង Cash payment day book ខាងលើ យើងអាចកត់ត្រានៅក្នុង Ledger account ដូចខាងក្រោម៖

| SALES DAY BOOK | | | | |
|---|---|---|---|---|
| Date | Invoice Number | Customer | Receivables ledger Ref. | Total invoiced |
| 2019 | | | | $ |
| 10 Jan | 247 | Jones Co. | RL 8 | 105.00 |
| | 248 | Smith | RL 14 | 86.40 |
| 11 Jan | 249 | Jones Co. | RL 8 | 31.80 |
| | 250 | Smith | RL 14 | 1,264.60 |
| | | | | **1,487.80** |

| SALE RETURNS DAY BOOK | | | |
|---|---|---|---|
| **Date** | **Customer and Goods** | **Receivables ledger Ref.** | **Amount** |
| 2019 | | | $ |
| 25 Jan | Smith | | |
| | 3 pair Texas Boots | RL 14 | 135.00 |

| PURCHASE DAY BOOK | | | |
|---|---|---|---|
| **Date** | **Suppliers** | **Payable ledger Ref.** | **Total Invoiced** |
| 2019 | | | $ |
| 04 Jan | RST Co. | PL 18 | 215.00 |
| 10 Jan | WST Co. | PL 45 | 130.00 |
| 12 Jan | RST Co. | PL 18 | 12,000.50 |
| | | | **12,345.50** |

| PURCHASE RETURN DAY BOOK | | | |
|---|---|---|---|
| **Date** | **Suppliers** | **Payable ledger Ref.** | **Total Invoiced** |
| 2019 | | | $ |
| 29 Jan | RST Co. | | |
| | 300 Cardboard boxes | PL 45 | 46.60 |

| CASH RECEIPT DAY BOOK | | | | | | |
|---|---|---|---|---|---|---|
| **Date** | **Narrative** | **Discounts allowed** | **Total** | **Receivables ledger** | **Cash Sales** | **Sundry** |
| 2019 | | $ | $ | $ | $ | $ |
| 10 Jan | Cash sale | | 150 | | 150 | |
| 16 Jan | Receivables: Smith | 50 | 950 | 1,000 | | |
| | | **50** | **1,100** | **1,000** | **150** | |

| CASH PAYMENT DAY BOOK | | | | | | |
|---|---|---|---|---|---|---|
| Date | Narrative | Discounts received | Total | Payables ledger | Cash Purchase | Rent Expense |
| 2019 | | $ | $ | $ | $ | $ |
| 18 Jan | Payables: RST Co. | - | 300 | 300 | - | - |
| | Rent | - | 100 | - | - | 100 |
| | | - | 400 | 300 | - | 100 |

## Receivables Ledger

**Jones Co.** **A/c No. SL 8**

| 2019 | | $ | 2019 | | $ |
|---|---|---|---|---|---|
| 10 Jan | Sales ( Invoice no. 247 ) | 105.00 | 31 Jan | Balance c/d | 136.80 |
| 11 Jan | Sales ( Invoice no. 249 ) | 31.80 | | | |
| | | 136.80 | | | 136.80 |
| 01 Feb | Balance b/d | 136.80 | | | |

**Smith** **A/c No. SL 14**

| 2019 | | $ | 2019 | | $ |
|---|---|---|---|---|---|
| 10 Jan | Sales ( Invoice no. 248 ) | 86.40 | 16 Jan | Cash | 1,000.00 |
| 11 Jan | Sales ( Invoice no. 250 ) | 1,264.60 | 25 Jan | Reurns inwards | 135.00 |
| | | | 31 Jan | Balance c/d | 216.00 |
| | | 1,351.00 | | | 1,351.00 |
| 01 Feb | Balance b/d | 216.00 | | | |

## Payables Ledger

**WST Co.** **A/c No. PL 18**

| 2019 | | $ | 2019 | | $ |
|---|---|---|---|---|---|
| 31 Jan | Balance c/d | 130.00 | 10 Jan | Purchases | 130.00 |
| | | 130.00 | | | 130.00 |
| | | | 01 Feb | Balance b/d | 130.00 |

**RST Co.** **A/c No. PL 45**

| Date | Details | $ | Date | Details | $ |
|---|---|---|---|---|---|
| 2019 | | $ | 2019 | | $ |
| 10 Jan | Cash | 300.00 | 04 Jan | Purchases | 215.00 |
| 11 Jan | Returns outwards | 46.60 | 12 Jan | Purchases | 12,000.50 |
| 31 Jan | Balance c/d | 11,868.90 | | | |
| | | 12,215.50 | | | 12,215.50 |
| | | | 01 Feb | Balance b/d | 11,868.90 |

## General Ledger

### គណនីសាច់ប្រាក់ (Cash)

| Date | Details | $ | Date | Details | $ |
|---|---|---|---|---|---|
| 2019 | | $ | 2019 | | $ |
| 31 Jan | Receipt | 1,100.00 | 31 Jan | Payment | 400.00 |
| | | | 31 Jan | Balance c/d | 700.00 |
| | | 1,100.00 | | | 1,100.00 |
| 01 Feb | Balance b/d | 700.00 | | | |

### គណនីត្រូវទទួល (Receivables control a/c)

| Date | Details | $ | Date | Details | $ |
|---|---|---|---|---|---|
| 2019 | | $ | 2019 | | $ |
| 31 Jan | Sales | 1,487.80 | 31 Jan | Cash | 1,000.00 |
| | | | 31 Jan | Returns inwards | 135.00 |
| | | | 31 Jan | Balance c/d | 352.80 |
| | | 1,487.80 | | | 1,487.80 |
| 01 Feb | Balance b/d | 352.80 | | | |

### គណនីត្រូវសង (Payables control a/c)

| Date | Details | $ | Date | Details | $ |
|---|---|---|---|---|---|
| 2019 | | $ | 2019 | | $ |
| 31 Jan | Cash | 300.00 | 31 Jan | Purchases | 12,345.50 |
| 31 Jan | Returns outwards | 46.60 | | | |
| 31 Jan | Balance c/d | 11,988.90 | | | |
| | | 12,345.50 | | | 12,345.50 |
| | | | 01 Feb | Balance b/d | 11,998.90 |

### គណនីការលក់ទំនិញ (Sales)

| 2019 | | $ | 2019 | | $ |
|---|---|---|---|---|---|
| 31 Jan | Balance c/d | 1,637.80 | 31 Jan | Cash | 150.00 |
| | | | 12 Jan | Receivables | 1,487.80 |
| | | 1,637.80 | | | 1,637.80 |
| | | | 01 Feb | Balance b/d | 1,637.80 |

### គណនីបង្វិលទំនិញមកវិញ (Returns inwards)

| 2019 | | $ | 2019 | | $ |
|---|---|---|---|---|---|
| 31 Jan | Balance c/d | 135.00 | 31 Jan | Receivables | 135.00 |
| | | 135.00 | | | 135.00 |
| | | | 01 Feb | Balance b/d | 135.00 |

### គណនីការផ្តល់ការបញ្ចុះតម្លៃ (Discount Allowed)

| 2019 | | $ | 2019 | | $ |
|---|---|---|---|---|---|
| 31 Jan | Balance c/d | 50.00 | 31 Jan | Receivables | 50.00 |
| | | 50.00 | | | 50.00 |
| | | | 01 Feb | Balance b/d | 50.00 |

### គណនីការទិញទំនិញ (Purchases)

| 2019 | | $ | 2019 | | $ |
|---|---|---|---|---|---|
| 31 Jan | Cash | 0.00 | 31 Jan | Balance c/d | 12,345.50 |
| 31 Jan | Payables | 12,345.50 | | | |
| | | 12,345.50 | | | 12,345.50 |
| 01 Feb | Balance b/d | 12,345.50 | | | |

### គណនីការបង្វិលទំនិញទៅវិញ (Return outwards)

| 2019 | | $ | 2019 | | $ |
|---|---|---|---|---|---|
| 11 Jan | Returns outwards | 46.60 | 31 Jan | Balance c/d | 46.60 |
| | | 46.60 | | | 46.60 |
| 01 Feb | Balance b/d | 46.60 | | | |

### គណនីចំណាយការជួល (Rent Expense)

| 2019 | | $ | 2019 | | $ |
|---|---|---|---|---|---|
| 11 Jan | Cash | 100.00 | 31 Jan | Balance c/d | 100.00 |
| | | 100.00 | | | 100.00 |
| 01 Feb | Balance b/d | 100.00 | | | |

**អនុវត្តន៍៖** ចូរកំណត់ការកត់ត្រានៅក្នុង General Journal និង General Ledger សម្រាប់ប្រតិបត្តិការ ដូចខាងក្រោម៖

a) ទិញម៉ាស៊ីនភ្លើងសម្រាប់ប្រើប្រាស់ក្នុងក្រុមហ៊ុន ដោយជំពាក់ ក្នុងតម្លៃ $8,000
b) ទិញទំនិញដោយជំពាក់ពីក្រុមហ៊ុន B ក្នុងតម្លៃ $500
c) លក់ទំនិញដោយជំពាក់ទៅឱ្យអតិថិជន C ក្នុងតម្លៃ $1,200
d) សងប្រាក់ទៅឱ្យក្រុមហ៊ុន D ចំនួន $300
e) ទទួលបានប្រាក់សងពីអតិថិជន E ចំនួន $180
f) ទូទាត់ប្រាក់បៀវត្សឱ្យបុគ្គលិក $4,000
g) ទទួលបានវិក្កយបត្រថ្លៃជួលអគារ $700 ពីម្ចាស់អគារ G
h) បង់ថ្លៃជួលអគារ $700 ទៅឱ្យម្ចាស់អគារ G
i) បង់ថ្លៃជានាវ៉ាប់រង $90 ជូនក្រុមហ៊ុនព្រូដិនសល

## ៤.៥. គណនេយ្យសម្រាប់ការបញ្ចុះតម្លៃ (Accounting for Discounts)

ការបញ្ចុះតម្លៃសម្រាប់ការលក់ និងការទិញទំនិញ ត្រូវបានបែងចែកជាពីរប្រភេទ៖

### ៤.៥.១. ការបញ្ចុះតម្លៃជួញដូរ (Trade Discount)

Trade Discount ៖ គឺជាការកាត់បន្ថយនូវថ្លៃទំនិញ ដែលជាធម្មតា កើតមានសម្រាប់ការទិញ ឬលក់ក្នុងចំនួនច្រើន ឬចំពោះប្រភេទអតិថិជនដែលមានគោលការណ៍កំណត់ដាក់លាក់ ហើយនឹងត្រូវបានបង្ហាញនៅក្នុងវិក្កយបត្រតែម្តង។ ក្នុងករណីដែលមានការបញ្ចុះតម្លៃប្រភេទនេះ, នោះតម្លៃនៃការលក់ ឬទិញទំនិញ នឹងត្រូវកត់ត្រាតាមតម្លៃក្រោយពីដកការបញ្ចុះតម្លៃរួច។

**ឧទាហរណ៍៖**

- ក្រុមហ៊ុនបានលក់ទំនិញឱ្យអតិថិជនរបស់ខ្លួនក្នុងតម្លៃ $5,000 ដោយជំពាក់ ព្រមទាំងទទួលបានកាបញ្ចុះតម្លៃ ២% ភ្លាមៗ ដោយសារអតិថិជនបានទិញទំនិញក្នុងបរិមាណច្រើនតាមគោលការណ៍កំណត់។ ដូចនេះ ការកត់ត្រាសម្រាប់ប្រតិបត្តិការនេះគឺ៖

| | | |
|---|---|---|
| Dr. Receivables ($5,000x98%) | $4,900 | |
| Cr. Sales | | $4,900 |

- ក្រុមហ៊ុនបានទិញទំនិញពីអ្នកផ្គត់ផ្គង់របស់ខ្លួនក្នុងតម្លៃ $5,000 ដោយជំពាក់ ព្រមទាំងទទួលបានកាបញ្ចុះតម្លៃ ២% ភ្លាមៗ ដោយសារក្រុមហ៊ុនបានទិញទំនិញក្នុងបរិមាណច្រើនតាមគោលការណ៍កំណត់។ ដូចនេះ ការកត់ត្រាសម្រាប់ប្រតិបត្តិការនេះគឺ៖

| | | |
|---|---|---|
| Dr. Purchase ($5,000x98%) | $4,900 | |
| Cr. Payables | | $4,900 |

### ៤.៥.២. ការបញ្ចុះតម្លៃសាច់ប្រាក់ (Cash Discount)

Cash Discount៖ ជាការកាត់បន្ថយចំនួនទឹកប្រាក់ដែលត្រូវបង់សងអ្នកផ្គត់ផ្គង់ នៅពេលធ្វើការទូទាត់សាច់ប្រាក់។ ជាទូទៅ Cash Discount កើតមាននៅពេលដែលអ្នកទិញធ្វើការទូទាត់ នៅក្នុងរយៈពេលដែលបានកំណត់ថាទទួលបានការបញ្ចុះតម្លៃ។ ក្នុងករណីដែលកើតមានមានការបញ្ចុះតម្លៃប្រភេទនេះ, នោះការលក់ ឬទិញទំនិញ នឹងត្រូវកត់ត្រាតាមតម្លៃសរុបនៃវិក្កយបត្រដោយពុំគិតពីការបញ្ចុះតម្លៃនោះទេ។ ប៉ុន្តែ ការបញ្ចុះតម្លៃនេះ នឹងកត់ត្រានៅពេលដែលសាច់ប្រាក់ត្រូវទូទាត់។ ការកត់ត្រានឹងត្រូវធ្វើឡើងទាំងអ្នកទិញ (បង្ហាញថា Cash discount received) និងអ្នកលក់ (បង្ហាញថា Cash discount allowed)។

**ឧទាហរណ៍៖**

❖ ក្រុមហ៊ុនបានលក់ទំនិញជូនអតិថិជនរបស់ខ្លួនក្នុងតម្លៃ $5,000 និងមានលក្ខខណ្ឌបង់ "2/10, n/30" ដែលមានន័យថាបើអតិថិជនបង់ប្រាក់ក្នុងរយៈពេល ១០ ថ្ងៃក្រោយពីថ្ងៃទិញទំនិញ នោះអតិថិជន នឹងទទួលបានការបញ្ចុះតម្លៃ ២% ហើយអតិថិជនមានរយៈពេល ៣០ ថ្ងៃ ដើម្បីទូទាត់សងប្រាក់ ដូចនេះ ការកត់ត្រាសម្រាប់ប្រតិបត្តិការនេះ៖

<u>ថ្ងៃលក់ទំនិញ</u>

| | | |
|---|---|---|
| Dr. Receivables | $5,000 | |
| Cr. Sales | | $5,000 |

<u>ថ្ងៃសងប្រាក់ដោយមិនទទួលបានការបញ្ចុះតម្លៃ</u>

| | | |
|---|---|---|
| Dr. Cash | $5,000 | |
| Cr. Receivables | | $5,000 |

<u>ថ្ងៃសងប្រាក់ដោយទទួលបានការបញ្ចុះតម្លៃ</u>

| | | |
|---|---|---|
| Dr. Cash | $4,900 | |
| Dr. Sale discount (2%x5,000) | $100 | |
| Cr. Receivables | | $5,000 |

❖ ក្រុមហ៊ុនបានទិញទំនិញពីអ្នកផ្គត់ផ្គង់របស់ខ្លួនក្នុងតម្លៃ $5,000 និងមានលក្ខខណ្ឌបង់ "2/10, n/30" ដែលមានន័យបើក្រុមហ៊ុនបង់ប្រាក់ក្នុងរយៈពេល ១០ ថ្ងៃក្រោយពីថ្ងៃទិញទំនិញ នោះក្រុមហ៊ុន នឹងទទួលបានការបញ្ចុះតម្លៃ ២% ហើយក្រុមហ៊ុនមានរយៈពេល ៣០ ថ្ងៃ ដើម្បីទូទាត់សងប្រាក់ ។ ដូចនេះ ការកត់ត្រាសម្រាប់ប្រតិបត្តិការនេះ៖

<u>ថ្ងៃទិញទំនិញ</u>

| | | |
|---|---|---|
| Dr. Purchase | $5,000 | |
| Cr. Payables | | $5,000 |

ថ្ងៃសងប្រាក់ដោយមិនទទួលបានការបញ្ចុះតម្លៃ

| | | |
|---|---|---|
| Dr. Receivables | $5,000 | |
| Cr. Cash | | $5,000 |

ថ្ងៃសងប្រាក់ដោយទទួលបានការបញ្ចុះតតម្លៃ

| | | |
|---|---|---|
| Dr. Receivables | $5,000 | |
| Cr. Cash | | $4,900 |
| Cr. Purchase discount (2%x5,000) | | $100 |

**អនុវត្តៈ** ក្រុមហ៊ុន Soft Supplies Co. ថ្មីៗនេះ បានទិញពីក្រុមហ៊ុន Hard Imports Co. នូវម៉ាស៊ីនព្រីនធ័រ ចំនួន ១០ គ្រឿង ដែលមានតម្លៃ $200 ក្នុងមួយគ្រឿង។ ក្រុមហ៊ុនទាំងពីរបានព្រមព្រៀងគ្នាថាមាន Trade Discount ចំនួន 10% និងមាន Cash Discount ចំនួន 5% ប្រសិនបើទូទាត់សងទំនិញទាំងនេះ ក្នុងរយៈពេល ១៤ ថ្ងៃ។

ចូរគណនាៈ

a) Trade Discount សរុប

b) Cash Discount សរុប

## ៤.៦. សេចក្តីសន្និដ្ឋាន

នៅក្នុងកិច្ចការគណនេយ្យ ប្រតិបត្តិការអាជីវកម្មដែលបានកើតមានឡើង ត្រូវបានកត់ត្រាជាដំបូងនៅក្នុងបញ្ជីកត់ត្រាប្រចាំថ្ងៃ រួមមានៈ បញ្ជីលក់ទំនិញប្រចាំថ្ងៃ បញ្ជីទិញទំនិញប្រចាំថ្ងៃ បញ្ជីសាច់ប្រាក់ប្រចាំថ្ងៃ និងបញ្ជីទិន្នានុប្បវត្តិ។ បន្ទាប់មកប្រតិបត្តិទាំងនោះ នឹងត្រូវកត់ត្រាបញ្ចូលនៅក្នុងគណនីសៀវភៅធំ (Ledger accounts) ទៅតាមនីតិវិធីដែលបានកំណត់។ នៅក្នុងសៀវភៅធំ ក្រុមហ៊ុននីមួយៗ អាចធ្វើរៀបចំគ្រប់គ្រងទៅតាមផ្នែកមួយៗ ដើម្បីងាយស្រួលក្នុងការតាមដានប្រតិបត្តិទាំងនោះ ដែលរួមមាន សៀវភៅធំសម្រាប់អតិថិជនជំពាក់ (Receivables Ledger), សៀវភៅធំសម្រាប់អ្នកផ្គត់ផ្គង់ (Payables Ledger) និង សៀវភៅធំទូទៅ (General Ledger) ជាដើម។

មេរៀននេះ ក៏បានបង្ហាញអំពីប្រភេទនៃអប្បហា ដែលត្រូវបែងចែកជាពីរ គឺ អប្បហាជួញដូរ (Trade Discount) និងអប្បហាសាច់ប្រាក់(Cash Discount)។ សម្រាប់អប្បហាជួញដូរ គេត្រូវកត់ត្រានៅក្នុងគណនីដាច់ដោយឡែកនោះ ពោលគឺ តម្លៃអប្បហានេះ ត្រូវបានដកចេញពីតម្លៃទំនិញតែម្តង។ ចំពោះអប្បហាសាច់ប្រាក់វិញ គេត្រូវកត់ត្រានៅក្នុងគណនីដាច់ដោយឡែកមួយ ហៅថាគណនី Dicount received ឬ Discount allowed ។

# លំហាត់

## I. សំណួរពហុជ្រើសរើស (MCQ)

1) តើខាងក្រោមនេះមួយណាមិនមែនជាបញ្ជីកត់ត្រាចំបង (Book of Prime Entry)?

   a. Sales day book

   b. Purchase day book

   c. Journal

   d. Asset Register

2) តើបញ្ជីកត់ត្រាចំបង (Book of Prime Entry) ខាងក្រោមនេះ មួយណា ត្រូវបានប្រើក្នុងការកត់ត្រាទំនិញបង្វិលទៅឱ្យអ្នកផ្គត់ផ្គង់វិញ?

   a. Journal

   b. Sale returns day book

   c. Cash book

   d. Purchase return day book

3) ក្រុមហ៊ុនសារាប្រើប្រព័ន្ធ Imprest System សម្រាប់គ្រប់គ្រងការចំណាយសាច់ប្រាក់រង្វទេយ្យ (Petty Cash)។ នៅក្នុងខែឧសភា ឆ្នាំ២០២០, ប្រតិបត្តិការចំណាយសាច់ប្រាក់រង្វទេយ្យបានកើតមានឡើងដូចខាងក្រោម៖

| | | $ |
|---|---|---|
| 02-05-20 | Stamps | 15.00 |
| 03-05-20 | Coffee | 25.00 |
| 08-05-20 | Taxi Fare | 18.00 |
| 18-05-20 | Photocopying | 9.50 |
| 28-05-20 | Stationary | 7.00 |

នៅចុងខែឧសភា ឆ្នាំ២០២០, ទឹកប្រាក់រង្វទេយ្យនៅសល់ ចំនួន $59.50។ តើទឹកប្រាក់អតិប្បរមាសម្រាប់ប្រព័ន្ធសាច់ប្រាក់រង្វទេយ្យនេះ ស្មើនឹងប៉ុន្មាន?

   a. $65.00

   b. $115.00

   c. $124.50

   d. $134.00

4) តើអ្វីទៅជា Trade Discount?

a. ការកាត់បន្ថយនូវទឹកប្រាក់នៅក្នុងវិក្កយបត្រដែលចេញដោយអ្នកលក់ ប្រសិនបើអតិថិជនទូទាត់សាច់ប្រាក់ភ្លាមៗ។

b. ការកាត់បន្ថយថ្លៃដែលអ្នកលក់ផ្តល់ជូនសម្រាប់ការផ្តល់ជូនជាពិសេស នូវការទិញផលិតផលជាក់លាក់ណាមួយ។

c. ការសងប្រាក់មកវិញ (Refund) ដែអ្នកលក់ព្រមព្រៀងជាមួយអតិថិជន បន្ទាប់ពីវិក្កយបត្រត្រូវបានចេញជូនក្នុងតម្លៃពេញ។

d. ការកាត់បន្ថយនូវថ្លៃក្នុងវិក្កយបត្រដោយអ្នកលក់ ដោយសារតែមានលក្ខខណ្ឌទិញលក់ជាមួយអតិថិជន។

5) លោកគ្រីស ទិញទំនិញដោយជំពាក់ពីក្រុមហ៊ុន A ក្នុងតម្លៃ $100។ ក្រុមហ៊ុន A បានផ្តល់នូវការបញ្ចុះតម្លៃ (Trade Discount) ជូនលោកគ្រីស ១៥% និងផ្តល់ជូននូវការបញ្ចុះតម្លៃ (Cash Discount) ១០% បន្ថែមទៀត ប្រសិនបើលោកគ្រីសទូទាត់ប្រាក់ក្នុងរយៈពេល ៣០ ថ្ងៃ។ ប្រសិនបើលោកគ្រីសបានទូទាត់ប្រាក់ក្នុងរយៈពេល ៣០ ថ្ងៃ, តើលោកគ្រីស ត្រូវបង់សាច់ប្រាក់ប៉ុន្មានជូនក្រុមហ៊ុន A?

a. $115.00
b. $85.00
c. $75.00
d. $76.50

6) Helen ទិញទំនិញសម្រាប់លក់វិញក្នុងតម្លៃ $450 ជាសាច់ប្រាក់។ នាងទទួលបានការបញ្ចុះតម្លៃ (Trade Discount) ១០%។ តើការកត់ត្រាខាងក្រោមនេះ មួយណាត្រឹមត្រូវ សម្រាប់ប្រតិបត្តិការនេះ៖

a. Dr. Purchases $450, Cr. Cash $450
b. Dr. Purchases $405, Cr. Payables $405
c. Dr. Purchases $450, Cr. Cash $405, Cr. Purchases discount $45
d. Dr. Purchases $405, Cr. Cash $405

## II. ចូរបំពេញតារាងខាងក្រោម៖

លោកGary បើកនូវអាជីវកម្មប្រឹក្សាយោបល់ខាង computer ដែលមានឈ្មោះថាTechnology Consultants ហើយបំពេញនូវប្រតិបត្តិការណ៍ក្នុងខែមេសា ឆ្នាំ២០២០ ដូចខាងក្រោម៖

01 មេសា Gary បានដាក់ទុនវិនិយោគ $100,000 ជាសាច់ប្រាក់ រួមជាមួយនឹង $24,000 ជាសំភារៈបរិក្ខា

02 មេសា បង់$7,200 ជាសាច់ប្រាក់សម្រាប់ជួលការិយាល័យរយៈពេល 6 ខែ

03 មេសា ទិញសំភារៈបរិក្ខាតំលៃ $12,000 និងសំភារៈការិយាល័យតំលៃ $2,400 ដោយជំពាក់ (ត្រូវសងក្នុងកំឡុងពេល 10 ថ្ងៃ)

06 មេសា ទទួលចំណូលពីសេវាកម្មតំលៃ $2,000 ជាសាច់ប្រាក់

09 មេសា បំពេញសេវាកម្មឲ្យអតិថិជនតំលៃ $8,000 ដែលអតិថិជននឹងបង់ក្នុងរយៈពេល 30 ថ្ងៃ

13 មេសា បង់ $14,400 ដើម្បីទូទាត់ Trade Payables ដែលបានកើតឡើងនៅថ្ងៃទី03 ខែមេសា

19 មេសា បង់ $6,000 ជាសាច់ប្រាក់សម្រាប់ការធានារ៉ាប់រងរយៈពេល 6 ខែ

22 មេសា ទទួលលុយបាន $6,400 ជាផ្នែកមួយនៃការបង់ពីអតិថិជនដែលបានជំពាក់នៅថ្ងៃទី 09 ខែមេសា

25 មេសា បំពេញការងារជូនអតិថិជនមួយទៀតតំលៃ $2,640 ដោយជំពាក់

28 មេសា លោក Gary ដកសាច់ប្រាក់ $6,200 ដើម្បីចាយវាយផ្ទាល់ខ្លួន

29 មេសា ទិញសំភារៈការិយាល័យបន្ថែមតម្លៃ $800 ដោយជំពាក់

30 មេសា បង់ថ្លៃទឹកភ្លើងសម្រាប់ខែមេសា $700 ជាសាច់ប្រាក់

a) ចូរកត់ត្រាទិនានុប្បវត្ត (General Journal)

| No. | Date | Description | Dr. | Cr. |
|---|---|---|---|---|
| 1 | | | | |
| 2 | | | | |
| 3 | | | | |
| 4 | | | | |
| 5 | | | | |

| | | | | |
|---|---|---|---|---|
| 6 | | | | |
| 7 | | | | |
| 8 | | | | |
| 9 | | | | |
| 10 | | | | |
| 11 | | | | |
| 12 | | | | |

b) ចូរកត់ត្រាក្នុងគណនីសៀវភៅធំ (General Ledger)

Cash

Trade Receivables

Office Supplies

Office Equipment

Trade Payables

Capital

Drawings

Service Revenue

Insurance Expense

Rent Expense

| | |
|---|---|
| | |

Utilities Expense

| | |
|---|---|
| | |

## III. សំណួរត្រិះរិះ

1) ផ្អែកតាមព័ត៌មានដែលបានផ្តល់ តើប្រតិបត្តិការខាងក្រោមនេះ ត្រូវកត់ត្រានៅក្នុងបញ្ជីប្រចាំថ្ងៃមួយណា?
   a. ម្ចាស់ក្រុមហ៊ុនបានយករថយន្តរបស់ខ្លួន ទៅក្នុងដំណើរការរកស៊ីនរបស់ក្រុមហ៊ុន
   b. ក្រុមហ៊ុនបានទិញរថយន្តមួយគ្រឿងទៀតសម្រាប់ដំណើរការក្រុមហ៊ុន
   c. ក្រុមហ៊ុនបានលក់ទំនិញដោយជំពាក់ នូវទំនិញដែលបានទិញជាសាច់ប្រាក់កន្លងទៅ
   d. ក្រុមហ៊ុនបានបង្វិលទំនិញទៅអ្នកផ្គត់ផ្គង់វិញ ដោយសារមិនត្រឹមត្រូវតាមសំណើ
   e. ក្រុមហ៊ុនបានទិញកុំព្យូទ័រដោយជំពាក់ ក្នុងគោលបំណងទុកលក់វិញ
   f. ក្រុមហ៊ុនបានទូទាត់សាច់ប្រាក់ជូនអ្នកផ្គត់ផ្គង់ក្នុងការទិញទ្រព្យសកម្មរយៈវែង ដោយជំពាក់កន្លងទៅ
2) ផ្អែកតាមព័ត៌មានដែលបានផ្តល់ជូនខាងក្រោមនេះ ចូររៀបចំបញ្ជីលក់ទំនិញប្រចាំថ្ងៃ (Sales day book) និងបន្ទាប់មកកត់ត្រានៅក្នុងគណនីសៀវភៅធំដែលពាក់ព័ន្ធ៖

<u>២០២១</u>

០៣ មករា លក់ទំនិញជូនក្រុមហ៊ុន I ក្នុងតម្លៃ$197
០៦ មករា លក់ទំនិញជូនក្រុមហ៊ុន T ក្នុងតម្លៃ$224
០៩ មករា លក់ទំនិញជូនក្រុមហ៊ុន J ក្នុងតម្លៃ$96
១៤ មករា លក់ទំនិញជូនក្រុមហ៊ុន T ក្នុងតម្លៃ$302
១៩ មករា លក់ទំនិញជូនក្រុមហ៊ុន N ក្នុងតម្លៃ$561
២៤ មករា លក់ទំនិញជូនក្រុមហ៊ុន T ក្នុងតម្លៃ$177

3) ផ្អែកតាមព័ត៌មានដែលបានផ្តល់ជូនខាងក្រោមនេះ ចូររៀបចំបញ្ជីទិញទំនិញប្រចាំថ្ងៃ (Purchases day book) និងបន្ទាប់មកកត់ត្រានៅក្នុងគណនីសៀវភៅធំដែលពាក់ព័ន្ធ៖

**២០២១**

០២ មីនា ទិញទំនិញជូនក្រុមហ៊ុន A ក្នុងតម្លៃ$78
០៦ មីនា ទិញទំនិញជូនក្រុមហ៊ុន B ក្នុងតម្លៃ$118
០៩ មីនា ទិញទំនិញជូនក្រុមហ៊ុន C ក្នុងតម្លៃ$21
១៨ មីនា ទិញទំនិញជូនក្រុមហ៊ុន C ក្នុងតម្លៃ$65
២១ មីនា ទិញទំនិញជូនក្រុមហ៊ុន D ក្នុងតម្លៃ$43
៣១ មីនា ទិញទំនិញជូនក្រុមហ៊ុន B ក្នុងតម្លៃ$76

4) ផ្អែកតាមព័ត៌មានដែលបានផ្តល់ជូនខាងក្រោមនេះ ចូររៀបចំបញ្ជីសាច់ប្រាក់ប្រចាំថ្ងៃ (Cash day book) ដោយបែងចែកជាពីរ Cash receipt book និង Cash Payment book ។ បន្ទាប់មក ចូរកត់ត្រានៅក្នុងគណនីសៀវភៅធំដែលពាក់ព័ន្ធ។

**២០២១**

០១ កុម្ភៈ សមតុល្យដើមគ្រា មាតម្លៃ$505
០២ កុម្ភៈ បង់ថ្លៃជួលការិយាល័យតម្លៃ$240
០៦ កុម្ភៈ លក់ទំនិញជាសាច់ប្រាក់តម្លៃ$89
០៩ កុម្ភៈ សងប្រាក់អ្នកផ្គត់ផ្គង់ដែលបានជំពាក់ ចំនួន$110
១៨ កុម្ភៈ ម្ចាស់ក្រុមហ៊ុនបានដាក់ប្រាក់ក្នុងការរកស៊ីបន្ថែមចំនួន$430
២១ កុម្ភៈ ទូទាត់ប្រាក់បៀវត្សបុគ្គលិកចំនួន$135
២២ កុម្ភៈ ទទួលបានប្រាក់ចំណូលពីកម្រៃជើងសារចំនួន$76
២៥ កុម្ភៈ ទិញទំនិញជាសាច់ប្រាក់តម្លៃ$56
២៨ កុម្ភៈ បង់ថ្លៃភ្លើងតម្លៃ$23

5) នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៩ បញ្ជីសាច់ប្រាក់ (Cash Book) របស់ក្រុមហ៊ុន B មានសមតុល្យសាច់ប្រាក់ Cash Receipt $224 និង Cash Payment $336។ ក្នុងរយៈពេលមួយសប្តាហ៍ ត្រឹមថ្ងៃទី០៦ ខែឧសភា កើតមាននូវប្រតិបត្តិការខាងក្រោម៖

01 ឧសភា ក្រុមហ៊ុនបានលក់ទំនិញ $160 ទៅក្រុមហ៊ុន C ដោយជំពាក់

01 ឧសភា ក្រុមហ៊ុនបានដកសាច់ប្រាក់ $50 ពីធនាគារ សម្រាប់ទុកចំណាយរដ្ឋទេយ្យ

02 ឧសភា ក្រុមហ៊ុនបានទិញទំនិញពីក្រុមហ៊ុន A ដោយជំពាក់ $380 ដោយទទួលបានការបញ្ចុះតម្លៃ (Trade Discount) 15%

02 ឧសភា ក្រុមហ៊ុនបានសងបំណុលដែលបានជំពាក់ក្រុមហ៊ុន R ដោយទទួលបានការបញ្ចុះតម្លៃ (Cash Discount) ១០% ។ ការទូទាត់ត្រូវបានធ្វើដោយមូលប្បទានបត្រ។

03 ឧសភា ក្រុមហ៊ុន បានលក់ទំនិញជាសាច់ប្រាក់ $45

04 ឧសភា ក្រុមហ៊ុនបានលក់ទំនិញ $80 ទៅឱ្យក្រុមហ៊ុន M ដោយជំពាក់ និងផ្តល់ជូនការបញ្ចុះតម្លៃ 12.50% ប្រសិនបើទូទាត់សងក្នុងរយៈពេល 7 ថ្ងៃ។

04 ឧសភា ក្រុមហ៊ុនបានបង់ចំណាយទូរស័ព្ទ $210 ជាមូលប្បទានបត្រ

04 ឧសភា ក្រុមហ៊ុន បានទិញទំនិញ $400 ដោយជំពាក់ពីក្រុមហ៊ុន D

05 ឧសភា ក្រុមហ៊ុនទទួលបានការទូទាត់ជាមូលប្បទានបត្រពីក្រុមហ៊ុន H $180 ។ ក្រុមហ៊ុនទទួលបានការបញ្ចុះតម្លៃ $20 ពីការទូទាត់សាច់ប្រាក់នេះ។

05 ឧសភា ក្រុមហ៊ុនបានលក់ទំនិញ $304 ទៅឱ្យក្រុមហ៊ុន M ដោយជំពាក់

05 ឧសភា ក្រុមហ៊ុន បានទិញទំនិញ $135 ពីក្រុមហ៊ុន G ជាមូលប្បទានបត្រ

06 ឧសភា ក្រុមហ៊ុន ទទួលបានការទូទាត់ជាមូលប្បទានបត្រ $482 ពីក្រុមហ៊ុន D

06 ឧសភា ក្រុមហ៊ុន បានទិញទំនិញ $100 ដោយជំពាក់ពីក្រុមហ៊ុន G

ចូររៀបចំបញ្ជីកត់ត្រាប្រចាំថ្ងៃ (Books of Prime Entry)៖

a. Sales day book
b. Purchase day book
c. Cash receipt day book
d. Cash payment day book

6) ក្រុមហ៊ុន ABC បានកើតមានប្រតិបត្តិការសម្រាប់ខែមេសា ឆ្នាំ២០២១ ដូចខាងក្រោម៖

<u>2021</u>

01 April លោកសុខដែលជាម្ចាស់ក្រុមហ៊ុន ABC បានដាក់ទុនវិនិយោគផ្ទាល់ខ្លួនចំនួន $50,000 ជាសាច់ប្រាក់នៅគណនីធនាគាររបស់ក្រុមហ៊ុន។

02 April ក្រុមហ៊ុនបានទិញសម្ភារបរិក្ខារការិយាល័យចំនួន $3,500 ជាសាច់ប្រាក់។

05 April ក្រុមហ៊ុនបានទិញរថយន្តសម្រាប់ដឹកជញ្ជូនទំនិញចំនួន $12,000 ជាសាច់ប្រាក់។

06 April ក្រុមហ៊ុនបានទិញទំនិញទុកលក់វិញដោយជំពាក់ ក្នុងតម្លៃ $16,000 ។

09 April ក្រុមហ៊ុនទទួលបានវិក្កយបត្រជួលតម្លៃ $1,000។

10 April ក្រុមហ៊ុនបានលក់ទំនិញជូនអតិថិជនជាសាច់ប្រាក់ក្នុងតម្លៃ $8,000។

12 April ក្រុមហ៊ុនទទួលបានការបង្វិលទំនិញវិញពីអតិថិជន ចំនួន $500។

17 April ក្រុមហ៊ុនបានបង្វិលទំនិញទៅអ្នកផ្គត់ផ្គង់វិញ ក្នុងតម្លៃ $400។

20 April ក្រុមហ៊ុនបានទូទាត់ថ្លៃផ្សព្វផ្សាយពាណិជ្ជកម្មចំនួន $180។

25 April ក្រុមហ៊ុនបានទូទាត់ថ្លៃទឹកភ្លើង ចំនួន $200។

28 April ក្រុមហ៊ុនបានទូទាត់ប្រាក់បៀវត្សបុគ្គលិកចំនួន $1,600។

ផ្អែកលើព័ត៌មានខាងលើ ចូររៀបចំ៖

a. ការកត់ត្រាទិនានុប្បវត្តិ(Journal)
b. ការកត់ត្រាសៀវភៅធំ (Ledger)
c. សមតុល្យគណនីសៀវភៅធំ (Balance off)
d. តារាងតុល្យភាព (Trial Balance)
e. របាយការណ៍ចំណេញ/ខាត (SOPL) និងតារាងតុល្យការ (SOFP)

7) Sasha បានបង្កើតក្រុមហ៊ុនឯកកម្មសិទ្ធិ។ រាល់ការទិញទំនិញរបស់នាង ត្រូវបានកើតឡើងដោយជំពាក់។ នៅក្នុងខែកញ្ញា ឆ្នាំ២០១៩ នាងបានទិញទំនិញដូចខាងក្រោម៖

- ទំនិញតម្លៃ $450 ដោយអ្នកលក់បានផ្តល់នូវការបញ្ចុះតម្លៃ (Cash Discount) 2% ប្រសិនបើនាងទូទាត់សងក្នុងរយៈពេល ១៤ ថ្ងៃ ដែលទទួលបានការបញ្ចុះតម្លៃនេះ។
- ទំនិញពីអ្នកលក់ផ្សេងមួយទៀត ដែលនាងត្រូវបង់ប្រាក់ $114 បន្ទាប់ពីដកការបញ្ចុះតម្លៃ (Trade Discount) 5%។

Sasha ក៏បានលក់ទំនិញដោយជំពាក់ $1,000 ដោយនាងបានផ្តល់នូវការបញ្ចុះតម្លៃ (Cash Discount) 4% ហើយអតិថិជនទទួលបានការបញ្ចុះតម្លៃនេះ។

ចូរគណនារក Sale Discount និង Purchase discount សម្រាប់ខែកញ្ញា ឆ្នាំ២០១៩ របស់ក្រុមហ៊ុន Sasha ?

# មេរៀនទី៥៖ ពន្ធលើការលក់ទំនិញ/ផ្គត់ផ្គង់សេវា (អាករតម្លៃបន្ថែម)
## (Chapter 5: Sales Tax (Value Added Tax))

គោលបំណងនៃមេរៀនទី៥ នេះ ផ្តោតលើ៖

- ការកត់ត្រាទ្វេភាគសម្រាប់ពន្ធលើការលក់ទំនិញ/ផ្គត់ផ្គង់សេវា
- ការរៀបចំវិក្កយបត្រសម្រាប់ការលក់ទំនិញ/ផ្គត់ផ្គង់សេវាជាប់អាករតម្លៃបន្ថែម។

ក្រោយបញ្ចប់មេរៀនទី៥ នេះ យើងអាច៖

- ស្គាល់អាករតម្លៃបន្ថែម (VAT)
- គណនាតម្លៃអាករតម្លៃបន្ថែមនៅក្នុងវិក្កយបត្រ
- ស្គាល់អាករតម្លៃបន្ថែមជាតុចូល (VAT Input) និង អាករតម្លៃបន្ថែមជាតុចេញ (VAT Output) ព្រមទាំងការរៀបចំបង់ប្រាក់ពន្ធ (VAT) ជូនរដ្ឋ
- កត់ត្រាទ្វេភាគសម្រាប់ពន្ធលើការលក់ទំនិញ/ផ្គត់ផ្គង់សេវា
- គណនាអាករតម្លៃបន្ថែម ក្នុងករណីមានការលក់បញ្ចុះតម្លៃ។

### ៥.១. សេចក្តីផ្តើម

ពន្ធលើការលក់ទំនិញ/ផ្គត់ផ្គង់សេវា គឺជាពន្ធប្រយោលដែលត្រូវអនុវត្តលើការលក់ទំនិញ ឬផ្គត់ផ្គង់សេវា។ នៅក្នុងប្រទេសកម្ពុជា, ពន្ធលើការលក់ទំនិញ/ផ្គត់ផ្គង់សេវា ត្រូវកំណត់ថា អាករតម្លៃបន្ថែម (Value Added Tax) ឬហៅកាត់យ៉ាងខ្លីថា អតប (VAT) ដែលមានអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការក្នុងការគ្រប់គ្រងប្រមូលពន្ធជូនរដ្ឋ។ អត្រាពន្ធ សម្រាប់អាករតម្លៃបន្ថែម រួមមាន៖[3]

- ១០% សម្រាប់ទំនិញនាំចូលនិងការផ្គត់ផ្គង់ក្នុងស្រុក
- 0% សម្រាប់ការនាំចេញ

អាជីវកម្មដែលជាប់ពន្ធតាមរបបស្វ័យប្រកាស និងធ្វើការផ្គត់ផ្គង់ជាប់អាករ ចាំបាច់ត្រូវចុះបញ្ជីអាករតម្លៃបបន្ថែម នៅអគ្គនាយដ្ឋានពន្ធដារ និងបន្ទាប់មកត្រូវធ្វើការបង់ពន្ធជូនរដ្ឋទៅតាមពេលវេលាជាទៀតទាត់ តាមច្បាប់ពន្ធដារកំណត់។

អាករតម្លៃបន្ថែម គឺជាប្រភេទពន្ធបូកបន្ត ដែលត្រូវប្រមូលនៅតាមដំណាក់កាលនៃការលក់ទំនិញ ឬផ្គត់ផ្គង់សេវា ពេញមួយវដ្តជីវិតនៃទំនិញ ឬសេវានោះ។ ខាងក្រោមនេះ គឺជាឧទាហរណ៍ដែលក្រុមហ៊ុនផលិតសំលៀកបំពាក់ទិញក្រណាត់ជាវត្ថុធាតុដើម និងធាតុចូលផ្សេងៗទៀត។ ក្រោយមក ក្រុមហ៊ុនបានលក់សំលៀកបំពាក់ជូនក្រុមហ៊ុនបោះដុំ ដែលត្រូវលក់បន្តជូនក្រុមហ៊ុនលក់រាយ ហើយចុងបញ្ចប់

[3] ច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ១៩៩៧ មាត្រា៦៤

សំលៀកបំពាក់ត្រូវលក់ជូនអតិថិជនប្រើប្រាស់ចុងក្រោយ។ សន្មតថាគ្រប់ទំនិញទាំងអស់ជាប់អត្រា VAT ១០%។

| | តម្លៃមុនបង់ពន្ធ | VAT 10% | តម្លៃសរុប |
|---|---|---|---|
| | $ | $ | $ |
| (a)(i) ក្រុមហ៊ុនផលិតទិញក្រណាត់និងធាតុចូលផ្សេងទៀត | 100 | 10 | 110 |
| (ii) ក្រុមហ៊ុនផលិតបានលក់សំលៀកបំពាក់ជូនក្រុមហ៊ុនបោះដុំ | 300 | 30 | 330 |
| ក្រុមហ៊ុនផលិតត្រូវបង់ពន្ធជូនរដ្ឋចំនួន | | 20 | |
| (b)(i) ក្រុមហ៊ុនបោះដុំបានទិញសំលៀកបំពាក់ពីក្រុមហ៊ុនផលិត | 300 | 30 | 330 |
| (ii) ក្រុមហ៊ុនបោះដុំបានលក់សំលៀកបំពាក់ជូនក្រុមហ៊ុនលក់រាយ | 450 | 45 | 450 |
| ក្រុមហ៊ុនបោះដុំត្រូវបង់ពន្ធជូនរដ្ឋចំនួន | | 15 | |
| (c) (i) ក្រុមហ៊ុនលក់រាយបានទិញសំលៀកបំពាក់ពីក្រុមហ៊ុនបោះដុំ | 450 | 45 | 450 |
| (ii) ក្រុមហ៊ុនលក់រាយបានលក់ទំនិញជូនអតិថិជនប្រើប្រាស់ | 600 | 60 | 660 |
| ក្រុមហ៊ុនលក់រាយត្រូវបង់ពន្ធជូនរដ្ឋចំនួន | | 15 | |
| (d) អតិថិជនបានទិញសំលៀកបំពាក់ប្រើប្រាស់ | 600 | 60 | 660 |

ដូចនេះ ពន្ធសរុបដែលត្រូវបង់ជូនរដ្ឋលើការផលិត និងលក់សំលៀកបំពាក់នេះ សរុបចំនួន $60 ប៉ុន្តែការបង់ត្រូវធ្វើជាដំណាក់កាលដូចខាងក្រោម៖

| | $ |
|---|---|
| ក្រុមហ៊ុនលក់វត្ថុធាតុដើម | 10 |
| ក្រុមហ៊ុនផលិតសំលៀកបំពាក់ | 20 |
| ក្រុមហ៊ុនបោះដុំសំលៀកបំពាក់ | 15 |
| ក្រុមហ៊ុនលក់រាយសំលៀកបំពាក់ | 15 |
| អាករតម្លៃបន្ថែមសរុប (VAT) ដែលត្រូវបង់ជូនរដ្ឋ | 60 |

ប៉ុន្តែក្រុមហ៊ុនទាំងនេះ មិនមែនជាអ្នកចំណាយលើការបង់ពន្ធជូនរដ្ឋ $60 នេះទេ។ អតិថិជនដែលបានទិញសំលៀកបំពាក់ ដើម្បីប្រើប្រាស់ ទៅវិញទេ ជាអ្នកដែលត្រូវចំណាយបង់ពន្ធជូនរដ្ឋ $60។

## ៥.២. ការគណនា Input VAT និង Output VAT

រាល់ក្រុមហ៊ុនដែលបានចុះបញ្ជី VAT នៅអគ្គនាយដ្ឋានពន្ធដារ នឹងត្រូវគិតពន្ធ (Output VAT) លើការលក់ទំនិញឬផ្គត់ផ្គង់សេវា ហើយត្រូវរងការគិតពន្ធ (Input VAT) លើការទិញទំនិញ ឬទទួលសេវា ពីក្រុមហ៊ុនផ្គត់ផ្គង់ដែលបានចុះបញ្ជី VAT ដូចគ្នា។ ដូចនេះ VAT ដែលបានគិតបន្ថែមទៅលើតម្លៃទំនិញឬសេវាដែលក្រុមហ៊ុនបានលក់ ហៅថា Output VAT ចំណែកឯ VAT ដែលត្រូវបង់បន្ថែមទៅលើតម្លៃទំនិញឬសេវាដែលក្រុមហ៊ុនបានទិញ ហៅថា Input VAT។

ដើម្បីគណនារក VAT អ្នកត្រូវដឹងអំពីតម្លៃនៅក្នុងវិក្កយបត្រជាតម្លៃរួមបញ្ចូលទាំងពន្ធ (Inclusive of VAT) ឬក៏ជាតម្លៃមិនរួមបញ្ចូលពន្ធ (Exclusive of VAT)។

**ឧទាហរណ៍៖** តម្លៃនៃការទិញទំនិញសុទ្ធ (មិនរួមបញ្ចូលពន្ធ) $100 ហើយជាប់អត្រាពន្ធ VAT ចំនួន 10% នោះយើងបាន៖

| | |
|---|---|
| តម្លៃទំនិញសុទ្ធ (មិនរួមបញ្ចូលពន្ធ) | $100 |
| VAT ($100 x 10%) | $10 |
| តម្លៃទំនិញដុល(រួមបញ្ចូលពន្ធ) | $110 |

**ចំណាំ៖** ក្នុងករណីដែលគេឱ្យតម្លៃទំនិញ ជាតម្លៃដុល(រួមបញ្ចូលពន្ធ) ហើយយើងតម្រូវឱ្យគណនារកតម្លៃសុទ្ធ(មិនរួមបញ្ចូលពន្ធ) ឬតម្លៃពន្ធ(VAT) នោះយើងត្រូវ៖

គណនារកតម្លៃសុទ្ធ(មិនរួមបញ្ចូលពន្ធ) = តម្លៃដុល(រួមបញ្ចូលពន្ធ)/ (1+អត្រាពន្ធ)

**ឧទាហរណ៍៖** តម្លៃនៃការលក់ទំនិញដុល(រួមបញ្ចូលពន្ធ) $165 ដែលទំនិញនេះជាប់ VAT 10% នោះ៖ តម្លៃទំនិញសុទ្ធ (មិនរួមបញ្ចូលពន្ធ)= $165/(1+10%) = $150 និង VAT = $165-$150= $15 ។

**អនុវត្ត៖** ខាងក្រោមជាព័ត៌មានដែលពាក់ព័ន្ធអាករតម្លៃបន្ថែម (VAT) របស់ក្រុមហ៊ុន EVA សម្រាប់ខែមិថុនា ២០១៩៖

| | $ |
|---|---|
| Sale (including VAT) | 109,250 |
| Purchase (net of VAT) | 64,000 |

អត្រា VAT ស្មើនឹង 10% ។ ចូរគណនា៖ a) Output VAT b) Input VAT

## ៥.៣. ការកត់ត្រាទ្វេភាគសម្រាប់អាករតម្លៃបន្ថែម

### ៥.៣.១. ការកត់ត្រា Dr. និង Cr.

ការកត់ត្រាទ្វេភាគសម្រាប់ការទិញឬលក់ទំនិញជាប់អាករតម្លៃបន្ថែម អាចត្រូវបានកែសម្រួលដោយបន្ថែមគណនីអាករតម្លៃបន្ថែម (VAT)។ នៅក្នុងបញ្ជីកត់ត្រាដំបូង ក៏អាចត្រូវបន្ថែមព័ត៌មានអាករតម្លៃបន្ថែមផងដែរ មុនពេលកត់ត្រានៅក្នុងសៀវភៅធំ។

អាករតម្លៃបន្ថែម ត្រូវបានប្រមូល ដោយក្រុមហ៊ុនដែលបានចុះបញ្ជី VAT ជាមួយអគ្គនាយកដ្ឋានពន្ធដារ ហើយក្រុមហ៊ុនទាំងនោះ ត្រូវរៀបចំបញ្ជីប្រចាំខែ ដើម្បីបង់បន្តទៅអគ្គនាយកដ្ឋានពន្ធដារ។ ដូចនេះ វិក្កយបត្រទិញ-លក់ ត្រូវបង្ហាញតម្លៃអាករតម្លៃបន្ថែមផងដែរ។ ប៉ុន្តែនៅក្នុងការកត់ត្រា យើងចាំបាច់ត្រូវបង្ហាញតែតម្លៃលក់សុទ្ធ (មិនបញ្ចូលតម្លៃអាករតម្លៃបន្ថែម) ប៉ុណ្ណោះ នៅក្នុងគណនីលក់ (Sales Account) គណនីទិញ (Purchase Account) និងគណនីបង្វិលទំនិញ (Return Accounts) ដូចបង្ហាញខាងក្រោម៖

- <u>ការលក់ទំនិញ</u>

    Dr. Trade Receivables (gross amount) $x
    Cr. Sales (net amount) $x
    Cr. VAT Account $x

- <u>ការទិញទំនិញ</u>

    Dr. Purchase (net amount) $x
    Dr. VAT Account (VAT input) $x
    Cr. Trade Payables (gross amount) $x

- <u>ការបង្វិលទំនិញពីអតិថិជនវិញ (Return Inwards)</u>

    Dr. Returns inwards (net amount) $x
    Dr. VAT account (តម្លៃ VAT លើទំនិញបង្វិល) $x
    Cr. Trade receivables (gross amount) $x

- <u>ការបង្វិលទំនិញទៅអ្នកផ្គត់ផ្គង់វិញ (Return Outwards)</u>

    Dr. Trade payables (gross amount) $x
    Cr. Returns outwards (net amount) $x
    Cr. VAT account (តម្លៃ VAT លើទំនិញបង្វិល) $x

<u>**ចំណាំ៖**</u> ក្នុងករណីដែលការទិញទំនិញពីក្រុមហ៊ុនដែលមិនបានចុះបញ្ជី VAT នៅអគ្គនាយកដ្ឋានពន្ធដារ ការកត់ត្រា នឹងត្រូវធ្វើឡើងដូចធម្មតា ពោលគឺ៖ Dr. Purchase (gross amount) និង Cr. Trade Payables (Gross amount) ។

## ៥.៣.២. បញ្ជីកត់ត្រាប្រចាំថ្ងៃ

ខាងក្រោមជាការបង្ហាញការកត់ត្រានៅក្នុងបញ្ជីកត់ត្រាប្រចាំថ្ងៃពាក់ព័ន្ធការទិញ-លក់ទំនិញ៖

- <u>Sales Day Book</u>

    នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២១ ក្រុមហ៊ុនបានលក់ទំនិញជូនក្រុមហ៊ុន G Charman ដោយជំពាក់ តម្លៃសរុប $220 រួមបញ្ចូលទាំងពន្ធ 10% នោះការកត់ត្រានៅក្នុង Sales Day Book ត្រូវបានបង្ហាញដូចខាងក្រោម៖

Sales Day Book

| 2021 | | Net | VAT | Gross |
|---|---|---|---|---|
| | | $ | $ | $ |
| 01 May | G Charman | 200 | 20 | 220 |
| … | | … | … | … |
| ចំនួនទឹកប្រាក់សរុបដែលត្រូវចុះក្នុងសៀវភៅធំ | | 200 | 20 | 220 |

- <u>Purchases Day Book</u>

  នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២១ ក្រុមហ៊ុនបានទិញទំនិញពីក្រុមហ៊ុន H Wilde ដោយជំពាក់ តម្លៃសរុប $165 រួមបញ្ចូលទាំងពន្ធ 10% នោះការកត់ត្រានៅក្នុង Purchase Day Book ត្រូវបានបង្ហាញដូចខាងក្រោម៖

Purchases Day Book

| 2021 | | Net | VAT | Gross |
|---|---|---|---|---|
| | | $ | $ | $ |
| 02 May | H Wilde | 150 | 15 | 165 |
| … | | … | … | … |
| ចំនួនទឹកប្រាក់សរុបដែលត្រូវចុះក្នុងសៀវភៅធំ | | 150 | 15 | 165 |

- <u>Returns Inwards Day Book</u>

  នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ ក្រុមហ៊ុន G Charman បានបង្វិលទំនិញដែលបានទិញមកក្រុមហ៊ុនវិញ ក្នុងតម្លៃសរុប $55 រួមបញ្ចូលទាំងពន្ធ 10% នោះការកត់ត្រានៅក្នុង Returns Inwards Day Book ត្រូវបានបង្ហាញដូចខាងក្រោម៖

Returns Inwards Day Book

| 2021 | | Net | VAT | Gross |
|---|---|---|---|---|
| | | $ | $ | $ |
| 03 May | G Charman | 50 | 5 | 55 |
| … | | … | … | … |
| ចំនួនទឹកប្រាក់សរុបដែលត្រូវចុះក្នុងសៀវភៅធំ | | 50 | 5 | 55 |

- <u>Returns Outwards Day Book</u>

  នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ ក្រុមហ៊ុន បានបង្វិលទំនិញដែលបានទិញ ទៅក្រុមហ៊ុន H Wilde វិញ ក្នុងតម្លៃសរុប $44 រួមបញ្ចូលទាំងពន្ធ 10% នោះការកត់ត្រានៅក្នុង Returns Outwards Day Book ត្រូវបានបង្ហាញដូចខាងក្រោម៖

Returns Outwards Day Book

| 2021 | | Net | VAT | Gross |
|---|---|---|---|---|
| | | $ | $ | $ |
| 04 May | H Wilde | 40 | 4 | 44 |
| … | | … | … | … |
| ចំនួនទឹកប្រាក់សរុបដែលត្រូវចុះក្នុងសៀវភៅធំ | | 40 | 4 | 44 |

### ៥.៣.៣. បញ្ជីសៀវភៅធំ (General Ledger)

ខាងក្រោមនេះ យើងនឹងបង្ហាញការកត់ត្រាជារួមនៅក្នុង គណនីសៀវភៅធំតែម្តង ដោយពុំបានបង្ហាញការកត់ត្រានៅក្នុងបញ្ជីអតិថិជន ឬអ្នកផ្គត់ផ្គង់ម្នាក់ៗនោះទេ។

គណនីការលក់ (Sales Account)

| 2021 | | $ | 2021 | | $ |
|---|---|---|---|---|---|
| | | | 30 May | Total of the month | 200 |

គណនីការទិញ (Purchases Account)

| 2021 | | $ | 2021 | | $ |
|---|---|---|---|---|---|
| 30 May | Total of the month | 150 | | | |

គណនី Returns Inwards

| 2021 | | $ | 2021 | | $ |
|---|---|---|---|---|---|
| 30 May | Total of the month | 50 | | | |

គណនី Returns Outwards

| 2021 | | $ | 2021 | | $ |
|---|---|---|---|---|---|
| | | | 30 May | Total of the month | 40 |

គណនីអាករតម្លៃបន្ថែម (VAT)

| 2021 | | $ | 2021 | | $ |
|---|---|---|---|---|---|
| 30 May | VAT on purchase | 15 | 30 May | VAT on sales | 20 |
| 30 May | VAT on returns inwards | 5 | 30 May | VAT on returns outwards | 4 |
| 30 May | Balance c/d | 4 | | | |
| | | 24 | | | 24 |
| | | | 01 Jun | Balance b/d | 4 |

ចំនួនទឹកប្រាក់សមតុល្យរបស់គណនីអាករតម្លៃតម្លៃបន្ថែម (VAT) មានន័យថា ក្រុមហ៊ុនបានកំពុងជំពាក់ប្រាក់ពន្ធដែលនឹងត្រូវបង់ជូនអគ្គនាយដ្ឋានពន្ធដារ។ ចំនួនទឹកប្រាក់នេះ បានមកពីអាករតម្លៃបន្ថែមជាតុចេញ (Output VAT) ដកនឹងអាករតម្លៃបន្ថែមជាតុចូល (Input VAT)។ ទឹកប្រាក់ដែលជំពាក់រដ្ឋនេះ ចាត់ទុកថាជាប្រភេទគណនីបំណុលរយៈពេលខ្លី (Current Liability)។ រហូតដល់

ពេលដែលក្រុមហ៊ុនធ្វើការបង់ប្រាក់ពន្ធដែលជំពាក់ជូនរដ្ឋ នោះការកត់ត្រា នឹងត្រូវធ្វើដូចខាងក្រោម (ឧទាហរណ៍ ប្រាក់ពន្ធដែលជំពាក់រដ្ឋ $4 ត្រូវបង់នៅថ្ងៃទី ១៥ មិថុនា ២០២១)៖

គណនីអាករតម្លៃបន្ថែម (VAT)

| | | | | | |
|---|---|---|---|---|---|
| 2021 | | $ | 2021 | | $ |
| 15 Jun | Cash | 4 | 01 Jun | Balance b/d | 4 |

**<u>អនុវត្ត៖</u>** នៅក្នុងខែមេសា ឆ្នាំ២០២១ ក្រុមហ៊ុន G បានទទួលអាករតម្លៃបន្ថែម (Output VAT) ពីការលក់ប្រចាំខែមេសា ចំនួន $4,000 និងបានទូទាត់អាករតម្លៃបន្ថែម (Input VAT) ទៅក្រុមហ៊ុនផ្គត់ផ្គង់ លើការទិញទំនិញប្រចាំខែមេសា ចំនួន $3,500 ដែលក្នុងនោះ មានអាករតម្លៃបន្ថែមចំនួន $250 បានបង់ទៅក្រុមហ៊ុនផ្គត់ផ្គង់មានលេខបញ្ជី VAT នៅអគ្គនាយកដ្ឋានពន្ធដារ។ ចូររៀបចំ គណនីសៀវភៅធំ សម្រាប់គណនីអាករតម្លៃបន្ថែម?

គណនីអាករតម្លៃបន្ថែម (VAT)

| | | | | | |
|---|---|---|---|---|---|
| 2021 | | $ | 2021 | | $ |
| 30 Apr | Balance c/d | ___ | | | ___ |
| | | | 01 May | Balance b/d | |

## ៥.៤. ប្រភេទផ្សេងទៀតនៃប្រតិបត្តិការពាក់ព័ន្ធនឹងអាករតម្លៃបន្ថែម

### ៥.៤.១. ការទិញទ្រព្យសកម្មរយៈពេលវែង

ពន្ធ VAT ផងដែរក៏ត្រូវបានបង់ សម្រាប់ទ្រព្យសកម្មរយៈពេលវែង ដែលក្រុមហ៊ុនបានទិញ ឬចំណាយផ្សេងៗទៀត ដើម្បីដំណើរការអាជីវកម្ម។ សម្រាប់ប្រភេទអាជីវកម្មមួយចំនួន អាចធ្វើការស្នើសុំត្រឡប់មកវិញបាននូវទឹកប្រាក់បង់ពន្ធ VAT រួចហើយលើការទិញទ្រព្យសកម្មរយៈពេលវែង ដោយត្រូវកាត់កងជាមួយអាករតម្លៃបន្ថែមជាតុចេញ (Output VAT) ដោយយោងតាមបទបញ្ញត្តិដែលមានជាធរមាន។ ខាងក្រោមនេះជាឧទាហរណ៍ សម្រាប់ការទិញទ្រព្យសកម្មរយៈពេលវែង៖

ប្រសិនបើម៉ាស៊ីនមួយ មានតម្លៃ $5,000 (មិនបញ្ចូល VAT), តម្លៃពន្ធ VAT គឺស្មើនឹង $500 (10% នៃ $5,000) ។ ប្រសិនបើក្រុមហ៊ុនអាចស្នើសុំទូទាត់ត្រឡប់មកវិញនូវប្រាក់ពន្ធដែលបានបង់នេះ ការកត់ត្រា គួរត្រូវបានធ្វើដូចខាងក្រោម៖

| | | |
|---|---|---|
| Dr. Machinery | $5,000 | |
| Dr. VAT (input VAT) | $500 | |
| Cr. Cash/Payables | | $5,500 |

ប៉ុន្តែប្រសិនបើប្រាក់ពន្ធ VAT នោះ មិនអាចស្នើសុំទូទាត់សងត្រឡប់មកវិញបាន នោះការកត់ត្រា៖

| | | |
|---|---|---|
| Dr. Machinery | $5,500 | |
| Cr. Cash/Payables | | $5,500 |

## ៥.៤.២. ការលក់ជាសាច់ប្រាក់ និងការចំណាយជាសាច់ប្រាក់ដទៃទៀត

ប្រាក់ពន្ធ VAT ដែលបានប្រមូលក្នុងការលក់ទំនិញ/ផ្តល់ផ្គត់សេវាជាសាច់ប្រាក់ (Cash Sales) ត្រូវរៀបចំកត់ត្រាដូចគ្នានឹងការលក់ទំនិញ/ផ្តល់ផ្គត់សេវាដោយជំពាក់ (sales ledger) ។ ចំណែកឯ, ប្រាក់ពន្ធ VAT ដែលបានបង់នៅពេលក្រុមហ៊ុនធ្វើការចំណាយ(ចំណាយរដ្ឋទេយ្យ ឬចំណាយផ្សេងៗទៀត) គឺអាចធ្វើការស្នើសុំទូទាត់សងត្រឡប់មកវិញបានដូចគ្នានឹងការទិញទំនិញ/សេវា(purchases ledger) ផងដែរ។ សម្រាប់ការកត់ត្រា នឹងបង្ហាញនៅក្នុងឧទាហរណ៍ខាងក្រោម៖

ក្រុមហ៊ុន K បានកើតមាននូវការលក់ទំនិញជាសាច់ប្រាក់សម្រាប់ខែមេសា ឆ្នាំ២០១៩ សរុបចំនួន $4,000 និងកើតមានចំណាយលើការបង់សេវាទូរសព្ទចំនួន $100 (តម្លៃមិនទាន់បញ្ចូលពន្ធ VAT)។ សន្មតថា អត្រាពន្ធ ស្មើនឹង 10% នោះការកត់ត្រាបង្ហាញដូចខាងក្រោម៖

- Cash sales

| | | |
|---|---|---|
| Dr. Cash | $4,400 | |
| Cr. Sales Income | | $4,000 |
| Cr. VAT (Output VAT) | | $400 |

- **ចំណាយផ្សេងៗទៀត (ប្រសិនបើក្រុមហ៊ុនអាចស្នើសុំទូទាត់ត្រឡប់មកវិញនូវប្រាក់ពន្ធដែលបានបង់នេះ**

| | | |
|---|---|---|
| Dr. Telephone expense | $100 | |
| Dr. VAT (Input VAT) | $10 | |
| Cr. Cash | | $110 |

**<u>អនុវត្ត៖</u>** ព័ត៌មានខាងក្រោម ត្រូវបានដកស្រង់ចេញពីបញ្ជីកត់ត្រាប្រចាំថ្ងៃ៖

| ទឹកប្រាក់សុទ្ធ (មុនពេលបូកបន្ថែម VAT) សម្រាប់ខែមីនា ឆ្នាំ២០២០ | $ |
|---|---|
| Sales for the month | 3,240 |
| Purchase for the month | 2,850 |
| Returns inwards for the month | 214 |
| Returns outwards for the month | 180 |

គេឱ្យព័ត៌មានបន្ថែមដូចខាងក្រោម៖

(i) នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២០ សមតុល្យនៅក្នុងគណនី VAT ខាងឥណទាន មានចំនួន $320 ។

(ii) ការលក់ទំនិញជាសាច់ប្រាក់រួមបញ្ចូលទាំងពន្ធ VAT សម្រាប់ខែមីនា មានចំនួនសរុប $1,270 ។

(iii) ចំណាយរដ្ឋទេយ្យដែលបានកើតមានក្នុងខែមីនានេះ មានចំនួនសរុប $123 ដោយរួមបញ្ចូលទាំងប្រាក់ពន្ធ VAT ហើយប្រាក់ពន្ធដែលបានបង់នេះ អាចស្នើសុំទូទាត់មកវិញបាន។

ចូររៀបចំគណនីអាករតម្លៃបន្ថែម (VAT)? សន្មតថា អត្រា VAT = 17.5% ។

គណនីអាករតម្លៃបន្ថែម (VAT)

| 2020 | | $ | 2020 | | $ |
|---|---|---|---|---|---|
| 31 Mar | VAT on purchase | ……. | 01 Mar | Balance b/d | ……… |
| 31 Mar | VAT on returns inwards | ……… | 31 Mar | VAT on sales | ……… |
| 31 Mar | VAT on petty cash exp. | …….. | 31 Mar | VAT on returns outwards | ……… |
| 31 Mar | Balance c/d | …….. | 31 Mar | VAT on cash sales | ……… |
| | | …….. | | | ………. |
| | | | 01 Apr | Balance b/d | ………. |

## ៥.៥. ទំនាក់ទំនងនៃការបញ្ចុះតម្លៃ និងអាករតម្លៃបន្ថែម (Discount and VAT)

ដូចបានបង្ហាញនៅក្នុងមេរៀនដែលបានសិក្សាកន្លងទៅ, ការបញ្ចុះតម្លៃ ត្រូវបានបែងចែកជាពីរពោលគឺ៖ Trade Discount និង Cash Discount ។ សម្រាប់ Trade Discount, ការកត់ត្រាមិនបានបង្ហាញក្នុងគណនីណាមួយឡើយ ដោយសារតម្លៃកត់ត្រាការទិញ-លក់ទំនិញ ត្រូវប្រើតម្លៃក្រោយការបញ្ចុះតម្លៃ (Trade Discount)។ ចំណែកឯ, Cash Discount ត្រូវបានកត់ត្រាដាច់ដោយឡែកនៅក្នុងគណនី Sales discount ឬ Purchases discount ។

ដូចនេះប្រសិនបើប្រតិបត្តិការកើតឡើងពាក់ព័ន្ធនឹងពន្ធ VAT ការបញ្ចុះតម្លៃ(Cash Discount) គួរត្រូវបានដកចេញពីតម្លៃវិក្កយបត្រ មុនពេលគិតប្រាក់ពន្ធដែលត្រូវបង់។ ខាងក្រោមជាឧទាហរណ៍បង្ហាញអំពីទំនាក់ទំនងនៃការបញ្ចុះតម្លៃ និងអាករតម្លៃបន្ថែម៖

ក្រុមហ៊ុនបានលក់ទំនិញតម្លៃ $750 ជូនអតិថិជន ប៉ុន្តែក្រុមហ៊ុនបានអនុញ្ញាតឱ្យមាន Trade Discount ចំនួន 20% ។ ក្រុមហ៊ុនបានផ្តល់ផងដែរនូវ Cash Discount ចំនួន 5% ប្រសិនបើអតិថិជនទូទាត់ប្រាក់ភ្លាមៗ ។ តើតម្លៃវិក្កយបត្រសរុបសម្រាប់ការលក់ទំនិញ ស្មើនឹងប៉ុន្មាន?

**ចម្លើយ៖**

ជំហានទី១៖ រកតម្លៃទំនិញក្រោយបញ្ចុះតម្លៃ Trade Discount (20%)

$750 – (20%x$750) = $600

ជំហានទី២៖ រកតម្លៃទំនិញក្រោយបញ្ចុះតម្លៃ Cash Discount (5%)

$600 – (5%x$600) = $570

ជំហានទី៣៖ រកតម្លៃពន្ធ VAT (10%)

VAT = $570 x 10% = $57

ជំហានទី៤៖ រកតម្លៃទំនិញដែលត្រូវបង្ហាញក្នុងវិក្កយបត្រទិញ-លក់

- ថ្លៃចេញវិក្កយបត្រ (ប្រសិនអតិថិជនមិនទាន់បង់ប្រាក់ភ្លាម)
  Price shown in invoice = $600 + $57 = $657
- ក្នុងករណីប្រសិនបើអតិថិជនបង់ប្រាក់ភ្លាមៗ នោះទទួលបាន Cash discount តម្លៃទំនិញដែលអតិថិជនត្រូវបង់ = $570 + $57 = $627

**ចំណាំ៖**

a. ការគណនារកតម្លៃពន្ធ VAT ត្រូវធ្វើឡើងបន្ទាប់ពីដកការបញ្ចុះតម្លៃទាំង Trade Discount និង Cash discount ប្រសិនបើមានទាំងពីរ។
b. តម្លៃទំនិញដែលត្រូវបង្ហាញនៅលើវិក្កយបត្រ ត្រូវយកតម្លៃទំនិញដកតែ Trade discount ប៉ុណ្ណោះ (មិនត្រូវដក Cash discount នោះទេ) មកបូកបញ្ចូលតម្លៃពន្ធដែលបានគណនាខាងលើ។

## ៥.៦. សេចក្តីសន្និដ្ឋាន

ជារួម VAT គឺពន្ធប្រយោលមួយប្រភេទដែលត្រូវអនុវត្តលើការលក់ទំនិញ ឬផ្គត់ផ្គង់សេវា ហើយសម្រាប់ប្រទេសកម្ពុជា, ពន្ធលើការលក់ទំនិញ/ផ្គត់ផ្គង់សេវា ត្រូវកំណត់ឈ្មោះថា អាករតម្លៃបន្ថែម (Value Added Tax) ឬហៅកាត់យ៉ាងខ្លីថា អតប (VAT)។ រាល់ក្រុមហ៊ុនដែលចុះបញ្ជី VAT ទើបអនុវត្តការកត់ត្រាដូចបង្ហាញនៅក្នុងមេរៀននេះ។ ចំណុចដែលត្រូវចងចាំ រួមមាន៖

- ពន្ធ VAT ត្រូវបានបែងចែកជាពីរ អាករតម្លៃបន្ថែមជាតុចេញ (Output VAT) និង អាករតម្លៃបន្ថែមជាតុចូល (Input VAT) ហើយអាករតម្លៃបន្ថែមជាតុចូលនេះ ត្រូវបានប្រើដើម្បីកាត់កងការបង់ប្រាក់ពន្ធ VAT ជូនរដ្ឋបាន តាមបទបញ្ញត្តិដែលមានជាធរមាន។
- ការគណនារកតម្លៃពន្ធ VAT៖
  - ពីតម្លៃទំនិញសុទ្ធ(មិនបញ្ចូលពន្ធ) នោះ VAT = Net Price x អត្រាពន្ធ
  - ប៉ុន្តែប្រសិនជាគិតពីតម្លៃដុល(បញ្ចូលពន្ធរួចហើយ) នោះ៖
    VAT = Gross Price x (អត្រាពន្ធ/(1+ អត្រាពន្ធ))
- ការគណនារកតម្លៃពន្ធ VAT ក្នុងករណីមានការបញ្ចុះតម្លៃ ត្រូវធ្វើឡើងបន្ទាប់ពីដកការបញ្ចុះតម្លៃទាំង Trade Discount និង Cash discount ប្រសិនបើមានទាំងពីរ។ ចំណែកឯ, តម្លៃទំនិញដែលត្រូវបង្ហាញនៅលើវិក្កយបត្រ ត្រូវយកតម្លៃទំនិញដកតែ Trade discount ប៉ុណ្ណោះ (មិនត្រូវដក Cash discount នោះទេ) មកបូកបញ្ចូលតម្លៃពន្ធដែលបានគណនាខាងលើ។

# លំហាត់៖

## I. សំណួរពហុជ្រើសរើស (MCQ)

1) តើពំនោលខាងក្រោមនេះ មួយណាត្រឹមត្រូវពាក់ព័ន្ធនឹងអាករតម្លៃបន្ថែម (VAT)?
   a. អាករតម្លៃបន្ថែម គឺជាពន្ធផ្ទាល់ដែលបានកំណត់លើការលក់ទំនិញ ឬផ្គត់ផ្គង់សេវា។
   b. អាករតម្លៃបន្ថែម គឺជាពន្ធប្រយោលដែលបានកំណត់លើការលក់ទំនិញ ឬផ្គត់ផ្គង់សេវា។
   c. ក្រុមហ៊ុនដែលបានចុះបញ្ជី VAT អាចស្នើសុំអាករតម្លៃបន្ថែមដែលខ្លួនបានបង់នៅពេលទិញទំនិញ មកវិញទាំងអស់។
   d. ចម្លើយទាំងបីខាងលើសុទ្ធតែត្រឹមត្រូវ។

2) ព័ត៌មានខាងក្រោមនេះ គឺពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ក្រុមហ៊ុន H សម្រាប់ខែឧសភា ឆ្នាំ ២០២១៖

| | $ |
|---|---|
| Sales (including VAT) | 120,000 |
| Purchases (net of VAT) | 65,000 |

គេឱ្យអត្រាពន្ធ VAT ស្មើនឹង ១០% តើតម្លៃអាករតម្លៃបន្ថែមជាតុចេញ (Output VAT) និងអាករតម្លៃបន្ថែមជាតុចូល (VAT Input) ស្មើនឹងប៉ុន្មាន?

   a. Output VAT=$12,000 Input VAT=$6,500
   b. Output VAT=$12,000 Input VAT=$5,909
   c. Output VAT=$10,909 Input VAT=$6,500
   d. Output VAT=$10,909 Input VAT=$5,909

3) លោកចិន្តា លក់ទំនិញ $6,000 ដោយត្រូវបង់ពន្ធ VAT $900 ពោលគឺមានតម្លៃសរុប $6,900។ តើការកត់ត្រាការលក់នេះ ត្រូវរួមបញ្ចូលនូវការកត់ត្រាមួយណាខាងក្រោម?
   a. Cr. គណនីអាករតម្លៃបន្ថែម (VAT) $900
   b. Cr. គណនីការលក់ (Sales) $6,900
   c. Dr. គណនីការលក់ (Sales) $6,000
   d. Dr. គណនីអាករតម្លៃបន្ថែម (VAT) $900

4) លោក Melissa បានបង្កើតក្រុមហ៊ុនមួយ ដោយពុំទាន់បានចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារដើម្បីបង់ពន្ធនៅឡើយ។ ថ្មីៗនេះ គាត់ទទួលបានវិក្កយបត្រទិញទំនិញមួយ ដែលមានតម្លៃ $500 មុនបង់ពន្ធ ដែលជាប់អត្រា VAT 17.50% ។ ដូចនេះ តម្លៃវិក្កយបត្រសរុប $587 ។

ការកត់ត្រាគណនេយ្យត្រឹមត្រូវមួយណាខាងក្រោម ដែលលោក Melissa ត្រូវធ្វើសម្រាប់វិក្កយបត្រមួយនេះ?

a. Dr. Purchases $500, Dr. Sale tax (VAT) $87, Cr. Payables $587
b. Dr. Purchases $587, Cr. Sales tax (VAT) $87, Cr. Payables $500
c. Dr. Purchases $500, Cr. Payables $500
d. Dr. Purchases $587, Cr. Payables $587

5) ការលក់ទំនិញសរុប (រួមទាំងអាករតម្លៃបន្ថែម VAT) $27,612.50 និងការទិញទំនិញសរុប (មិនបូកបញ្ចូលអាករតម្លៃបន្ថែម VAT) $18,000។ តើតម្លៃសមតុល្យគណនីអាករតម្លៃបន្ថែម (VAT Account) ស្មើប៉ុន្មាន? ប្រសិនបើអត្រាពន្ធ VAT ស្មើនឹង 17.5% ។
a. $962.50 ខាង Debit
b. $962.50 ខាង Credit
c. $1,682.10 ខាង Debit
d. $1,682.10 ខាង Credit

## II. ចូរបំពេញចន្លោះខាងក្រោម៖

1) ព័ត៌មានខាងក្រោម ត្រូវបានដកស្រង់ចេញពីបញ្ជីកត់ត្រាប្រចាំថ្ងៃ៖

| ទឹកប្រាក់សុទ្ធ (មុនពេលបូកបន្ថែម VAT) សម្រាប់ខែកក្កដា ឆ្នាំ២០២០ | $ |
|---|---|
| Sales for the month | 1,750 |
| Purchase for the month | 1,125 |
| Returns inwards for the month | 230 |
| Returns outwards for the month | 178 |

ចូរបំពេញចន្លោះនៅក្នុងគណនី VAT ខាងក្រោម៖

គណនីអាករតម្លៃបន្ថែម (VAT)

| 2020 | | $ | 2020 | | $ |
|---|---|---|---|---|---|
| 31 Jul | VAT on purchase | ……. | 31 Jul | VAT on sales | ……… |
| 31 Jul | VAT on returns inwards | …… | 31 Jul | VAT on returns outwards | ……… |
| 31 Jul | Balance c/d | …… | | | |
| | | …… | | | ……… |
| | | | 01 Aug | Balance b/d | ……… |

2) ព័ត៌មានខាងក្រោម ត្រូវបានដកស្រង់ចេញពីបញ្ជីកត់ត្រាប្រចាំថ្ងៃ៖

| ទឹកប្រាក់សុទ្ធ (មុនពេលបូកបន្ថែម VAT) សម្រាប់ខែតុលា ឆ្នាំ២០២០ | $ |
|---|---|
| Sales for the month | 12,560 |
| Purchase for the month | 8,790 |
| Returns inwards for the month | 256 |
| Returns outwards for the month | 670 |

ចូរបំពេញចន្លោះនៅក្នុងគណនី VAT ខាងក្រោម៖

គណនីអាករតម្លៃបន្ថែម (VAT)

| 2020 | | $ | 2020 | | $ |
|---|---|---|---|---|---|
| 31 Oct | VAT on purchase | ……… | 31 Oct | VAT on sales | ……… |
| 31 Oct | VAT on returns inwards | ……… | 31 Oct | VAT on returns outwards | ……… |
| 31 Oct | Balance c/d | ……… | | | |
| | | ……… | | | ……… |
| | | | 01 Nov | Balance b/d | ……… |

3) ព័ត៌មានខាងក្រោម ត្រូវបានដកស្រង់ចេញពីបញ្ជីកត់ត្រាប្រចាំថ្ងៃ៖

| ទឹកប្រាក់សុទ្ធ (មុនពេលបូកបន្ថែម VAT) សម្រាប់ខែមីនា ឆ្នាំ២០១៩ | $ |
|---|---|
| Sales for the month | 895 |
| Purchase for the month | 785 |
| Returns inwards for the month | 18 |
| Returns outwards for the month | 9 |

គេឱ្យព័ត៌មានបន្ថែមដូចខាងក្រោម៖

(i) សមតុល្យអាករតម្លៃបន្ថែម (VAT) នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៩ គឺ $26 ។

(ii) ក្រុមហ៊ុនបានបង់ពន្ធ VAT ជូនរដ្ឋ នៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៩ ចំនួន $145 ។

ចូរបំពេញចន្លោះនៅក្នុងគណនី VAT ខាងក្រោម៖

គណនីអាករតម្លៃបន្ថែម (VAT)

| 2019 | | $ | 2019 | | $ |
|---|---|---|---|---|---|
| 09 Mar | Cash book | ……… | 01 Mar | Balance b/d | ……… |
| 31 Mar | VAT on purchase | ……… | 31 Mar | VAT on sales | ……… |
| 31 Mar | VAT on returns inwards | ……… | 31 Mar | VAT on returns outwards | ……… |
| 31 Mar | Balance c/d | ……… | | | |
| | | ……… | | | ……… |
| | | | 01 Apr | Balance b/d | ……… |

4) ព័ត៌មានខាងក្រោម ត្រូវបានដកស្រង់ចេញពីបញ្ជីកត់ត្រាប្រចាំថ្ងៃ៖

| ទឹកប្រាក់សុទ្ធ (មុនពេលបូកបន្ថែម VAT) សម្រាប់ខែមិថុនា ឆ្នាំ២០២០ | $ |
|---|---|
| Sales for the month | 7,450 |
| Purchase for the month | 5,780 |
| Returns inwards for the month | 874 |
| Returns outwards for the month | 1,010 |

គេឱ្យព័ត៌មានបន្ថែមដូចខាងក្រោម៖

(i) ការលក់ទំនិញជាសាច់ប្រាក់រួមបញ្ចូលទាំងពន្ធ VAT សម្រាប់ខែមិថុនា មានចំនួនសរុប $985 ។

(ii) ទ្រព្យសកម្មរយៈពេលវែង ត្រូវបានទិញចូលក្នុងតម្លៃ $2,350 ក្នុងខែមិថុនា ដោយក្នុងនោះរួមមានពន្ធ VAT ចំនួន $350 ដែលអាចស្នើសុំទូទាត់មកវិញបាន។

ចូរបំពេញចន្លោះនៅក្នុងគណនី VAT ខាងក្រោម៖

គណនីអាករតម្លៃបន្ថែម (VAT)

| 2020 | | $ | 2020 | | $ |
|---|---|---|---|---|---|
| 30 Jun | VAT on purchase | ......... | 30 Jun | VAT on sales | ......... |
| 30 Jun | VAT on returns inwards | ......... | 30 Jun | VAT on returns outwards | ......... |
| 30 Jun | VAT on Fixed Asset | ......... | 30 Jun | VAT on cash sales | ......... |
| 30 Jun | Balance c/d | ......... | | | |
| | | ......... | | | ......... |
| | | | 01 Jul | Balance b/d | ......... |

5) ព័ត៌មានខាងក្រោម ត្រូវបានដកស្រង់ចេញពីបញ្ជីកត់ត្រាប្រចាំថ្ងៃ៖

| ទឹកប្រាក់សុទ្ធ (មុនពេលបូកបន្ថែម VAT) សម្រាប់ខែមេសា ឆ្នាំ២០២០ | $ |
|---|---|
| Sales for the month | 5,240 |
| Purchase for the month | 3,950 |
| Returns inwards for the month | 412 |
| Returns outwards for the month | 380 |

គេឱ្យព័ត៌មានបន្ថែមដូចខាងក្រោម៖

(i) នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ សមតុល្យនៅក្នុងគណនី VAT មានចំនួន $220.73 ។

(ii) ការលក់ទំនិញជាសាច់ប្រាក់រួមបញ្ចូលទាំងពន្ធ VAT សម្រាប់ខែមេសា មានចំនួនសរុប $870 ។

(iii) ចំណាយរដ្ឋទេយ្យកើតមានក្នុងខែមេសា មាន $342 (តម្លៃរួមទាំងពន្ធ VAT និងអាចស្នើសុំទូទាត់មកវិញបាន)

(iv) ទ្រព្យសកម្មរយៈពេលវែង ត្រូវបានទិញចូលក្នុងតម្លៃ $2,350 ក្នុងខែមិថុនា ដោយក្នុងនោះរួមមានពន្ធ VAT ចំនួន $350 ដែលអាចស្នើសុំទូទាត់មកវិញបាន។

(v) ពន្ធ VAT ដែលបានបង់ជូនរដ្ឋនៅថ្ងៃទី១៨ ខែមេសា មានសរុប $299 ។

ចូរបំពេញចន្លោះនៅក្នុងគណនី VAT ខាងក្រោម៖

គណនីអាករតម្លៃបន្ថែម (VAT)

| 2020 | | $ | 2020 | | $ |
|---|---|---|---|---|---|
| 18 Apr | Cash book | ……….. | 01 Apr | Balance b/d | ……… |
| 30 Apr | VAT on purchase | ……… | 30 Apr | VAT on sales | ……… |
| 30 Apr | VAT on returns inwards | ……… | 30 Apr | VAT on returns outwards | ……… |
| 30 Apr | VAT on Petty cash exp. | ……… | 30 Apr | VAT on cash sales | ……… |
| 30 Apr | VAT on Fixed Asset | ……… | | | |
| 30 Apr | Balance c/d | ……… | | | |
| | | ……… | | | ……….. |
| | | | 01 May | Balance b/d | ……….. |

## III. សំណួរត្រិះរិះ

1) ចូរគណនារកតម្លៃអាករតម្លៃបន្ថែម (VAT) សម្រាប់ប្រតិបត្តិការខាងក្រោម សន្មត VAT=10% ៖

   a). ការលក់ទំនិញជាសាច់ប្រាក់រួមបញ្ចូលទាំង VAT សរុបចំនួន $274.95

   b). ការលក់ទំនិញសុទ្ធ (មិនបញ្ចូលតម្លៃពន្ធ VAT) សរុប $1,345.00

   c). ចំណាយសាច់ប្រាក់រដ្ឋទេយ្យរួមទាំងតម្លៃពន្ធ VAT សរុប $38.75

2) បញ្ជីកត់ត្រារបស់ក្រុមហ៊ុន Bradleigh បង្ហាញព័ត៌មានសម្រាប់ខែកុម្ភៈ ឆ្នាំ២០២១ ដូចខាងក្រោម៖

   - VAT on sales for the month = $867.54
   - VAT on returns inwards for the month = $12.54
   - VAT on purchases for the month = $342.54
   - ចំណាយជាសាច់ប្រាក់ត្រូវបានទូទាត់ក្នុងខែ សរុប $108.45 ដែលទឹកប្រាក់នេះរួមបញ្ចូលទាំងពន្ធ VAT នូវអត្រា 17.5% ហើយក្រុមហ៊ុនអាចស្នើសុំទូទាត់មកវិញបាន។

   ចូរគណនារកតម្លៃ VAT ដែលក្រុមហ៊ុនត្រូវជំពាក់ មិនទាន់ទូទាត់ជូនរដ្ឋ?

3) ចូរពិនិត្យគណនីខាងក្រោម៖

គណនីអាករតម្លៃបន្ថែម (VAT)

| 2019 | | $ | 2019 | | $ |
|---|---|---|---|---|---|
| 31 May | VAT on purchase | 289 | 01 May | Balance b/d | 56 |
| 31 May | VAT on returns inwards | 12 | 31 May | VAT on sales | 546 |
| 31 May | Balance c/d | ……?… | 31 May | VAT on returns outwards | 7 |
| | | 609 | | | 609 |
| | | | 01 Apr | Balance b/d | ……?…. |

ចូរឆ្លើយនូវសំណួរខាងក្រោម៖

a. តើតម្លៃសមតុល្យនៅថ្ងៃទី០១ ខែឧសភា តំណាងឱ្យអ្វី?
b. ចូរគណនារកតម្លៃសមតុល្យនៅថ្ងៃទី០១ ខែមិថុនា?
c. តើតម្លៃសមតុល្យនៅថ្ងៃទី០១ ខែមិថុនា នឹងបង្ហាញនៅកន្លែងណានៃ Final Accounts?

4) ព័ត៌មានខាងក្រោម ត្រូវបានដកស្រង់ចេញពីបញ្ជីកត់ត្រាប្រចាំថ្ងៃ សម្រាប់រយៈពេល ៣ ខែ ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០៖

Sales Day Book

| Detail | Net | VAT | Gross |
|---|---|---|---|
| Total for period | $785.00 | $137.38 | $922.38 |

Purchases Day Book

| Detail | Net | VAT | Gross |
|---|---|---|---|
| Total for period | $562.00 | $98.35 | $660.35 |

Returns Inwards Day Book

| Detail | Net | VAT | Gross |
|---|---|---|---|
| Total for period | $68.00 | $11.90 | $79.90 |

Returns Outwards Day Book

| Detail | Net | VAT | Gross |
|---|---|---|---|
| Total for period | $44.00 | $7.70 | $51.70 |

ព័ត៌មានបន្ថែម ត្រូវបានផ្តល់ដូចខាងក្រោម៖

(i) នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ សមតុល្យនៅក្នុងគណនី VAT មានចំនួន $117 ។
(ii) ទឹកប្រាក់បង់ពន្ធ VAT ចំនួន $183 ត្រូវបានបង់ជូនពន្ធដារនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០២០។
(iii) ប្រាក់ពន្ធដែលស្នើសុំទូទាត់វិញបានពីការចំណាយផ្សេងៗ មានចំនួនសរុប $58 សម្រាប់ រយៈពេល ៣ខែ ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។

ផ្អែកលើព័ត៌មានខាងលើ ចូររៀបចំគណនីអាករតម្លៃបន្ថែម (VAT) សម្រាប់រយៈពេល ៣ខែ នេះ ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។

5) គេឱ្យប្រតិបត្តិការខាងក្រោម៖

a) ការលក់ទំនិញមានតម្លៃសរុប $1,500 ដោយមានជាប់ Cash Discount 5%។

b) ការលក់ទំនិញមានតម្លៃសរុប $1,000 ដោយទទួលបាន Trade Discount 20% និងមាន Cash discount 2.5% ។

c) ការលក់ទំនិញមានតម្លៃសរុប $2,000 ដោយទទួលបាន Trade Discount 10% និងមាន Cash discount 1.25% ។

d) ការលក់ទំនិញមានតម្លៃសរុប $640 ដោយទទួលបាន Trade Discount 25% និងមាន Cash discount 3% ។

សន្មតថាអត្រា VAT =17.5% ចូរគណនារក៖

(i) តម្លៃវិក្កយបត្រសរុប

(ii) តម្លៃវិក្កយបត្រសរុប ប្រសិនបើក្រុមហ៊ុនទទួលបាន Cash discount។

# មេរៀនទី៦៖ ចំណាយមូលធន និងចំណាយប្រតិបត្តិការ

Chapter 6: Capital and revenue expenditure

**គោលបំណងនៃមេរៀនទី៦ នេះ ផ្តោតលើ៖**

- ចំណាយមូលធន (Capital Expenditure)
- ចំណាយប្រតិបត្តិការ (Revenue Expenditure)

ក្រោយបញ្ចប់មេរៀនទី៦ នេះ យើងអាច៖

- បែងចែករវាង ចំណាយមូលធន និងចំណាយប្រតិបត្តិការ
- ស្គាល់ពីភាពខុសគ្នារវាងចំណូលមូលធន និងចំណូលប្រតិបត្តិការ
- យល់ដឹងពីប្រភេទចំណាយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ
- យល់ដឹងពីគណនីចំណាយគ្រប់ភេទទាំងអស់។

## ៦.១. សេចក្តីផ្តើម

គ្រប់ក្រុមហ៊ុនអាជីវកម្ម អាចមានការទិញទ្រព្យសកម្ម (Assets)មួយចំនួនសម្រាប់ប្រើប្រាស់នៅក្នុងដំណើរអាជីវកម្ម និងមួយចំនួនទៀតសម្រាប់លក់បន្ត។ សម្រាប់ភាពខុសគ្នានោះ គឺថាទ្រព្យសកម្មណាដែលបានទិញដោយមានបំណងលក់បន្ត នឹងត្រូវបានកត់ត្រាបញ្ចូលទៅក្នុងគណនីការទិញទំនិញ។ ចំណែកឯ, ទ្រព្យសកម្មដែលបានទិញ ក្នុងគោលបំណងទុកប្រើប្រាស់នៅក្នុងដំណើរការអាជីវកម្ម នឹងត្រូវកត់ត្រានៅក្នុងគណនីទ្រព្យសកម្មរយៈពេលវែង ទៅតាមប្រភេទទ្រព្យសកម្មដែលក្រុមហ៊ុនបានទិញ ឧទាហរណ៍ យានយន្ត គ្រឿងម៉ាស៊ីន ដីនិងអគារ ជាដើម។

ការកត់ត្រានៅក្នុងគណនីខុសគ្នានេះ នឹងមានឥទ្ធិពលទៅលើទីតាំងដែលទ្រព្យសកម្ម ត្រូវបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ចំណាយការទិញដែលបានកត់ត្រានៅក្នុងគណនី "ទ្រព្យសកម្មរយៈពេលវែង" មិនត្រូវបានចាត់ទុកជាការចំណាយនៅក្នុងរបាយការណ៍ចំណេញ/ខាត ភ្លាមៗនោះទេ។ មានតែការចំណាយទិញទ្រព្យសកម្ម ដែលបានកត់ត្រានៅក្នុងគណនីការទិញទំនិញប៉ុណ្ណោះ នឹងត្រូវបង្ហាញជាការចំណាយនៅក្នុងរបាយការណ៍ចំណេញ/ខាត។

ក្រៅពីនេះ មេរៀនទី៦ នេះ នឹងបង្ហាញបន្ថែមទៀតនូវចំណាយទាំងឡាយណាដែលត្រូវចាត់ទុកជាចំណាយមូលធន និងណាខ្លះត្រូវចាត់ទុកជាចំណាយប្រតិបត្តិការ។

## ៦.២.ការចាត់ថ្នាក់ចំណាយមូលធន និងចំណាយប្រតិបត្តិការ

នៅពេលដែលក្រុមហ៊ុនធ្វើការចាយវាយ (ចំណាយ) នោះការចំណាយ អាចក្លាយជាទ្រព្យសកម្មសម្រាប់អាជីវកម្មប្រើប្រាស់ក្នុងការរកស៊ី (Capital Expenditure) ឬអាចក្លាយទៅជាចំណាយតែម្តង (Revenue Expenditure)។ ប្រសិនបើយើងមិនអាចបែងចែកការចំណាយទាំងនេះឱ្យត្រឹមត្រូវនោះទេ នោះវានឹងនាំឱ្យការបង្ហាញចំណេញក្នុងការរកស៊ីរបស់ក្រុមហ៊ុន មិនត្រឹមត្រូវ។ ជាលទ្ធផល យើងនឹងមិនអាចដឹងច្បាស់ថាការរកស៊ីរបស់ក្រុមហ៊ុន ល្អ ឬយ៉ាងណានោះទេ។

យើងដឹងរួចមកហើយថា Revenue Expenditure នឹងត្រូវបង្ហាញជា ចំណាយ (Expenses) នៅក្នុងរបាយការណ៍ចំណេញ/ខាត ហើយ Capital Expenditure នឹងត្រូវបង្ហាញនៅក្នុងរបាយស្ថានភាពហិរញ្ញវត្ថុ ឬតារាងតុល្យការ (Balance Sheet)។ ដូចនេះ តើពេលណាដែលក្រុមហ៊ុនធ្វើការចំណាយនឹងត្រូវចាត់ជា ទ្រព្យសកម្ម (Assets) ដែលត្រូវបានគេហៅ Capital Expenditure និងពេលណាការចំណាយ ត្រូវបានចាត់ទុកថាជាចំណាយតែម្តង (Expenses) ដែលត្រូវបានគេហៅ Revenue Expenditure ។

Capital Expenditure គឺជាការចំណាយទាំងឡាយណាដែលចូលរួមបង្កើតទ្រព្យសកម្ម របស់ក្រុមហ៊ុន មានន័យថា រាល់ការចំណាយ ត្រូវបានបូកបញ្ចូលទៅក្នុងថ្លៃដើមនៃ Non-current Asset ។ ឧទាហរណ៍ ការចំណាយទិញទ្រព្យសកម្ម, ការចំណាយលើការដំឡើងទ្រព្យសកម្ម, ការចំណាយដើម្បីបង្កើនសមត្ថភាព/លទ្ធភាពនៃការប្រើប្រាស់ទ្រព្យសកម្ម និងចំណាយផ្សេងៗដែលដែលពាក់ព័ន្ធដោយផ្ទាល់ក្នុងការទិញ Non-current assets យកមកប្រើប្រាស់បាន ដែលមិនមែនការចំណាយប្រចាំ។

Revenue Expenditure គឺជាការចំណាយទាំងឡាយណាដែលបានកើតឡើងក្នុងគោលបំណងនៃការលក់ដូរ ឬថែរក្សា Non-current assets ឬត្រូវបានហៅថាចំណាយប្រតិបត្តិការ ។ ឧទាហរណ៍ ការចំណាយទិញ ឬផលិតទំនិញដែលបានលក់ ឬចំណាយក្នុងការផ្តល់សេវា, ចំណាយការលក់ និងការបែងចែក, ចំណាយរដ្ឋបាល ចំណាយជួសជុល Non-current assets ។ល។

តារាងខាងក្រោមនេះ បង្ហាញអំពីឧទាហរណ៍នៃចំណាយមូលធន និងចំណាយប្រតិបត្តិការ

| **ចំណាយមូលធន (Capital Expenditure)** | **ចំណាយប្រតិបត្តិការ (Revenue Expenditure)** |
|---|---|
| ចំណាយទិញទ្រព្យសកម្មរយៈពេលវែង | ចំណាយជួលជុល និងថែទាំទ្រព្យសកម្មជាប្រចាំ |
| ថ្លៃដឹកទ្រព្យសកម្មមកក្រុមហ៊ុន | ចំណាយពន្ធផ្លូវ |
| ថ្លៃសេវាច្បាប់ (legal fee) | ចំណាយបណ្តុះបណ្តាល |
| ចំណាយក្រោយមកទៀតដែលធ្វើឱ្យទ្រព្យសកម្មកើតសមត្ថភាព | ចំណាយប្រាក់បៀវត្សបុគ្គលិក |
| ... | ... |

<u>**ឧទាហរណ៍៖**</u> ក្រុមហ៊ុន DHP Autos បានកើតមានចំណាយមួយចំនួនដូចខាងក្រោម ក្នុងការិយបរិច្ឆេទគណនេយ្យចុងក្រោយ ទាក់ទងនឹងការទិញឡានសម្រាប់ទុកដឹកទំនិញ។

| | $ |
|---|---|
| តម្លៃឡានដឹកទំនិញ | 12,000 |
| ចំណាយបិទផ្លាកសញ្ញាក្រុមហ៊ុនជាប់នឹងឡាន | 400 |
| ចំណាយដូរសំបកកង់សាគួររបស់ឡាន | 360 |
| ចំណាយបង់ពន្ធផ្លូវ | 150 |
| ចំណាយប្រេងឥន្ធនៈ | 980 |
| ចំណាយដូរគ្រឿងម៉ាស៊ីនឡានថ្មី | 2,400 |

ការចំណាយអាចត្រូវបានចាត់ថ្នាក់ជាចំណាយមូលធននិងចំណាយប្រតិបត្តិការ ដូចដែលបានបង្ហាញតារាងខាងក្រោម។

| ចំណាយ | ប្រភេទនៃចំណាយ | បរិយាយ | ចំណាយដើមទុន | ប្រាក់ចំណូល |
|---|---|---|---|---|
| តម្លៃឡានដឹកទំនិញ | មូលធន | ការទិញសម្ភារៈថ្មី | $12,000 | |
| ចំណាយបិទផ្លាកសញ្ញាក្រុមហ៊ុនជាប់នឹងឡាន | មូលធន | ការបន្ថែមតម្លៃលើសម្ភារៈថ្មី | $400 | |
| ចំណាយជួរសំបកកង់សាគួរបស់ឡាន | ប្រតិបត្តិការ | មិនបន្ថែមតម្លៃ,ដំណើរការពីមួយថ្ងៃទៅមួយថ្ងៃការចំណាយ | | $360 |
| ចំណាយបង់ពន្ធផ្លូវ | ប្រតិបត្តិការ | ចំណាយទៀងទាត់ កើតឡើងជារៀងរាល់ឆ្នាំ | | $150 |
| ចំណាយប្រេងឥន្ធនៈ | ប្រតិបត្តិការ | ទៀងទាត់ពីមួយថ្ងៃទៅមួយថ្ងៃការចំណាយ | | $980 |
| ចំណាយជួរគ្រឿងម៉ាស៊ីនឡានថ្មី | មូលធន | ចំណាយមួយផ្នែកការបន្ថែមតម្លៃទៅសម្ភារៈ | $2,400 | |
| **សរុប** | | | **$14,800** | **$1,490** |

**អនុវត្តៈ**

តើចំណាយខាងក្រោមនេះ ណាខ្លះត្រូវចាត់ជា Capital Expenditure ហើយណាខ្លះ ជា Revenue Expenditure?

a. ចំណាយទិញអចលនទ្រព្យ
b. ចំណាយផ្នែកច្បាប់(Legal Fee) ក្នុងការទិញអចលនទ្រព្យខាងលើ
c. ចំណាយក្នុងធ្វើឱ្យសមត្ថភាពដំណើរការនៃកុំព្យូទ័រប្រសើរឡើង ដើម្បីបំរើឱ្យការរកស៊ី
d. ចំណាយជួសជុល និងថែទាំកុំព្យូទ័រ
e. ចំណាយទិញម៉ាស៊ីនភ្លើងថ្មី
f. ចំណាយពន្ធគយក្នុងការទិញម៉ាស៊ីនខាងលើពីក្រៅប្រទេស
g. ចំណាយដឹកជញ្ជូនម៉ាស៊ីនខាងលើពីកំពង់ផែទៅកាន់ក្រុមហ៊ុន
h. ចំណាយដំឡើងម៉ាស៊ីនខាងលើ ដើម្បីដាក់ឱ្យប្រើប្រាស់បាន
i. ចំណាយប្រាក់បៀវត្សជូនកម្មករកាន់ម៉ាស៊ីននោះ

## ៦.៣. កិច្ចសន្យាជួលទ្រព្យសកម្ម-ភតិសន្យា (Lease)

នៅក្នុងដំណើរការអាជីវកម្ម ក្រុមហ៊ុនអាចនឹងប្រឈមនឹងកង្វះខាតថវិកាក្នុងការទិញទ្រព្យសកម្មដែលមានតម្លៃថ្លៃ ដូចជា អគារការិយាល័យ ម៉ាស៊ីនហ្វូតូកូពី ជាដើម។ ដើម្បីអាចទទួលបានទ្រព្យសកម្មទាំងនេះ យកមកប្រើប្រាស់ ក្រុមហ៊ុនអាជីវកម្មអាចជ្រើសរើសធ្វើការចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុន

ផ្គត់ផ្គង់ទ្រព្យសកម្ម ឬក្រុមហ៊ុនជួលទ្រព្យសកម្ម។ កិច្ចព្រមព្រៀងជួលទ្រព្យសកម្មទាំងនោះ ត្រូវបានគេហៅថាភតិសន្យា។

ភតិសន្យា គឺជាកិច្ចព្រមព្រៀងមួយដែលបានផ្តល់សិទ្ធិក្នុងការគ្រប់គ្រងប្រើប្រាស់ទ្រព្យសកម្មមួយនៅក្នុងរយៈពេលជាក់លាក់ណាមួយ។[4] នៅក្នុងភតិសន្យា ភាគីពាក់ព័ន្ធ រួមមានអ្នកឱ្យខ្ចី ហៅថាភតិបតី (Lessor) និងអ្នកខ្ចី ហៅថាភតិកៈ (Lessee)។

គ្រប់ភតិសន្យាទាំងអស់ ត្រូវធ្វើការកត់ត្រានៅក្នុងគណនីទ្រព្យសកម្ម និងគណនីបំណុលរបស់ក្រុមហ៊ុនអាជីវកម្ម។ រាល់ការទូទាត់ថ្លៃជួល ត្រូវបានចាត់ទុកថាជាការចំណាយរួមគ្នា ក្នុងនោះរួមមានចំណាយការប្រាក់ ដែលត្រូវបានចាត់ទុកថាជាការចំណាយប្រតិបត្តិការ និងមួយផ្នែកទៀតនៃថ្លៃជួលត្រូវបានចាត់ទុកថាជាចំណាយមូលធន។

ទោះបីជាយ៉ាងណាក៏ដោយ, ក៏នៅមានករណីលើកលែងផងដែរ សម្រាប់ភតិសន្យារយៈពេលខ្លី (Short-term leases) ដែលមានរយៈពេលតិចជាងមួយឆ្នាំ និងភតិសន្យានៃទ្រព្យសកម្មដែលមានតម្លៃទាប ដូចជាកុំព្យូទ័រយួរដៃជាដើម។ សម្រាប់ភតិសន្យាប្រភេទនេះ មិនត្រូវឱ្យធ្វើការបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុឡើយ ប៉ុន្តែគ្រាន់តែបង្ហាញថ្លៃជួលទ្រព្យសកម្មនោះជាចំណាយនៅក្នុងរបាយការណ៍ចំណេញ/ខាត ប៉ុណ្ណោះ។

## ៦.៤. ចំណាយស្រាវជ្រាវ និងចំណាយអភិវឌ្ឍន៍

អ្នកជំនួញនឹងចំណាយប្រាក់ជាញឹកញាប់ទៅលើការស្រាវជ្រាវនិងការអភិវឌ្ឍន៍។ នេះអាចជាបង្កើតដំណើរការថ្មីឬផលិតផលថ្មី។ ការស្រាវជ្រាវពាក់ព័ន្ធនឹងការងារទ្រឹស្តីឬពិសោធន៍ដើម្បីទទួលបានចំណេះដឹងថ្មីៗការអភិវឌ្ឍទាក់ទងនឹងចំណេះដឹងនេះដែលត្រូវបានប្រើ ដើម្បីបង្កើតផលិតផលប្រព័ន្ធឬសេវាកម្ម។

Research សំដៅលើសកម្មភាពដែលយើងធ្វើការសិក្សាស្រាវជ្រាវ ក្នុងគោលបំណងទទួលបានចំនេះដឹង ឬការយល់ដឹងអ្វីមួយ។ សកម្មភាព Research រួមមាន៖

- សកម្មភាពសំដៅដល់ការទទួលបានចំនេះដឹងថ្មី
- ការស្រាវជ្រាវរក application ទៅលើរបកគំហើញ ឬចំនេះដឹងដ៏ទៃទៀត
- ការស្រាវជ្រាវរកទំនិញជំនួស ឬដំណើការជំនួស
- ការបង្កើត ឬDesign ទំនិញ ឬដំណើរការថ្មីដែលអាចមកជំនួសរបស់ចាស់។

Development សំដៅលើការបង្កើតរបស់អ្វីមួយដែលថ្មី (វាជាដំណើរការក្រោយ Research) ដែលរួមមានសកម្មភាព៖

- ការបង្កើតទំនិញថ្មីមកជំនួយទំនិញចាស់ (ឧទាហរណ៍ស៊េរីថ្មីៗ នៃទូរស័ព្ទ Iphone)
- ការបង្កើតទំនិញដោយប្រើបច្ចេកវិទ្យាថ្មី ជាដើម។

[4] ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ១៦ (IFRS 16)

នៅក្នុងដំណើរការនេះ ចំណាយដែលបានកើតឡើង ត្រូវបានបែងចែកជាពីរ គឺ ចំណាយស្រាវជ្រាវ (Research Expense) និងចំណាយអភិវឌ្ឍន៍ (Development Expense)។[5]

ចំណាំ៖ ចំណាយលើការ Research ត្រូវតែកត់ត្រាជាចំណាយនៅក្នុងឆ្នាំដែលវាកើតឡើង (Revenue Expenditure)។ ប៉ុន្តែចំណាយលើការ Development ត្រូវកត់ត្រាជាទ្រព្យសកម្មរយៈពេលវែង (Capital Expenditure) និងត្រូវដករំលស់ជាប្រចាំឆ្នាំ ឬបើមិនដូចនេះទេត្រូវធ្វើ Impairment Test ។ សម្រាប់រំលស់ជាប្រចាំឆ្នាំ ឬបើមិនដូចនេះទេត្រូវធ្វើ Impairment Test នឹងត្រូវសិក្សានៅក្នុងមុខវិជ្ជាគណនេយ្យក្រោយៗទៀត។

**<u>អនុវត្តន៍</u>៖** មុនថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៦ លោក Marley បានចំណាយអស់ $300,000 ដើម្បីគាំទ្រដល់គម្រោង Research មួយ។ ក្រោយទទួលបានលទ្ធផលល្អ នៅខែឧសភា លោក Marley បានចំណាយបន្ថែមទៀតអស់ $600,000 ដើម្បីអភិវឌ្ឍទំនិញថ្មីមួយ ហើយផលិតកម្មក៏កើតមានឡើងនៅខែឧសភាដូចគ្នា។

តើចំណាយប្រតិបត្តិការសរុប សម្រាប់បង្ហាញក្នុងរបាយការណ៍ចំណេញ/ខាត សម្រាប់ឆ្នាំបញ្ចប់គិតត្រឹមថ្ងៃទី៣១ ខែមេសា ឆ្នាំ២០១៧ ស្មើនឹងប៉ុន្មាន?

A. $ គ្មាន

B. $300,000

C. $600,000

D. $900,000

## ៦.៥. ចំណូលមូលធន និងចំណូលប្រតិបត្តិការ (Capital and revenue income)

ចំណូលមូលធន (Capital income) សំដៅដល់ចំណូលដែលបានមកពីការលក់ទ្រព្យសកម្មមិនមែនទិញទុកសម្រាប់លក់ (មានន័យថាចំណូលពីការលក់ទ្រព្យសកម្មរយៈពេលវែង)។ ចំណេញ/ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែងទាំងនេះ ត្រូវបង្ហាញនៅក្នុងរបាយការណ៍ចំណេញ/ខាត (SOPL) សម្រាប់ក្រុមហ៊ុនអាជីវកម្ម នៅក្នុងការិយបរិច្ឆេទគណនេយ្យដែលការលក់នោះបានកើតឡើង។

ចំណូលប្រតិបត្តិការ (Revenue income) សំដៅដល់ចំណូលទាំងឡាយណាដែលបានមកពី៖

- ការលក់ទ្រព្យសកម្មដែលបានទិញ/ផលិតសម្រាប់ទុកលក់វិញ (Inventory)
- ការជួល, ការប្រាក់ និងភាគលាភ(Dividends) ទទួលបានពីទ្រព្យសកម្មដែលក្រុមហ៊ុនកំពុងកាន់កាប់។

ចំណូលប្រតិបត្តិការទាំងនេះ ក៏ត្រូវបង្ហាញនៅក្នុងរបាយការណ៍ចំណេញ/ខាត (SOPL) ដូចគ្នា។

## ៦.៦. សារៈសំខាន់នៃការចាត់ថ្នាក់ចំណាយមូលធន និងចំណាយប្រតិបត្តិការ

វាជារឿងសំខាន់នៅក្នុងការបែងចែងចំណូល និងចំណាយទាំងអស់ជាប្រភេទមូលធន និងប្រតិបត្តិការ។ ប្រសិនបើមិនមានការបែងចែកនោះទេ នោះលទ្ធផលនៃរបាយការណ៍ហិរញ្ញវត្ថុ នឹង

[5] ស្តង់ដាគណនេយ្យអន្តរជាតិ ៣៨ (IAS 38)

បង្ហាញតួលេខខុស សម្រាប់អ្នកប្រើប្រាស់ ដោយសារការកត់ត្រាសម្រាប់ប្រភេទទាំងពីរនេះ មានលក្ខណៈខុសគ្នាដាច់ស្រលះ។ សម្រាប់ចំណាយប្រតិបត្តិការ តម្រូវឱ្យយើងធ្វើការរាយការណ៍នៅក្នុងរបាយការណ៍ចំណេញ/ខាត (SOPL) ហើយចំណាយមូលធន តម្រូវឱ្យយើងត្រូវរាយការណ៍នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (SOFP)។ ជារួម ប្រសិនបើយើងធ្វើការចាត់ថ្នាក់ចំណាយទាំងនេះខុស នឹងនាំឱ្យការបង្ហាញផលចំណេញសម្រាប់ក្រុមហ៊ុនអាជីវកម្ម ក៏ខុសផងដែរ។

ការចាត់ថ្នាក់ចំណូល និងចំណាយទាំងអស់ គឺពិតជាមានសារៈសំខាន់ ដើម្បីធានាថាក្រុមហ៊ុនអាជីវកម្ម នឹងបង្ហាញនូវរបាយការណ៍មួយត្រឹមត្រូវ នូវទឹកប្រាក់នៃទ្រព្យសកម្ម និងផលចំណេញរបស់ខ្លួន។ វាក៏នឹងផ្តល់នូវមូលដ្ឋានទៅដល់ការរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ផងដែរ ដែលយើងនឹងត្រូវសិក្សាបន្តនៅក្នុងគណនេយ្យហិរញ្ញវត្ថុភាគ ២។

ឧទាហរណ៍៖ ក្រុមហ៊ុនមួយ បានចំណាយថវិកាចំនួន $500 ក្នុងការទិញកុំព្យូទ័រ និងបានចំណាយ $500 ទៀតសម្រាប់សេវាជួសជុលនិងថែទាំ។ ចំណាយទិញកុំព្យូទ័រ គឺជាចំណាយមូលធនដែលតម្រូវឱ្យយើងត្រូវរាយការណ៍ នៅក្នុងគណនីទ្រព្យសកម្មមួយនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (SOFP)។ ចំណែកឯ, ចំណាយជួសជុលនិងថែទាំ គឺជាចំណាយប្រតិបត្តិការ ដែលតម្រូវឱ្យយើងត្រូវរាយការណ៍នៅក្នុងរបាយការណ៍ចំណេញ/ខាត (SOPL)។ ក្នុងករណីដែលយើងចាត់ថ្នាក់ចំណាយទិញកុំព្យូទ័រ គឺជាចំណាយប្រតិបត្តិការ នោះយើងត្រូវរាយការណ៍នៅក្នុងរបាយការណ៍ចំណេញ/ខាត។ ការណ៍នេះ នឹងនាំឱ្យចំណាយរបស់ក្រុមហ៊ុនមានការកើនឡើង។ ជាលទ្ធផល ចំណេញដែលក្រុមហ៊ុនត្រូវបង្ហាញនឹងធាក់ចុះ។

## ៦.៧. សេចក្តីសន្និដ្ឋាន

ចំណាយមូលធន សំដៅដល់ចំណាយទាំងឡាយណាដែលចូលរួមបង្កើតនូវទ្រព្យសកម្មរបស់ក្រុមហ៊ុនអាជីវកម្ម។ ដូចនេះ រាល់ការចំណាយថវិកា ត្រូវបានបូកបញ្ចូលទៅក្នុងថ្លៃដើមនៃទ្រព្យសកម្មរយៈពេលវែង។

ចំណាយប្រតិបត្តិការ សំដៅដល់ចំណាយទាំងឡាយណាដែលបានកើតឡើងក្នុងគោលបំណងនៃការលក់ដូរ ឬថែទាំទ្រព្យសកម្មរយៈពេលវែង។ ដូចនេះ រាល់ការចំណាយថវិកា ត្រូវរាយការណ៍ជាចំណាយនៅក្នុងរបាយការណ៍ចំណេញ/ខាតរបស់ក្រុមហ៊ុនអាជីវកម្ម។

# លំហាត់

## I. សំណួរពហុជ្រើសរើស (MCQ)

1) តើចំណាយខាងក្រោមនេះ គួរត្រូវបានចាត់ទុកជា Capital Expenditure?
   a. ចំណាយលាបពណ៌អគារ (Painting)
   b. ចំណាយជួសជុលដូរបង្អួចមួយនៃអគារ
   c. ចំណាយទិញរថយន្តដោយអ្នកលក់រថយន្តសម្រាប់ទុកលក់វិញ
   d. ចំណាយផ្នែកច្បាប់(Legal Fee) កើតឡើងនៅពេលទិញអគារ

2) តើតម្លៃមួយណាខាងក្រោមនេះ នៅក្នុងវិក្កយបត្រ ត្រូវបានចាត់ទុកជា Revenue Expenditure?
   a. ពន្ធផ្លូវ
   b. ថ្លៃដឹកជញ្ជូន
   c. តម្លៃរថយន្ត
   d. ពន្ធនាំចូលរថយន្ត

3) ក្រុមហ៊ុន បានទិញសម្ភារៈបរិក្ខាមួយប្រភេទ(Equipment) ដែលវិក័យប័ត្របង្ហាញដូចខាងក្រោម៖

| | |
|---|---|
| Water treatment equipment (ម៉ាស៊ីនចម្រោះទឹក) | $39,800 |
| Delivery (ចំណាយដឹកម៉ាស៊ីនមកក្រុមហ៊ុន) | $1,100 |
| Maintenance Charge (ចំណាយថែទាំម៉ាស៊ីន) | $3,980 |
| Training cost (ចំណាយបណ្តុះបណ្តាល) | $7,854 |
| Invoice total (ចំណាយសរុប) | $52,734 |

តើក្នុងការទិញម៉ាស៊ីន មានចំណាយជាមូលធន (Capital Expenditure) ស្មើនឹងប៉ុន្មាន?
   a. $39,800
   b. $40,900
   c. $44,880
   d. $52,734

4) ក្រុមហ៊ុន ខ បានទិញម៉ាស៊ីនហ្វូតូកូពីថ្មីមួយ។ ម៉ាស៊ីននេះ មានតម្លៃ $80,000 ។ ការដឹកជញ្ជូនចំណាយអស់ $2,000 និងការដំឡើងចំណាយអស់ $5,000។ មុននឹងអាចដំណើរការម៉ាស៊ីននេះ កូពីឯកសារឱ្យអតិថិជនបាន ក្រុមហ៊ុនត្រូវធ្វើតេសម៉ាស៊ីននេះសិន ដោយត្រូវចំណាយលើក្រដាស និងទឹកថ្នាំអស់ $1,000។ តើតម្លៃរបស់ម៉ាស៊ីននេះ សរុបប៉ុន្មានដែលត្រូវបង្ហាញនៅក្នុង Balance Sheet?
   a. $80,000
   b. $82,000
   c. $87,000
   d. $88,000

5) តើប្រយោគខាងក្រោមទាំងបីនេះ ណាខ្លះត្រឹមត្រូវសម្រាប់ការចាត់ថ្នាក់ចំណាយស្រាវជ្រាវ និងចំណាយអភិវឌ្ឍន៍៖

(i). ចំណាយលើការស្រាវជ្រាវ ត្រូវតែកត់ត្រាជាចំណាយនៅក្នុងឆ្នាំដែលវាកើតឡើង។

(ii). ចំណាយលើការអភិវឌ្ឍ ត្រូវកត់ត្រាជាទ្រព្យសកម្មរយៈពេលវែង។

(iii). ចំណាយលើការអភិវឌ្ឍ គឺជាចំណាយប្រតិបត្តិការ។

a. (i) និង (ii)

b. (i) និង (iii)

c. (ii) និង (iii)

d. (i), (ii) និង (iii)

## II. ចូរផ្គូរផ្គងនូវពាក្យគន្លឹះខាងក្រោម៖

| | |
|---|---|
| 1. ចំណាយមូលធន | A. ចំណាយទាំងឡាយណាដែលចូលរួមបង្កើតនូវទ្រព្យសកម្មរបស់ក្រុមហ៊ុនអាជីវកម្ម និងត្រូវបានបូកបញ្ចូលទៅក្នុងថ្លៃដើមនៃទ្រព្យសកម្មរយៈពេលវែង។ |
| 2.ចំណាយប្រតិបត្តិការ | B. ភាគីអ្នកឱ្យខ្ចី នូវទ្រព្យសកម្ម នៅក្នុងភតិសន្យា។ |
| 3. ចំណូលមូលធន | C. ភាគីអ្នកខ្ចី នៅក្នុងភតិសន្យា នឹងទទួលបាននូវសិទ្ធិគ្រប់គ្រងប្រើប្រាស់ទ្រព្យសកម្ម នៅក្នុងរយៈពេលជាក់លាក់មួយ។ |
| 4. ចំណូលប្រតិបត្តិការ | D. ចំណូលដែលបានមកពីការលក់ទ្រព្យសកម្មមិនមែនទិញទុកសម្រាប់លក់ (ចំណូលពីការលក់ទ្រព្យសកម្មរយៈពេលវែង)។ |
| 5. ភតិសន្យា | E. ចំណាយទាំងឡាយណាដែលបានកើតឡើងក្នុងគោលបំណងនៃការលក់ដូរ ឬថែទាំទ្រព្យសកម្មរយៈពេលវែង។ |
| 6. ចំណាយស្រាវជ្រាវ | F. ចំណាយក្នុងការបង្កើតរបស់អ្វីមួយដែលថ្មី បន្ទាប់ពីក្រុមហ៊ុនបានសិក្សាលម្អិតរួចហើយ។ |
| 7. ចំណាយអភិវឌ្ឍន៍ | G. ចំណូលទាំងឡាយណាដែលបានមកពីការរលក់ទ្រព្យសកម្មដែលបានទិញ/ផលិតសម្រាប់ទុកលក់វិញ។ |
| 8. ភតិបតី (Lessor) | H. ភតិសន្យាគឺជាកិច្ចព្រមព្រៀងមួយដែលបានផ្តល់សិទ្ធិក្នុងការគ្រប់គ្រងប្រើប្រាស់ទ្រព្យសកម្មមួយ នៅក្នុងរយៈពេលជាក់លាក់មួយ។ |
| 9. ភតិកៈ (Lessee) | I. ចំណាយលើសកម្មភាពដែលយើងធ្វើការសិក្សា ក្នុងគោលបំណងទទួលបានចំនេះដឹងថ្មី ឬការយល់ដឹងអ្វីមួយថ្មី។ |

## III. សំណួរត្រិះរិះ

1) ចូរចាត់ថ្នាក់ចំណាយខាងក្រោម ជាចំណាយមូលធន ឬ ចំណាយប្រតិបត្តិការៈ
   (a) វិក្កយបត្រអគ្គិសនីសម្រាប់ឆ្នាំ
   (b) ថ្លៃដើមនៃម៉ាស៊ីនភ្លើងថ្មីមួយ
   (c) ថ្លៃដើមនៃការដំឡើងម៉ាស៊ីនភ្លើង
   (d) ចំណាយដឹកជញ្ជូនម៉ាស៊ីនភ្លើង
   (e) ថ្លៃជួសជុលនិងថែទាំម៉ាស៊ីនភ្លើង
   (f) ចំណាយធ្វើឱ្យម៉ាស៊ីនភ្លើងអាចប្រើបាន ៣ ឆ្នាំថែមទៀត។
2) នៅក្នុងហាងលក់អាហារ ចូរបែងចែកចំណាយខាងក្រោមនេះ ទៅជាចំណាយមូលធន និង ចំណាយប្រតិបត្តិការៈ
   (a) ការទិញខ្ទះខ្លាញ់ជ្រៅ
   (b) ចំណាយគូសផ្លាកសញ្ញានៅខាងក្រៅហាងថ្មី
   (c) ថ្លៃជួលសម្រាប់ទីតាំង
   (d) ទិញនំសម្រាប់ធ្វើប៊ីហ្គឺរ
   (e) ថ្លៃដឹកជញ្ជូនសម្រាប់ក្នុងការទិញខ្ទះខ្លាញ់ជ្រៅ
   (f) ការប្រាក់នៃប្រាក់កម្ចីដែលបានខ្ចីយកទៅទិញខ្ទះខ្លាញ់ជ្រៅ
   (g) ប្រាក់បៀវត្សរ៍សម្រាប់បុគ្គលិកក្រៅម៉ោង
   (h) ការទិញម៉ាស៊ីនភេសជ្ជៈ។
3) សម្រាប់ចំណូលខាងក្រោមនេះ តើវាជាចំណូលមូលធន ឬចំណូលប្រតិបត្តិការៈ
   (a) ការលក់សាឡុងដោយក្រុមហ៊ុនលក់គ្រឿងសង្ហារឹម
   (b) ការលក់ទូដែកដាក់រក្សាប្រាក់ ដោយក្រុមហ៊ុនលក់រថយន្ត
   (c) ប្រាក់កម្ចីទទួលបានដោយក្រុមហ៊ុនលក់សម្ភារកីឡា
   (d) ការប្រាក់ទទួលបាន ដោយហាងលក់សំលៀកបំពាក់
   (e) ការលក់ហាងដោយហាងលក់អាហារ
   (f) ការលក់ផ្ទះដោយក្រុមហ៊ុនទិញ-លក់អចលនៈទ្រព្យ។
4) សម្រាប់កសិដ្ឋានមួយ ចូរបែងចែកចំណាយដូចខាងក្រោមនេះ ជាចំណាយមូលធន និងចំណាយ ប្រតិបត្តិការៈ
   (a) ថ្លៃដឹកជញ្ជូនថ្នាំសំលាប់សត្វល្អិត
   (b) ចំណាយជានាប់រងលើត្រាក់ទ័រ
   (c) ថ្លៃដំឡើងគ្រឿងម៉ាស៊ីនថ្មីសម្រាប់ចម្រាញ់ទឹកដោះគោ
   (d) ប្រាក់ឈ្នួលសម្រាប់កម្មករ
   (e) ចំណាយប្រេងឥន្ទនៈសម្រាប់អ្នកច្រូតកាត់
   (f) ថ្លៃសាងសង់កន្លែងស្តុកទុកផលិតកសិកម្ម
   (g) ចំណាយជួសជុលកន្លែងស្តុកទុកផលិតកសិកម្ម។

5) Craig Watson គឺជាអ្នកគ្រប់គ្រង ITC សម្រាប់ក្រុមហ៊ុនធំមួយ។ គាត់ទទួលខុសត្រូវក្នុងការដំឡើងឈុតកុំព្យូទ័រថ្មី។ ការចំណាយដូចខាងក្រោមនេះ ត្រូវបានកើតឡើងជាមួយនឹងការដំឡើងនេះ។ គាត់មិនច្បាស់ទេថាតើត្រូវចាត់ថ្នាក់ចំណាយទាំងនេះ ជាចំណាយមូលធន ឬចំណាយប្រតិបត្តិការ។ Craig ស្នើសុំឱ្យអ្នកជួយចាត់ថ្នាក់នូវចំណាយទាំងនេះ៖
   (a) ថ្លៃកុំព្យូទ័រថ្មីចំនួន ១២ គ្រឿង
   (b) ថ្លៃដើមដឹកជញ្ជូនកុំព្យូទ័រទាំងនេះ
   (c) តុនិងកៅអីថ្មីសម្រាប់ដាក់កុំព្យូទ័រធ្វើការ
   (d) ថ្លៃភ្លើងសម្រាប់ឱ្យកុំព្យូទ័រអាចកំពុងដំណើរការបានរយៈពេលមួយឆ្នាំ
   (e) ថ្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំសម្រាប់សូហ្វវែរ
   (f) សម្ភារការិយាល័យសម្រាប់ម៉ាស៊ីនព្រីនធ័រ
   (g) ថ្លៃសំអាតកន្លែងដំឡើងកុំព្យូទ័រ
   (h) ថ្លៃដំឡើងប្រព័ន្ធឥតខ្សែថ្មីសម្រាប់កុំព្យូទ័រ។

6) ចំណាយដូចខាងក្រោមនេះ បានកើតមានឡើងនៅក្នុងការប្រើប្រាស់ឡានដឹកទំនិញមួយដែលឥឡូវនេះក្រុមហ៊ុនបានប្រើប្រាស់ឡាននេះ រយៈពេលប្រាំឆ្នាំមកហើយ។ ចូរចាត់ថ្នាក់ចំណាយខាងក្រោមនេះ ជាចំណាយមូលធន ឬ ចំណាយប្រតិបត្តិការ។
   (a) ចំណាយតុបតែងឡានក្នុងគោលបំណងអាជីវកម្ម
   (b) ថ្លៃធានារ៉ាប់រងសម្រាប់អ្នកបើកបរ
   (c) ពន្ធផ្លូវ
   (d) ថ្លៃសាំងឡាន
   (e) ចំណាយលាបថ្នាំឡានតាមពណ៌អាជីវកម្ម
   (f) ចំណាយដំឡើងប្រព័ន្ធនាំផ្លូវ (Navigation System) សម្រាប់ការប្រើប្រាស់អាជីវកម្ម
   (g) ថ្លៃជួរសំបកកង់ឡាន។

7) លោក Ashley បានបើកដំណើរការកន្លែងល្បែងកំសាន្តមួយ។ ចំណាយខាងក្រោមនេះ បានកើតឡើង។ ចូរចាត់ថ្នាក់ចំណាយទាំងនេះ ទៅជាចំណាយមូលធន និងចំណាយប្រតិបត្តិការ៖
   (a) ការជួលដីសម្រាប់កន្លែងល្បែងកំសាន្ត
   (b) ថ្លៃអគ្គិសនីនៅក្នុងដំណើរអាជីវកម្ម
   (c) ប្រាក់បៀវត្សបុគ្គលិកក្រៅម៉ោង
   (d) ទិញឧបករណ៍ល្បែងថ្មី
   (e) ថ្លៃដឹកជញ្ជូនឧបករណ៍ល្បែងថ្មី
   (f) ថ្លៃដើមនៃការដំឡើងប្រព័ន្ធសន្តិសុខថ្មី
   (g) ថ្លៃជួរអំពូលនៃផ្លាកសញ្ញាបង្ហាញផ្លូវនៅខាងក្រៅបរិវេណ
   (h) ការបណ្តុះបណ្តាលបុគ្គលិកអំពីរបៀបដំណើរការឧបករណ៍ល្បែង។

8) ចូរចាត់ថ្នាក់នូវចំណាយនីមួយៗខាងក្រោមនេះ ជាចំណាយមូលធន និងចំណាយប្រតិបត្តិការ៖

(a) ម៉ាស៊ីនភ្លើងថ្មី

(b) ជួសជុលម៉ាស៊ីនភ្លើង

(c) ថ្លៃដឹកចូលនូវទំនិញដែលបានទិញទុកលក់វិញ (Carriage inwards)

(d) ថ្លៃដំឡើងម៉ាស៊ីនភ្លើងថ្មី

(e)ថ្លៃដឹកចូលនូវម៉ាស៊ីនភ្លើងថ្មី(Carriage inwards)

(f) ប្រាក់បៀវត្សបុគ្គលិកស្រាវជ្រាវ

(g) ថ្លៃឈ្នួលស្ថាបត្យករសម្រាប់ការរចនារោងចក្រថ្មី

(h) ថ្លៃលាបពណ៌រោងចក្រថ្មី។

9) ផ្អែកតាមព័ត៌មានខាងក្រោមនេះ ចូរគណនាតម្លៃចំណាយមូលធនសរុបរបស់រោងចក្រថ្មីមួយ៖

| | $ |
|---|---|
| តម្លៃទិញដី | 140,000 |
| ថ្លៃសាងសង់រោងចក្រ | 85,000 |
| ការធានារ៉ាប់រងសម្រាប់រោងចក្រនិងឧបករណ៍ | 4,800 |
| ថ្លៃដំឡើងរោងចក្រនិងឧបករណ៍ | 3,600 |
| ចំណាយដំណើរការ | 8,900 |
| ថ្លៃសេវាផ្នែកច្បាប់ | 12,000 |
| សរុបការចំណាយសរុប | 254,300 |

10) ផ្អែកតាមទិន្នន័យខាងក្រោមនេះ ចូរគណនាចំណាយមូលធនសរុប និងចំណាយប្រតិបត្តិការសរុប៖

| | $ |
|---|---|
| ទិញម៉ាស៊ីនថ្មី | 4,500 |
| ថ្លៃដឹកជញ្ជូនចូលនូវម៉ាស៊ីនថ្មី | 755 |
| ថ្លៃប្រេងឥន្ធនៈម៉ាស៊ីន សម្រាប់រយៈពេលមួយឆ្នាំ | 1,120 |
| ថ្លៃដំឡើងម៉ាស៊ីន | 92 |
| ចំណាយថែទាំម៉ាស៊ីន | 217 |

11) ចំណាយខាងក្រោមទាក់ទងនឹងការទិញ និងធ្វើទំនើបកម្មនូវដីនិងអគារថ្មីមួយកន្លែង។ ចូរគណនារក ចំណាយមូលធនសរុប និងចំណាយប្រតិបត្តិការសរុប។

| | $ |
|---|---|
| ការទិញដីនិងអគារថ្មី | 48,000 |
| ការជួសជុលអគារ | 1,800 |
| ការចំណាយផ្លាស់ប្តូរបង្អួចថ្មី | 4,330 |

| | |
|---|---|
| ថ្លៃជួលមេធាវីសម្រាប់ការទិញដីនិងអគារ | 1,600 |
| ចំណាយដំណើការអាជីវកម្ម | 3,100 |

12) ចំណាយខាងក្រោមនេះ បានកើតឡើងនៅក្នុងដំណើរការទិញតូបអាហារថ្មីមួយ។ ចូរគណនាចំណាយមូលធនសរុប និងចំណាយប្រតិបត្តិការសរុប។

| | $ |
|---|---|
| ទិញតូបអាហារថ្មី | 5,600 |
| ថ្លៃដំឡើងតូបអាហារ | 460 |
| សន្និធិសម្រាប់តូបអាហារ | 710 |
| ចំណាយក្លាសេអាហារ សម្រាប់រយៈពេលមួយឆ្នាំដំបូង | 226 |
| ប្រាក់បៀវត្សបុគ្គលិក | 9,800 |
| ថ្លៃដឹកទំនិញចូលនូវអាហារសម្រាប់ទុកលក់វិញ | 188 |
| ថ្លៃដឹកជញ្ជូនសម្ភារៈសម្រាប់បង្កើតតូបអាហារ | 250 |

13) ចំណាយខាងក្រោមនេះ បានកើតមានឡើងនៅក្នុងការដំឡើងឡចំហាយកំដៅថ្មីមួយ នៅក្នុងរោងចក្រ។ ចូរគណនាចំណាយមូលធនសរុប និងចំណាយប្រតិបត្តិការសរុប។

| | $ |
|---|---|
| ថ្លៃដំឡើងនិងទិញឡចំហាយកំដៅថ្មី | 2,670 |
| ថ្លៃសេវាកម្មនៃឡចំហាយ | 312 |
| ចំណាយដំណើរការឡចំហាយ | 661 |
| ចំណាយជួសជុលការបែកបាក់ឡចំហាយ | 431 |
| ថ្លៃដឹកជញ្ជូនចូលនូវឡចំហាយថ្មី | 76 |

14) Keris Emery មានបំណងទិញរថយន្តមួយទឹក សម្រាប់ប្រើប្រាស់នៅក្នុងដំណើរការអាជីវកម្ម។ រថយន្តមួយ ត្រូវបានដាក់លក់នៅក្នុងកាសែត ក្នុងតម្លៃ $2,999។ ប៉ុន្តែ Keris បានចរចាតម្លៃនៅសល់ត្រឹមតែ $2,500។ ជាមួយគ្នានេះ, ក៏កើតមាននូវចំណាយបន្ថែមមួយចំនួនទៀតពាក់ព័ន្ធនឹងការទិញនេះ។ រថយន្តនឹងត្រូវប្តូរសំបកកង់ថ្មីក្នុងតម្លៃ $400 ក្នុងឈុតមួយ។ លើសពីនេះទៀត, Keris នឹងត្រូវការដំឡើងប្រព័ន្ធបង្ហាញផ្លូវក្នុងតម្លៃ $250។ ពន្ធផ្លូវសម្រាប់ឆ្នាំនេះ ត្រូវបង់ចំនួន $190 ហើយតាមការប៉ាន់ស្មានថ្លៃប្រេងសម្រាប់ឆ្នាំនេះ នឹងមានតម្លៃ $2,105។ Keris ក៏ចង់លាបពណ៌ឡាននេះ ដោយត្រូវចំណាយប្រាក់ $120។ យានដ្ឋានមួយ បានយល់ព្រមដូរកង់ឡាន និងដំឡើងប្រព័ន្ធបង្ហាញផ្លូវរួមគ្នាក្នុងតម្លៃ $600 ប្រសិនបើ Keris បង់ជាសាច់ប្រាក់។

Keris បានសម្រេចចិត្តទិញរថយន្តមួយនេះ ហើយយល់ព្រមយកយានដ្ឋានខាងលើ នៅក្នុងដំណើរការដូរកង់ឡាន និងដំឡើងប្រព័ន្ធបង្ហាញផ្លូវ។

តើឡាននេះមានតំលៃប៉ុន្មាន នៅលើតារាងតុល្យការ?

15) ចំណាយខាងក្រោមនេះ បានកើតមានឡើង ទាក់ទងនឹងដំណើរការហាងសម្ភារកីឡា ដែលលក់សម្ភារកីឡាវាយកូនហ្គោល។ ចូរចាត់ថ្នាក់ចំណាយទាំងនេះ ជាចំណាយមូលធន និងចំណាយប្រតិបត្តិការ ហើយចូរគណនាតម្លៃសរុបសម្រាប់ប្រភេទចំណាយនីមួយៗ។

| | $ |
|---|---|
| ការទិញសម្ភារកីឡាវាយកូនហ្គោលសម្រាប់លក់បន្ត | 1,990 |
| ថ្លៃដំឡើងសំភារបរិក្ខារនៅក្នុងហាង | 5,488 |
| ប្រាក់បៀវត្សសម្រាប់ជំនួយការហាង | 1,656 |
| ចំណាយធានារ៉ាប់រងលើអគារហាង | 868 |
| ថ្លៃដឹកជញ្ជូនសម្រាប់សម្ភារកីឡាវាយកូនហ្គោល | 143 |
| ចំណាយផ្នែកច្បាប់ក្នុងការបង្កើតអាជីវកម្ម | 870 |

16) ចូរចាត់ថ្នាក់នូវប្រតិបត្តិការខាងក្រោមនេះ ជាចំណាយ ឬចំណូល។ បន្ទាប់មក, ចូរចាត់ថ្នាក់នូវចំណាយ និងចំណូលទាំងនេះ ជាមូលធន ឬប្រតិបត្តិការ៖

(a) ការលក់ទឹកត្រីដោយហាងលក់គ្រឿងទេស
(b) ការទិញទូរសម្រាប់ដាក់តាំងទំនិញលក់ ដោយហាងលក់គ្រឿងទេស
(c) ថ្លៃដឹកជញ្ជូនចូលនូវការទិញសម្ភារបន្ទប់ទឹកដោយក្រុមហ៊ុនលក់សម្ភារបន្ទប់ទឹក
(d) លាបថ្នាំថ្មីនៃរថយន្តដែលប្រើប្រាស់នៅក្នុងអាជីវកម្ម
(e) លាបថ្នាំអគារថ្មីដែលទើបសាងសង់រួច
(f) ការទូទាត់ប្រាក់បៀវត្សជូនបុគ្គលិកដំឡើងម៉ាស៊ីនថ្មីនៅក្នុងរោងចក្រ
(g) ការទូទាត់ប្រាក់បៀវត្សជូនបុគ្គលិកជួសជុលម៉ាស៊ីនដែលមានស្រាប់នៅក្នុងរោងចក្រ
(h) ការទិញរថយន្តដោយអ្នកលក់រថយន្តមួយទឹក
(i) ការលក់ឡានដោយក្រុមហ៊ុនផ្តល់ការដឹកជញ្ជូនដល់ផ្ទះ
(j) ចំណូលពីការជួលទទួលបានដោយក្រុមហ៊ុនអាជីវកម្មសំអាតផ្ទះ។

17) ក្លឹបកីឡាសហគមន៍មួយ បានដំណើរការជាអង្គការមិនរកប្រាក់ចំណេញ (NGO)។ ចូរចាត់ថ្នាក់ប្រតិបត្តិការខាងក្រោម ជាចំណាយមូលធន, ចំណាយប្រតិបត្តិការ, ចំណូលមូលធន ឬចំណូលប្រតិបត្តិការ បន្ទាប់មកចូរគណនាទឹកប្រាក់សរុប សម្រាប់ប្រភេទនីមួយៗ។

| | $ |
|---|---|
| ការលក់សម្ភាររបស់ក្លឹបកីឡា | 560 |
| ការទិញសម្ភារការិយល័យសម្រាប់កន្លែងលក់អាហារសម្រន់ | 312 |
| ប្រាក់បៀវត្សសម្រាប់អ្នកសំអាតក្លឹបកីឡា | 89 |
| ការទិញឧបករណ៍ស្ពុកឃ័រថ្មីសម្រាប់ក្លឹបកីឡា | 750 |
| ការចំណាយអគ្គិសនីសម្រាប់ក្លឹបកីឡា | 221 |
| កម្រៃបង់ជាសមាជិកក្លឹបកីឡាប្រចាំឆ្នាំ | 408 |

| | |
|---|---|
| ប្រាក់កម្ចីទទួលបានពីក្រុមប្រឹក្សាមូលដ្ឋាន | 1,200 |
| ថ្លៃដឹកជញ្ជូនចូលនូវឧបករណ៍ស្នូកយ័រថ្មី | 109 |

18) Petra Gadd បានបង្កើតរបាយការណ៍ចំណេញ/ខាត សម្រាប់អាជីវកម្មដំបូងរបស់គាត់។ ទោះបីជាយ៉ាងណាក៏ដោយ, គាត់ បានបង្កើតកំហុសក្នុងការចាត់ថ្នាក់នូវចំណាយមួយចំនួន។

| | $ | $ |
|---|---|---|
| ប្រាក់ចំណេញដុល (Gross profit) | | 5,453 |
| ដកចំណាយ៖ | | |
| ជានារ៉ាប់រង | 423 | |
| ប្រាកបៀវត្ស | 3,123 | |
| ចំណាយដឹកទំនិញចេញ នូវទំនិញដែលបានលក់ | 123 | |
| សម្ភារបរិក្ខារថ្មី | 950 | |
| ចំណាយទីផ្សារ | 765 | |
| ថ្លៃដំឡើងសម្ភារបរិក្ខារថ្មី | 99 | (5,483) |
| ខាតសុទ្ធ (net loss) | | (30) |

នៅក្នុងប្រាក់ចំណេញដុល (gross profit) រួមមានប្រាក់ចំណូលពីការលក់ទ្រព្យសកម្មរយៈវែង ដែលមានចំនួន $320។

ចូររៀបចំរបាយការណ៍ចំណេញ/ខាត ឱ្យបានត្រឹមត្រូវ សម្រាប់ក្រុមហ៊ុនរបស់លោក Petra ។

19) គណនីខាងក្រោម គឺពាក់ព័ន្ធនឹងអាជីវកម្មរបស់ក្រុមហ៊ុន Chappell Ltd.។

ក្រុមហ៊ុន Chappell Ltd

| | $ | $ |
|---|---|---|
| ការលក់ទំនិញ | | 9,800 |
| ថ្លៃដើមទំនិញដែលបានលក់៖ | | |
| សន្និធិដើមគ្រា | 590 | |
| បូក ការទិញទំនិញ | 4,563 | |
| បូក ថ្លៃដឹកជញ្ជូនចូល (Carriage inwards) | 454 | |
| ដក សន្និធិចុងគ្រា | (677) | (4,940) |
| ប្រាក់ចំណេញដុល (Gross profit) | | 4,860 |

ទោះបីជាយ៉ាងណាក៏ដោយ, ក្រោយមក ក្រុមហ៊ុនបានរកឃើញនូវបញ្ហាខាងក្រោម៖

a. យានយន្តដែលប្រើក្នុងអាជីវកម្មត្រូវបានលក់ ដោយទទួលបានប្រាក់ចំណូលចំនួន $725 ដែលត្រូវបានដាក់បញ្ចូលនៅក្នុងតួលេខការលក់ទំនិញខាងលើ។
b. ការទិញគ្រឿងសង្ហារឹមសម្រាប់ការិយាល័យ ត្រូវបានបញ្ចូលក្នុងតួលេខការទិញទំនិញខាងលើ។ តម្លៃគ្រឿងសង្ហារឹមនេះ គឺ $1,160។

c. តួរលេខនៅក្នុងថ្លៃដឹកជញ្ជូនចូល (Carriage inwards) រួមមានថ្លៃដឹកជញ្ជូនចូលនូវទំនិញដែលបានទិញទុកលក់វិញ ក្នុងតម្លៃ $279។ តួលេខដែលនៅសល់ គឺជាចំណាយដឹកជញ្ជូនចូល នូវគ្រឿងសង្ហារឹមការិយាល័យ។

ផ្អែកលើព័ត៌មានខាងលើនេះ ចូរបង្កើតរបាយការណ៍នៃចំណេញដុលខាងលើឡើងវិញ។

# មេរៀនទី៧៖ ទស្សនទាន និងគោលការណ៍ទូទៅគណនេយ្យ

(Chapter 7: Accounting Concepts and Principles)

គោលបំណងនៃមេរៀនទី៧ នេះ ផ្តោតលើ៖

- ក្របខ័ណ្ឌទស្សនាទានគណនេយ្យ
- ស្តង់ដាគណនេយ្យ

ក្រោយបញ្ចប់មេរៀនទី៧ នេះ យើងអាច៖

- យល់ដឹងអំពីគោលការណ៍សំខាន់ៗ ដែលជាតម្រូវការចាំបាច់ក្នុងការបង្ហាញរបាយ-ការណ៍ហិរញ្ញវត្ថុ ជូនអ្នកប្រើប្រាស់។
- យល់ដឹងអំពីទស្សនាទានគណនេយ្យ ដែលយកមកអនុវត្តក្នុងអាជីវកម្ម។
- ស្គាល់នូវការប្រែប្រួលស្តង់ដាគណនេយ្យអន្តរជាតិ ដែលជះឥទ្ធិពលដល់អាជីវកម្ម។

## ៧.១. សេចក្តីផ្តើម

សម្រាប់កិច្ចការគណនេយ្យ តម្រូវឱ្យមានស្តង់ដាសម្រាប់ណែនាំក្នុងការកត់ត្រា និងរាយការណ៍នូវព័ត៌មានគណនេយ្យ សម្រាប់ក្រុមហ៊ុនអាជីវកម្មនីមួយៗ ហើយស្តង់ដាគណនេយ្យ គឺខុសៗគ្នាពីប្រទេសមួយ ទៅប្រទេសមួយ។ ស្តង់ដាគណនេយ្យជាសកល មានពីរសំខាន់ៗ គឺ ១)-GAAP (Generally Accepted Accounting Principles) ដែលត្រូវបានអនុវត្តភាគច្រើននៅសហរដ្ឋអាមេរិច, និង ២)- IFRS (International Financial Reporting Standard) ដែលត្រូវបានអនុវត្តដោយប្រទេសប្រហែល ១១០ រួមមានកម្ពុជាយើងផងដែរ។ ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standards Board-IASB) គឺជាក្រុមដែលតាក់តែង និងរៀបចំកម្រងស្តង់ដាគណនេយ្យអន្តរជាតិ IFRS ។

សម្រាប់ប្រទេសកម្ពុជា យើងបានកំណត់ប្រើប្រាស់ស្តង់ដាគណនេយ្យអន្តរជាតិ (IFRS) ជាមូលដ្ឋានក្នុងការរៀបចំស្តង់ដាគណនេយ្យកម្ពុជា ហៅថា CFRS (Cambodian Financial Reporting Standards) ដែលមាននិយ័តករគណនេយ្យនិងសវនកម្មជាអ្នកទទួលខុសត្រូវក្នុងការរៀបចំ និងតាមដានការអនុវត្តស្តង់ដាទាំងនេះ។ ទោះបីជាយ៉ាងណាក៏ដោយ, មិនមែនគ្រប់ក្រុមហ៊ុនទាំងអស់ត្រូវតែអនុវត្តស្តង់ដាគណនេយ្យ CFRS នោះទេ ពោលគឺមានតែក្រុមហ៊ុនធំៗ ដែលត្រូវលក្ខខណ្ឌកំណត់ដោយច្បាប់ប៉ុណ្ណោះ ចាំបាច់រៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដា CFRS។

សម្រាប់ក្រុមហ៊ុនធុនតូចនិងមធ្យម អាចប្រើប្រាស់ស្តង់ដាគណនេយ្យមួយផ្សេងទៀត នោះគឺស្តង់ដាគណនេយ្យកម្ពុជាសម្រាប់អង្គភាពធុនតូចនិងមធ្យម ដែលហៅថាកាត់ថា CFRS for SME (Cambodian Financial Reporting Standards for SME)។ ទន្ទឹមនេះ, ក្រុមហ៊ុនទាំងអស់ដែលជាប់កាតព្វកិច្ចបង់ពន្ធជូនរដ្ឋ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ទៅតាមច្បាប់ពន្ធដាររបស់ប្រទេសកម្ពុជាផងដែរ។

## ៧.២. គោលការណ៍គណនេយ្យសំខាន់ៗ

ការអនុវត្តជាទូទៅនៃកិច្ចការគណនេយ្យ ត្រូវបានធ្វើឡើងជាបណ្តើរៗ។ នីតិវិធីនៃការអនុវត្តកិច្ចការគណនេយ្យទាំងនេះ ត្រូវបានយកទៅអនុវត្តដោយគណនេយ្យករ ដោយនីតិវិធីទាំងនេះត្រូវបានអនុវត្តដោយគោរពតាមគោលការណ៍ និងចរិតលក្ខណៈមួយចំនួនដែលត្រូវបានគេទទួលយកជាទូទៅ។ គោលការណ៍ និងចរិតលក្ខណៈជាមូលដ្ឋាន គឺជាការសន្មតជាទូទៅនូវការបង្ហាញព័ត៌មានហិរញ្ញវត្ថុនៅក្នុងគណនីនីមួយៗរបស់អង្គភាពអាជីវកម្ម។ ការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុ ត្រូវតែ/គួរតែគោរពតាមគោលការណ៍ និងមានចរិតលក្ខណៈទាំងនេះ ដើម្បីផ្តល់ជូនអ្នកប្រើប្រាស់ នូវរបាយការណ៍ហិរញ្ញវត្ថុដែលអាចធ្វើការសម្រេចចិត្តមួយត្រឹមត្រូវ និងទាន់ពេលវេលា។ អ្នកប្រើប្រាស់ព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុនអាជីវកម្មរួមមាន៖

- អ្នកវិនិយោគ
- បុគ្គលិកក្រុមហ៊ុន
- អ្នកផ្តល់កម្ចី (រួមទាំងធនាគារ)
- អ្នកផ្គត់ផ្គង់
- អតិថិជន
- រដ្ឋាភិបាល
- សាធារណៈជន

ខាងក្រោមនេះ គឺជាការបង្ហាញអំពីគោលការណ៍គណនេយ្យ៖

### ៧.២.១. អង្គភាពអាជីវកម្ម (Business Entity)

ការកត់ត្រាគណនេយ្យសម្រាប់ក្រុមហ៊ុនអាជីវកម្មមួយ ត្រូវធ្វើឡើងតែសម្រាប់អាជីវកម្មនោះតែប៉ុណ្ណោះ មានន័យថារាល់ប្រតិបត្តិការទាំងឡាយណាដែលជាប់ពាក់ព័ន្ធនឹងការងារផ្ទាល់ខ្លួនរបស់ម្ចាស់ក្រុមហ៊ុន មិនត្រូវបានកត់ត្រានៅក្នុងបញ្ជីគណនីរបស់ក្រុមហ៊ុននោះឡើយ។ ក្នុងន័យនេះ, ក្រុមហ៊ុនអាជីវកម្ម ត្រូវចាត់ទុកថាជាអង្គភាពប្រកបអាជីវកម្មដាក់ដោយឡែកមួយពីម្ចាស់ក្រុមហ៊ុន (ឧទាហរណ៍៖ លុយដែលម្ចាស់ក្រុមហ៊ុនចាយវាយផ្ទាល់ខ្លួន មិនត្រូវពាក់ព័ន្ធនឹងលុយដែលប្រើប្រាស់នៅក្នុងក្រុមហ៊ុនអាជីវកម្មឡើយ)។

### ៧.២.២. និរន្តរភាពអាជីវកម្ម (Going Concern)

ការសន្មតអំពីនិរន្តរភាពអាជីវកម្ម មានន័យថាក្រុមហ៊ុនអាជីវកម្មមួយនឹងបន្តការរកស៊ីលក់ដូររបស់ខ្លួនក្នុងរយៈពេលមួយសម្របសម្រួលនាពេលខាងមុខ ដោយមិនត្រូវបញ្ឈប់ការរកស៊ីរបស់ខ្លួនក្នុងរយៈពេលមួយឆ្នាំ ឬពីរឆ្នាំខាងមុខនោះទេ ហើយដាក់ដេញថ្លៃលក់ឡាយឡុងនូវទ្រព្យរបស់ក្រុមហ៊ុននោះឡើយ។ ដូចនេះ តម្លៃទឹកប្រាក់ដែលបង្ហាញនៅក្នុងគណនីទ្រព្យសកម្មរបស់ក្រុមហ៊ុន ត្រូវកំណត់តាមតម្លៃមួយដែលអាចវាស់វែងបាន និងមានភស្តុតាងបញ្ជាក់ត្រឹមត្រូវ។

### ៧.២.៣. មូលដ្ឋានបង្គរ ( Accrual Basis Accounting )

ទស្សនាទានមូលដ្ឋានបង្គរ មានន័យថារបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើង ផ្អែកលើមូលដ្ឋានដែលថាចំណូល និងចំណាយត្រូវទទួលស្គាល់នៅពេលដែលចំណូល និងចំណាយទាំងអស់បានកើតឡើង បើទោះបីជាសាច់ប្រាក់ត្រូវបានទូទាត់នៅក្នុងពេលវេលាផ្សេងក៏ដោយ។ ឧទាហរណ៍៖ ក្រុមហ៊ុនលក់គ្រឿងអគ្គិសនី បានលក់ទូរទឹកកកជូនអតិថិជនរបស់ខ្លួនក្នុងតម្លៃ $1,000 នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ប៉ុន្តែអតិថិជនរបស់ក្រុមហ៊ុននឹងទូទាត់ប្រាក់នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០២១។ ផ្អែកតាមមូលដ្ឋានគណនេយ្យបង្គរ ក្រុមហ៊ុននេះ ត្រូវចាត់ទុកថាចំណូល $1,000 គឺជាចំណូលក្នុងឆ្នាំ២០២០ ពុំមែនជាចំណូលក្នុងឆ្នាំ ២០២១ នោះទេ។

### ៧.២.៤. គោលការណ៍តម្លៃដើមគ្រា ( Historical Cost )

នៅពេលណាដែលទ្រព្យសកម្មទាំងចរន្ត និងរយៈពេលវែង អាចត្រូវបានកំណត់តាមតម្លៃដើមដែលទ្រព្យសកម្មទាំងនោះត្រូវបានទិញចូល នោះយើងចាត់ទុកថាជាការអនុវត្តតាមគោលការណ៍ថ្លៃដើម។ តម្លៃដើមរបស់ទ្រព្យសកម្មទាំងនេះ គឺជាតម្លៃសត្យានុម័ត និងមានភស្តុតាងបញ្ជាក់ត្រឹមត្រូវ ដែលមានន័យថាតម្លៃនេះ ត្រូវចាត់ទុកថាត្រឹមត្រូវ ឬអាចទទួលយកបានជាងតម្លៃកើតចេញពីការវាយតម្លៃមួយចំនួនដែលគ្មានភស្តុតាងបញ្ជាក់ត្រឹមត្រូវ ឬកើតឡើងដោយសន្មត់ផ្សេងៗ។ ឧទាហរណ៍ តម្លៃអគារការិល័យរបស់ក្រុមហ៊ុនបានបង្ហាញតម្លៃ $100,000 នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដែលតម្លៃនេះជាតម្លៃដើមដែលក្រុមបានទិញកាលថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨។

### ៧.២.៥. សង្គតិភាព ( Consistency )

សង្គតិភាព សំដៅដល់ការប្រើប្រាស់នូវវិធីសាស្ត្រដូចគ្នាសម្រាប់ប្រភេទដូចគ្នាទាំងពីកំឡុងពេលមួយ ទៅកំឡុងពេលមួយទៀត ឬនៅក្នុងកំឡុងពេលតែមួយ ពីក្រុមហ៊ុនទៅក្រុមហ៊ុនមួយទៀត។ គោលការណ៍សង្គតិភាពនេះ នឹងជួយឱ្យសម្រេចបាននូវភាពអាចប្រៀបធៀបបាននៃរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងក្រុមហ៊ុនផ្ទាល់ ឬរវាងក្រុមហ៊ុននិងក្រុមហ៊ុន។

### ៧.២.៦. ភាពជាសារវន្ត ( Materiality )

ភាពជាសារវន្ត មានន័យថា ព័ត៌មានជាសារវន្ត ប្រសិនបើបាត់ ឬបង្ហាញខុសនូវព័ត៌មាននោះនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ នឹងធ្វើឱ្យមានឥទ្ធិពលដល់ការសម្រេចចិត្តរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនោះ។ គោលការណ៍ភាពជាសារវន្តនេះ ក៏នឹងជួយឱ្យក្រុមហ៊ុនរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដោយត្រូវបង្ហាញរាល់ព័ត៌មានសំខាន់ៗ ហើយប្រសិនបើព័ត៌មានណាមិនសំខាន់ ក្រុមហ៊ុនធ្វើការបង្ហាញជាសរុបរួមមួយបាន។

### ៧.២.៧. គោលការណ៍ប្រុងប្រយ័ត្ន ( Prudence )

គោលការណ៍ប្រុងប្រយ័ត្ន មានន័យថាការគិតគូរដោយប្រុងប្រយ័ត្ន នៅពេលធ្វើការវិនិច្ឆ័យ ឬសម្រេចចិត្តក្រោមកាលៈទេសៈមិនច្បាស់លាស់។ គោលការណ៍ប្រុងប្រយ័ត្ន ទាមទារឱ្យ

គណនីត្រូវរៀបចំដោយមានការប្រុងប្រយ័ត្នក្នុងកម្រិតមួយដែលអាចទទួលយកបាន។ ឧទាហរណ៍៖ ការវាយតម្លៃសន្និធិនៅចុងគ្រា មិនត្រូវផ្អែកលើតម្លៃដែលខ្ពស់ហួសហេតុពេក ពោលគឺ តម្លៃសន្និធិចុងគ្រាត្រូវបានកំណត់ថា ជាតម្លៃទាបជាងគេរវាងតម្លៃដើម(Cost) និងតម្លៃទទួលស្គាល់សុទ្ធ (Net Realizable Value)។

### ៧.២.៨. គោលការណ៍ទ្វេភាគ (Duality)

គោលការណ៍ទ្វេភាគ ត្រូវភ្ជាប់ជាមួយនឹងសមីការគណនេយ្យដែលបានសិក្សានៅក្នុងមេរៀនទី២ រួចហើយ។ ប្រតិបត្តិការហិរញ្ញវត្ថុនីមួយៗ ត្រូវមានឥទ្ធិពលពីរទៅលើក្រុមហ៊ុន ហើយនឹងកើតមាននូវការកត់ត្រាពីរ ដែលម្ខាងកត់ត្រាខាងឥណពន្ធ(Debit) និងម្ខាងទៀតកត់ត្រាខាងឥណទាន (credit)។ ទឹកប្រាក់សរុបក្នុងការកត់ត្រាខាងឥណពន្ធ ត្រូវស្មើនឹងទឹកប្រាក់សរុបក្នុងការកត់ត្រាខាងឥណទាន។

### ៧.២.៩. គោលការណ៍ទទួលស្គាល់ (Realization)

គោលការណ៍ទទួលស្គាល់ សំដៅដល់ការទទួលស្គាល់ប្រតិបត្តិការនៅពេលដែលកើតមានឡើង។ ឧទាហរណ៍ ចំណូលត្រូវទទួលស្គាល់នៅពេលដែលកម្មសិទ្ធិនៃភាពជាម្ចាស់នៃទំនិញ/សេវាត្រូវបានផ្ទេរពីអ្នកលក់ ទៅអ្នកទិញ។ ក្នុងន័យនេះ, ការទទួលស្គាល់ប្រតិបត្តិការកើតឡើង មិនជាប់ពាក់ព័ន្ធនឹងការទទួលបាន/ទូទាត់សាច់ប្រាក់ឡើយ។ ម្យ៉ាងវិញទៀត, ការលក់ដោយជំពាក់ ត្រូវទទួលស្គាល់នៅពេលដែលទំនិញ/សេវា បានផ្តល់ជូនអតិថិជន។

## ៧.៣. ចរិតលក្ខណៈដែលធ្វើឱ្យព័ត៌មានហិរញ្ញវត្ថុអាចប្រើការបាន

ផ្អែកតាមក្របខ័ណ្ឌទស្សនាទានសម្រាប់របាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០១៨ ដើម្បីធ្វើឱ្យព័ត៌មានហិរញ្ញវត្ថុនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ កាន់តែផ្តល់អត្ថប្រយោជន៍សម្រាប់អ្នកប្រើប្រាស់ ត្រូវមានចរិតលក្ខណៈមួយចំនួនជាចាំបាច់។ ក្នុងចំណោមចរិតលក្ខណៈនៃព័ត៌មានហិរញ្ញវត្ថុទាំងនេះ, ក្របខ័ណ្ឌទស្សនាទានសម្រាប់របាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០១៨ បានកំណត់ចរិតលក្ខណៈសំខាន់បំផុតចំនួន ២ ដែលរាល់ការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុ ត្រូវតែមានលក្ខណៈទាំងពីរនេះជាចាំបាច់ នោះគឺ៖

### ៧.៣.១. សមានគតិភាព (Relevance)

ព័ត៌មានដែលមានសមានគតិភាព ត្រូវតែអាចផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់ព័ត៌មានទាំងនេះ ធ្វើការសម្រេចចិត្តដាច់ដោយឡែកមួយ។ ព័ត៌មានហិរញ្ញវត្ថុ ដែលអាចធ្វើការសម្រេចចិត្តដាច់ដោយឡែកមួយ ត្រូវតែមានតម្លៃព្យាករបាន(Predictive Value) ឬតម្លៃអាចបញ្ជាក់បាន (Confirmative Value) ឬមានតម្លៃទាំងពីរ។ តម្លៃព្យាករបាន(Predictive Value) មានន័យថាព័ត៌មានអាចធ្វើការព្យាករបាន និងអាចមានឥទ្ធិពលលើការសម្រេចចិត្តនាពេលខាងមុខបាន។ តម្លៃបញ្ជាក់បាន (Confirmative Value) មានន័យថាព័ត៌មានអាចប្រើសម្រាប់ផ្ទៀងផ្ទាត់ ឬបញ្ជាក់ ឬសូម្បីតែអាចកែសម្រួលឱ្យត្រឹមត្រូវ មុនធ្វើការព្យាករព័ត៌មានទាំងនោះបាន។

ឧទាហរណ៍៖ ក្រុមហ៊ុនលក់ទូរសព្ទដៃមួយដែលមានលក់ទូរសព្ទដៃម៉ាកសាមស៊ុងក្នុងចំនួនមួយដ៏ច្រើនក្នុងឆ្នាំនេះ គ្រោងនឹងលក់ម៉ូដែលថ្មីនៃទូរសព្ទម៉ាកសាមស៊ុងនេះក្នុងឆ្នាំបន្ទាប់។ ដូចនេះក្រុមហ៊ុនបានព្យាករការលក់ទូរសព្ទម៉ូដែលថ្មីនេះ តាមការលក់ទូរសព្ទម៉ូដែលចាស់ (មានន័យថាព័ត៌មានគឺអាចព្យាករបាន)។ ប៉ុន្តែការលក់ជាក់ស្តែងក្នុងត្រីមាសទី១ គឺទាបជាងការរំពឹងទុក នោះក្រុមហ៊ុនត្រូវធ្វើការកែសម្រួលគម្រោងថវិកាសម្រាប់ត្រីមាសបន្តបន្ទាប់ (មានន័យថាព័ត៌មានគឺអាចបញ្ជាក់បាន)។

### ៧.៣.២. ភាពតំណាងពេញលេញ( Faithful Representation )

ដើម្បីឱ្យព័ត៌មានមានភាពតំណាងពេញលេញ ព័ត៌មានទាំងនោះត្រូវតែ៖ ១).ពេញពេញ (Complete), ២).អព្យាក្រឹត (Neutral) និង ៣).មិនមានកំហុសឆ្គង(Free from error)។ ពេញពេញ(Complete)មានន័យថាព័ត៌មានត្រូវតែរួមបញ្ចូលគ្រប់ព័ត៌មានដែលចាំបាច់ទាំងអស់ (ត្រូវរាយការណ៍ទាំងការពិពណ៌នា និងការពន្យល់អំពីព័ត៌មានទាំងនោះ) ដើម្បីឱ្យអ្នកប្រើប្រាស់យល់អំពីព័ត៌មានដែលបង្ហាញបាន។ អព្យាក្រឹត (Neutral) មានន័យថា ព័ត៌មានត្រូវតែមិនលម្អៀងក្នុងការជ្រើសរើស ឬបង្ហាញការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុឡើយ ពោលគឺព័ត៌មានមិនត្រូវបានក្លែងបន្លំ ដែលនឹងធ្វើឱ្យអ្នកប្រើប្រាស់ធ្វើការសម្រេចខុសនោះឡើយ។ មិនមានកំហុសឆ្គង(Free from error) មានន័យថា ព័ត៌មានគឺគ្មានកំហុសឆ្គង ឬលប់បំបាត់ ឬក៏មិនមានកំហុសនៅក្នុងដំណើរការនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

ក្រៅពីចរឹកលក្ខណៈជាមូលដ្ឋានពីរខាងលើ, ដើម្បីធ្វើឱ្យព័ត៌មានហិរញ្ញវត្ថុកាន់តែផ្តល់ប្រយោជន៍ច្រើនដល់អ្នកប្រើប្រាស់ ព័ត៌មានគួរតែមានចរឹកលក្ខណៈ ៤ បន្ថែមទៀត ដូចខាងក្រោមនេះ៖

### ៧.៣.៣. ភាពអាចប្រៀបធៀបបាន ( Comparability )

ព័ត៌មានដែលអាចប្រៀបធៀបបាន នឹងជួយឱ្យអ្នកប្រើប្រាស់អាចកំណត់ ឬយល់ដឹងនូវភាពដូចគ្នា ឬខុសគ្នា នៅក្នុងប្រភេទព័ត៌មាននោះ។ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ត្រូវរៀបចំពីមួយពេលទៅមួយពេល ត្រូវតែអាចធ្វើការប្រៀបធៀបបានក្នុងកម្រិតក្រុមហ៊ុនផ្ទាល់ ឬជាមួយក្រុមហ៊ុនផ្សេងទៀតតែក្នុងវិស័យតែមួយ។ ភាពអាចប្រៀបធៀបបានទាមទារនូវការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ត្រូវតែឈរលើមូលដ្ឋាននៃសង្គតិភាពដែលបានបង្ហាញនៅក្នុងចំណុចខាងលើនៃមេរៀននេះ។

### ៧.៣.៤. ភាពអាចផ្ទៀងផ្ទាត់បាន( Verifiability )

ព័ត៌មានដែលអាចផ្ទៀងផ្ទាត់បាន គឺជាព័ត៌មានដែលអាចបញ្ជាក់បានពីភាគីឯករាជ្យណាមួយ ហើយព័ត៌មានទាំងនោះអាចផ្តល់ឱ្យអ្នកប្រើប្រាស់ធ្វើការសម្រេចបានល្អ ឬត្រឹមត្រូវជាងព័ត៌មានដែលមិនមានភាគីឯករាជ្យបញ្ជាក់បាន។ ភាពអាចផ្ទៀងផ្ទាត់បាន មានន័យថា ទទួលបានព័ត៌មានដូចគ្នា អ្នកប្រើប្រាស់មួយចំនួនអាចនឹងធ្វើការសន្និដ្ឋានបានដូចគ្នា។

### ៧.៣.៥. ភាពទាន់ពេលវេលា ( Timeliness )

ភាពទាន់ពេលវេលា មានន័យថាអ្នកធ្វើការសម្រេចចិត្តទទួលបានព័ត៌មានទាន់ពេលវេលា ហើយប្រើប្រាស់ព័ត៌មានទាំងនេះក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ ជាទូទៅ, ព័ត៌មានកាន់តែចាស់ កាន់តែគ្មានប្រយោជន៍សម្រាប់អ្នកធ្វើការសម្រេចចិត្ត។ ដូចនេះ ប្រសិនបើក្រុមហ៊ុនពន្យាពេលក្នុងការផ្សព្វផ្សាយព័ត៌មានហិរញ្ញវត្ថុ នោះព័ត៌មានទាំងនោះនឹងក្លាយជាព័ត៌មានគ្មានប្រយោជន៍ ឬមានប្រយោជន៍កាន់តែតិច សម្រាប់អ្នកប្រើប្រាស់។ ប៉ុន្តែភាពទាន់ពេលវេលានៃការផ្សព្វផ្សាយព័ត៌មាននេះ ក៏ត្រូវគិតអំពីភាពជឿងជាក់បាននៃព័ត៌មានផងដែរ មានន័យថាផ្សព្វផ្សាយព័ត៌មានកាន់តែលឿន នោះគុណភាពនៃព័ត៌មានក៏នឹងធ្លាក់ចុះផងដែរ។

### ៧.៣.៦. ភាពអាចយល់បាន ( Understandability )

ភាពអាចយល់បាន មានន័យថាព័ត៌មានត្រូវបានចាត់ថ្នាក់ រៀបចំ និងបង្ហាញបានច្បាស់លាស់ និងយ៉ាងល្អិតល្អន់។ របាយការណ៍ហិរញ្ញវត្ថុត្រូវរៀបចំសម្រាប់អ្នកប្រើប្រាស់ដែលមានចំណេះដឹងផ្នែកអាជីវកម្ម ឬផ្នែកសេដ្ឋកិច្ច និងសម្រាប់អ្នកវិភាគព័ត៌មានទាំងនោះ។ ដូចនេះសម្រាប់ប័ត៌មានដែលមានភាពស៊ាំញុាំ ពិបាកយល់ ក្រុមហ៊ុនមិនត្រូវបង្ហាញព័ត៌មានទាំងនោះបែបធម្មតានោះទេ ប៉ុន្តែត្រូវមានការពន្យល់នូវព័ត៌មានទាំងនោះឱ្យបានលម្អិត។

## ៧.៤. សេចក្តីផ្តើមអំពីស្តង់ដាគណនេយ្យ

ដូចបានបញ្ជាក់នៅក្នុងសេចក្តីផ្តើមនៃមេរៀននេះ ស្តង់ដាគណនេយ្យអន្តរជាតិ ត្រូវបានប្រើប្រាស់ភាគច្រើនសម្រាប់តែក្រុមហ៊ុនសាជីវកម្មតែប៉ុណ្ណោះ។ សម្រាប់ក្រុមហ៊ុនឯកកម្មសិទ្ធិ និងក្រុមហ៊ុនសហកម្មសិទ្ធិ មិនតម្រូវឱ្យអនុវត្តតាមស្តង់ដានេះឡើយ។ ស្តង់ដាគណនេយ្យអន្តរជាតិនេះ ពុំមែនជាច្បាប់ឡើយ។ ផ្ទុយទៅវិញ ក្រុមហ៊ុនទាំងឡាយត្រូវអនុវត្តតាមច្បាប់ពាណិជ្ជកម្មដែលដាក់ចេញដោយរដ្ឋាភិបាលរបស់ប្រទេសមួយ។ ទោះបីជាយ៉ាងក៏ដោយស្តង់ដាគណនេយ្យអន្តរជាតិ ក៏ជាផ្នែកមួយនៃច្បាប់ពាណិជ្ជកម្មផងដែរ ដែលតម្រូវឱ្យក្រុមហ៊ុនទាំងអស់មានបញ្ជីការគណនេយ្យឱ្យស្របតាមស្តង់ដាគណនេយ្យអន្តរជាតិនេះ។

ជារួម ការបង្កើតឡើងនូវស្តង់ដាគណនេយ្យអន្តរជាតិ ត្រូវបានធ្វើឡើងជាពីរដំណាក់កាល។ ដំបូងឡើងស្តង់ដាគណនេយ្យអន្តរជាតិ ត្រូវបានបង្កើតឡើងដោយគណៈកម្មាធិការស្តង់ដាគណនេយ្យអន្តរជាតិ( International Accounting Standards Committee-IASC ) ដោយបានអនុម័តដាក់ឱ្យប្រើប្រាស់ស្តង់ដាគណនេយ្យអន្តរជាតិហៅថា IAS ។ ក្រោយមក, គណៈកម្មាធិការស្តង់ដាគណនេយ្យអន្តរជាតិ( IASC ) ក៏ត្រូវបានជំនួយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ ( International Accounting Standards Body-IASB ) ដោយបានអនុម័តនូវស្តង់ដាគណនេយ្យអន្តរជាតិ ហៅថា IFRS និងធ្វើការកែសម្រួលស្តង់ដាគណនេយ្យអន្តរជាតិ IAS ឱ្យស្របតាមបរិបទនៃការប្រែប្រួលទិដ្ឋភាពសេដ្ឋកិច្ច និងសង្គមបច្ចុប្បន្ន។

ដូចនេះ, ស្តង់ដាគណនេយ្យអន្តរជាតិ រួមមានទាំង IAS និង IFRS ដែលក្រុមហ៊ុនអាជីវកម្មត្រូវអនុលោមតាម។ ស្តង់ដាគណនេយ្យអន្តរជាតិទាំងនោះរួមមាន៖

| ស្តង់ដា | ការពិពណ៌នា |
|---|---|
| IAS 1 | Presentation of financial statements |
| IAS 2 | Inventories |
| IAS 7 | Statement of cash flow |
| IAS 8 | Accounting policies, changes in accounting estimates and errors |
| IAS 10 | Events after the reporting periods |
| IAS 12 | Income taxes |
| 1AS 16 | Property, plant and equipment |
| IAS 19 | Employee benefits |
| IAS 20 | Accounting for government grants and disclosure of government assistance |
| IAS 21 | The effects of changes in foreign exchange rates |
| IAS 23 | Borrowing costs |
| IAS 24 | Related party disclosures |
| IAS 26 | Accounting and reporting by retirement benefit plans |
| IAS 27 | Separate financial statement |
| IAS 28 | Investment in associates and joint ventures |
| IAS 32 | Financial instruments: Presentation |
| IAS 33 | Earning per share |
| IAS 34 | Interim financial reporting |
| IAS 36 | Impairment of assets |
| IAS 37 | Provisions, contingent liabilities and contingent assets |
| IAS 38 | Intangible assets |
| IAS 39 | Financial instrument: Recognition and measurement |
| IAS 40 | Investment property |
| IAS 41 | Agriculture |
| IFRS 1 | First-time adaptation of financial reporting standards |
| IFRS 2 | Share-based payment |
| IFRS 3 | Business combinations |
| IFRS 5 | Non-current assets held for sale and discontinued operations |
| IFRS 6 | Exploration for and evaluation of mineral resources |

| ស្តង់ដា | ការពិពណ៌នា |
|---|---|
| IFRS 7 | Financial instruments: Disclosures |
| IFRS 8 | Operating segments |
| IFRS 9 | Financial instruments |
| IFRS 10 | Consolidated financial statements |
| IFRS 11 | Joint arrangements |
| IFRS 12 | Disclosure of interests in other entities |
| IFRS 13 | Fair value measurement |
| IFRS 14 | Regulatory deferral accounts |
| IFRS 15 | Revenue from contracts with customers |
| IFRS 16 | Leases |
| IFRS 17 | Insurance contracts |

ប្រភព៖ https://www.ifrs.org/issued-standards/list-of-standards/

## ៧.៥. សេចក្តីសន្និដ្ឋាន

ជារួម មេរៀនទី៧ នេះ បានបង្ហាញក្របខ័ណ្ឌនៃការរៀបចំការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុជូនអ្នកប្រើប្រាស់ទាំងអស់ ឱ្យបានសុក្រឹត្យ ត្រឹមត្រូវ និងទាន់ពេលវេលា ដោយសារអ្នកប្រើប្រាស់ត្រូវការជាចាំបាច់នូវព័ត៌មានទាំងនេះ ដើម្បីធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងក្រុមហ៊ុនអាជីវកម្មទាំងនេះ។ ដូចនេះ ដើម្បីឱ្យព័ត៌មានហិរញ្ញវត្ថុទាំងអស់នោះ មានគុណភាពសម្រាប់អ្នកប្រើប្រាស់ ក្រុមហ៊ុនអាជីវកម្មចាំបាច់ត្រូវតែគោរពតាមគោលការណ៍គណនេយ្យ និងចរិតលក្ខណៈនៃព័ត៌មានហិរញ្ញវត្ថុដែលមានពន្យល់ក្នុងមេរៀននេះ និងជាពិសេស ត្រូវរៀបចំគណនីនីមួយៗនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឱ្យស្របតាមស្តង់ដាគណនេយ្យអន្តរជាតិ។

# លំហាត់៖

## I. សំណួរពហុជ្រើសរើស (MCQ)

1) ចំណូលត្រូវបានទទួលស្គាល់នៅពេលទំនិញ/សេវាត្រូវបានលក់ជូនអតិថិជន និងចំណាយត្រូវបានទទួលស្គាល់ថាបានកើតមានឡើងនៅពេលទំនិញ/សេវាត្រូវបានប្រគល់-ទទួល។ តើនេះជាគោលការណ៍គណនេយ្យមួយណាខាងក្រោម?
   a. Business entity
   b. Materiality
   c. Accruals
   d. Duality

2) តើគោលការណ៍គណនេយ្យខាងក្រោមមួយណា បានចែងថា ការលប់បំបាត់ ឬការរាយការណ៍ខុសនូវព័ត៌មានហិរញ្ញវត្ថុ អាចធ្វើឱ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ សម្រេចចិត្តខុស?
   a. Consistency
   b. Accruals
   c. Materiality
   d. Going concerns

3) ដើម្បីឱ្យព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពតំណាងពេញលេញ (faithful representation) តើពីរចំណុចណាក្នុងចំណោមចំណុចខាងក្រោម ជាផ្នែកនៃភាពតំណាងពេញលេញ (faithful representation)?
   1. អព្យាក្រឹត្យ (Neutral)
   2. សមានគតិភាព (Relevance)
   3. ការបង្ហាញត្រឹមត្រូវ (Fair presentation)
   4. ការមិនមានកំហុងឆ្គងជាសារវន្ត (Free from material error)
      a. 1 និង 2
      b. 1 និង 3
      c. 1 និង 4
      d. 3 និង 4

4) តើខាងក្រោមនេះមួយណាជាគោលការណ៍គណនេយ្យដែលថា ប្រភេទព័ត៌មានហិរញ្ញវត្ថុដូចគ្នាត្រូវតែអនុវត្តវិធីសាស្ត្រគណនេយ្យដូចគ្នា?
   a. Prudence
   b. Accruals
   c. Historical cost
   d. Consistency

5) ខាងក្រោមនេះ ជាប្រភេទនៃចរិតលក្ខណៈអំពីព័ត៌មានហិរញ្ញវត្ថុ៖

1. សមានគតិភាព (Relevance)
2. សង្គតិភាព (Consistency)
3. ភាពតំណាងពេញលេញ (Faithful representation)
4. ភាពត្រឹមត្រូវ (Accuracy)

តើពីរណាក្នុងចំណោមចរិតលក្ខណៈខាងលើនេះ គឺជាចរិតលក្ខណៈដែលធ្វើឱ្យការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុ មានប្រយោជន៍សម្រាប់អ្នកប្រើប្រាស់ យោងតាមក្របខ័ណ្ឌទស្សនាទាននៃការរាយការណ៍ហិរញ្ញវត្ថុ?

a. 1 និង 2
b. 2 និង 4
c. 3 និង 4
d. 1 និង 3

## II. ចូរផ្គូរផ្គងនូវពាក្យគន្លឹះខាងក្រោម៖

| | |
|---|---|
| 1. Business entity | A. របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយសន្មត់តាមមូលដ្ឋានដែលថាក្រុមហ៊ុនដែលបានរាយការណ៍ នឹងនៅតែបន្តដំណើការអាជីវកម្មរបស់ខ្លួនក្នុងរយៈពេលខាងមុខបាន។ |
| 2.Duality | B. ក្នុងកាលៈទេសៈដែលមានភាពមិនប្រាកប្រជា ការវិនិច្ឆ័យ ឬសម្រេចចិត្ត ត្រូវធ្វើឡើងដោយប្រុងប្រយ័ត្នខ្ពស់។ |
| 3. Going Concern | C. ការរាយការណ៍ហិរញ្ញវត្ថុ ត្រូវធ្វើឡើងដោយមានការចាត់ថ្នាក់ រៀបចំ និងបង្ហាញ ឱ្យបានច្បាស់លាស់ និងលម្អិតល្អន់។ |
| 4. Materiality | D. ក្រុមហ៊ុនអាជីវកម្មមួយ គឺជានីតិបុគ្គលដាច់ដោយឡែកពីម្ចាស់ក្រុមហ៊ុន ឬអ្នកគ្រប់គ្រង។ |
| 5. Historical cost | E. ព័ត៌មានត្រូវបានលប់ ឬបង្ហាញខុស នឹងធ្វើឱ្យអ្នកប្រើប្រាស់ ធ្វើការសម្រេចចិត្តខុស។ |
| 6. Prudence | F. អ្នកប្រើប្រាស់ដែលមានចំណេះដឹង និងភាពឯករាជ្យផ្សេងៗគ្នា អាចធ្វើការសន្និដ្ឋានដូចគ្នា ពីព័ត៌មានទទួលបានតែមួយ។ |
| 7. Comparability | G. គឺជាប្រព័ន្ធគណនេយ្យដែលបង្ហាញថា ប្រតិបត្តិការហិរញ្ញវត្ថុត្រូវរងនូវឥទ្ធិពលពីរ គឺការកត់ត្រាខាង Debit និង ខាង Credit។ |

| | |
|---|---|
| 8. Timeliness | H. ទ្រព្យសកម្ម ត្រូវបានបង្ហាញតម្លៃនៅថ្ងៃទ្រព្យសកម្មនោះត្រូវបានទិញចូល។ |
| 9. Understandability | I. អ្នកប្រើប្រាស់អាចកំណត់ និងយល់ដឹងអំពីភាពដូចគ្នា និងភាពខុសគ្នានៃព័ត៌មានដែលបានរាយការណ៍។ |
| 10. Verifiability | J. ព័ត៌មានហិរញ្ញវត្ថុអាចដល់ដៃអ្នកប្រើប្រាស់ទាន់ពេលវេលា ដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវផ្អែកតាមព័ត៌មាននោះ។ |

## III. សំណួរត្រិះរិះ

1) ចូររៀបរាប់ប្រភេទអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនអាជីវកម្ម ឱ្យបានចំនួន ៤?

2) ចូរកំណត់គោលការណ៍គណនេយ្យ (accounting principles) សម្រាប់សេណារីយ៉ូខាងក្រោម៖

a) សន្និធិត្រូវបានកំណត់តម្លៃតាមតម្លៃលក់ ដោយសន្មត់ថាក្រុមហ៊ុនលក់ទំនិញអស់ មិនដែលនៅសល់ទេ។

b) ម្ចាស់ក្រុមហ៊ុនឯកកម្មសិទ្ធិ បានសម្រេចថាបញ្ចូលចំណាយថ្លៃសាំងរថយន្តដែលគាត់បានប្រើទាំងដើម្បីការងារ និងកិច្ចការផ្ទាល់ខ្លួន នៅក្នុងចំណាយរបស់ក្រុមហ៊ុន។

c) ក្រុមហ៊ុនប្រភេទដូចគ្នានឹងក្រុមហ៊ុនរបស់យើង ថ្មីៗនេះត្រូវបានដាក់លក់ក្នុងតម្លៃ $80,000 តម្លៃជាងតម្លៃទ្រព្យសុទ្ធរបស់ក្រុមហ៊ុន (net assets)។ ហេតុនេះ ម្ចាស់ក្រុមហ៊ុនរបស់យើង មានបំណងចង់បញ្ចូលតម្លៃលើសពីតម្លៃទ្រព្យសុទ្ធរបស់ក្រុមហ៊ុននេះទៅក្នុង ទ្រព្យសកម្មរយៈពេលវែង (Goodwill) ដោយសារគាត់ជឿជាក់ថា តម្លៃក្រុមហ៊ុន គឺមានតម្លៃលើសពីទ្រព្យសុទ្ធដែលមានបច្ចុប្បន្ន។

d) ការបញ្ចូលចំណូលការលក់ទំនិញទៅក្នុងបញ្ជីអតិថិជនដែលបានទិញជាទៀងទាត់ មុនពេលអតិថិជនធ្វើការបញ្ជាទិញ។

3) ចូរកំណត់គោលការណ៍គណនេយ្យពាក់ព័ន្ធ សម្រាប់ករណីខាងក្រោម៖

a) ការដកចំនួនទឹកប្រាក់ដែលទូទាត់ចំណាយធានារ៉ាប់រង ដោយសារចំណាយនោះនឹងកើតឡើងនៅឆ្នាំក្រោយ។

b) ការរក្សានៅដដែលនូវអត្រាសំវិធានធនសម្រាប់បំណុលសង្ស័យអតិថិជនមិនសង បើទោះបីជាអត្រានេះមិនអាចកំណត់ថាត្រឹមត្រូវសម្រាប់ការកំណត់បំណុលអតិថិជនមិនសងនាពេលអនាគតក៏ដោយ។

c) ការកំណត់តម្លៃសន្និធិចុងគ្រា តាមតម្លៃលក់សម្រាប់អាជីវកម្មជោគជ័យ។

d) ការកំណត់យកតម្លៃទ្រព្យសកម្មរយៈពេលវែងតាមតម្លៃទីផ្សារ។

4) ចូរកំណត់ចរិតលក្ខណៈនៃព័ត៌មានហិរញ្ញវត្ថុ សម្រាប់ស្ថានភាពខាងក្រោម៖

(i). កាលពីឆ្នាំមុន ក្រុមហ៊ុន X មានអត្រាចំណេញដុល (Gross profit margin) 20%។ ក្នុងឆ្នាំនេះ អត្រាចំណេញដុលនេះបានថយចុះមកត្រឹម 18% ។ អ្នកវិនិយោគម្នាក់ បានពិនិត្យអាជីវកម្មផ្សេងទៀតនៅក្នុងវិស័យតែមួយ ហើយបានរកឃើញថា អត្រាចំណេញដុលជាមធ្យមសម្រាប់អាជីវកម្មប្រភេទដូចគ្នាបានថយចុះពី 17% មក 16%។

(ii). ក្រុមហ៊ុន X មានតម្រូវការខ្ចីលុយធនាគារ។ កម្ចីដែលនឹងត្រូវផ្ដល់ គឺផ្អែកលើតម្លៃសរុបនៃទ្រព្យសកម្មរយៈពេលវែង។ ក្រុមហ៊ុន X បានចាត់ថ្នាក់គណនីអតិថិជន (Receivables) ជាទ្រព្យសកម្មរយៈពេលវែង ដើម្បីអាចធ្វើឱ្យធនាគារផ្ដល់កម្ចីនោះមកក្រុមហ៊ុន។

(iii). លេខកំណត់ចំណាំស្ដីពីវិធីសាស្ត្រ និងអត្រារំលស់សម្រាប់ទ្រព្យសកម្មរយៈពេលវែងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបង្ហាញនៅជិតនឹងតួលេខទឹកប្រាក់រំលស់នោះ។

(iv). ចំណាយមួយប្រភេទដែលបង្ហាញនៅក្នុងរបាយការណ៍ចំណេញ/ខាត ចំនួន $250,000 គឺតំណាងឱ្យការខាតបង់ដោយសារអគ្គីភ័យ។ ប្រសិនបើព័ត៌មានត្រូវបានបង្ហាញដាច់ដោយឡែក នោះនៅពេលដែលអ្នកវិនិយោគធ្វើការវិភាគចំណាយនាពេលអនាគតរបស់ក្រុមហ៊ុន X គាត់អាចដកចំណាយប្រភេទនេះចេញបាន ដោយចំណាយខាតបង់ដោយសារអគ្គីភ័យនេះ ប្រហែលជាចំណាយមិនមែនកើតឡើងជារៀងរាល់ឆ្នាំនោះទេ។

5) តើស្តង់ដាគណនេយ្យមួយណានៃស្តង់ដាគណនេយ្យអន្តរជាតិ ត្រូវប្រើសម្រាប់ប្រតិបត្តិការខាងក្រោម៖

a. រំលស់សម្រាប់ទ្រព្យសកម្មរយៈពេលវែង
b. របៀបដែលទំនិញត្រូវបានទិញសម្រាប់ទុកលក់វិញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ
c. របៀបកែសម្រួលរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនៅពេលមានកំហុសឆ្គង និងរបៀបនៃការកែសម្រួលឱ្យត្រឹមត្រូវវិញ
d. របៀបចាត់ថ្នាក់ការជួលទ្រព្យសកម្មរយៈពេលវែងសម្រាប់ប្រើប្រាស់នៅក្នុងអាជីវកម្ម។

# មេរៀនទី ៨៖ ការកែតម្រូវលើរបាយការណ៍ហិរញ្ញវត្ថុ

(Chapter 8: Adjustment to Financial Statement)

គោលបំណងនៃមេរៀនទី៨ នេះ ផ្តោតលើ៖

- ❖ ប្រភេទគណនីមួយចំនួនដែលត្រូវកែតម្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ
- ❖ ទស្សនាទានចំណូល-ចំណាយបង្គរ (Accrual Concept) និងចំណូល-ចំណាយបង់ប្រាក់ជាមុន (Prepayment Concept)។

ក្រោយបញ្ចប់មេរៀនទី៨ នេះ យើងអាច៖

- ❖ ស្គាល់អំពីប្រភេទនៃការកែតម្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ
- ❖ រៀបចំបញ្ជីគណនីសម្រាប់ចំណូល-ចំណាយបង្គរ (Accruals)
- ❖ រៀបចំបញ្ជីគណនីចំណូល-ចំណាយបង់ប្រាក់ជាមុន (Prepayments)
- ❖ រៀបចំរបាយការណ៍ចំណេញ/ខាត (SOPL) និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (SOFP) ក្រោយពីធ្វើការកែតម្រូវរួច។

## ៨.១. សេចក្តីផ្តើម

ការកែសំរួលគណនីកើតឡើងចំពោះតែគណនេយ្យបង្គរប៉ុណ្ណោះ។ ការរៀបចំការកែតម្រូវគណនីនេះ ត្រូវបានប្រើ ដើម្បីទទួលស្គាល់ចំណូលនៅពេលក្រុមហ៊ុនបានលក់ទំនិញ ឬផ្តល់សេវាជូនអតិថិជន ព្រមទាំងទទួលស្គាល់ចំណាយនៅពេលក្រុមហ៊ុនទទួលបានទំនិញ/ការផ្គត់ផ្គង់សេវា ក្នុងអំឡុងការិយ-បរិច្ឆេទគណនេយ្យមួយកំណត់។ ដូចនេះ សម្រាប់ប្រព័ន្ធគណនេយ្យបង្គរ នឹងកើតមាននូវ ចំណូលមិនទាន់ទទួលបានសាច់ប្រាក់ (Receivables) ឬចំណាយមិនទាន់បានការទូទាត់សាច់ប្រាក់ (Payables) ដែលហៅថា Accruals, និងចំណូលដែលអតិថិជនបានទូទាត់សាច់ប្រាក់ជាមុន ប៉ុន្តែក្រុមហ៊ុនមិនទាន់ដឹកទំនិញ ឬផ្តល់សេវាជូនអតិថិជននៅឡើយ (Unearned Revenue) ឬចំណាយដែលក្រុមហ៊ុនបានទូទាត់សាច់ប្រាក់ជាមុន តែក្រុមហ៊ុនមិនទាន់បានទទួលទំនិញ ឬសេវាកម្មនោះនៅឡើយ ដែលហៅថា Prepaid expenses ។ ចំណូលនិងចំណាយប្រភេទនេះ នឹងត្រូវបង្ហាញជាទ្រព្យសកម្ម ឬបំណុលនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ក្រៅពីប្រភេទកែតម្រូវខាងលើនេះ, ក៏នៅមានការកត់ត្រាកែតម្រូវសម្រាប់ការងារគណនេយ្យផ្សេងទៀតផងដែរ។ ជារួម, ខាងក្រោមនេះ ជាប្រភេទនៃការកែតម្រូវគណនេយ្យ សម្រាប់ចុងការិយ-បរិច្ឆេទគណនេយ្យ សម្រាប់ក្រុមហ៊ុនអាជីវកម្ម៖

- ចំណូល-ចំណាយបង្គរ (Accruals)
- ចំណូល-ចំណាយបង់មុន (Prepayments)
- សន្និធិ (Inventory)

- សំវិធានធន (Provision)
- រំលស់(Depreciation)
- សំវិធានធន និងចំណាយបំណុលទារមិនបាន(bad debt expense and allowance)

យើងបានសិក្សារួចហើយនូវការកត់ត្រាកែតម្រូវនៅចុងគ្រាសម្រាប់សន្និធិ (Inventory) នៅក្នុងមេរៀនទី៣ ។ នៅក្នុងមេរៀននេះ យើងនឹងផ្តោតជាសំខាន់តែការកត់ត្រាកែតម្រូវលើចំណូល-ចំណាយបង្ករ (Accruals), និងចំណូល-ចំណាយបង់មុន (Prepayments)។ ចំណែកឯ, សំវិធានធន (Provision) រំលស់(Depreciation) និងសំវិធានធន និងចំណាយបំណុលទារមិនបាន(bad debt expense and allowance) នឹងត្រូវសិក្សាបន្តនៅក្នុងមុខវិជ្ជាគណនេយ្យហិរញ្ញវត្ថុកម្រិត ២ ។

## ៨.២. ចំណូល-ចំណាយបង្ករ (Accruals)

### ៨.២.១. ចំណូលបង្ករ (Accrued Income)

Accrued income (receivables) សំដៅដល់ចំណូលដែលបានកើតមានឡើងនៅក្នុងការិយបរិច្ឆេទគណនេយ្យ តែមិនទាន់ទទួលបានសាច់ប្រាក់ពីអតិថិជន។ ចំណូលប្រភេទនេះ នឹងបង្ហាញជាប្រភេទគណនីទ្រព្យសកម្ម (Assets) នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ឬតារាងតុល្យការ។ ការកត់ត្រា៖

| | | |
|---|---|---|
| Dr. Receivables | $xxx | |
| Cr. Income | | $xxx |

### ៨.២.២. ចំណាយបង្ករ (Accrued expenses)

Accrued expenses (payables) សំដៅដល់ចំណាយដែលបានកើតមានឡើងនៅក្នុងការិយបរិច្ឆេទគណនេយ្យ តែមិនទាន់បានទូទាត់សាច់ប្រាក់ជូនអ្នកផ្គត់ផ្គង់។ ចំណាយទាំងនេះ នឹងត្រូវបង្ហាញជាប្រភេទគណនីបំណុល (Liabilities) នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ឬតារាងតុល្យការ។ ការកត់ត្រា ត្រូវធ្វើឡើងដូចខាងក្រោម៖

| | | |
|---|---|---|
| Dr. Expense | $xxx | |
| Cr. Accruals | | $xxx |

<u>**ឧទាហរណ៍៖**</u>

❶ ក្រុមហ៊ុន A ដែលមានការិយបរិច្ឆេទឆ្នាំបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ត្រូវបង់ចំណាយធានារ៉ាប់រងជាទៀតទាត់ប្រចាំឆ្នាំ តម្លៃ $600 ។ ប្រសិនបើចំណាយធានារ៉ាប់រងនេះ ត្រូវបានទូទាត់ទាន់ពេលវេលាក្នុងឆ្នាំ នោះក្រុមហ៊ុនត្រូវកត់ត្រាដូចខាងក្រោម៖

គណនីចំណាយធានារ៉ាប់រង (Insurance Expense)

| | | | | | |
|---|---|---|---|---|---|
| 2020 | | $ | 2020 | | $ |
| 31 Dec | Cash | 600 | 31 Dec | SOPL | 600 |

គណនីសាច់ប្រាក់(Cash Account)

| 2020 | | $ | 2020 | | $ |
|---|---|---|---|---|---|
| | | | 31 Dec | Insurance | 600 |

គណនី SOPL

| 2020 | | $ | 2020 | | $ |
|---|---|---|---|---|---|
| 31 Dec | Insurance expense | 600 | | | |

ប៉ុន្តែឧបមាថាក្រុមហ៊ុន A ធ្វើការទូទាត់ច្រើនដងក្នុងមួយឆ្នាំ ជូនក្រុមហ៊ុនធានារ៉ាប់រង។ ជាសរុបរួម នៅចុងឆ្នាំក្រុមហ៊ុន A ទើបតែទូទាត់ប្រាក់បានសរុបចំនួន $520 មានន័យថាក្រុមហ៊ុន A នៅជំពាក់ក្រុមហ៊ុនធានារ៉ាប់រង ចំនួន $80 ។ ដូចនេះ បញ្ហានេះបានបង្កើតឱ្យមានចំណាយបង្គរ (Accrued Expense) មានន័យថាចំណាយធានារ៉ាប់រងសម្រាប់ក្រុមហ៊ុន A មានសរុប $600 ប៉ុន្តែក្រុមហ៊ុនទូទាត់ជាសាច់ប្រាក់បានតែ $520 នៅសល់ $80 ដែលជា Accruals ។ ការកត់ត្រានៅក្នុងសៀវភៅធំគឺៈ

គណនីចំណាយធានារ៉ាប់រង (Insurance Expense)

| 2020 | | $ | 2020 | | $ |
|---|---|---|---|---|---|
| 31 Dec | Cash | 520 | 31 Dec | SOPL | 600 |
| 31 Dec | Accruals (balance c/d) | 80 | | | |
| | | 600 | | | 600 |

គណនីសាច់ប្រាក់(Cash Account)

| 2020 | | $ | 2020 | | $ |
|---|---|---|---|---|---|
| | | | 31 Dec | Insurance | 520 |

គណនី Accruals

| 2020 | | $ | 2020 | | $ |
|---|---|---|---|---|---|
| | | | 31 Dec | Insurance | 80 |

គណនី SOPL

| 2020 | | $ | 2020 | | $ |
|---|---|---|---|---|---|
| 31 Dec | Insurance expense | 600 | | | |

សមតុល្យចុងគ្រានៃ Accruals សម្រាប់ចំណាយធានារ៉ាប់រងនោះ នឹងត្រូវធ្វើការកត់ត្រាបញ្ច្រាស់ (reversed entry) មកវិញ ហើយទឹកប្រាក់សមតុល្យចុងគ្រានោះនឹងត្រូវក្លាយជាសមតុល្យដើមគ្រាសម្រាប់គណនីចំណាយធានារ៉ាប់រងនៅដើមការិយបរិច្ឆេទគណនេយ្យ ដូចខាងក្រោមៈ

គណនី Accruals

| 2020 | | $ | 2020 | | $ |
|---|---|---|---|---|---|
| 31 Dec | Balance c/d | 80 | 31 Dec | Insurance expense | 80 |
| | | 80 | | | 80 |
| 2021 | | | 2021 | | |
| 01 Jan | Insurance Expense | 80 | 01 Jan | Balance b/d | 80 |

គណនីចំណាយធានារ៉ាប់រង (Insurance Expense)

| 2020 | | $ | 2020 | | $ |
|---|---|---|---|---|---|
| | | | 01 Jan | balance b/d | 80 |

❷ នៅក្នុងឆ្នាំ២០១៨ លោកចិត្រា បានបង់វិក្កយបត្រទឹកភ្លើង ដូចខាងក្រោម៖

| ថ្ងៃខែឆ្នាំបង់ប្រាក់ | ទឹកប្រាក់ ($) | សម្រាប់ពេលវេលាប្រើប្រាស់ |
|---|---|---|
| 12.03.2018 | 168 | ត្រីមាស ត្រឹមថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ |
| 09.06.2018 | 134 | ត្រីមាស ត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ |
| 12.09.2018 | 118 | ត្រីមាស ត្រឹមថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៨ |
| 12.12.2018 | 158 | ត្រីមាស ត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ |

នៅក្នុងខែមីនា ឆ្នាំ២០១៩ លោកចិត្រា ទទួលបានវិក្កយបត្រទឹកភ្លើង តម្លៃ $189 ដែលលោកបានប្រើប្រាស់សម្រាប់មួយត្រីមាស គិតត្រឹមថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩។

ចូរគណនារក Electricity Expense និង Electricity Accrual សម្រាប់ការិយបរិច្ឆេទបញ្ចប់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងចូរកត់ត្រាប្រតិបត្តិការទាំងនេះ។

**<u>ចម្លើយ៖</u>**

គណនីចំណាយទឹកភ្លើង (Electricity Expense)

| 2018 | | $ | 2018 | | $ |
|---|---|---|---|---|---|
| 12 Mar | Cash | 168 | 01 Jan | Accrual reversed | 56 |
| 09 Jun | Cash | 134 | 31 Dec | SOPL | 585 |
| 12 Sep | Cash | 118 | | | |
| 12 Dec | Cash | 158 | | | |
| 31 Dec | Accruals (1/3*189) | 63 | | | |
| | | 641 | | | 641 |

គណនី Accruals

| 2018 | | $ | 2018 | | $ |
|---|---|---|---|---|---|
| 01 Jan | Accrual reversed | 56 | 01 Jan | balance b/d | 56 |
| 31 Dec | Balance c/d | 63 | 31 Dec | Electricity Accrual | 63 |
| | | 119 | | | 119 |
| | | | 2019 | | |
| | | | 01 Jan | Balance b/d | 63 |

គណនីសាច់ប្រាក់ (Cash Account)

| 2018 | | $ | 2018 | | $ |
|---|---|---|---|---|---|
| | | | 12 Mar | Cash | 168 |
| | | | 09 Jun | Cash | 134 |
| | | | 12 Sep | Cash | 118 |
| | | | 12 Dec | Cash | 158 |

**<u>អនុវត្តៈ</u>** លោកចន្ថា បានបង្កើតក្រុមហ៊ុន KH ដែលជាក្រុមហ៊ុនរកស៊ីផ្តល់សេវាកម្មកំចាត់សត្វល្អិតនៅតាមគេហដ្ឋាន។ សម្រាប់អាជីវកម្មនេះ គាត់ត្រូវការជួលបុគ្គលិកមួយក្រុមដែលមានសមាជិក ៨ នាក់ និងត្រូវបង់ប្រាក់បៀវត្សសរុប $48,000 ក្នុងមួយឆ្នាំក្នុងម្នាក់ នៅក្នុងឆ្នាំ២០១៥។ នៅដើមឆ្នាំ២០១៦ លោកចន្ថា ត្រូវដំឡើងប្រាក់បៀវត្សជូនបុគ្គលិក 10% ដែលត្រូវជា $52,800 ក្នុងមួយឆ្នាំក្នុងម្នាក់។

នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ គាត់បានជួលបុគ្គលិកហាត់ការម្នាក់ដែលត្រូវផ្តល់ប្រាក់បៀវត្សជូន $33,600 ក្នុងមួយឆ្នាំ។ ការទូទាត់ប្រាក់បៀវត្សជូនបុគ្គលិកទាំងអស់ ត្រូវធ្វើនៅដើមខែបន្ទាប់ពីបុគ្គលិកបំពេញការងាររួចរាល់ មានន័យថា ប្រាក់បៀវត្សសម្រាប់ខែមករា ត្រូវបើកជូននៅដើមខែកុម្ភៈ ដូចគ្នាសម្រាប់ខែបន្តបន្ទាប់។

a. តើចំណាយប្រាក់បៀវត្សសរុប(Salary Expense) សម្រាប់ក្រុមហ៊ុន KH សម្រាប់ការិយបរិច្ឆេទបញ្ចប់ ៣១ ខែធ្នូ ឆ្នាំ២០១៦ ស្មើប៉ុន្មាន?

b. តើប្រាក់បៀវត្សមិនទាន់បានទូទាត់ជូនបុគ្គលិក Accrued Salary (Salary Payable) នៅចុងការិយបច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ស្មើប៉ុន្មាន?

## ៨.៣. ចំណាយបង់ប្រាក់ជាមុននិងចំណូលបង់ប្រាក់ជាមុន (Prepayments)

### ៨.៣.១. ចំណាយបង់ប្រាក់ជាមុន (Prepaid expenses)

Prepaid expenses សំដៅដល់ចំណាយដែលក្រុមហ៊ុនបានទូទាត់សាច់ប្រាក់ជាមុន តែក្រុមហ៊ុនមិនទាន់បានប្រើប្រាស់ទំនិញ ឬសេវានោះនៅឡើយ នោះមានន័យថាក្រុមហ៊ុនមិនត្រូវកត់ត្រាជាចំណាយនោះទេ ហើយត្រូវចាត់ទុកចំណាយប្រភេទនេះ ជាទ្រព្យសកម្ម (Assets) នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ឬតារាងតុល្យការ។ សម្រាប់ចំណាយប្រភេទនេះ ត្រូវកត់ត្រាដូចខាងក្រោម៖

Dr. Prepaid expense ( Asset ) $xxx

Cr. Cash $xxx

### ៨.៣.២. ចំណូលបង់ប្រាក់ជាមុន ( Unearned income )

Unearned income សំដៅដល់ចំណូលដែលក្រុមហ៊ុនទទួលបានសាច់ប្រាក់ជាមុនពីអតិថិជន តែក្រុមហ៊ុនមិនទាន់បានដឹកនាំទំនិញ ឬផ្តល់សេវាកម្មជូនអតិថិជននៅឡើយ។ ក្នុងន័យនេះ, ក្រុមហ៊ុន មិនត្រូវកត់ត្រាជាចំណូលនោះទេ ប៉ុន្តែត្រូវចាត់ទុកចំណូលប្រភេទនេះ ថាជាបំណុល ( Liabilities ) នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ឬតារាងតុល្យការ។ សម្រាប់ចំណូលប្រភេទនេះ ត្រូវកត់ត្រាដូចខាងក្រោម៖

Dr. Cash $xxx

Cr. Unearned income ( Liabilities ) $xxx

ឧទាហរណ៍៖

❶ ក្រុមហ៊ុន A ដូចក្នុងឧទាហរណ៍ Accruals ខាងលើផងដែរ កើតមានចំណាយការជួលការិយាល័យ ក្នុងតម្លៃ $5,000 សម្រាប់ការជួលរយៈពេលមួយឆ្នាំ ដោយត្រូវទូទាត់មុនប្រាក់ជាមុន។ ឧបមាថាក្រុមហ៊ុន A បានទូទាត់ប្រាក់ចំនួន $5,500 ក្នុងឆ្នាំ២០២០ ជូនម្ចាស់អគារជួល។ ដូចនេះ ការកត់ត្រា Prepayments នៅក្នុងសៀវភៅធំ គឺស្រដៀងគ្នានឹងការកត់ត្រាសម្រាប់ Accruals ដែរ គឺ៖

គណនីចំណាយការជួល ( Rent Expense )

| | | | | | |
|---|---|---|---|---|---|
| 2020 | | $ | 2020 | | $ |
| 31 Dec | Cash | 5,500 | 31 Dec | SOPL | 5,000 |
| | | | 31 Dec | Prepayment( balance c/d ) | 500 |
| | | 5,500 | | | 5,500 |
| 2021 | | | | | |
| 01 Jan | Balance b/d | 500 | | | |

គណនីសាច់ប្រាក់( Cash Account )

| | | | | | |
|---|---|---|---|---|---|
| 2020 | | $ | 2020 | | $ |
| | | | 31 Dec | Rent | 5,500 |

គណនី Prepayments

| | | | | | |
|---|---|---|---|---|---|
| 2020 | | $ | 2020 | | $ |
| 31 Dec | Rent | 500 | 31 Dec | Balance c/d | 500 |
| | | 500 | | | 500 |
| 2021 | | | 2021 | | |
| 01 Jan | Balance b/d | 500 | 01 Jan | Rent | 500 |

គណនី SOPL

| 2020 | | $ | 2020 | | $ |
|---|---|---|---|---|---|
| 31 Dec | Insurance expense | 5,000 | | | |

❷ ក្រុមហ៊ុន A ខាងលើបានផ្តល់សេវាជូនអតិថិជន ដោយអតិថិជនបានទូទាត់កម្រៃសេវាមកក្រុមហ៊ុន A ជាមុន។ នៅចុងការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ក្រុមហ៊ុនទទួលបានការទូទាត់សាច់ប្រាក់ពីអតិថិជនចំនួន $830 ដែលក្នុងនោះអតិថិជនបានទទួលសេវារួចហើយពីក្រុមហ៊ុន A ដែលមានតម្លៃ $780 ។ ទឹកប្រាក់ដែលអតិថិជនទូទាត់លើសនេះ គឺជាការទូទាត់ជាមុនសម្រាប់សេវាដែលនឹងត្រូវផ្តល់ក្នុងខែមករា ឆ្នាំ២០២១។ សម្រាប់ចំណូលប្រភេទនេះ ក្រុមហ៊ុន A ត្រូវកត់ត្រាដូចខាងក្រោម៖

គណនីចំណូលពីសេវា (Service Revenue)

| 2020 | | $ | 2020 | | $ |
|---|---|---|---|---|---|
| 31 Dec | SOPL | 780 | 31 Dec | Cash | 830 |
| 31 Dec | Unearned Revenue | | | | |
| | (balance c/d) | 50 | | | |
| | | 830 | | | 830 |
| | | | 2021 | | |
| | | | 01 Jan | Balance b/d | 50 |

គណនីសាច់ប្រាក់(Cash Account)

| 2020 | | $ | 2020 | | $ |
|---|---|---|---|---|---|
| 31 Dec | Service Revenue | 830 | | | |

គណនី Unearned Revenue

| 2020 | | $ | 2020 | | $ |
|---|---|---|---|---|---|
| 31 Dec | Balance c/d | 50 | 31 Dec | Service revenue | 50 |
| | | 50 | | | 50 |
| 2021 | | | | | |
| 01 Jan | Service revenue | 50 | 01 Jan | Balance b/d | 50 |

គណនី SOPL

| 2020 | | $ | 2020 | | $ |
|---|---|---|---|---|---|
| | | | 31 Dec | Service revenue | 780 |

**អនុវត្តៈ**

❶ ក្រុមហ៊ុនកញ្ញា រៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំបញ្ចប់ថ្ងៃទី៣០ ខែមិថុនា រាល់ឆ្នាំ។ ក្រុមហ៊ុនត្រូវបង់ចំណាយធានារ៉ាប់រងប្រចាំត្រីមាសជាមុននៅថ្ងៃទី ០១ មីនា, ០១ មិថុនា, ០១ កញ្ញា, និង ០១ ធ្នូ ជារៀងរាល់ឆ្នាំ។ ចំណាយធានារ៉ាប់រងប្រចាំឆ្នាំស្មើនឹង $24,000 ត្រឹមថ្ងៃទី៣១ សីហា ២០១៦ ក្រោយពីឆ្នាំនេះ ចំណាយធានារ៉ាប់រងត្រូវកើនឡើងដល់ $30,000 ក្នុងមួយឆ្នាំ។ តើចំណាយធានារ៉ាប់រង (Insurance Expense) និង Prepayment សម្រាប់ធានារ៉ាប់រងនេះ ក្នុងឆ្នាំបញ្ចប់ ៣០ មិថុនា ២០១៧ ស្មើនឹងប៉ុន្មាន?

| | Expense | Prepayment |
|---|---|---|
| A. | $29,000 | $2,500 |
| B. | $29,000 | $5,000 |
| C. | $28,500 | $2,500 |
| D. | $28,500 | $5,000 |

❷ ក្រុមហ៊ុនមួយ ទទួលបានចំណូលការជួលពីការដាក់ជួលការិយាល័យដែលនៅទំនេររបស់ខ្លួន។ ចំណូលការជួលត្រូវទទួលបានជាមុនប្រចាំត្រីមាស ដូចខាងក្រោមៈ

| ថ្ងៃខែឆ្នាំទទួលបានចំណូល | ពេលវេលានៃការជួល | $ |
|---|---|---|
| 01 តុលា 2018 | ៣ ខែ ត្រឹមថ្ងៃទី31 ធ្នូ 2018 | 7,500 |
| 30 ធ្នូ 2018 | ៣ ខែ ត្រឹមថ្ងៃទី31 មីនា 2019 | 7,500 |
| 04 មេសា 2019 | ៣ ខែ ត្រឹមថ្ងៃទី30 មិថុនា 2019 | 9,000 |
| 01 កក្កដា 2019 | ៣ ខែ ត្រឹមថ្ងៃទី30 កញ្ញា 2019 | 9,000 |
| 01 កក្កដា 2019 | ៣ ខែ ត្រឹមថ្ងៃទី31 ធ្នូ 2019 | 9,000 |

ចូរគណនារកចំណូលពីការជួល (Rent Income) និង Unearned Revenue សម្រាប់ក្រុមហ៊ុននេះ សម្រាប់ការិយបរិច្ឆេទបញ្ចប់ត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៩?

## ៨.៤. Accruals និង Prepayments នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

### ៨.៤.១. របាយការណ៍ចំណេញ/ខាត (SOPL)

នៅក្នុងរបាយការណ៍ចំណេញ/ខាត(SOPL) ចំណាយ និងចំណូល ត្រូវបង្ហាញតែចំនួនទឹកប្រាក់ដែលកើតឡើងតែក្នុងការិយបរិច្ឆេទគណនេយ្យប៉ុណ្ណោះ។ ក្នុងន័យនេះ, ប្រសិនបើចំណូល និងចំណាយទាំងនោះមិនបានកើតឡើងនៅក្នុងការិយបរិច្ឆេទគណនេយ្យនោះទេ ចំនួនទឹកប្រាក់ដែលទទួលបាន ឬបានទូទាត់ហើយ នឹងត្រូវក្លាយទៅជា Prepayments ឬ Accruals ដែលត្រូវបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (SOFP) ឬតារាងតុល្យការ។ ដូចនេះ, ចំនួនទឹកប្រាក់នៅក្នុងគណនីចំណូល ឬ ចំណាយទាំងនោះ ត្រូវធ្វើការកែសម្រួលឡើងវិញ។

### ៨.៤.២. របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (SOFP)

នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ Accruals និង Prepayments នៅក្នុងទ្រព្យសកម្មរយៈពេលខ្លី ឬបំណុលរយៈពេលខ្លី ដូចក្នុងតារាងខាងក្រោម៖

| ប្រភេទសមតុល្យចុងគ្រា | សមតុល្យនៅក្នុងគណនី | ប្រភេទគណនីនៅក្នុង SOFP |
|---|---|---|
| Accrued Income | ខាងឥណពន្ធ (Debit) | ទ្រព្យសកម្មរយៈពេលខ្លី |
| Accrued Expense | ខាងឥណទាន (Credit) | បំណុលរយៈពេលខ្លី |
| Prepaid Income | ខាងឥណទាន (Credit) | បំណុលរយៈពេលខ្លី |
| Prepaid Expense | ខាងឥណពន្ធ (Debit) | ទ្រព្យសកម្មរយៈពេលខ្លី |

ឧទាហរណ៍៖ តារាងតុល្យការខាងក្រោម បង្ហាញអំពីព័ត៌មានគណនីជារួមរបស់ក្រុមហ៊ុន H Speller នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩៖

| | Dr. | Cr. |
|---|---|---|
| | $ | $ |
| Inventory នៅថ្ងៃទី០១ មករា ២០១៩ | 6,105 | |
| Sales | | 56,193 |
| Purchases | 30,010 | |
| Office expense | 3,980 | |
| Rent expense | 1,750 | |
| Wages expense | 11,325 | |
| Land and Building | 26,500 | |
| Equipment | 4,990 | |
| Trade receivables | 2,655 | |
| Trade payables | | 3,156 |
| Bank | 1,074 | |
| Capital | | 34,500 |
| Drawings | 5,460 | |
| | 93,849 | 93,849 |

គេឱ្យព័ត៌មានបន្ថែមដូចខាងក្រោម៖

1. សន្និធិ (Inventory) នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ មានតម្លៃ $7,230 ។
2. ចំណាយដំណើរការអាជីវកម្ម(Office expense) នៅជំពាក់ក្រុមហ៊ុនផ្សេងចំនួន $510។
3. ចំណាយការជួល (Rent) នៅមិនទាន់ទូទាត់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ចំនួន $230។
4. ចំណាយបៀវត្ស (Wages) បានបើកជូនបុគ្គលិកមុនសម្រាប់ឆ្នាំ២០២០ ចំនួន $995។

ផ្អែកលើព័ត៌មានដែលបានផ្តល់ខាងលើ យើងអាចរៀបចំរបាយការណ៍ចំណេញ/ខាត (SOPL) និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (SOFP) ឬតារាងតុល្យភាព(Balance sheet) ដូចខាងក្រោម៖

H Speller

Statement of Profit or Loss (SOPL)

សម្រាប់ឆ្នាំ បញ្ចប់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | $ | $ |
|---|---|---|
| Sales | | 56,193 |
| Cost of goods sold: | | |
| Opening inventory | 6,105 | |
| Add: Purchase | 30,010 | |
| Less: Closing inventory | (7,230) | (28,885) |
| Gross Profit | | 27,308 |
| Less: Operating expense | | |
| Office expense ($3,980 + $510) | 4,490 | |
| Rent expense ($1,750 + $230) | 1,980 | |
| Wages expense ($11,325 - $995) | 10,330 | (16,800) |
| Net Profit | | 10,508 |

H Speller

Statement of Financial Position (SOFP)

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | $ | | $ |
|---|---|---|---|
| **Noncurrent Assets:** | | **Equity** | |
| Land and Building | 26,500 | Capital(34,500-5,460+10,508) | 39,548 |
| Equipment | 4,990 | | |
| **Total noncurrent assets** | **31,490** | **Total equity** | **39,548** |
| **Current Assets:** | | **Current liabilities** | |
| Inventory (31 Dec 2019) | 7,230 | Accruals ($510+$230) | 740 |
| Prepayments (Wages: $995) | 995 | Trade Payables | 3,156 |
| Trade receivables | 2,655 | **Total current liabilities** | **3,896** |
| Bank | 1,074 | | |
| **Total current assets** | **11,954** | **Total liabilities** | **3,896** |
| **Total Assets** | **43,444** | **Total Liabilities and Equity** | **43,444** |

## ៨.៥. សេចក្តីសន្និដ្ឋាន

នៅក្នុងចុងការិយបរិច្ឆេទនៃកិច្ចការគណនេយ្យ តម្រូវឱ្យគណនេយ្យករ រៀបចំកែសម្រួលនូវគណនីមួយចំនួន ដែលត្រូវរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ នៅក្នុងមេរៀននេះ យើងបានសិក្សាជាសំខាន់លើ Accruals និង Prepayment ដែលពាក់ព័ន្ធនឹងចំណូល និងចំណាយដែលមិនបានកើតឡើងនៅក្នុងការិយបរិច្ឆេទនៃការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុ។ សម្រាប់ក្រុមហ៊ុនអាជីវកម្ម ចំណុចដែលត្រូវចងចាំ រួមមាន៖

- ចំណូលបង្គរ (Accrued Income/Receivables) ត្រូវបង្ហាញជាគណនីទ្រព្យសកម្មរយៈពេលខ្លី (Current Asset) នៅក្នុង SOFP ។
- ចំណាយបង្គរ (Accrued expense/Accruals) ត្រូវបង្ហាញជាគណនីបំណុលរយៈពេលខ្លី (Current Liability) នៅក្នុង SOFP ។
- ចំណូលទទួលបានជាមុន (Prepaid Income/Unearned Income) ត្រូវបង្ហាញជាគណនីបំណុលរយៈពេលខ្លី (Current Liability) នៅក្នុង SOFP ។
- ចំណាយទូទាត់ជាមុន (Prepaid Expense/Prepayments) ត្រូវបង្ហាញជាគណនីទ្រព្យសកម្មរយៈពេលខ្លី (Current Asset) នៅក្នុង SOFP ។

# លំហាត់៖

## I. សំណួរពហុជ្រើសរើស (MCQ)

1) ខាងក្រោមនេះ មួយណាជាការកត់ត្រាត្រឹមត្រូវ នៅពេលដែលអតិថិជនបានបង់សាច់ប្រាក់ជាចំណូលចូលមកក្រុមហ៊ុន ប៉ុន្តែក្រុមហ៊ុនមិនទាន់បានដឹកទំនិញជូនអតិថិជននៅឡើយ?

a. Dr. Sales
   Cr. Cash

b. Dr. Cash
   Cr. Sales

c. Dr. Cash
   Cr. Unearned Income

d. Dr. Unearned Income
   Cr. Sales

2) តម្លៃជួលការិយាល័យ ត្រូវបានបង់ $1,200 នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១២ សម្រាប់ការជួលរយៈពេលមួយឆ្នាំបញ្ចប់ត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៣ និងត្រូវបានបង់ $1,600 នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៣ សម្រាប់ការជួលរយៈពេលមួយឆ្នាំបញ្ចប់ត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ ។ តើចំណាយការជួលការិយាល័យនេះសរុបក្នុងរយៈពេលមួយឆ្នាំបញ្ចប់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្មើប៉ុន្មាន?

a. $1,200
b. $1,300
c. $1,500
d. $1,600

3) នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ ក្រុមហ៊ុន Y បានបង់ថ្លៃជួលឃ្លាំងសរុប $8,400 សម្រាប់ការជួលរយៈពេល ២៤ខែ រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ ។ តើចំណាយការជួលសរុបស្មើប៉ុន្មានដែលត្រូវរាយការណ៍នៅក្នុងរបាយការណ៍ចំណេញខាត (SOPL) និងតម្លៃនៃការជួលប៉ុន្មានដែលត្រូវរាយការណ៍នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (SOFP) សម្រាប់ឆ្នាំបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២?

| | SOPL | SOFP |
|---|---|---|
| a. | $4,200 | Prepayment $3,500 |
| b. | $4,200 | Prepayment $4,200 |
| c. | $5,250 | Accrual $3,500 |
| d. | $5,250 | Accrual $4,200 |

4) ក្រុមហ៊ុន Brown បានត្រូវបង់ថ្លៃធានារ៉ាប់រងចំនួន $600 ជូនក្រុមហ៊ុនធានារ៉ាប់រង Manulife នៅរៀងរាល់ឆ្នាំនៅដើមឆ្នាំ ពោលគឺ នៅរៀងរាល់ថ្ងៃទី០១ ខែមករា នៃឆ្នាំនីមួយៗ ។ ឧបមាថាការិយបរិច្ឆេទគណនេយ្យសម្រាប់ក្រុមហ៊ុន Brown ត្រូវកំណត់យកពីថ្ងៃទី ០១ ខែតុលា រហូតដល់ថ្ងៃទី៣១ ខែកញ្ញានៃឆ្នាំបន្ទាប់។ ឆ្នាំ២០១៧ ជាឆ្នាំដំបូងនៃការបង់ធានារ៉ាប់រង។ តើចំណាយធានារ៉ាប់រងសម្រាប់ការិយបរិច្ឆេទបញ្ចប់ត្រឹមថ្ងៃទី៣១ ខែកញ្ញា ឆ្នាំ២០១៧ ដែលត្រូវបង្ហាញនៅក្នុងរបាយការណ៍ចំណេញ/ខាត ស្មើនឹងប៉ុន្មាន?

a. $600
b. $450
c. $300
d. $150

5) សេចក្តីព្រាងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Buster សម្រាប់ឆ្នាំបញ្ចប់ត្រឹមថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០ បង្ហាញថាក្រុមហ៊ុនខាតចំនួន $1,486 ។ នៅពេលដែលរៀបចំរបាយការណ៍នោះ, គណនេយ្យកររបស់ក្រុមហ៊ុន មិនទាន់បានបញ្ចូលតម្លៃ Accrual ចំនួន $1,625 និង Prepayment ចំនួន $834 នៅឡើយ។ តើក្រុមហ៊ុន Buster ចំណេញ ឬខាតប៉ុន្មាន បន្ទាប់ពីបញ្ចូល Accrual និង Prepayment ខាងលើនេះរួចហើយ?

a. ខាតចំនួន $695
b. ខាតចំនួន $2,277
c. ចំណេញចំនួន $3,945
d. ចំណេញចំនួន $1,807

## II. ចូរបំពេញចន្លោះខាងក្រោម៖

1) ប្រតិបត្តិការខាងក្រោមនេះ បានកើតមានឡើងនៅក្នុងឆ្នាំបញ្ចប់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។ ចូរបំពេញចន្លោះនៅក្នុងគណនីអក្សរ T នៃបញ្ជីសៀវភៅធំ តាមករណីខាងក្រោម៖

A. ចំណាយផ្សាយពាណិជ្ជកម្ម ត្រូវបានទូទាត់ក្នុងឆ្នាំ២០២០ សរុបចំនួន $712 ប៉ុន្តែគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ក្រុមហ៊ុននៅជំពាក់ក្រុមហ៊ុនផ្សាយពាណិជ្ជកម្មចំនួន $45 ទៀត។

គណនីចំណាយផ្សាយពាណិជ្ជកម្ម (Advertising Expense)

| | | | |
|---|---|---|---|
| 2020 | $ | 2020 | $ |
| 31 Dec ………………………………… | | 31 Dec ………………………………… | |
| 31 Dec ………………………………… | | | |
| | ……… | | ……… |
| | | 2021 | |
| | | 01 Jan ………………………………… | |

គណនី Accruals

| | | | |
|---|---|---|---|
| 2020 | $ | 2020 | $ |
| 31 Dec ……………………………… | ……. | 31 Dec ……………………………… | ……… |
| | ……….. | | ……….. |
| 2021 | | 2021 | |
| 01 Jan ……………………………… | | 01 Jan ……………………………… | |

B. ក្រុមហ៊ុនបានទូទាត់ចំណាយធានារ៉ាប់រងក្នុងឆ្នាំ ២០២០ ចំនួន $556 ដែលក្នុងនោះមាន $21 គឺចំណាយធានារ៉ាប់រងសម្រាប់ខែមករា ឆ្នាំ២០២១។

គណនីចំណាយធានារ៉ាប់រង (Insurance Expense)

| | | | |
|---|---|---|---|
| 2020 | $ | 2020 | $ |
| 31 Dec ……………………………… | ……. | 31 Dec ……………………………… | ……… |
| | | 31 Dec ……………………………… | ……… |
| | ……… | | ……… |
| 2021 | | | |
| 01 Jan ……………………………… | | | |

គណនី Prepayments

| | | | |
|---|---|---|---|
| 2020 | $ | 2020 | $ |
| 31 Dec ……………………………… | ……. | 31 Dec ……………………………… | ……… |
| | ……….. | | ……….. |
| 2021 | | 2021 | |
| 01 Jan ……………………………… | | 01 Jan ……………………………… | |

C. ក្រុមហ៊ុនបានទូទាត់ចំណាយទឹកភ្លើងក្នុងឆ្នាំ ២០២០ ចំនួន $650 ដែលក្នុងនោះមាន $250 គឺចំណាយសម្រាប់ឆ្នាំ២០២១។

គណនីចំណាយទឹកភ្លើង (Utility Expense)

| | | | |
|---|---|---|---|
| 2020 | $ | 2020 | $ |
| 31 Dec ……………………………… | ……. | 31 Dec ……………………………… | ……… |
| | | 31 Dec ……………………………… | ……… |
| | ……… | | ……… |
| 2021 | | | |
| 01 Jan ……………………………… | | | |

គណនី Prepayments

| | | | |
|---|---|---|---|
| 2020 | $ | 2020 | $ |
| 31 Dec …………………………………… | | 31 Dec …………………………………… | |
| | ……… | | ……… |
| 2021 | | 2021 | |
| 01 Jan …………………………………… | | 01 Jan …………………………………… | |

D. ក្រុមហ៊ុនទទួលបានការទូទាត់ចំណូលជាមូលប្បទានបត្រ ពីការដាក់ជួលការិយល័យដែលទំនេរចំនួន $1,100 ក្នុងឆ្នាំ២០២០។ ប៉ុន្តែក្នុងចំណូលទឹកប្រាក់ដែលបានទូទាត់នោះ មានទឹកប្រាក់ចំនួន $275 គឺជាតម្លៃជួលសម្រាប់ត្រីមាសទី១ នៃឆ្នាំ២០២១។

គណនីចំណូលការជួល (Rent Income)

| | | | |
|---|---|---|---|
| 2020 | $ | 2020 | $ |
| 31 Dec …………………………………… | | 31 Dec …………………………………… | |
| 31 Dec …………………………………… | | | |
| | ……… | | ……… |
| | | 2021 | |
| | | 01 Jan …………………………………… | |

គណនី Unearned Income

| | | | |
|---|---|---|---|
| 2020 | $ | 2020 | $ |
| 31 Dec …………………………………… | | 31 Dec …………………………………… | |
| | ……… | | ……… |
| 2021 | | 2021 | |
| 01 Jan …………………………………… | | 01 Jan …………………………………… | |

2) ប្រតិបត្តិការខាងក្រោមនេះ បានកើតមានឡើងនៅក្នុងឆ្នាំបញ្ចប់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។ ចូរបំពេញចន្លោះនៅក្នុងគណនីអក្សរ T នៃបញ្ជីសៀវភៅធំ តាមករណីខាងក្រោម៖

A. ក្រុមហ៊ុនបានទូទាត់ចំណាយធានារ៉ាប់រងក្នុងឆ្នាំ២០១៩ ដូចខាងក្រោម៖

| ថ្ងៃខែទូទាត់ | ទឹកប្រាក់ទូទាត់ | រយៈពេលនៃការធានារ៉ាប់រង |
|---|---|---|
| ០១ មករា | $400 | ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែឧសភា |
| ១៤ ឧសភា | $400 | ពីថ្ងៃទី០១ ខែមិថុនា ដល់ថ្ងៃទី៣១ ខែតុលា |
| ១០ វិច្ឆិកា | $400 | ពីថ្ងៃទី០១ ខែវិច្ឆិកា ដល់ថ្ងៃទី៣១ ខែមីនា |

### គណនីចំណាយធានារ៉ាប់រង ( Insurance Expense )

| | | $ | | | $ |
|---|---|---|---|---|---|
| 2019 | | | 2019 | | |
| 01 Jan | …………………………………… | | 31 Dec | …………………………………… | |
| 14 May | …………………………………… | | 31 Dec | …………………………………… | |
| 14 May | …………………………………… | | | | |
| | | ……… | | | ……… |
| 2020 | | | | | |
| 01 Jan | …………………………………… | | | | |

### គណនី Prepayments

| | | $ | | | $ |
|---|---|---|---|---|---|
| 2019 | | | 2019 | | |
| 31 Dec | …………………………………… | | 31 Dec | …………………………………… | |
| | | ……… | | | ……… |
| 2020 | | | 2020 | | |
| 01 Jan | …………………………………… | | 01 Jan | …………………………………… | |

B. ក្រុមហ៊ុនបានប្រាក់កម្រៃជាចំណូល ជាមូលប្បទានបត្រដែលមានតម្លៃ $560 ដែលក្នុងនោះរួមមាន ¼ នៃទឹកប្រាក់សរុបនេះ គឺជាចំណូលនៅឆ្នាំបន្ទាប់។

### គណនីចំណូលជាប្រាក់កម្រៃ ( Commission Fee )

| | | $ | | | $ |
|---|---|---|---|---|---|
| 2019 | | | 2019 | | |
| 31 Dec | …………………………………… | | 31 Dec | …………………………………… | |
| 31 Dec | …………………………………… | | | | |
| | | ……… | | | ……… |
| | | | 2020 | | |
| | | | 01 Jan | …………………………………… | |

### គណនី Unearned Income

| | | $ | | | $ |
|---|---|---|---|---|---|
| 2019 | | | 2019 | | |
| 31 Dec | …………………………………… | | 31 Dec | …………………………………… | |
| | | ……… | | | ……… |
| 2020 | | | 2020 | | |
| 01 Jan | …………………………………… | | 01 Jan | …………………………………… | |

C. ក្រុមហ៊ុនទទួលបានការបង់ជាសាច់ប្រាក់ចំនួន $1,600 ដែលជាចំណូលពីការជួល។ ប៉ុន្តែទឹកប្រាក់ដែលទូទាត់នេះ គឺសម្រាប់ការជួលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០។

គណនីចំណូលការជួល ( Rent Income )

| | | | |
|---|---|---|---|
| 2019 | $ | 2019 | $ |
| 31 Dec …………………………………………… | | 31 Dec …………………………………………… | |
| 31 Dec …………………………………………… | | | |
| | ……… | | ……… |
| | | 2020 | |
| | | 01 Jan …………………………………………… | |

គណនី Unearned Income

| | | | |
|---|---|---|---|
| 2019 | $ | 2019 | $ |
| 31 Dec …………………………………………… | | 31 Dec …………………………………………… | |
| | ……… | | ……… |
| 2020 | | 2020 | |
| 01 Jan …………………………………………… | | 01 Jan …………………………………………… | |

D. នៅចុងឆ្នាំ២០១៨ ក្រុមហ៊ុននៅជំពាក់បៀវត្សបុគ្គលិក ចំនួន $400 ហើយនៅក្នុងឆ្នាំ ២០១៩ ក្រុមហ៊ុនបានទូទាត់ចំណាយបៀវត្សបុគ្គលិក បានចំនួន $3,600 ។ នៅចុងឆ្នាំ ២០១៩ បៀវត្សដែលនៅជំពាក់បុគ្គលិក មិនទាន់បានទូទាត់ មានចំនួន $470 ។

គណនីចំណាយបៀវត្ស ( Salary Expense )

| | | | |
|---|---|---|---|
| 2019 | $ | 2019 | $ |
| 31 Dec …………………………………………… | | 01 Jan …………………………………………… | |
| 31 Dec …………………………………………… | | 31 Dec …………………………………………… | |
| | ……… | | ……… |
| 2020 | | | |
| 01 Jan …………………………………………… | | | |

គណនី Accruals

| 2019 | $ | 2019 | $ |
|---|---|---|---|
| 31 Dec ……………………………………… | | 31 Dec ……………………………………… | |
| | ……….. | | ……….. |
| 2019 | | 2019 | |
| 01 Jan ……………………………………… | | 01 Jan ……………………………………… | |

3) តារាងតុល្យការខាងក្រោម បង្ហាញអំពីព័ត៌មានគណនីជារួមរបស់ក្រុមហ៊ុន J នៅចុងឆ្នាំថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៨៖

| | Dr. | Cr. |
|---|---|---|
| | $ | $ |
| Equipment | 11,400 | |
| Machinery | 5,340 | |
| Sales | | 45,312 |
| Purchases | 31,980 | |
| Insurance expense | 1,013 | |
| Salary Expense | 6,409 | |
| Rent expense | 3,870 | |
| Opening Inventory | 3,231 | |
| Trade receivables | 4,231 | |
| Trade payables | | 5,436 |
| Bank | 891 | |
| Capital | | 24,500 |
| Drawings | 6,883 | |
| | 75,248 | 75,248 |

គេឱ្យព័ត៌មានបន្ថែមដូចខាងក្រោម៖

1. សន្និធិ (Inventory) នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ មានតម្លៃ $5,670 ។
2. ចំណាយបៀវត្ស (Wages) មិនបានបើកជូនបុគ្គលិកគិតត្រឹមថ្ងៃទី៣១ ធ្នូ ចំនួន $703។
3. ចំណាយការជួល (Rent) នៅមិនទាន់ទូទាត់នៅចុងឆ្នាំ ចំនួន $540។

ផ្អែកលើព័ត៌មានដែលបានផ្តល់ខាងលើ ចូរបំពេញចន្លោះនៅក្នុងរបាយការណ៍ចំណេញ/ខាត (SOPL) និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (SOFP) ដូចខាងក្រោម៖

J Company

Statement of Profit or Loss ( SOPL )

សម្រាប់ឆ្នាំ បញ្ចប់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

| | $ | $ |
|---|---|---|
| **Sales** | | ………… |
| Cost of goods sold: | | |
| Opening inventory | ………… | |
| Add: Purchase | ………… | |
| Less: Closing inventory | ………… | …………… |
| **Gross Profit** | | …………… |
| **Operating expense** | | |
| Insurance expense | ………… | |
| Salary expense | ………… | |
| Rent expense | ………… | …………… |
| **Net Profit** | | …………… |

J Company

Statement of Financial Position ( SOFP )

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

| | $ | | $ |
|---|---|---|---|
| **Noncurrent Assets:** | | **Equity** | |
| Equipment | ………… | Capital | ……… |
| Machinery | ………… | | |
| **Total noncurrent assets** | ………… | **Total equity** | ………… |
| **Current Assets:** | | **Current liabilities:** | |
| Prepayments | ………… | Accruals | ………… |
| Inventory | ………… | Trade Payables | ………… |
| Trade receivables | ………… | **Total current liabilities** | ………… |
| Bank | ………… | | |
| **Total current assets** | ………… | **Total Liabilities** | ………… |
| **Total Assets** | ………… | **Total Equity and Liabilities** | ………… |

4) តារាងតុល្យការខាងក្រោម ត្រូវបានដកស្រង់ពីគណនីសៀវភៅធំរបស់ក្រុមហ៊ុន C នៅចុងឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០៖

| | Dr. | Cr. |
|---|---|---|
| | $ | $ |
| Opening Inventory | 12,560 | |
| Sales | | 119,000 |
| Purchases | 71,500 | |
| Insurance expense | 8,930 | |
| Utility expense | 2,360 | |
| Wages and salary expense | 23,400 | |
| Property | 74,000 | |
| Plant | 7,560 | |
| Trade receivables | 8,340 | |
| Trade payables | | 7,431 |
| Bank | 2,210 | |
| Capital | | 91,312 |
| Drawings | 6,883 | |
| | 217,743 | 217,743 |

គេឱ្យព័ត៌មានបន្ថែមដូចខាងក្រោម៖

1. សន្និធិ (Inventory) នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ មានតម្លៃ $13,420 ។
2. ចំណាយបៀវត្ស (Wages and salaries) មិនបានបើកជូនបុគ្គលិកគិតត្រឹមថ្ងៃទី៣១ ធ្នូ ចំនួន $799។
3. ចំណាយធានារ៉ាប់រង (Insurance) បានទូទាត់ជាមុនសម្រាប់ការធានារ៉ាប់រងនៅឆ្នាំបន្ទាប់ ចំនួន $190។
4. ចំណាយទឹកភ្លើង (Utility) បានទូទាត់នៅចុងឆ្នាំជាមុន សម្រាប់ថ្លៃប្រើប្រាស់ក្នុងខែមករា ឆ្នាំ២០២១ ចំនួន $312 ។

ផ្អែកលើព័ត៌មានដែលបានផ្តល់ខាងលើ ចូរបំពេញចន្លោះនៅក្នុងរបាយការណ៍ចំណេញ/ខាត (SOPL) និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (SOFP) ដូចខាងក្រោម៖

C Company

Statement of Profit or Loss ( SOPL )

សម្រាប់ឆ្នាំ បញ្ចប់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | $ | $ |
|---|---|---|
| **Sales** | | ………… |
| Cost of goods sold: | | |
| Opening inventory | ………… | |
| Add: Purchase | ………… | |
| Less: Closing inventory | ………… | …………… |
| **Gross Profit** | | …………… |
| **Operating expense** | | |
| Insurance expense | ………… | |
| Utility expense | ………… | |
| Wages and salary expense | ………… | …………… |
| **Net Profit** | | …………… |

C Company

Statement of Financial Position ( SOFP )

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | $ | | $ |
|---|---|---|---|
| **Noncurrent Assets:** | | **Equity** | |
| Property | ………… | Capital | ……… |
| Plants | ………… | | |
| **Total noncurrent assets** | ………… | **Total Equity** | ………… |
| **Current Assets:** | | **Current liabilities:** | |
| Prepayments | ………… | Accruals | ………… |
| Inventory | ………… | Trade Payables | ……… |
| Trade receivables | ………… | **Total current liabilities** | ………… |
| Bank | ………… | | |
| **Total current assets** | ………… | **Total Liabilities** | ………… |
| **Total Assets** | ………… | **Total Equity and Liabilities** | ………… |

5) តារាងតុល្យការខាងក្រោម ត្រូវបានដកស្រង់ពីគណនីសៀវភៅធំរបស់ក្រុមហ៊ុន M ៖

| | Dr. | Cr. |
|---|---|---|
| | $ | $ |
| Sales and Purchases | 256,000 | 379,000 |
| Premises (ដីនិងអគារ) | 220,000 | |
| Plants, machinery and equipment | 31,500 | |
| Administration expense | 4,720 | |
| Salaries expense | 28,900 | |
| Insurance expense | 2,890 | |
| Sundry expense (ចំណាយផ្សេងៗ) | 990 | |
| Selling expense | 6,725 | |
| Power costs (ចំណាយអគ្គីសនី) | 3,780 | |
| Vehicles (រថយន្ត) | 18,900 | |
| Trade receivables and payables | 12,772 | 9,995 |
| Inventory (នៅថ្ងៃទី០១ មករា ២០១៩) | 23,450 | |
| Bank | | 3,132 |
| Capital | | 242,000 |
| Drawings | 23,500 | |
| | 634,127 | 634,127 |

គេឱ្យព័ត៌មានបន្ថែមដូចខាងក្រោម គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩៖

1. សន្និធិ (Inventory) នៅសល់ចំនួន $16,740 ។
2. ចំណាយប្រើសប្រាស់អគ្គីសនី មិនទាន់បានទូទាត់ មានចំនួន $235។
3. ចំណាយផ្សេងៗ (Sundry Expense) ចំនួន $90 នៅជំពាក់អ្នកផ្គត់ផ្គង់។
4. ចំណាយបៀវត្ស បានបើកជូនបុគ្គលិកមុន មានចំនួន $1,150។
5. ចំណាយជានារ៉ាប់រង បានទូទាត់ជាមុនមានចំនួណ $312 ។

ផ្អែកលើព័ត៌មានដែលបានផ្តល់ខាងលើ ចូរបំពេញចន្លោះនៅក្នុងរបាយការណ៍ចំណេញ/ខាត (SOPL) និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (SOFP) សម្រាប់ឆ្នាំ បញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ដូចខាងក្រោម៖

M Company

Statement of Profit or Loss ( SOPL )

សម្រាប់ឆ្នាំ បញ្ចប់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | $ | $ |
|---|---|---|
| **Sales** | | ………… |
| Cost of goods sold: | | |
| Opening inventory | ………… | |
| Add: Purchase | ………… | |
| Less: Closing inventory | ………… | …………… |
| **Gross Profit** | | …………… |
| **Operating expense** | | |
| Administration expense | ………… | |
| Salary expense | ………… | |
| Insurance expense | ………… | |
| Sundry expense | ………… | |
| Selling expense | ………… | |
| Power costs | ………… | …………… |
| **Net Profit** | | …………… |

M Company

Statement of Financial Position ( SOFP )

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | $ | | $ |
|---|---|---|---|
| **Noncurrent Assets:** | | **Equity:** | |
| Premises | ………… | Capital | ………… |
| Plant, machinery and equipment | ………… | | |
| **Total noncurrent assets** | ………… | **Total equity** | ………… |
| **Current Assets:** | | **Current liabilities:** | |
| Prepayments | ………… | Accruals | ………… |
| Inventory | ………… | Trade Payables | ……… |
| Trade receivables | ………… | **Total current liabilities** | ………… |
| Bank | ………… | | |
| **Total current assets** | ………… | **Total Liabilities** | ………… |
| **Total Assets** | ………… | **Total Equity and Liabilities** | ………… |

## III. សំណួរត្រិះរិះ

1) ព័ត៌មានលម្អិតស្តីពីគោលការណ៍ធានារ៉ាប់រងរបស់ក្រុមហ៊ុនមួយ បង្ហាញដូចខាងក្រោម៖
   - ចំណាយធានារ៉ាប់រងសម្រាប់ឆ្នាំបញ្ចប់ 31 March 2016 ដែលត្រូវបង់ក្នុង ខែមេសា ២០១៥ $21,600
   - ចំណាយធានារ៉ាប់រងសម្រាប់ឆ្នាំបញ្ចប់ 31 March 2017 ដែលត្រូវបង់ក្នុង ខែមេសា ២០១៦ $24,000

   តើចំណាយធានារ៉ាប់រង (Insurance Expense) ប៉ុន្មានដែលត្រូវបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៅថ្ងៃទី៣០ មិថុនា ២០១៦? ចូរបញ្ជាក់ថាតើមាន Accrual ឬ Prepayment ដែរឬទេ?

2) ប្រតិបត្តិការខាងក្រោមនេះ បានកើតមានឡើងនៅក្នុងឆ្នាំបញ្ចប់ត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨។ ចូររៀបចំគណនីអក្សរ T នៃបញ្ជីសៀវភៅធំ តាមករណីនីមួយខាងក្រោម៖

   A. ចំណាយធានារ៉ាប់រងចំនួន $930 បានកើតមានឡើង ប៉ុន្តែក្រុមហ៊ុនទូទាត់បានតែ $725 ប៉ុណ្ណោះក្នុងឆ្នាំ។

   B. ចំណាយទឹកភ្លើង បានកើតឡើងមានចំនួន $1,340។ ក្រុមហ៊ុនមានគោលការណ៍ទូទាត់ជាមូលប្បទានបត្រចំនួន $400 រៀងរាល់បីខែម្តង ដោយចាប់ផ្តើមនៅថ្ងៃទី០១ ខែមេសា និងរៀងរាល់បីខែបន្ទាប់ពីនេះ ។

   C. ក្រុមហ៊ុនបានជួលអគារមួយ ក្នុងតម្លៃ $5,800 ក្នុងមួយឆ្នាំ។ ប៉ុន្តែក្រុមហ៊ុនទទួលបានការទូទាត់ជាមូលប្បទានបត្របានតែ $4,750 ប៉ុណ្ណោះគិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨។

   D. ក្រុមហ៊ុនបានទូទាត់ជាមូលប្បទានបត្រតម្លៃ $750 សម្រាប់ចំណាយជួសជុលនិងថែទាំងរថយន្ត ជូនក្រុមហ៊ុនហុងដាកម្ពុជា។ តម្លៃដែលបានបង់នេះ រួមបញ្ចូលចំណាយជួសជុលនិងថែទាំរថយន្តសម្រាប់រយៈពេល ១៥ ខែ គិតចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៧។

3) ចូររៀបចំគណនីអក្សរ T នៃបញ្ជីសៀវភៅធំ សម្រាប់ក្រុមហ៊ុន S ផ្អែកតាមព័ត៌មានខាងក្រោម៖

   A. ចំណាយទឹកភ្លើង ដែលមិនទាន់បានបង់នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ មានចំនួន $32 ហើយក្នុងឆ្នាំ២០១៦ ក្រុមហ៊ុនបានទូទាត់រួច មានចំនួន $453 ។ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ក្រុមហ៊ុននៅមិនទាន់បានទូទាត់ថ្លៃទឹកភ្លើងដែលបានប្រើប្រាស់ ចំនួន $56 ។

   B. ចំណាយធានារ៉ាប់រង ដែលមិនទាន់បង់នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ មានចំនួន $187 និងក្រុមហ៊ុនបានទូទាត់ក្នុងឆ្នាំ២០១៦ មានចំនួន $955។ នៅក្នុងទឹកប្រាក់ដែលទូទាត់នោះ មាន $42 ជាទឹកប្រាក់ដែលក្រុមហ៊ុនបានទូទាត់មុន សម្រាប់សេវាធានារ៉ាប់រងក្នុងឆ្នាំ២០១៧។

C. នៅក្នុងឆ្នាំ២០១៥ ក្រុមហ៊ុនបានបើកបៀវត្សសម្រាប់ឆ្នាំ២០១៦ ជូនបុគ្គលិក ចំនួន $211 ហើយក្នុងឆ្នាំ២០១៦ ក្រុមហ៊ុនបានបើកបៀវត្សជូនបុគ្គលិក បានចំនួន $6,980 ។ ប៉ុន្តែ ក្រុមហ៊ុននៅជំពាក់ប្រាក់បៀវត្សបុគ្គលិកគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ចំនួន $544 ។

D. ក្រុមហ៊ុនបានទូទាត់ថ្លៃសេវាទូរស័ព្ទ ក្នុងឆ្នាំ២០១៦ បានចំនួន $378 និងនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ ក្រុមហ៊ុនបានទូទាត់មុន ចំនួន $17 ។ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ក្រុមហ៊ុនក៏បានបង់សេវាទូរស័ព្ទនេះជាមុន ចំនួន $61 ។

4) ផ្អែកតាមព័ត៌មានខាងក្រោមនេះ ចូររៀបចំគណនីសៀវភៅធំ សម្រាប់ចំណាយទឹកភ្លើង ឆ្នាំ ២០១៩៖

(i). វិក្កយបត្រទឹក មិនទាន់បានទូទាត់គិតត្រឹមថ្ងៃទី០១ ខែមករា សរុបចំនួន $45

(ii). វិក្កយបត្រភ្លើង ដែលបានបង់ប្រាក់ទុកមុនគិតត្រឹមថ្ងៃទី០១ ខែមករា សរុបចំនួន $12

(iii). ក្រុមហ៊ុនបានទូទាត់ថ្លៃទឹកជារៀងរាល់ខែ ចំនួន$35 ក្នុងមួយខែ

(iv). ក្រុមហ៊ុនបានទូទាត់ថ្លៃភ្លើងនៅថ្ងៃទី០២ ខែមករា ចំនួន $250

(v). ក្រុមហ៊ុនបានទូទាត់ថ្លៃភ្លើងនៅថ្ងៃទី១៥ ខែមិថុនា ចំនួន $460

(vi). ក្រុមហ៊ុននៅជំពាក់ថ្លៃទឹកគិតត្រឹមថ្ងៃទី៣១ ខែធ្នូ សរុបចំនួន $81

(vii). ក្រុមហ៊ុននៅជំពាក់ថ្លៃភ្លើងគិតត្រឹមថ្ងៃទី៣១ ខែធ្នូ សរុបចំនួន $33

5) តារាងតុល្យការខាងក្រោម ត្រូវបានដកស្រង់ចេញពីបញ្ជីសៀវភៅធំរបស់ក្រុមហ៊ុន I ៖

| | Dr. | Cr. |
|---|---|---|
| | $ | $ |
| Buildings | 32,000 | |
| Equipment | 9,060 | |
| Sales | | 143,750 |
| Purchases | 99,600 | |
| Electricity expense | 1,231 | |
| Wages and salary Expense | 18,721 | |
| Rent expense | 3,233 | |
| Inventory នៅថ្ងៃទី០១ ខែមករា ២០២០ | 9,875 | |
| Trade receivables | 7,861 | |
| Trade payables | | 6,546 |
| Bank | 3,132 | |
| Insurance expense | 787 | |
| Office expense | 5,625 | |
| Capital | | 52,440 |
| Drawings | 11,611 | |
| | 202,736 | 202,736 |

គេឱ្យព័ត៌មានបន្ថែមដូចខាងក្រោម គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០៖

1. សន្និធិ (Inventory)នៅចុងឆ្នាំ មានតម្លៃ $8,760 ។
2. ចំណាយទឹកភ្លើង (Electricity) នៅជំពាក់អគ្គិសនីកម្ពុជា ចំនួន $67។
3. ចំណាយបៀវត្ស (Wages and Salaries) នៅជំពាក់បុគ្គលិក ចំនួន $540។
4. ចំណាយការជួល (Rent) បានទូទាត់ជូនម្ចាស់អគារមុន ចំនួន $119 ។
5. ចំណាយធានារ៉ាប់រង បានទូទាត់ជូនក្រុមហ៊ុនធានារ៉ាប់រងមុន ចំនួន $53 ។

ផ្អែកលើព័ត៌មានដែលបានផ្តល់ខាងលើ ចូររៀបចំ៖

a) របាយការណ៍ចំណេញ/ខាត (SOPL) សម្រាប់ឆ្នាំ បញ្ចប់គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០

b) របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (SOFP) នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

# ឯកសារយោង

## ឯកសារយោងចម្បង៖


- BPP Learning Media (2020). Foundations in Accountancy/ACCA: Financial Accounting (FFA/FA). BPP Learning Media Ltd. London
- Frank Wood & David Horner (2010). Business Accounting Basics. Pearson Education Limited. London


## ឯកសារយោងផ្សេងៗទៀត៖


- ច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ១៩៩៧
- ប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចជាតិ នៃមាតិកាចវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ស្តង់ដាគណនេយ្យអន្តរជាតិ ១ (IAS 1)
- ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ១៦ (IFRS 16)
- ស្តង់ដាគណនេយ្យអន្តរជាតិ ៣៨ (IAS 38)
- https://www.ifrs.org/issued-standards/list-of-standards/

គាំទ្រថវិកាលើការរៀបរៀង និពន្ធ និងកែលម្អដោយ
ក្រសួងអប់រំ យុវជន និងកីឡា

មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

អាសយដ្ឋាន ផ្លូវលេខ៩៦ គ្រីស្តូហ្វ័រ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា (www.num.edu.kh)